សុខ សុត្ថាល សាស្ត្រាចារ្យបរិញ្ញាទស្សនវិជ្ជា

# ទស្សនវិជ្ជា

## សំនួរ ចំលើយ អត្ថាធិប្បាយ



## ថ្នាក់បញ្ចប់

០៨៦.១១

# ទស្សនវិជ្ជា

*សំណួរចំលើយតាមអត្ថាធិប្បាយ*

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
២៤០៤

សៀវភៅដែលសិស្សថ្នាក់ទីបញ្ចប់មិនគួរបំភ្លេចគឺ

# រូបវិទ្យា លំហាត់ជ្រើសរើស

របស់

អ្នកគ្រូ ឡៅ ស៊ាន ឡេង

សាស្ត្រាចារ្យបរិញ្ញា រូបវិទ្យា វិទ្យាល័យភ្នំដូនពេញ

សៀវភៅនេះមាន

— តារាងរូបមន្ត
— លំហាត់ជាងហាសិប ដកស្រង់ពីការប្រឡង ក្នុងប្រទេសនានា
— កំណែ Annales Sciences physiques Série DD' 1973-1974

# បញ្ជីអត្ថបទ

## សំណួរ - ចំលើយ

ទំព័រ


| | | |
|---|---|---|
| 1 | អ្វីជាទស្សនវិជ្ជា | 9 |
| 2- | បញ្ញា | 18 |
| 3 | ការរកឃើញថ្មី | 28 |
| 4- | របៀបទូទៅកែគំនិត | 36 |
| 5- | សង្គមនិងគំនិតសង្គម | 44 |
| 6. | គណិតវិទ្យា | 53 |
| 7- | សង្គមរូបធាតុនិងជីវិតសាធារណ៍ | 62 |
| 8- | ជីវវិទ្យា | 73 |
| 9- | មនុស្សវិទ្យា | 80 |
| 10- | សង្គមវិទ្យា | 97 |
| 11- | ចំណោទនៃតម្លៃជាតិមនុស្ស | 110 |
| 12.- | ឆន្ទៈ | 115 |
| 13- | គោលការណ៍យកិច្ចនិងកុសល | 119 |
| 14- | សីលញ្ញាណ | 129 |
| 15- | ទំនួលខុសត្រូវនិងវិបាកវិភិក្ខុយ | 135 |
| 16- | ជីវិតផ្ទាល់ខ្លួនគ្រួសារធំ | 145 |
| 17 | សិទ្ធិនិងច្បាប់ | 154 |
| 18 | រដ្ឋសារ | 157 |
| 19 | យុត្តិធម៌និងការគោរពបុគ្គល សម្បូរសភាព | 165 |
| 20 | បញ្ហាសេដ្ឋកិច្ច | 171 |
| 21 | [illegible] | 181 |

# អត្ថាធិប្បាយ


ប្រការទី ១- ទស្សនវិជ្ជានិងវិទ្យាសាស្ត្រ

ប្រការទី ២- គណិតវិទ្យា និង ពិសោធន៍

ប្រការទី ៣- គណិតវិទ្យានិងសត្ថ:

ប្រការទី ៤- សារៈសំខាន់នៃទស្សនវិជ្ជា

ប្រការទី ៥- គណិតវិទ្យាជាឧបករណ៍របស់សាស្ត្រ

ប្រការទី ៦- ការពិត (fait) និងទ្រឹស្ដី

ប្រការទី ៧- សាស្ត្រអំពីសីលវិជ្ជានិងសាស្ត្រមនុស្សជាតិ -

ប្រការទី ៨- វិជ្ជាឯកទេសនៃសាស្ត្រនិងរបៀបគិតទូទៅ

ប្រការទី ៩- តក្កវិជ្ជាជាសីលវិជ្ជានៃគំនិត

ប្រការទី ១០- ទីបញ្ចប់នៃសីលវិជ្ជានិងសុភមង្គល

# ១– អ្វីជាទស្សនវិជ្ជា ?

1 - អ្វីជាទស្សនវិជ្ជា ?

ទស្សនវិជ្ជា គឺ ស្នេហាគតិបណ្ឌិត ។

2 - នរណាជាអ្នកអោយនិយមន័យដូចខាងលើនេះ ?

លោក ពីតាករ (Pythagore), អ្នកទស្សនវិជ្ជាក្រិច ។

3.- តើចំណែក លោក សូក្រាត (Socrate) យល់យ៉ាងណាដែរចំពោះពាក្យ " ទស្សនវិជ្ជា " នេះ ?

លោកសូក្រាតយល់ថា " ទស្សនវិជ្ជា " គឺ ត្រូវការគតិបណ្ឌិត ព្រោះមនុស្សខ្វះគតិបណ្ឌិត ។

4 - នរណាខ្លះដែលជឿថា មនុស្សមានគតិបណ្ឌិតរួចហើយ ពោលគឺចំណេះជាសាកល ?

ពួក សូភីស " (Sophiste) ពួកទស្សនវិជ្ជាមួយក្រុមដែលប្រឆាំងនឹងគំនិតរបស់សូក្រាត ។

5- តើលោកសូក្រាត បានបញ្ជាក់សំដីអ្វីខ្លះទៅលើន័យថា មនុស្សគ្មានចំណេះជាសាកល ?

លោក សូក្រាតបានពោលថា : " ខ្ញុំដឹងតែមួយមុខគឺខ្ញុំគ្មានចេះអ្វីទាំងអស់ "

(Je ne sais qu'nne chose c'est que je ne sais rien)

6- តើអ្វីទៅដែលហៅថា គតិបណ្ឌិតនោះ ?

គឺការយកបញ្ញាទៅពិនិត្យយ៉ាងត្រឹមត្រូវលើបញ្ហាទាំងឡាយមានបញ្ហាមនុស្សជាដើម ក៏ត្រូវមាន លក្ខណៈប្រកបទៅដោយវិចារណញ្ញាណ នៃអាកប្បកិរិយា គឺការចេះប្រមាណនូវកំលាំងចំណង់របស់ខ្លួន ជាមួយនឹងអំណាចត្រួតត្រាលើខ្លួនឯង ។

7- លោកសូក្រាតបានពោលយ៉ាងដូចម្ដេច ចំពោះការពិចារណារបស់មនុស្សតាមបែបទស្សនវិជ្ជា ?

លោកសូក្រាតពោលថា ការពិចារណាតាមបែបទស្សនវិជ្ជា គឺ ហាត់ស្លាប់ ព្រោះសូក្រាតពិចារណាលើន័យរបស់ជីវិត ។

8- ចុះសិស្សថ្នាក់បញ្ចប់ត្រូវពិចារណា ទៅលើអ្វី ?

សិស្សថ្នាក់បញ្ចប់ត្រូវពិចារណាទៅលើកម្មវត្ថុនៃការសិក្សារបស់គេដូចជា :

១- ឧបករណ៍គំនិតដែលជាផលនៃពិសោធន៍របស់មនុស្សជំនាន់មុន ។

២- ស្នាដៃគំនិតវិវត្តន៍របស់ល្បី ។

9- តើយើងត្រូវពិចារណាអ្វីខ្លះជាបឋម ?

យើងត្រូវពិចារណាលើខ្លួនយើងជាមុន បន្ទាប់មកទើបយើងចាប់ពិចារណា លើអ្វីៗដែលនៅជុំវិញខ្លួនយើង ។

10- គម្រូនៃទស្សនវិជ្ជា បើពោលដោយសង្ខេបចែកជាប៉ុន្មានពួកធំៗ ?

កម្មវត្ថុនៃទស្សនវិជ្ជា ចែកជាបួនភាគធំ គឺ :

១ - ចិត្តវិជ្ជា – ( Psychologie )

២ - តក្កវិជ្ជា – ( Logique )

៣ - សីលវិជ្ជា – ( Morale )

៤ - បរមត្ថវិជ្ជា ( Métaphysique )

11 - តើសព្វថ្ងៃចែកការងារធំទាំងបួនរបស់ទស្សនវិជ្ជាស្ថិតនៅនិរន្តរយុគ ?

សព្វថ្ងៃមកទាំងបួន នៃទស្សនវិជ្ជាពុំស្ថិតនៅជានិរន្តរទៀតទេ ការបំបែកជាពីរចំណែកវិញគឺ : ពុទ្ធិនិងអំពើ

12 - អ្វីទៅហៅថាពុទ្ធិ ?

ពុទ្ធិ (Connaissance) គឺការចេះដឹងដែលការណ៍ខាងលើ ការសិក្សាពីចំណេះវិជ្ជាផ្សេងៗ ដូចជា ចិត្តវិជ្ជា - តក្កវិជ្ជា - សីលវិជ្ជា និង បរមត្ថវិជ្ជា ។

13 - អ្វីទៅហៅថាអំពើ ?

អំពើគឺអ្វីដែលមនុស្សធ្វើ ហើយជាគុណធម៌ពីគ្រប់វិស័យ ដូចជាវិស័យនយោបាយ-សង្គម: សីលវិជ្ជា-សង្គមវិទ្យា ។ល។

14 - គំនិតទស្សនវិជ្ជាមានលក្ខណៈពិសេសប៉ុន្មាន ?

គំនិតទស្សនវិជ្ជាមានលក្ខណៈពិសេសពីរ គឺ :

១ - គំនិតរិះគិត

២ - គំនិត មនុស្សប្រសើរ

15 - អ្វីទៅហៅថា គំនិតរិះគិត ?

គំនិតរិះគិត គឺ គំនិតដែលមានការពិចារណាលើការប្រព្រឹត្តហើយ ។

16 - អ្វីទៅហៅថា គំនិតអញ្ញាស្រ័យ ?

គំនិតអញ្ញាស្រ័យ គឺ គំនិត និយមតាមការពិចារណារបស់ខ្លួនឯង និងការពិចារណារបស់អ្នកដទៃផង ។

ឧ - គំនិតយើងក៏ខុស , គំនិតគេក៏ខុស
គំនិតយើងក៏ត្រូវ , គំនិតគេក៏ត្រូវ ។

17 - តើទស្សនវិជ្ជាមានគោលបំណងយ៉ាងណា ?

ទស្សនវិជ្ជាមានបំណងស្វែងរកសច្ចៈដើម្បីបញ្ញាញាណទូទៅវិជ្ជា ។ កាលបើបាន « សច្ចៈ » ហើយ ទស្សនវិជ្ជាញុំាងឲ្យប្រតិបត្តិ ។

18 - តើត្រូវចាំបាច់មានទស្សនវិជ្ជា ឬទេ ?

បើកាលណាគេត្រូវការ វិចារណញ្ញាណ និងគតិបណ្ឌិត គេក៏តែងតែត្រូវការទស្សនវិជ្ជាជានិច្ច ។ គេពុំអាចលះបង់ទស្សនវិជ្ជាជាគុណៈត្រាតែគេមាន ទោះបង់ចោលលក្ខណៈបរកោ សញ្ចេតនា ។

19 - តើគេអាចនិយាយថា ទស្សនវិជ្ជាជាចំណេះទូទៅបាន ឬទេ ?

គេអាចនិយាយថា ទស្សនវិជ្ជាជាចំណេះទូទៅបាន ព្រោះ ទស្សនវិជ្ជាជាគ្រឿងសោធវិជ្ជាក្នុងលោកផង និងក្រៅលោកផង គឺពុំវត្ថុទោះជាយ៉ាងណាក៏ដោយ ចំណេះទូទៅនោះត្រូវប្រកបដោយវិចារណញ្ញាណផងដែរ ។

20 - តើអ្នកយល់ថា មនុស្សគ្រប់រូបត្រូវមានទស្សនវិជ្ជាផ្ទាល់ខ្លួន ឬទេ ?

មនុស្សជាសត្វដែលបរិភោគយកនូវសញ្ចេតនាហារ ។ ដូច្នេះ

មនុស្សគ្រប់រូបសុទ្ធតែមានឱកាសស្មើគ្នា បើមនុស្សមានឱកាសស្មើគ្នា មនុស្សតែងត្រូវការវិចារណញ្ញាណ មនុស្សត្រូវតែមានទស្សនវិជ្ជា ដោយខានពុំបាន ។

**21 - ទស្សនវិជ្ជាដែលបាត់បង់បន្តិចម្តងៗ នូវកម្មវត្ថុទាំងឡាយរបស់ខ្លួន តើអាចមានកម្មវត្ថុអ្វីទៀតនឹងយកមកសិក្សា ?**

ពីដើមទស្សនវិជ្ជាបានបាត់បង់បន្តិចម្តងៗនូវកម្មវត្ថុនានាឡាយរបស់ខ្លួនបណ្ដាលមកពីការរីកចំរើនលូតលាស់នៃស្យង់ តែទស្សនវិជ្ជាស្ថិតនៅជានិច្ចក្នុងកំដៃរបស់ខ្លួន ព្រមទាំងពុំខ្វះកម្មវត្ថុសម្រាប់សិក្សាឡើយ ។ ព្រោះថា ក្រៅពីទ្រឹស្តីព្រះពុទ្ធដែលបាននិយាយពី រូប-ទុក្ខ-ព្រលឹង វិញ្ញាណ, តើស្យង់បានរកឃើញជីវិតក្រោយលោក-និងជីវិតក្រោយរូបហើយឬនៅ ? នេះពុំបានទាំងយកកម្មវត្ថុថ្មីៗ របស់ទស្សនវិជ្ជាដែលមានអ្នកប្រាជ្ញអក្សរសាស្ត្រខ្លះកំពុងត្រូវគេលើកតំកើង ក្រោយដែលបានរកឃើញកម្មវត្ថុនៃទស្សនវិជ្ជាថ្មីៗជាច្រើនដូចជា សាត្រ ( J - P . sartre ) ជាដើម ។

**22 - តើសង្គមយើងសព្វថ្ងៃ ដែលជាសង្គមពោរពេញទៅ ដោយការរីកចំរើនគ្រប់វិស័យទាំងអស់របស់ស្យង់ ត្រូវការពឹងផ្អែកទៅលើទស្សនវិជ្ជាទៀតឬទេ ?**

ជាមួយគ្នានឹងការជឿនលឿនរបស់ស្យង់ សង្គមលោកសព្វថ្ងៃមិនគ្រាន់តែបានទទួលនូវផលវិបាក បណ្ដាលមកពី "ស្យ៉ង់

ខ្លះញាណ ” (Science sans conscience) ពុំគួរ
គេតែលោកមានវិញ្ញាណ ក៏ពុំមែនគិតតែពីយកខ្លាំងជាតិកម្ទេចរូបកាយ
មនុស្សលោកលោះពួកគេទាំងអស់ ។ ព្រោះថា បើគំនិត
អាតូមិច (Atomique) បានសម្លាប់មនុស្សអស់រាប់ពាន់សែននាក់
ឯអនាគតកាល,គំនិតគ្រាប់បែកអ៊ីដ្រូសែន (Hydrogène)
និងតុណចំនួនមនុស្សរាប់លានដ៏ឥតប្រមាណ ។
ដូច្នេះគេត្រូវការមនុស្សវិទ្យាសាស្ត្រ ដើម្បីបង្កប់នូវគំនិតនៃ
ផ្សះផ្សារនៅក្នុងការគិតនោះ ។

23- អ្នកយល់យ៉ាងណាដែរ ចំពោះការសិក្សាមនុស្សវិទ្យា
នៅថ្នាក់បញ្ចប់ ។

ការសិក្សាមនុស្សវិទ្យានៅថ្នាក់បញ្ចប់ គឺការបើកផ្លូវឲ្យគ្រូ
ព្រមទាំងសិស្សលើកកម្ពស់ច្បាប់សិក្សា ។ ព្រោះថាសិស្សអាច
ជាពិសេសស្គាល់បែកខ្ញែកចំណេះដឹងច្បាស់លាស់នៃមនុស្ស
វិទ្យាផង និងស្រួលដល់ការឈានទៅរកនូវមុខវិជ្ជាផ្សេងៗទៀត
ខ្ពង់ខ្ពស់ទៀតនៅក្នុងសិក្សាសង្គមសាស្ត្រវិទ្យា (Ethno-
logie) មនុស្សជាតិវិទ្យា (Anthropologie) ជា
ដើម ។ល។ ដែលបានទំនាក់ទំនងជាប្រចាំការយ៉ាងជិតស្និទ្ធ
នឹងមនុស្សវិទ្យា ។

24- មានបុគ្គលខ្លះយល់ថា ៖

“ការសិក្សាមនុស្សវិទ្យា គឺការពិចារណាទៅលើខ្លួន
ឯង និងទៅលើអ្វីៗដែលនៅជុំវិញខ្លួនឯង ”
តើអ្នកយល់យ៉ាងដូចម្ដេចចំពោះទស្សនៈខាងលើនេះ ?

សូក្រាតបានពោលថា ៖
« សិក្សាទស្សនវិជ្ជា គឺ ហាត់ស្លាប់ » តើយើងគួរយកគំនិតពិចារណារបស់សូក្រាតមករៀបរៀបនិងវត្ថុទី១នៃសំនួរទស្សនវិជ្ជានេះបានឬទេ ?
លោកសូក្រាតបានពោលដូចព្រះពុទ្ធដែរ គឺ ត្រូវយកចិត្តទុកដាក់នឹងខ្លួនឯងសិនហើយ, ទៅពិចារណាលើអ្នកដទៃ ។ ព្រះពុទ្ធទៀតថា កម្មផល, និងច្រវាក់នៃវាលវដ្តសង្សារកើតមានបានមកពីការយករូបជាបច្ច័យ ។ ដូច្នេះបើបានរូបហើយ, បញ្ហាច្បាស់ជាស្ថិតនៅលើរូបនេះជាបឋម ។
ព្រះពុទ្ធពុំត្រាស់តែប្រាប់យើងឲ្យយកចិត្តទុកដាក់នឹងខ្លួនយើងប៉ុណ្ណោះទេ, តែលោកបានបញ្ជាក់ថែមទៀតថា រូបនេះឯងជាប្រភពនៃជីវិត ។ ឧទាហរណ៍ = ទុក្ខកើតមកពីមានរូប- គឺមានរូបត្រូវតែមានទុក្ខ ។ ដូច្នេះបើបានទុក្ខហើយ ហេតុអ្វីក៏ពិចារណា រកមើលហេតុនៃទុក្ខនេះតាមពិចារណាវិញ ?
ត្រូវគ្នានឹងទស្សនៈរបស់សូក្រាត ដែលបានពោលដូចព្រះពុទ្ធដែរ « សិក្សាទស្សនវិជ្ជា គឺហាត់ស្លាប់ » (Philosopher c'est apprendre à mourrir) ។ ត្រង់ន័យនេះ សូក្រាតបានបញ្ជាក់ថា បើចង់ចាប់ពិចារណាពីហេតុការណ៍ទាំងឡាយដទៃណាមួយគេត្រូវចាប់ពិចារណាពីបញ្ហាជីវិត ពោល គឺ រាងកាយរបស់យើងជាមុនសិន ។ ក្នុងការស្វែងរកធម្មជាតិ ព្រះពុទ្ធពុំបានមានបន្ទូលប្រាប់ឲ្យយើងទៅពិចារណាលើព្រះឥន្ទ្រ ព្រះព្រហ្មឬអាទិទេពឯណានោះទេ តែទ្រង់បានផ្ដៅឲ្យពិចារណាការកសាងចិត្តក្នុងខ្លួនយើងតែប៉ុណ្ណោះ ។

ដូច្នេះយើងឃើញថាវត្ថុទី១នៃតិទានលើនេះ  គឺខ្លួន យក
ដំណោះស្រាយរកគួបសិរីប៉ុណ្ណោះ ។
វត្ថុទី២  នៃមេចាំនៃចំពង់  ត្រូវពិចារណាការលើផ្លូវបែប
ទៅវិញទៅមកនេះ, មនុស្សឃើញច្បាស់ថា ការផែល
មនុស្សបានជួបពីមួយទៅមួយទៀត  ពេលគឺក្នុងនោះ
ម្តាយមកក្នុងសង្គម ។
មនុស្សគេះនេះគេត្រូវតែចាប់យកបញ្ហាមួយ  គឺ សង្គមមនុស្ស
ហើយដែលមានលក្ខណៈខុសពីបញ្ហាអត្ត  ដោយតក្រូវតែ
បាន ។ ការប្រព្រឹត្តប្រឈមសាមួយបញ្ហាសង្គម ព្រោះមនុស្ស
ចូលក្នុងនៅក្នុងសង្គម ដូច្នេះនោះបើញាណឬ អញ្ញាណក៏ដោយ
មនុស្សត្រូវតែធ្វើការដោះស្រាយបញ្ហាទាំងឡាយនោះ  ជា
មួយអ្នកដទៃដែលជាសមាជិកនៃសង្គមនោះ ។
បើគ្រាន់តែយោងលើទៅលើសីលធម៌ Morale ខ្លួនឯង
ចុះណ្តោះយើងក៏ហាក់ដូចជាគ្រប់គ្រាន់ណាស់ ចំពោះវត្ថុទី ២
នៃតិទានលើនេះ ។ ឧទាហរណ៍ៈ ស្រុកកម្ពុជាយើងតាំងពី
ដើមរៀងមកជាតិនៃសាសនាព្រះពុទ្ធ ព្រមទាំងពុំដែលមានកំណាច
ផ្តើមបង្ករបួសពាន រៀបផ្លូវចិត្តជាប់គងលើទីតាំង  ដើម
មនុស្សគិតពីផ្លាស្លាតិយមជើងរស់ស្រួលតែឯង  ឃើញថាថា
មានតណ្ហាគណការចំពោះបុគ្គល ។ បើយើងមានចរិតស់នៅតែ
ឯកឯងតាមក្នុងសង្គមនោះវាជាការប្រសើរពេកហើយ ។ ក៏ប៉ុន្តែ
ត្រូវតែនៅជុំវិញយើងជាច «បុគ្គល» របស់អ្នកដទៃជុំអញ្ញាត
ឲ្យយើងរស់នៅជាសុខសប្បាយជាមួយគេ ។ ដូច្នេះយើង
សំរួះសំរួល  សាមួយបញ្ហាទាំងឡាយដែលនាំទៅរៀបនៅវិ

យើងត្រូវតែពិចារណាតាផ្លូវមួយៗ ដែលនាំឲ្យវិញខ្លួន យើង ដោយខានពុំបាន ។

នេះគ្រាន់តែផ្នែកមួយដែលយើងបានយកសីលញាណ Conscience morale មកពិចារណាតែប៉ុណ្ណោះ ។

មកដែលបានលោកយកខាងលើនេះ ជាទ្រឹស្ដីទស្សនវិជ្ជា (théorie philisophique) ដែលប្រកបដោយតក្កភាព (Logique)ពីរយ៉ាងគឺ ៖

១- ចំណែកនៃការពិចារណាទៅលើវត្ថុ ។

២- ចំណែកនៃការពិចារណាទៅលើចរិតភាព ឬអត្តិភាពនៃការរស់ដែលនាំឲ្យវិញយើងផង ។

*

* *

# ២- បញ្ញា

25 អ្វីទៅហៅថា «បញ្ញា» ?

អ្នកប្រាជ្ញម្នាក់ឈ្មោះ «ហាត់ ម៉ាន់» (Hartman) បាន អោយនិយមន័យ បញ្ញា ថាជា «អនុគមន៍សំរបខ្លួនតាម ករណីថ្មី» ។ ដូច្នេះបើតាមយោបល់របស់អ្នកប្រាជ្ញនេះ បញ្ញាជាការប្រើឧបករណ៍សាកល ដើម្បីសំរបខ្លួនតាមក្នុង ការដោះស្រាយបញ្ហាទូទៅ ដែលមានគោលដៅជាក់លាក់ ។

26 អ្វីទៅហៅថា «សភាវគតិ»

សភាវគតិជាអាកប្បកិរិយាកំណើតដែលដដែល សំរាប់សត្វមាន ជីវិតទៅតាមប្រភេទនិមួយៗ ។

27 គេថាវត្តញាំងចេះធ្វើសំបុក ។ ក្រោយមកវាចេះយក ដង្កូវមកបង្ខាំងទុកក្នុងសំបុក សំរាប់អោយកូនស៊ី តើយើងយល់ថាសត្វវត្តញាំងមានបញ្ញាឬទេ ?

សត្វវត្តញាំងគ្មានបញ្ញាទេ តែសត្វនេះមានសភាវគតិដិត ចំណាប់ ។

28 តើមនុស្សខុសនឹងសត្វត្រង់លក្ខណៈណា ?

មនុស្សខុសនឹងសត្វ ត្រង់មនុស្សមាន [illegible] បង្កើត បញ្ញា ។

29 តើសត្វមានសភាវគតិយ៉ាងដូចម្ដេច ?

សត្វមានសភាវគតិរឹងហើយគង់តែងតែរល់ ចំពោះមនុស្សមាន

ភាពចង់ភ្ជាប់និងបត់បែនបានរបស់អាកប្បកិរិយា ដែលជាលក្ខណៈរបស់បញ្ញា ។

30- តើបញ្ញា អំណាច-និងសភាវគតិនៅក្រោមការត្រួតត្រារបស់អ្វី ? ចូរលើកឧទាហរណ៍រូបីមកបញ្ជាក់ ?

បញ្ញា អំណាចនិងសភាវគតិជានិច្ចនៅក្រោមការត្រួតត្រារបស់តណ្ហា គឺរាល់សត្វទាំងឡាយ កើតមានជីវិតមកលើលោកនេះ ។ ដោយសារអំណាចសត្វស្វាពុំព្រមនេះធ្វើសំបុកដេកនៅ ចាញ់បក្សីទាំងពួងនិងសត្វស្លាបតូចៗដូចជាចាបញាំង ឪឡាក់ៗ ល។ ដោយសារសភាវគតិសត្វទាំងឡាយនេះប្រព្រឹត្តធ្វើនូវចលនា បញ្ចេញសំលេងនិងធ្វើក្បាច់របស់វា ។ ដោយសារខ្វះបញ្ញាសត្វទាំងឡាយ ពុំមានការពិចារណាដូចមនុស្សយើងឡើយ ។ សត្វមួយចំនួនមានសភាវគតិ តែពុំមានបញ្ញា វាបានហើរចូលភ្លើងហើយស្លាប់អស់ល់ ។ តែឥតមានបញ្ញា បានកើតមកពីនេះរបស់វា ក្រោយមកក៏បានសោកសង្វេងដោយមេរោគហ្វូតមានកូនបន្តទៀត ។ បើមានសភាវគតិតែឥត " សភាវគតិពីភេទ " បានសុខចិត្តឲ្យកូនវាឲ្យសង្ខ្វះក្នុងការបន្តពូជ ។ មនុស្សក្រៅពីមនុស្សមុនគេប្រវត្តិខ្លះបាននេះធ្វើដូរទៅនេះបរាជ័យ នេះជំនឿសាច់ ព្រោះនេះបង្កើតភ្លើងដោយដុំថ្ម តែមនុស្សនោះបានសេពមេថុននិងម្ដាយរបស់ខ្លួនហើយបន្តសកម្មភាពផ្ទេរភេទ (Complexe d'œdipe) ដោយតណ្ហារបស់ខ្លួន ។

31- តើមានអ្វីអាចឈ្នះតណ្ហាបានឬទេ ?

មានតែ គុណសត្វៈប៉ុណ្ណោះដែលអាចឈ្នះលើតណ្ហាបាន ។

32 តើនរណាប្រាប់មនុស្សឲ្យចេះធ្វើ "ពុទ្ធិសត្វៈ" ?
ព្រះពុទ្ធប្រាប់មនុស្សនិងចង្អុលប្រាប់មនុស្សឲ្យយល់ពីការ ផត
ន័យរបស់ "សរីរាង្គ" ហើយប្រាប់មនុស្សឲ្យបណ្ដុះពុទ្ធិសត្វៈ ។

33 ដោយការសិក្សា មនុស្សមាន ពុទ្ធិសត្វៈឬទេ ?
ដោយការសិក្សាតែម្យ៉ាង មនុស្សគ្មានពុទ្ធិសត្វៈឡើយ ។

34 ចុះនរណាមានពុទ្ធិសត្វៈជាសកល
ព្រះពុទ្ធមានពុទ្ធិសត្វៈជាសកល ។

35 តើចំណេះចេះដឹងនិងការស្រាវជ្រាវរបស់អ្នកប្រាជ្ញ ទាំងស្រុងសព្វថ្ងៃនេះអាចចាត់ទុកថាជាពុទ្ធិសាកល បានឬទេ ?
ចំណេះចេះដឹងនិងការស្រាវជ្រាវ របស់អ្នកប្រាជ្ញបច្ចុប្បន្នជា លក្ខណៈផុះផាលនៃបញ្ញាមនុស្ស ។ គេពុំអាចចាត់ជាពុទ្ធិសាកលប្រកបដោយសត្វៈបានឡើយ ព្រោះចំណេះចេះដឹង នោះមានការខ្វះខាតលើផែកខាងតែពុទ្ធិច្រើនណាស់ ។

36 ចូរអ្នករកឧទាហរណ៍ប្រៀបធៀបបញ្ជាក់ថាពុទ្ធិ របស់អ្នកប្រាជ្ញបច្ចុប្បន្នពុំទាន់មានតំលៃអោយស្មើនឹងពុទ្ធិសត្វៈ សកលដែលព្រះពុទ្ធបានចង្អុលប្រាប់នោះនៅឡើយ ?
វិទ្យាសាស្ត្របានចំរើនលូតលាស់យ៉ាងខ្លាំង ។ នេះជា សក្ខីភាពបញ្ជាក់ពីសំខុះតែបញ្ញារបស់មនុស្សដែលចេះតែរីក ទៅមុខឥតឈប់ ។ គេបានឃើញមនុស្សចេះធ្វើម៉ាស៊ីនគិត លេខ(Machine à calculer) គេបានឃើញមនុស្សបង្កើត

គ្រឿងយន្តចំនើនកោះហើរទៅដល់ឋានព្រះច័ន្ទ ព្រមទាំងយកភ្ញៀវឋានព្រះចន្ទបានថែមទៀតផង ។ គេបានឃើញមនុស្សបង្កើតគ្រឿងប្រហារយ៉ាងពោរពេញ ហើយហាក់តំណាំងហើយជាសូចនា គំរាំងអាតូមិកនិងភ្លើងព្រាយរំលែកម៉ែត្រ ដែលគេបានឃើញមនុស្សនេះបង្កើតមនុស្សយន្ត (Robot) ដើរដោយកំលាំងអគ្គិសនី ។ ហើយថាកំលាំងក្នុងរបស់មនុស្សមានជីវិត ស្ទើរនឹងក្លាយទៅជាលើកលែងដល់ ។ ទោះជាយ៉ាងនេះក្តី យើងក៏នៅតែឃើញថាមនុស្សពុំទាន់អស់លក្ខណៈល្ងី (Idiotie) របស់ខ្លួននៅឡើយ ព្រោះមនុស្សពុំចេះគ្រប់គ្រងរាងកាយរបស់ខ្លួនឲ្យបានគីតតែងាសបានទៅនៅឡើយហើយមនុស្សក៏ពុំអាចចៀសផុតពីសេចក្តីស្លាប់ ដែលមានលើមនុស្សគ្រប់រូបជានិច្ចឡើយ ។ តែចំពោះសេចក្តីស្លាប់ចុះវាជារបស់ដែលហួសគំនិតបាន. ចុះបើមនុស្សទៅយកបញ្ញាមកប្រើយ៉ាងដូច្នេះ ហេតុអ្វីក៏មនុស្សមិនសាកល្បងធ្វើគ្រឿងយន្ត សម្រាប់ផលិតកំណាព្យ (La poésie) ដែលគឺស្លាប់ទៅតាមរូបធាតុហើយនោះផង ?

ឆ្លើយៈ បញ្ហាមនុស្សបច្ចុប្បន្នពុំទាន់ឲ្យតំលៃថា «ធាតុទិសត្វៈសាកល» នៅឡើយទេ ។

37- ដើម្បីវាស់បញ្ញារបស់ក្មេង, អ្នកប្រាជ្ញឈ្មោះប៊ីណេ (Binet) និង ស៊ីម៉ុង (Simon) បានរកឃើញបានយ៉ាងណា ដើម្បីឲ្យដឹងថាក្មេងនោះមានបញ្ញាឬគ្មានបញ្ញា ?

អ្នកប្រាជ្ញទាំងពីរនេះបានកំណត់អាយុបញ្ញា (âge mental) ទៅនិងអាយុពិត (âge réel) ហើយ ... ដែលបានយក

គេហៅថា « លទ្ធបញ្ញា » ។ បើលទ្ធបញ្ញាត្រូវផ្គុំគ្នាតែមួយ (Unite) អ្នកប្រាជ្ញជាតិសំគាល់ថា ក្នុងពេលមានបញ្ញាខ្លួន ។ បើគិតតាមគំហើញ, គេយល់ឃើញថា ក្នុងពេលនេះមិនបញ្ញាចាស់ ឬ ថ្មីបញ្ញា ។

38 - តើវិធីវាស់បញ្ញារបស់លោក ប៊ីនេ និងស៊ីម៉ុងត្រឹមត្រូវ ទាំងអស់ទៅលើបញ្ញារបស់មនុស្សទូទៅឬទេ ?

វិធីវាស់បញ្ញារបស់អ្នកប្រាជ្ញទាំងពីរនេះពុំត្រូវចំពោះមនុស្ស ទាំងអស់បានឡើយ ព្រោះតែគុណធម៌នៃបញ្ញានិងកម្លាំងរបស់មនុស្ស សុទ្ធតែស្ថិតនៅក្នុងលក្ខណៈអរូបី ។ ហេតុដូច្នេះហើយបានជា បច្ចុប្បន្នកាលក្តី អតីតកាលក្តី គេតែងវាស់បញ្ញាមនុស្សដោយ ផ្តល់វិញ្ញាសាទៅឲ្យមនុស្សនោះស្រាយជាការផ្ទាល់ ។

39 - លោក « ការ៉ល់ម៉ាក្ស » ( Karl marx ) និយាយថា ៖ ភាពខុសគ្នារវាងស្ថាបត្យករដែលគ្មានថ្វីដៃសោះ និង សត្វឃ្មុំដែលពូកែ, នៅត្រង់ហេតុថា ស្ថាបត្យករមាន ប្លង់ផ្ទះនៅក្នុងក្បាលមុននឹងចាប់សង់ ។ តើអ្នកយល់ យ៉ាងណាចំពោះសំដីខាងលើនេះ ? ចូរវែកញែក ។

ស្ថាបត្យករ គឺជាមនុស្សដែលផលិតនូវស្នាដៃទៅតាមគំនិតវិជ្ជា របស់ខ្លួន គឺ ស្ថាបត្យកម្ម ។ និយាយជាទូទៅ យើងអាចគិតជារូប ភាពនានាស្រេចតាមការស្រមៃរបស់ខួរក្បាលនៃស្ថាបត្យករនោះ ៗ មុននឹងសាងនូវសំណង់មួយ ស្ថាបត្យករបានគិតពិចារណា រាវរកនូវគោលសញ្ញាណបដិស្ឋានរបស់ខ្លួន, ព្រោះហេតុ

និស្ស័យនេះតែងកាត់ចងទៅលើការបញ្ញាញាណ ពិសេសសំរាប់ស្ថាបត្យករនេះណាស់ ។

ចំណែកសត្វឃ្មុំកាលណាវាចាប់ធ្វើសំបុក, វាពុំមានការគិតពិចារណា ហើយគ្មានរូបភាពសំណង់នៅក្នុងខួរក្បាលវាដូចមនុស្សទៀតទេ ។ គឺកាលណាវាបានជ្រើសរើសបន្តកញ្ចុំនិងធ្វើសំបុកហើយ ឃ្មុំក៏ចាប់ផ្ដុំគ្នាពាក់ពូនហើយរៀបនាសម្ពន្ធចំណាប់ ក៏ពុំពិសកាលគិតឃ្មុំត្រូវធ្វើញូក្រឡូងជាសំណង់ក្លាយៗតាំងរាប់គ្រាក្បាលគិត ។ ដូច្នេះឃ្មុំគ្មានរូបភាពនៃសំបុករបស់វានៅក្នុងក្បាលដូចមនុស្ស ឬ ស្ថាបត្យករឡើយ ។ បើដូច្នេះហេតុដូចម្ដេចក៏ ( karl - marx ) យកប្រៀបប្រដូចស្ថាបត្យករគ្មានថ្វីដៃទៅនឹងឃ្មុំ ?

យើងទៀតថា គឺកាលយ៉ាត់ចង់ប្រដូច ស្ថាបត្យករឬ គិត សំបុកឃ្មុំនេះតែមួយ ពេលគឺ ត្រៀងសំណង់ដែលជាស្នាដៃរបស់ស្ថាបត្យករគ្មានថ្វីដៃប្រដូចបាននឹងសំបុកឃ្មុំនោះពិត ។ ចំណែកស្ថាបត្យករនោះគាត់ក៏ត្រូវកាលយ៉ាត់ប្រដូចទៅនឹងឃ្មុំ , ព្រោះ « មនុស្សឃ្មុំ » នោះ ខុសទៅនឹង « សត្វឃ្មុំ » តែត្រង់ខ្លួនមាន « រូបភាពនៃសំណង់ គំនូរ » នៅក្នុងក្បាលខ្លួនមុននឹងចាប់ធ្វើរាស ឬ សាងសំណង់នោះតែប៉ុណ្ណោះ ។

**គេច្រើនពោលថា សង់សាក់រូស្សូ (J. J. Rousseau) មានចំណូលចិត្តទៅនឹង " តន្ត្រីវិទ្យា " ដោយសារគាត់មានការស្រលាញ់ធម្មជាតិ និងការរំភើបសប្បាយដែលធម្មជាតិបានផ្ដល់ឲ្យគាត់ ។ តើអ្នកយល់យ៉ាង**

ដូចម្ដេចចំពោះសំដីរបស់អ្នកទស្សនវិជ្ជានេះ ? ដើម្បីពិនិត្យលើសំដីរបស់លោករូសូ គប្បីយើងរំឭកពីសភាពនិងជីវិតខ្លះ ៗ របស់អ្នកទស្សនវិជ្ជានេះសិន ។

លោករូសូ កើតនៅក្រុងស៊ឺណែវ (GENEVE) ប្រទេសស្វីស (SUISSE) មាតារបស់លោកបានចូលមរណភាពនៅថ្ងៃកំណើតរបស់លោកនៅចំថ្ងៃទី ២៨ មិថុនា ១៧១២ ដប់ឆ្នាំក្រោយមក, ឪពុកលោករូសូ ដែលមានកង្វល់ក្នុងចិត្ត ក៏សម្រេចចិត្តចោលស្រុក ។ ពេលនោះលោករូសូក៏ស្ថិតនៅក្រោមការមើលថែរក្សារបស់អ្នកគង្វាលសាសនាម្នាក់ឈ្មោះ ឡំបែរស៊ីយេ (Lambercier) ។ ពីរឆ្នាំក្រោយមករូសូត្រូវគេបញ្ជូនទៅបំរើជាងចំលាក់ម្នាក់ បន្ទាប់មកគាត់ក៏ចាប់ផ្ដើមដើរវង្វេងក្រៅរហូត ។ ដំបូងគាត់បានត្រូវស្ត្រីមេម៉ាយម្នាក់ឈ្មោះវ៉ារ៉េ (Mme de Waren) បញ្ជូនអោយទៅរស់នៅក្នុងអគារសង្គ្រោះផ្នែកសាសនាប្រូតេស្តង់ រួចចេញមកបំរើនៅក្នុងវិមានរបស់លោកស្រី «ឌឺវែរសឺលីស» និង លោក គូវ៉ុង (Gouvon) ។ ដោយ រូសូ មានរូបសម្ផស្សល្អពីធម្មជាតិគាត់ក៏ត្រូវស្ត្រីមេម៉ាយដែលជួយឧបត្ថម្ភនោះទទួលរក្សាគ្រាន់តែបំរើការបន្ទប់ប៉ុណ្ណោះ ។ ស្ថិតនៅក្នុងសភាពជា «គូនឹង» ដូច្នោះ, រូសូក៏មានការធុញទ្រាន់នឹងជីវិតហើយក៏សំរេចចិត្ត ដើរទេសក្នុងព្រៃដើម្បីស្លាប់ ។ តែមិនស្លាប់ រូសូត្រូវជាអ្នកទទួលនូវការសង្គ្រោះពីធម្មជាតិ ព្រោះមានសំណាងសង្គ្រោះ ។ លុះអាយុលោកបាន៣០ឆ្នាំ រូសូក៏បានត្រូវលោក «ឌឺម៉ុងតេគុយ» (M-De-Montegu) អគ្គរដ្ឋទូតបារាំងប្រចាំ

ក្រុងវ៉ែនីសទទួលបេសកកិច្ចជាស្មៀន ។ តែរួចក៏ត្រឡប់មក។ រូសូក៏មានមុខមាត់ ហើយក៏រាប់អានអ្នកសរសេររឿងពិតៗនៃបញ្ញាមនុស្ស ។ រូសូបានស្គាល់លោក «វ៉ុលតែរ» (Voltaire) ហេតុការទាំងនេះត្រឹមតែភាពនិពន្ធ ។ លុះរូសូអាយុ ៣៤ ឆ្នាំ, គាត់បានយកស្រីអ្នកបំរើគេនៅផ្ទះសំណាក់ម្នាក់ឈ្មោះ Thérèse ជាប្រពន្ធ ។ ស្រីនោះមកនៅជាមួយរូសូបានល្អ, ហើយកូនចៅគាត់ពុំបានចិញ្ចឹមខ្លួនឯងទេ-តែគាត់បានយកទៅដាក់ក្នុង «កុមារសង្គ្រោះ» ។ បន្ទាប់មកគាត់ក៏បោះបង់ចោលនាងតេរ៉េស (Thérèse) នោះ ហើយស្រឡាញ់ស្រីផ្សេងទៀត ។

រូសូបានសរសេរសៀវភៅស្ដីពី « សិល្បៈនិងវិទ្យា » ហេតុមានឈ្មោះល្បោះសម្លេង គឺសៀវភៅនេះបានរង្វាន់ពីបណ្ឌិតសភានៅឌីស៊ុង (Dijon) ។ ឈ្មោះគាត់ល្បីល្បាញ ចាប់ពីពេលនោះមករូសូសរសេរសៀវភៅពីការប្រែប្រួលមនុស្សជាមួយសៀវភៅឈ្មោះ «ដើមកំណើតនៃវិសមភាព» (Origine de l' inégalité) និងសៀវភៅឈ្មោះ «អេមីល» (Emile) ដែលបណ្ដាលឲ្យគេតាមចាប់ខ្លួនគាត់យកទៅដាក់គុក ដូច្នេះរូសូបានរត់ចោល ហើយក៏គេចខ្លួនទៅនៅស្វីស ។ នៅពេលនោះប្រពន្ធរបស់រូសូមានជំងឺជាច្រើន តែពេលក្រោយគាត់បានធូរស្បើយ ទើបបញ្ញាមនុស្សហៀបនឹងដែលគាត់ស្លាប់នៅក្នុងប្រទេសបារាំង ។ គាត់ស្លាប់នៅថ្ងៃទី ២ កក្កដា ១៧៧៨ ក្នុងអាយុ ៦៦ ឆ្នាំ នៅក្នុងស្ថានលោកហ្ស៊ីរ៉ាដាំង (Girardin) ហើយសពរបស់គាត់ត្រូវគេនាំយកទៅបញ្ចុះនៅក្នុងវិហារដែលគេហៅថា « វិហារទេពអមតៈ » ។

១០ឆ្នាំក្រោយមក , ទើបប្រាជ្ញគេការពិតយល់ឃើញថា គំនិតរួមជាតិនិយម , ទើបគេនាំគ្នាទៅរកវត្តសពគាត់ពីកោះ កោះបារាំងក្នុង វិមាន«បង់តេអុង» រួចតម្កល់សពនៅទីនេះ ។ ទស្សនវិជ្ជារូសូបានបញ្ជាក់ប្រាប់យើងថា , គាត់ជាមនុស្សដែល មានសញ្ញាណប្រកបដោយ «គំរូការបញ្ញាសត្វ» ។ ព្រោះ ទទួលនូវសេចក្តីអាណិតអាសូរពីកុមារភាពព្រាត់ព្រាស , គុំមានទទួល នូវសេចក្តីស្រលាញ់ (Sympathie - contagion) ពីអ្នក ក្រៅផ្ទះឡើយ , តែគាត់មានមនោគតិកំណើត (Imagination innée) ញែកចេញពីសង្គមមនុស្សរហូតស្អប់សង្គម នេះថែមទៀតផង ។

គាត់បានដើរឆ្លងព្រំទៅក្នុងស្រុក-បារាំង-ស្វីស-លើក ។ល។ ដើម្បីចៀសវាងពីបញ្ហាមនុស្ស ; តែគាត់ត្រឡប់ជាប្រទះនូវ លទ្ធផលពិតពីគម្ពីរជាតិដែលគេយល់ថា មានប្រយោជន៍ សម្រាប់សង្គមក្នុងមនោគតិនិងសង្គមនោះ ។ លុះរូសូបាន ឃើញគម្ពីរជាតិទាំងឡាយនោះដោយពិសោធន៍រួចហើយ ទើប គាត់ត្រឡប់មកពិនិត្យទស្សនវិជ្ជា នៃអ្នកដទៃសម្រាប់គាត់ចុះ គាត់បានបញ្ចេញគំនិតសំរេច ព្រោះហេតុផលពិតផល់វិជ្ជា ទាំងនេះត្រូវទៅនិងសេចក្តីបញ្ជាក់ពី សង្គមដែលគាត់ធ្លាប់ជួប ប្រទះនេះ ។

ស្នាដៃរូសូបានបង្កើតគំនិតនិងបានចំណេះគម្ពីរជាតិផង ៤ មូលហេតុគឺគាត់បានផ្តាច់ខ្លួនចេញពីសង្គម ហើយនាំ ទៅរកធម្មជាតិ ។ លុះបានលទ្ធផលពីការពិចារណានោះ ហើយ គាត់ក៏ចាប់ផ្តើមបង្ហាញប្រាប់ជាច្រើន ដែលមាន

ហេតុនេះការដោះស្រាយបញ្ហា នេះតាមសង្គមវិទ្យាវត្ថុ
វិស័យ ។ រូបមានបញ្ហាក្នុងជីវិតពុំព្រមដោះស្រាយហើយថែម
ទាំងទាត់ចូលទៅក្នុងកម្មជាតិ ។ ដូច្នេះក្តីការស្រឡាញ់
កម្មជាតិ ការចិញ្ចឹមសង្សារផែនកម្មជាតិផ្តល់ផលគាត់នេះ
រូបមានបញ្ហាតាមតែយកស្រើន ដូចបានរៀបរាប់មកហើយ
សម្រាប់ក្នុងមោយការចំណូលក្នុងទាំង « រូបវិទ្យា » ។

* * *

# ៣ ការបង្កើតថ្មី

**41** - អ្វីទៅហៅថាការបង្កើតថ្មី ?

ការបង្កើតថ្មីគឺសកម្មភាពសំយោគថ្មីនៃគំនិត ឬរូបភាព ។ គឺសកម្មភាពផ្គុំផ្គួបនៃបញ្ញាញាណចាស់ៗទាំងឡាយ ដើម្បីសំរេចគោលដៅមួយ ។

**42** - អ្វីទៅហៅថា ឥន្ទ្រិយារម្មណ៍ ( Sensation ) ?

ឥន្ទ្រិយារម្មណ៍ គឺអារម្មណ៍របស់ឥន្ទ្រិយ ជាបាតុភូតចិត្តសរីរ-វិទ្យា ( Phénomène psycho - physiologique ) ដែលកើតឡើងដោយរំញោចលើសរីរាង្គ ឥន្ទ្រិយមួយ ( Organe sensoriel ) ។

**43** - តើឥន្ទ្រិយារម្មណ៍កើតមកពីអ្វី ?

ឥន្ទ្រិយារម្មណ៍កើតមកពីការរំញោច ( Excitation ) ។

**44** តើរំញោចកើតមកពីអ្វី ?

រំញោច កើតមកពីការប៉ះទង្គិចគ្នារវាងសរីរាង្គឥន្ទ្រិយនិងវត្ថុ ចំឡែកដែលគេហៅថាភ្ញោច ( Excitant ) ។

**45** - តើភ្ញោចមានប៉ុន្មានប្រភេទ ?

ភ្ញោចមានបីប្រភេទធំៗគឺ:

ភ្ញោចមេកានិច ( Excitant mécanique ) មានកិនសម្ពាធ ។

ភ្ញោចរូបវិទ្យា( Excitant physique )មានកំដៅ ពន្លឺ សំឡេង អគ្គិសនី ។

ភ្ញោចគីមី ( Excitant chimique ) មានរសជាតិជូរ,រសជាតិចត់ ។

46 - បើសិនជាយើងត្រូវឡើងភក់ តើក្រិយារម្មណ៍របស់យើងបានទទួលស្គោចអ្វី ?

បើខ្សែភ្លើងភក់ ក្រិយារម្មណ៍របស់យើងទទួលស្គោចអេកាតិច ព្រោះរាងប្រយើងរបស់យើងទទួលការញោក់ , ស្ពុតស្រពាក់ ។

47 - បើសិនជាយើងរលាកភ្លើង តើក្រិយារម្មណ៍របស់យើងបានទទួលស្គោចអ្វី ?

បើយើងរលាកភ្លើង ក្រិយារម្មណ៍របស់យើងទទួលកំដៅបណ្ដាលមកយើងក៏ក្ដៅ ; ក្ដៅ . ស្ពា ។ យើងនឹងទទួលស្គោចខ្ញុំព្វា ។

48 - បើសិនយើងទទួលទានម្ហូប ឬ ផ្លែ តើក្រិយារម្មណ៍របស់យើងបានទទួលស្គោចអ្វី ?

បើសិនជាយើងទទួលទានម្ហូបឬផ្លែ យើងទទួលស្គោចគឺមី ព្រោះបណ្ដាលយើងទទួលរសជាតិផ្អែម ឬ ចត់ បណ្ដាលអោយយើងស្រៀវមួយរំពេច ។

49 - តើអ្វីដែលជាគ្រឿងបណ្ដាលអោយយើងមានស្គោចនោះ?

គឺកោសិកាចុងទាំងឡាយ ( Cellules terminales ) ។ កោសិកាកេះស្ទិតនៅចុងនៃសរីរាង្គទាំងពួងរបស់យើងទាំងអស់ , មានមុខការទទួលសម្ពស្សហើយបង្កើតជាស្គោចឡើង ។

តើស្គោចទាំងប៉ុន្មានទាក់ទងនឹងខួរក្បាល ឬ ទេ ?

ក្រោយទាំងពីរបានទាក់ទងទៅខួរក្បាលជាពិសេសបំផុត ។

51 - ចុះបើក្រោយទាំងពីរមានទំនាក់ទំនងទៅនឹងខួរក្បាល តើមានអ្វីជាអ្នកនាំចរន្តទៅដល់ខួរក្បាល ?

អ្នកដែលនាំចរន្តទៅដល់ខួរក្បាល គឺ សរសៃប្រសាទ (Voie nerveuse) ។

52 - ចុះមនុស្សដែលមានសិរីរាង្គ ប្រកបដោយសរសៃប្រសាទស្ទាប់អាចចាត់ទុកថាមនុស្សនោះ មានសក្រិយារម្មណ៍ឬទេ ?

មនុស្សមានសិរីរាង្គប្រកបដោយសរសៃប្រសាទស្ទាប់ , គេពុំអាចចាត់ទុកថាមានសក្រិយារម្មណ៍ឡើយ ព្រោះមនុស្សនោះពុំទទួលនូវសម្ផស្សផ្សេងៗ ។ ហេតុនេះក្រោយក៏នឹងកើតមានដែរ តែគេហៅថាបានរេផ្លិច (Réflexe) ។

53 - នៅពេលណាដែលគេសំគាល់ថា សក្រិយារម្មណ៍ជាការណ៍វេទនា (fait affectif) ?

គេសំគាល់សក្រិយារម្មណ៍ជាការណ៍វេទនា នៅពេលដែលសក្រិយារម្មណ៍នោះ មានលក្ខណៈនាំការអាចផ្ដល់នូវការត្រេកត្រអាល , ការស្រយុតស្រយង់ចិត្ត , ឬការខ្លាចចិត្ត ។

54 - នៅពេលណាដែលគេសំគាល់ថា សក្រិយារម្មណ៍ជាការណ៍បញ្ញា (fait de connaissance)?

គេសំគាល់សក្រិយារម្មណ៍ជាការណ៍បញ្ញា នៅពេលដែលសក្រិយារម្មណ៍នោះទាក់ទងនិងវត្ថុណាមួយនៅខាងក្រៅពិតប្រាកដ

55- តើគេអាចជឿបានថា មនុស្សស្លាប់ដៃ . ស្លាប់ជើង អាចមានឥន្ទ្រិយារម្មណ៍ទេ ? ហេតុអ្វី ?

គេអាចជឿបានថាមនុស្សពិការនេះ អាចមានឥន្ទ្រិយារម្មណ៍បាន ប៉ុន្តែមានលក្ខណៈជាឥន្ទ្រិយារម្មណ៍ ដែលមានសភាពជារូបភាពនៅក្នុងអារម្មណ៍របស់ខ្លួនប៉ុណ្ណោះ ។

56- តើឥន្ទ្រិយារម្មណ៍ជារូបភាពមាន នៅក្នុងឥន្ទ្រិយណា ច្រើនជាងគេ ? ហេតុអ្វី ?

ឥន្ទ្រិយារម្មណ៍ជារូបភាពមាននៅក្នុង ចក្ខុន្ទ្រិយនិងសោតិន្ទ្រិយ ច្រើនជាងគេ ព្រោះចក្ខុជាអ្នកទទួលនូវរូបភាពជាច្រើនយ៉ាង ណាស់មកហើយ ។ ចក្ខុបានឃើញរូបភាពជាមនុស្សរាប់រយ៍ ពិតជានៅក្នុងអារម្មណ៍ ពុំអាចនឹងលប់ចេញទៅវិញងាយ ស្រួល ៗ ឡើយ ។ ចំណែករូបភាពនោះ មានសក្តិពល អាចបណ្តាលអោយមនុស្សសប្បាយរីករាយ , ស៊ើបឬយំក៏បាន ។ នេះគឺដែលគេហៅថា មនុស្សនោះមានបញ្ញាគិត បង្កើត (Imagination créatrice) ដែលមនុស្សនោះ មានអារម្មណ៍រូបកាយនិងភាពកើតឡើងវិញ (Imagination reproductrice) ប៉ុណ្ណោះទេ ។ ម៉្យាងទៀតរូបភាពក៏បាននៅក្នុង សោតិន្ទ្រិយដែរ , ព្រោះសម្លេងអាចពិតជាដក់នៅក្នុងអារម្មណ៍ពិបាកលុប ទោះមនុស្សស្លាប់ទៅហើយ ក៏បាន ។ សម្លេងជាមនុស្សរាប់ម៉ឺនបង្កើតរូបភាព ក្នុងអារម្មណ៍ បណ្តាលអោយគេយំសោក ឬសើចរីករាយ ។ នេះជារូបភាពដែលស្ថិតនៅក្នុងទ្វារទាំងពីរនៃឥន្ទ្រិយរបស់ មនុស្សគ្រប់រូប ។

57 - ហេតុអ្វីបានជាមនុស្សអាចរំលឹកឡើងវិញ ឬស្គាល់ឡើងវិញនូវអតីតកាល ?

មនុស្សអាចរំលឹកឡើងវិញ ឬស្គាល់ឡើងវិញនូវអតីតកាល ព្រោះមនុស្សមានលំនឹក (mémoire) ។

58 - អ្នកប្រាជ្ញខ្លះបានស្មើថា "លំនឹក (mémoire) ជាករណី (fait) ដែលទាក់ទងទៅនឹងសរីរាង្គ" ; រីឯ ចំណែកអ្នកប្រាជ្ញខ្លះទៀតយល់ថា លំនឹកជាសក្តិមួយដែលទាក់ទងទៅនឹងចិត្តគំនិត" ។ តើអ្នកយល់យ៉ាងដូចម្តេចចំពោះមតិពីរផ្ទុយគ្នានេះ ?

ពួកអ្នករូបធាតុនិយម (matérialiste) យល់ថាលំនឹកទាក់ទងទៅនឹងសរីរាង្គ ចំណែកពួកអ្នកគំនិតនិយមពោលអះអាងថា « លំនឹក » កើតមកពីសក្តិដែលទាក់ទងទៅនឹងចិត្តគំនិត ។ បញ្ហាដែលចោទឡើងនេះពុំទាន់មានដំណោះស្រាយថាតើអ្វីជាកត្តាធ្វើឲ្យកើតមានឡើង « លំនឹក » ។ ចំណែកគោលយល់នៃសង្កេតរបស់ពួកអ្នកប្រាជ្ញនេះខុសគ្នា ។ អ្នកមួយយល់ថា បើគ្មានទំនាក់ទំនងនៃរាងកាយសរីរាង្គទេ, លំនឹកក៏ពុំអាចកើតមានបានដែរ ; អ្នកមួយយល់ទៀតថា បើគ្មានទំនាក់ទំនងនៃវិញ្ញាណចិត្តគំនិតទេ « លំនឹក » ច្បាស់ជាពុំអាចកើតឡើយ ។ ដើម្បីវិនិច្ឆ័យលើទស្សនៈទាំងពីរនេះ គប្បីពិនិត្យគំនិតអ្នកប្រាជ្ញទាំងនេះម្តងម្នាក់ ៖

តើសរីរាង្គជាតួបង្កើតលំនឹកដែរឬទេ? សរីរាង្គជាការប្រមូលផ្តុំនិងផ្សារភ្ជាប់បង្កើតជីវិត ឲ្យវិញ្ញាណរំញ័រវិញ្ញាណជាកន្លែងផ្ទុកនូវ

អារម្មណ៍ពីរអន្លាយ ។ តែក្នុងអារម្មណ៍នោះឯងគេឃើញ
មានធម៌ទោសញ្ញាតគតា ។ បរទោសញ្ញាតកាលណាក៏ចុកក្បួរ «ចំ
ណឹក» ដែលជាប្រធានតែការវែកញែកនោះឯង ។ ដូច្នេះយើង
ឃើញថា សរីរាង្គជាអ្នកផ្ដើមដាំទិបត្តិ «ចំណឹក» ។ ពុទ្ធិសាស្ត្រ
របស់អ្នកប្រាជ្ញតុនិយមប្រកបដោយសុភនិច្ច័យវែង ព្រោះបើ
សិនជាគ្មានសរីរាង្គកាលណាឡើយនឹងមានវិញ្ញាណ , បើសិន
ជាគ្មានវិញ្ញាណ ក្រដូចឡើយនឹងបានអារម្មណ៍ ។ បើសិនគ្មាន
អារម្មណ៍កាលណាឡើយនឹងមានបរទោសញ្ញាតគតា, ហើយបើ
គ្មានបរទោសញ្ញាតគតា , តើមាន «ចំណឹក» ពីណាមក ?

ចូរយើងក្រលេកមកមើលវិនិច្ឆ័យរបស់អ្នកតំរិះតិចបន្ទិច
វិញ, តើមានលក្ខណៈយ៉ាងណាដែរចំពោះពាក្យថា ៖
«ចំណឹកកើតមកពីចំណាក់ចំណងរវាងសត្វនឹងចិត្តគំនិត» ។

ដោយពុំដាច់យកសត្វមកវិនិច្ឆ័យ គឺគ្រាន់តែលើកយក
ចិត្តគំនិតតែម្យ៉ាងមកពិនិត្យក៏ឃើញមានឆ្លើយបានថា ខ្សែរ.
នេះប្រាសចាកទុក្ខតតិម្ហួយភាគធំស្រេចទៅហើយ ។
ព្រោះថាចិត្តគំនិត ក៏ស្ថិតនៅក្នុងបរទោសញ្ញាតគតាដែរ ។ ចិត្ត
គំនិតបានចូលទៅស្ថិតនៅក្នុងខ្លួនក្សាណ ដែលថាចំណងយ៉ាង
ធំនៃអារម្មណ៍ ។ ដូច្នេះ “ចំណឹក” កិតថាកើតមកពីចំណាក់
ចំណង “ចិត្តនិងសត្វ” នោះផង, និងសរីរាង្គកាយផង ។ សារុប
សេចក្ដីមកអ្នកដោយអោយតែ ចាក់គង់នឹងខ្លួនក្សាណសុទ្ធតែ
មានលក្ខណៈដាវិញ្ញាណ ទៅណាចំពោការខាងលើនេះទាំង
អស់ ។

៥៩ - អ្វីទៅហៅថាមនោគតិ ?

60 - អ្វីទៅហៅថាមនោគតិរំលឹកឡើងវិញ? (Imagination reproductrice)

ដែលហៅថាមនោគតិរំលឹកឡើងវិញគឺ មនោគតិដែលធ្វើឲ្យរូបភាពនៃព្រឹត្តិការណ៍មួយ ដែលកន្លងផុតទៅហើយ កើតឡើងវិញ , ហើយប្រកបដោយលក្ខណៈហាក់ដូចជារូបភាពបច្ចុប្បន្ន ។

61 - អ្វីទៅដែលហៅថាមនោគតិបង្កើត? (Imagination créatrice)

មនោគតិបង្កើត គឺ មនោគតិដែលបំបែករូបភាពទាំងឡាយដែលមាននៅក្នុងសំលឹក ដើម្បីយកមកធ្វើសំយោគរៀបចំជារូបភាពថ្មី ។

62 - តើមនោគតិបង្កើតចែកជាប៉ុន្មានសណ្ឋាន? គឺអ្វីខ្លះ?

មនោគតិបង្កើតចែកជាបីសណ្ឋាន គឺ:

១- សណ្ឋានឈឺ

២- សណ្ឋានថ្នាក់ទាប ,

៣- សណ្ឋានថ្នាក់ខ្ពស់ ។

63 - ចុះការយល់សប្តិ ជាមនោគតិបង្កើតក្នុងសណ្ឋានអ្វី?

ការយល់សប្តិជាមនោគតិបង្កើតក្នុងសណ្ឋានថ្នាក់ទាប ។ ព្រោះការយល់សប្តិ ជាសំណង់រូបភាពប្រកបដោយលក្ខណៈវត្ថុវិស័យភាពនៅពេលដែលលង់ក្នុងដំណេក ។

64 - ចុះនៅពេលយល់សប្តិ តើសរីរាង្គឥន្ទ្រិយបានដើរឬទេ?

នៅពេលយល់សប្តិ សរីរាង្គឥន្ទ្រិយឥតដើរទេ ។

65 បើនៅពេលយប់ស្ងាត់ សរីរាង្គត្រៀមតែងនៅទទេ ហេតុអ្វីក៏មានសំណាក់រូបភាព ? តើសំណាក់រូបភាពនោះយកពីណា ?

នៅពេលយប់ស្ងាត់ សរីរាង្គត្រៀមពុំទទួលយកអ្វីក្រៅតែមានព្រលឹងវិញ្ញាណប្រព្រឹត្តិ - ពេលនោះសរីរាង្គត្រៀមរាល់ខ្ទង់ផ្សេងទៀតជាប្រចាំនាំអារម្មណ៍ក្នុងការបង្កើតសំណាក់រូបភាព គឺកាលណាក្រុមរូបភាពប្រែប្រួលជាប់ជារូបភាពបន្ទាប់ ។

66 - អ្វីទៅហៅថាការរវើរវាយ : ( Rêveries )

ការរវើរវាយគឺជាសភាពមួយនៃចិត្តដែលតែងតែនឹកឃើញនូវរូបភាពផ្សេងៗកើតមានឡើង, ហើយរូបភាពទាំងឡាយដែលកើតមក សុទ្ធតែតាមរបៀបពន្លាត់គំនិតទាំងអស់ (Association des idées) ។

*

* *

## ៤- ល្បិចទូទៅនៃគំនិត

**67 - អ្វីទៅហៅថា "វិចារ"**

វិចារគឺជាតំណភ្ជាប់តភ្ជាប់នៃគំនិតជាច្រើន ដើម្បីទាញរកសន្និដ្ឋានមួយ ។

**68 - តើគេអាចចាត់ទុកវិចារថា ជាចំណងរបស់គំនិតបានឬទេ ?**

វិចារតគំនិតជាច្រើនដើម្បីរកឲ្យឃើញសន្និដ្ឋានមួយ, ដូច្នេះ គេអាចចាត់ទុកវិចារថាជាចំណងនៃគំនិតបាន ។

**69 - តើអំពើសំខាន់របស់គំនិតមានប៉ុន្មាន ?**

អំពើសំខាន់ៗរបស់គំនិតមានបី ,

១- បញ្ញត្តិ (concept)

២- វិនិច្ឆ័យ (Jugement)

៣- វិចារ (Raisonnement)

**70 - អ្វីទៅហៅថាបញ្ញត្តិ ?**

បញ្ញត្តិជាន័យរបស់ពាក្យមួយ , ជាអ្វីដែលគេគិតដល់ កាលណាគេប្រើពាក្យមួយ ។

**71 - តើមានបញ្ញត្តិជារូបទេ ?**

បញ្ញត្តិទាំងអស់សុទ្ធតែអរូប ដូច្នេះគ្មានបញ្ញត្តិរូបទេ ។

**72 - ហេតុអ្វីបញ្ញត្តិសុទ្ធតែអរូប ?**

បញ្ញត្តិទាំងអស់សុទ្ធតែអរូប ព្រោះបញ្ញត្តិជាអំពើរបស់គំនិត ហើយគំនិតសុទ្ធតែអរូប ។

គំនិតបានធ្វើតេក្តិកម្មដែលមនុស្សប្រាថ្នាចង់អោយមាន ហើយ ដែលមិនទាន់មាននៅឡើយ ។ បើយោលទៅតាមប្រវត្តិសាស្ត្រ គំនិតដែលមានលទ្ធផលជិតពិសោធន៍ ទៅការបង្ក: បានកើតមុនស្បង់ដឹងថាប្រភពនៃស្បង់ ។ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយ គំនិតត្រូវការ «ចំណេះ» របស់ស្បង់ ដើម្បីយកមកបំប្លែងអោយទៅជាសំណាង ។ ឧទាហរណ៍ : អ្នកប្រាជ្ញបាននាំគ្នាបង្កើតម៉ាស៊ីន ឌ័រ( Ordinateur )ដើម្បីគិតគូរឡើងវិញនូវវិញ្ញាសាទាំងឡាយ ដែលគេបានដាក់អោយគិតស្វែងរក ។ ម៉ាស៊ីន អ័កឌីនាទ័រនោះដោះវិញ្ញាសាដែលគេដាក់អោយមនុស្សបញ្ចេញនូវចំណេះរបស់ខ្លួនបានយ៉ាងត្រឹមត្រូវបំផុត ។ សាមីខ្លួនអ្នកប្រលង បង្ហាញសេចក្តីពេញចិត្តចំពោះលទ្ធផលពិតប្រាកដរបស់ខ្លួន , ពោលគឺគ្មាន អយុត្តិធម៌ក្នុងកំណែវិញ្ញាសា ។ អ្នកធ្លាក់ក៏ពេញចិត្ត , អ្នកជាប់ក៏ពេញចិត្ត , ព្រោះម៉ាស៊ីនបង្ហែកនេះបង្ហាញនូវភាពពិតនៃស្បង់ ។ អ្នកប្រាជ្ញបានដល់គោលដៅរបស់ខ្លួនដែលចង់បង្ហាញនូវភាពពិត , ហើយគំហើញនេះប្រកបដោយសត្តៈយ៉ាងជាក់លាក់ក្នុង ការបំពេញនូវសេចក្តីត្រូវការរបស់មនុស្សឃើញថា ស្បង់ពីកមុនគំនិតពិតប្រាកដមែន ។ ក៏ប៉ុន្តែអាស្រ័យគំនិតទាំងឡាយចូលមករួបរួមគ្នាដែរ , ទើបស្បង់បានសំរេចនូវគោលដៅរបស់ខ្លួន ។ ព្រោះថាដើម្បីបានអ័រឌីនាទ័រ អ្នកប្រាជ្ញបានប្រើសម្ភារៈដែលជាឧបករណ៍របស់គំនិត ដូចជាដែក , ចារ៉ូ ចំព្រ , ខ្សែភ្លើងនិងគ្រឿងដែល មានរូបជាតិវត្ថុ ដើម្បីផ្គុំ

78- តើអនុមានញែកគណិតវិទ្យា អាចហៅថាអនុមានញែកសំយោគ (déduction synthétique) បានឬទេ?

យើងនឹងថា , គណិតវិទ្យាសាស្ត្រដែលរៀនអំពីចំនួនហើយ អនុមានញែកសំយោគក៏មានគម្ពុត្ត ជាចំនួនដែរ, ដូច្នេះយើងអាចហៅអនុមានញែកគណិតវិទ្យាថា ជាអនុមានញែកសំយោគការដែរ ។

79- ក្រៅពីគណិតវិទ្យា តើមានសាស្ត្រណាខ្លះដែលត្រូវការប្រើអនុមានញែក ? ហេតុអ្វី ?

ក្រៅពីគណិតវិទ្យា គេត្រូវការអនុមានញែក ទៅប្រើក្នុងសាស្ត្រពិសោធ។ ព្រោះសាស្ត្រពិសោធត្រូវការភាពល្អិតល្អន់ដូចគណិតវិទ្យាដែរ ។

80. អ្វីទៅហៅថាអនុមានរួម ?

អនុមានរួមជាវិចារដែលចេញពីការពិសេសជាច្រើន ដើម្បីរួមកោយបានជាច្បាប់ទូទៅមួយ ។

81- តើអនុមានរួមមានគោលដៅយ៉ាងដូចម្ដេច ? ចូរលើកឧទាហរណ៍ ។

អនុមានរួមមានគោលដៅចង់ជ្រើសរើសលក្ខណៈរួមមួយ ។ ហេតុដូច្នេះហើយបានជាអនុមានរួម ចាំប្រហែលមកពីការសង្កេតការច្រើនមកពិនិត្យ ។

ឧទាហរណ៍ : ខ្ញុំសង្កេតឃើញឪពុកមិត្តខ្ញុំស្លាប់

— មិត្តខ្ញុំក៏ស្លាប់

— ឪពុកខ្ញុំក៏ស្លាប់

ដូច្នេះខ្ញុំក៏ត្រូវតែស្លាប់
ហើយមនុស្សទាំងអស់ត្រូវតែស្លាប់ដែរ ។

82- តើការសន្និដ្ឋានដោយវិធី ប្រើអនុមានរូបសុទ្ធតែត្រូវទាំងអស់ឬយ៉ាងដូចម្តេច ។

អនុមានរូបដែលធ្វើឡើងភ្លាមៗច្រើនតែជួបនឹងកំហុស ហើយពុំសូវបានត្រឹមត្រូវទេ ។

ឧទាហរណ៍ — ប៊ិចខុន ជាចោរលួចការខ្ញុំ
— យ៉ុនម៉ិញ ជាលួចខោខ្ញុំ។
— ដូច្នេះសៀវភៅខ្ញុំបាត់ឡូវនេះ ជា ជាអ្នកលួច ។

83- អ្វីទៅហៅថាវិភាគ ?

វិភាគគឺពន្យល់ ឬ ជាអ្នកបំបែកវត្ថុមួយទៅជាធាតុផ្សេងៗ ។

84- តើវិភាគបែកចេញជាប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិភាគបែកចេញជាពីរយ៉ាងគឺ ៖

១- វិភាគពិត (Analyse réelle)

២- វិភាគក្នុងគំនិត (Analyse idéale)

85- អ្វីទៅហៅថាវិភាគពិត ?

ដែលហៅថាវិភាគពិត គឺ គេយករូប ឬ សារធាតុ , ឬ ធាតុគួត រូបវិទ្យាដែលត្រូវសិក្សាឬពិនិត្យនោះមកបំបែកឲ្យទៅជាចំណែកដាច់ពីគ្នា ។ ដូចការគេកាត់ឬដែលត្រូវធ្វើវិភាគនេះ ជាដុំៗ ដើម្បីស្គាល់គ្រប់ធាតុពិតរបស់វត្ថុនោះ ។

109- បើស្បង់ទាំងឡាយសុទ្ធតែទទួលលក្ខណៈពិតរបស់ខ្លួនខុសពេលគ្នា, តើស្បង់ទាំងនោះបានពឹងផ្អែកគ្នាទៅវិញទៅមកដែរឬក៏ពឹងតែលើវិធានការផ្ទាល់ខ្លួន ?

ស្បង់ទាំងឡាយបានពឹងផ្អែកលើគ្នាទៅវិញទៅមក ដោយខានពុំបាន ។ ជាពិសេសគឺចំពួកស្បង់ដែលមានលក្ខណៈរូបីជាងគេ ។

110- នរណាដែលមានគំនិតទប់ភាពអសុត្ថៈ របស់ស្បង់មុនគេ ?

លោកអ្នកគុសកុង មានគំនិតទប់អសុត្ថៈ គឺការអាចផ្លាស់ប្តូរនៃស្បង់ទាំងឡាយដោយបញ្ចូលស្បង់ទៅក្នុងសង្គមវិទ្យា ។

111- តើគំនិតរបស់លោកអ្នកគុសកុង បានចៀសផុតពីការរិះគន់របស់អ្នកប្រាជ្ញដទៃទៀតឬទេ ? ហេតុអ្វី ?

គំនិតរបស់លោកអ្នកគុសកុងត្រូវទទួលការរិះគន់ពីសំណាក់អ្នកប្រាជ្ញដទៃទៀតជាច្រើន ។ ព្រោះថា លោកពុំបានត្រិះរិះពីទំនាក់ទំនងរវាងស្បង់ទាំងឡាយនេះឲ្យល្អ ។ ម្យ៉ាងទៀត លោកអ្នកគុសកុង បានសន្និដ្ឋានចំពោះតែផ្នែកនៃកុងវិជ្ជាខ្លះខុសនិងសត្ថៈ ដូចជា រូបវិទ្យានិង ស្បង់គីមី, លោកអ្នកគុសកុងចែកអោយដាច់ពីគ្នា ។ តាមពិតវិជ្ជាទាំងពីរនេះអាចមានទំនាក់ទំនងគ្នា, ព្រោះបើគេបានយករូបមន្តនៃវិជ្ជាទាំងពីរនេះទៅប្រើក៏ឃើញថាកើតជាស្បង់មួយថ្មីទៀត ដែលគេហៅថា "តារារូបវិទ្យា" (astrophysique ។

*

* *

វិភាគនិងសំយោគបានផលប្រយោជន៍ស្មើគ្នាគឺ វិភាគជាឧបករណ៍នៃរបកគំហើញធាតុដែលកប់ខ្លួន តែជាធាតុដែលមានស្រេចហើយ ។

សំយោគជាឧបករណ៍សំរាប់បង្ហាញ និងពន្យល់អោយបានច្បាស់នូវរបកគំហើញមួយ ព្រោះសំយោគជាអ្នកបង្រួមមកវិញ នូវការណ៍ទាំងអស់ដែលវិភាគជាអ្នករកឃើញ ។

92- អ្វីទៅហៅថាអព្ភន្តរញាណ ?

អព្ភន្តរញាណជាភាពរហ័សពុទ្ធិដ៏ខ្ពង់បំផុត , ជាគំហើញផ្ទាល់មុខជាចំណាប់ភ្លាម ដោយពុំចាំបាច់មានអ្នកបណ្តាល ។ ដូច្នេះអព្ភន្តរញាណជាពុទ្ធិគ្មានគិតពិចពិចិត្តគ្មានអ្នកបណ្តាល , ជាពុទ្ធិដែលកើតឡើង ដោយមានចិត្តតាំង ។

93- តើអព្ភន្តរញាណមានប៉ុន្មានបែប ? គឺអ្វីខ្លះ ?

អព្ភន្តរញាណមានបួនបែបគឺ :

១- អព្ភន្តរញាណចិត្តវិទ្យា (intuition pychologique )

២- អព្ភន្តរញាណឥន្ទ្រិយ (intuition sensible)

៣- អព្ភន្តរញាណបញ្ញា (intuition intellectuelle)

៤- អព្ភន្តរញាណប្រាកដ (intuition d'évidence)

94- តើអព្ភន្តរញាណទាំងបួនបែបបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ពុទ្ធិយើង ?

អព្ភន្តរញាណអោយយើងចាប់បានគតិបែបទទេ ដែល

០៥- តើអក្ខរញាណបានផ្តល់គុណសម្បត្តិ និងគុណវិបត្តិយ៉ាងដូចម្តេចខ្លះ?

អក្ខរញាណដែលជាល្បិចមួយនៃគំនិត អាចមានគុណសម្បត្តិផង, គុណវិបត្តិផង ។

អក្ខរញាណចិត្តវិទ្យា ញុំាងយើងឲ្យចាប់គតិបានដោយចិត្ត ។ ធ្វើឲ្យយើងយល់និងដឹងច្បាស់នូវសច្ចៈទាំងឡាយដោយពុំបាច់ពិសោធន៍និងពិចារណា ។ អក្ខរញាណនេះពុំបាចឲ្យអ្នកប្រព្រឹត្ត ទៀយហាត់និងប្រមើលមុខក្នុងគំនិតឡើយ ។

អក្ខរញាណឥន្ទ្រិយ ញុំាងអ្នកប្រព្រឹត្តឲ្យបានចាប់យកគតិៈ ស្រាវខ្លួនបាន ។ ផ្តល់ចំណេះស្រាយនៃញាណភ្លាមៗ ព្រោះទាំងបញ្ញាញាណស្គាល់ដោយមិនពិសោធន៍ ។ អក្ខរញាណឥន្ទ្រិយផ្តល់សច្ចៈនៃចំនាត់ចំណង ប្រៀបដូចពន្លឺចិត្តដែលចេញអរិយ្សាដោយវិនាសទេ ។

អក្ខរញាណបញ្ជាក់នូវផ្លូវអ្នកប្រាជ្ញមុនៗល្អផលដែលបាន បកពីតក្កភាពនៃពិសោធន៍ក្នុងស្បែក ។ មិនតែប៉ុណ្ណោះសោត គេតែងបានដឹងថា «អក្ខរញាណជាសារៈ ឬជាវិសេសនៃពិសោធន៍ផង ។

អក្ខរញាណបរមត្ថវិជ្ជា ជាសំណេរាយតិចក្រក់តែមាតិមេត គឺជាតេជ្ជទេណ្ណរាយនៃចិត្ត ដែលជាមិត្តភាពយកពីអំណាចទេពនៃព្រះជាម្ចាស់ ៈ

ក៏ប៉ុន្តែគេបានដឹងថា អក្ខរញាណទាំងអស់មានគុណវិបត្តិខ្លះព្រោះ ៈ

១ - កាផលដែលបានមកដោយតស៊ូប្រឹង,  ផាសលដែលអាចបំភ្លឺរហ័សដោយស្ងប់ប្រទះនឹងវិបត្តិផ្សេងៗ  ព្រោះយើងពុំបានពិចារណាក្រោយទាំងពុំបានពិនិត្យរាវរាប់ជាផង ។

២ - អត្តសញ្ញាណឥន្ទ្រិយច្រើនទៅតាមឥន្ទ្រិយរបស់យើង; ជួស្ទើតែយើងនឹងថា  អត្តសញ្ញាណជាការស្គាល់និងយល់ដោយគ្មានអ្នកគណនាក្តី  ក៏យើងទៀសពុំរួចពីកំហុសខ្លះដោយហេតុថាញៀចចំនិតនេះ  ពុំមុនវិចារណាចិត្ត  ហើយជាឧបករណ៍នៃវិចារណដោយសេរីទ្រទ្រង់គុណផលក៏សឹងបាន ។

* * *

# សៀង់និងគំនិតសៀង់

96 - អ្វីទៅហៅថាសៀង់ ?

សៀង់ជារបកគំហើញនៃចំណាក់ចំណងដែលបានក្នុង កថ : ជាការគិតខំ ស្វែងយល់និងស្គាល់អ្វីដែលមាន ។

97 - អ្វីទៅហៅថាតិចនិច ?

តិចនិចជាគំរោងវិធីជាក់លាក់ដើម្បីបង្កើតផលខ្ពស់ ដែលគេយល់ថាមានប្រយោជន៍ ។ តិចនិចតំរង់ទៅរកអ្វីដែលមានប្រយោជន៍ ហើយជាអ្នកបំពេញសេចក្ដីត្រូវការចាំបាច់របស់មនុស្ស ។ តិចនិចបង្កើតអ្វីដែលយើងប្រាថ្នាចង់អោយមាន ហើយដែលមិនទាន់មាននៅឡើយ ។

98 - តើសៀង់មានលក្ខណៈគំនិតយ៉ាងដូចម្ដេច ?

គំនិតសៀង់ មិនទទួលស្គាល់អ្វីដោយខ្វះភស្តុតាងទេ ។ សៀង់មិនរាប់យកពីរោះការចំលងទំនៀមឡាយ - ព្រោះសៀង់មានលក្ខណៈជាគំនិតរិះគន់ (Esprit critique) តែងតិះដៀលលើគំនិតផ្ទាល់របស់ខ្លួនថែមទៀតផង ។ សៀង់មានលក្ខណៈជាគំនិតសកល (Esprit universel) កាលណាសៀង់កើតចេញពីវិចារណញាណ ជាគំនិតជាក់ច្បាស់ ដែលជួយស្រឡះពីលក្ខណៈប្រហាក់ប្រហែលនៃគំនិតសាមញ្ញ ។

99 - អ្នកប្រាជ្ញឈ្មោះអ្វីដែលបាន បំបែកសៀង់ជាប្រាំមួយផ្នែក ? តើអ្វីខ្លះ ?

លោកអូគុស្តកុងបានបំបែកស្យង់ជាប្រាំមួយផ្នែកគឺ ៖

១- គណិតវិទ្យា

២- តារាវិទ្យា

៣- រូបវិទ្យា

៤- គីមី

៥- ជីវវិទ្យា

៦- សង្គមវិទ្យា ។

100 - គេបានពោលថា "ស្យង់" បានត្រូវឃ្លាតចេញពីទស្សនវិជ្ជាដោយការរីកចំរើននៃពុទ្ធិរបស់អ្នកប្រាជ្ញទាំងឡាយ ។ ចូររៀបរាប់ឈ្មោះអ្នកប្រាជ្ញវិទ្យាសាស្ត្រ និងមុខវិជ្ជារបស់អ្នកប្រាជ្ញទាំងនោះដែលអ្នកបានដឹង?

ដោយសារមនុស្សមានចំណង់ចង់កែប្រែធម្មជាតិ ដើម្បីតំរូវទៅតាមសេចក្តីត្រូវការរបស់ខ្លួន ទើបមនុស្សបង្កើតស្យង់ឡើង ។ ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយដែលបានជំនឿលើទំនោរគតិការណា (Tendance réfléchie) ជាគុះការ និងសត្វក្រោយទាំងចំណាយកំលាំងគំនិតបញ្ញារបស់ខ្លួន, ដើម្បីតាមដានរកប្រភពនៃសច្ចៈ (Origine de la vérité) ក្នុងមាតិការបស់ស្យង់ ។ រីឯអ្នកប្រាជ្ញទាំងនោះគេសង្កេតឃើញ

— លោក ញូតុន និង ទ្រឹស្តី មេកានិចរបស់លោក

— លោក អ៊ឺគ្លីត និង ទ្រឹស្តី គណិតវិទ្យា

— លោក គាលីលេ និង ទ្រឹស្តី រូបវិទ្យា

— លោក ឡាំសេង និង ស្ត្រី គីម

— លោក ឡាប៉ាក់ និង ស្ត្រី ស៊ីវិច្ឆ

— លោក គុង និង ស្ត្រី សង្គហវិទ្យាចំរើន ។ល។

101 - អ្នកយល់ដូចម្តេចចំពោះ មតិមួយដែលបានពោលថា ៖
« ទស្សនវិជ្ជាជាការពិចារណា មិនមែនជាការបូក បញ្ចូលចំណេះទាំងអស់ទេ » ។ ចូរវែកញែកនិងអោយ យោបល់ចំពោះមតិខាងលើនេះ ។

ទស្សនវិជ្ជា គឺ ស្នេហាគតិបណ្ឌិត, នេះជានិយមន័យដែល គេបានបកស្រាយតាមភាសារបស់ក្រិចថា « ភីឡូសូភីយ៉ា (PHILOSOPHIA) ។

ពាក្យថា « ស្នេហា » គឺចូលចិត្ត, ស្រឡាញ់និងចង់បាន ។ តើអ្នកទស្សនវិជ្ជាស្រឡាញ់និងចង់បានអ្វី? ឆ្លើយ ថាអ្នកទស្សនវិជ្ជាស្រឡាញ់ឧត្តមគតិត្រូវ, ទោះបីក្នុងវិស័យណាក៏ដោយ ។ ដូច្នេះដើម្បីអោយបានឧត្តមគតិត្រូវ, អ្នកទស្សនវិជ្ជាបានប្រើ មនោសញ្ចេតនានិងបញ្ញារបស់ខ្លួនស្រាវជ្រាវរក «ពុទ្ធិសច្ចៈ» ដោយប្រើជាចាំបាច់នូវការពិចារណា ។ ការពិចារណាហេតុ និងផលនៃធម្មជាតិ និងវត្ថុធាតុផ្សេងៗក្នុងធម្មជាតិជាតម្រូវរបស់អ្នកពិចារណា ។ ពិតមែនហើយ, ជួយនូវសញ្ញាណៗពុំ អាចត្រូវគេរាប់ថាវិជ្ជាការចេះដឹងទាំងអស់បានទេ ក៏ប៉ុន្តែ អាចបូកបញ្ចូលចំណេះដឹងប្រើតជាក់ទៅក្នុងគំនិតរបស់គេបាន ដែលអោយកែតម្រូវការរបស់គេទទួលបានពិតប្រាកដនោះបាន ។

សព្វថ្ងៃនេះ វិទ្យាស្ថានបច្ចេកទេសកើតមានឡើងស្ទើរ
តែគ្រប់អារ្យប្រទេសទាំងអស់ ។ ការបង្កើតសាលាពហុបច្ចេកទេស
(politechnique), នេះ ក៏មិនមែនមានន័យថាគ្រាន់តែឲ្យមាន
បន្តុះបណ្ដាលការងារបច្ចេកទេសប៉ុណ្ណោះទេ, តែគេបានបង្កើតឡើង
ដើម្បីបង្កើតមនុស្សទាំងឡាយណា ដែលមានវិជ្ជាទូលំទូលាយ
អាចទទួលយកការប្តូរចំណេះជាតិបច្ចេកទេសនោះបាន ។ ស្ទើរ
តែគ្រប់ភាគច្រើនទាំងអស់ជាចំណេះទាំងអស់នោះស្ទើរតែជាមនុស្ស
សក្តិ, គិតពិចក្ដី ពុំមែនតែចង់ក្ដី ត្រូវតែស្រាវជ្រាវណា
ទាំងអស់ ។ ម្យ៉ាងទៀតយើងឃើញថា គ្រប់គ្រាន់តែប្លុក
ចំណេះទាំងអស់ របស់មនុស្សប៉ុណ្ណោះទេ, តែត្រូវទទួលស្គាល់
ដឹងគ្រប់សព្វនោះគឺជាបន្តិច មាន្រស័យការពិចារណានេះ
ដែរ ។ ស្ទើរតែទាំងអស់នេះ នូវស្រាវជ្រាវពីគោលសេចក្ដី
របស់ខ្លួនថា " មនុស្សវិជ្ជា - ត្រូវការតែការពិចារណាលើ
លើចំណេះទាំងអស់ក្នុងលោក និងក្រៅលោក" ។

ជាមួយគ្នានឹងការពិចារណានេះ លោក "ប៉ូលវ៉ាឡេរី (Paul »
Valéry) » ក៏បានសរសេរនូវគំនិតនេះ ថាក្រោយមក
គឺ៖" ខ្ញុំជាមនុស្សវិជ្ជា ក្រោយទាំងឡាយណាដែលនឹងត
ស្វែងរកមើលឃើញសរុប (Vision globale) ផ្នែកចំណេះទាំង
អស់របស់ខ្លួន នោះបីតែនោះមានចំណេះស្ទើរតែមិនបាន
គឺជាទេ" លោកប៉ូលវ៉ាឡេរី បានគិតយ៉ាងដូចនេះ
បុគ្គលម្នាក់ៗ ត្រូវតែព្យាយាមក្នុងការស្វែងរកចំណេះដឹងទូលំទូលាយ

របស់ខ្លួន ។ ដូច្នេះមនុស្សនិយម ជាវិជ្ជាមួយដែលមកពីសង្គម លើការតស៊ូការពាររបស់ខ្លួន នៅក្រោយយកមកគុណជាពុទ្ធិ ខ្លួនខ្លួនឯងដែលពីកលោកសម័យថ្មី កំពុងតែមានយកតំលៃ ដោយឥតរូបតែកបាន ។

102- គេពោលថា ៖ “តិចនិចជាប្រតិបត្តិរបស់ស្យង់. ដូច្នេះ ខ្សែនេះបានបញ្ជាក់ថា តិចនិច សព្វថ្ងៃនេះពឹងផ្អែក លើស្យង់ទាំងស្រុង ។ ក្លួរពិនិត្យអាហារណ៍និងពន្យល់ អោយបានគ្រោះក្លាយថា ៖ ស្យង់ក៏ពឹងផ្អែកទាំង ស្រុងទៅលើតិចនិចដែរ” ។

គេនិយមពោលថា : «ស្យង់ថ្វាយកំណើតនៃចំណាក់ចំនង ដែលមានគុណតថៈ ។ ដូច្នេះ, ស្យង់ស្វែងរកសច្ចៈ, ទោះ សច្ចៈនោះមានលក្ខណៈយ៉ាងណាក៏ដោយ ។ ហេតុនេះ ហើយបានជាយើងឃើញថា ស្យង់ពុំត្រូវការប្រភាននិស័យ ភាព(subjectivité) ទេ ។ ជាមួយនឹងការចំរើនព្រងើរកត់ កើតឡើង នៅក្នុងធម្មជាតិ, ស្យង់បានជិតចំពន្យល់អោយ បានឃើញប្រត្យក្សនូវអ្វីដែលមាន ។ ឯចំណែកតិចនិចជា កំណើតជាក់លាក់ដើម្បីបន្តិកលទ្ធផល ដែលយល់ថាមាន ប្រយោជន៍ ។ អ្វីដែលមនុស្សត្រូវការ តិចនិចបានទទួល លក្ខណៈពីដើម្បីបំរើសេចក្តីត្រូវការនោះដែរ ។

១- ... (Positi...

73- អ្វីទៅហៅថាវិនិច្ឆ័យ ?

វិនិច្ឆ័យជាអំពើមួយរបស់គំនិត ដែលតែងអោយលក្ខណៈទៅបញ្ញត្តិ ។ ជាចំណងដែលចងបញ្ញត្តិពីរ ឬបញ្ញត្តិជាច្រើន អោយជាប់គ្នា ។

74- វិចារជាអ្វី ?

វិចារជាការប្រមូលផ្តុំនូវវិនិច្ឆ័យពីរ ឬវិនិច្ឆ័យជាច្រើន ។

75- អ្វីទៅហៅថាអនុមានញែក ?

អនុមានញែកគឺជាវិចារដែលញែក សន្និដ្ឋានចេញពីគោលការណ៍ទូទៅ ។ គន្លងជាគំរូនៃអនុមានញែកមួយដែរ ។

ឧទាហរណ៍ : មនុស្សទាំងអស់សុទ្ធតែត្រូវស្លាប់

សូក្រាតជាមនុស្សម្នាក់ ដូច្នេះសូក្រាតត្រូវតែស្លាប់ដែរ ។

76- តើគេចែកអនុមានញែកជាប៉ុន្មានបែប ? គឺអ្វីខ្លះ ?

គេចែកអនុមានញែកជាពីរបែបគឺ :

១- អនុមានញែកតាមរូបរាង (déduction formelle)

២- អនុមានញែកគណិតវិទ្យា (déduction mathématique

tique

77- តើគេអាចហៅអនុមានញែកតាមរូបរាងថាជាអនុមានញែកវិភាគបានឬទេ ?

គេអាចហៅអនុមានញែកតាមរូបរាងថាជាអនុមានញែកវិភាគបាន (déduction analytique)

ជីវិតហៀងយន្តស្វ័យប្រវត្តិនេះឲ្យមានរូបរាងឡើង ។ ផ្ទុយមកវិញ
ដែលពោលមកខាងលើនេះ ជាសំរោគតែទ្រឹស្ដីត្រូវតែងតែ
ស្យង់ក៏ពឹងលើតិចនិច , ដូច្នេះតិចនិចក៏ពឹងលើស្យង់ដើម្បី
ញុំាងអោយសប្រេចខ្លួនគោលបំណងរបស់ខ្លួន គ្រូនិងសេចក្តី
ប្រៀបប្រដូចមួយវត្ថុដែលជាគោលបេជា ៖

« ស្យង់ជាគសង់គ្រឹះដ៏តំណែងនៃទ្រឹស្ដី បញ្ចូនវិជ្ជាសាស្ត្រគតិត
ក្រោមសំណង់គោរ ដើម្បីស្វែងរកប្រភពច្បាស់លាស់ , រីឯ
តិចនិច ជាគ្រឿងផ្គុំសាច់នៃសំណង់ទាំងមូល » ។

103- បើស្យង់និយមការជាក់លាក់ , បើស្យង់មិនទទួលអ្វី
ទាំងឡាយដែលខ្វះភស្តុតាង តើស្យង់មានសច្ចៈដាច់
ខាតឬទេ ? ហេតុអ្វី ?

ពិតមែនតែស្យង់និយមការជាក់, ពិតមែនតែស្យង់មិនទទួល
ស្គាល់អ្វីទាំងឡាយដែលខ្វះភស្តុតាង , ស្យង់ពុំមានសច្ចៈដាច់
ខាតឡើយ ។ ព្រោះពុំមែនជាទ្រឹស្ដីមួយដែលបានទទួលពី
អាទិទេពទេ ។ ផ្ទុយទៅវិញស្យង់មានសច្ចៈដែលអាចផ្លាស់ប្តូរបាន ។

104- តើស្យង់បានផ្តាច់ខ្លួនអោយដាច់ពីធម្មជាតិឬទេ ?

ស្យង់ពុំមានបំណងនឹងផ្តាច់ខ្លួនអោយចេញពីធម្មជាតិទេ ។
តែផ្ទុយទៅវិញ ស្យង់បានប្រើគ្រប់មធ្យោបាយទាំងអស់របស់
ខ្លួនដើម្បីអោយបានជិតចូលទៅជិតធម្មជាតិ ។

105- បើជ្រើសរើសយកតែសំខាន់ៗ តើស្យង់បានប៉ុន្មាន
បែប ?

បើជ្រើសយកតែសំខាន់ៗ លោកអូគុស្តកុង ( Auguste Comte) បានចែកស្រង់ជាប្រាំមួយរបៀបដូចតទៅនេះ :-

១- គណិតវិទ្យា ( Mathématique )

២- តារាវិទ្យា ( Astronomie )

៣- រូបវិទ្យា ( Science physique )

៤- គីមី ( Chimie )

៥- ជីវវិទ្យា ( Biologie )

៦- សង្គមវិទ្យា ( Sociologie )

106 - ចុះគេបានដឹងថា « រូបវិទ្យា » (Science physique) មានលក្ខណៈ ជាស្រង់ពិតប្រាកដនៅក្នុងសតវត្សទីប៉ុន្មាន ?

រូបវិទ្យា ( Science physique ) បានទទួលលក្ខណៈជាស្រង់ពិតប្រាកដនៅក្នុងសតវត្សទី១៧ ។

107 - តើសតវត្សទី១៧នេះ អ្នកប្រាជ្ញឈ្មោះអ្វីដែលបានធ្វើរូបវិទ្យា អោយមានលក្ខណៈជាស្រង់ពិតប្រាកដ ?

អ្នកប្រាជ្ញដែលធ្វើ « រូបវិទ្យា » អោយមានលក្ខណៈពិតប្រាកដគឺលោក "កាលីលេ" និងលោក "ញូតុន" ( Galilée et Newton ) ។

108 - តើស្រង់ "គីមី" បានទទួលលក្ខណៈជាស្រង់ពិតប្រាកដនៅសតវត្សទីប៉ុន្មាន ? ដោយអ្នកប្រាជ្ញឈ្មោះអ្វី?

ស្រង់ "គីមី" បានទទួលលក្ខណៈជាស្រង់ពិតប្រាកដនៅសតវត្សទី១៨ដោយអ្នកប្រាជ្ញឈ្មោះ "ឡាវ៉ូស្យេ (Lavoisier)

86- តើវិភាគគំនិតជាវិភាគដូចម្ដេច ?

វិភាគគំនិត គឺ បំបែកគន្លងផ្សេងៗនៃធាតុក្នុងគំនិតដោយប្រើវិធី គំនិត ។

87- តើវិភាគមានគោលបំណងយ៉ាងដូចម្ដេច ?

គោលបំណងនៃវិភាគពិត ឬ វិភាគក្នុងគំនិត គឺ ធ្វើដោយមាន យល់ការណ៍ឲ្យច្បាស់លាស់ ។ វិភាគបំបែកតួគំនិតប្រមូលធាតុ ផ្សេងៗទាំងពួងទាំងរៀបរាយតាមរបៀបយ៉ាងល្អ ។ មិនតែ ប៉ុណ្ណោះ វាក៏ធ្វើឲ្យធាតុទាំងឡាយ ច្បាស់ពីទំនាក់ទំនងគ្នាផង ។

88- អ្វីទៅហៅថាសំយោគ ?

សំយោគជាការប្រមូលផ្ដុំធាតុផ្សេងៗទាំងឡាយ ដោយដាក់ ជាក្រុម ។

89- តើសំយោគមានប៉ុន្មានបែប ? គឺអ្វីខ្លះ ?

សំយោគមានពីរបែបគឺ ៖

១- សំយោគពិត (Synthèse réelle)

២- សំយោគក្នុងគំនិត (Synthese idéale)

90- តើវិភាគនិងសំយោគមានទំនាក់ទំនងនឹងគ្នាឬទេ ?

វិភាគនិងសំយោគជាសកម្មភាពពីររបស់ចិត្ត ដែលត្រូវការគ្នា ទៅវិញទៅមក ។ វិភាគមិនអាចប្រព្រឹត្តទៅដោយគ្មានសំ យោគទេ ហើយសំយោគក៏ដូចគ្នាដែរ ។

91- តើវិភាគនិងសំយោគ មានផលប្រយោជន៍យ៉ាងដូច ម្ដេចខ្លះ ?

# ៦- គណិតវិទ្យា

**112 -** អ្វីទៅដែលហៅថា គណិតវិទ្យា ?

គណិតវិទ្យា គឺជាវិជ្ជាដែលមានចែកចេញជាបីពួកគឺ, គណិតវិទ្យារូបី (mathématique concrète) គណិតវិទ្យាសុទ្ធសាធ (mathématique pure) និងគណិតវិទ្យាស្ដង់លំដាប់ (science de l'ordre) ។

**113-** អ្វីទៅដែលហៅថាគណិតវិទ្យារូបី ?

ដែលហៅថាគណិតវិទ្យារូបី គឺគណិតវិទ្យាដែលសិក្សាពីទំហំទាំងឡាយមានចំណាំឯណាមិនចលាចលទេ ។

**114 -** អ្វីទៅដែលហៅថាគណិតវិទ្យាសុទ្ធសាធ ?

ដែលហៅថាគណិតវិទ្យាសុទ្ធសាធ គឺវិទ្យាដែលរៀនពីបរិមាណនិងអំពីទំហំរូបី (grandeurs concrètes) ។

**115 -** អ្វីទៅដែលហៅថាគណិតវិទ្យាស្ដង់លំដាប់ ?

ដែលហៅថាគណិតវិទ្យាស្ដង់លំដាប់ គឺគណិតវិទ្យាដែលសិក្សាពីលំដាប់ (l'ordre) ។

**116 -** ដូច្នេះដើម្បីអោយងាយយល់ គេអាចសន្និដ្ឋានថា គណិតវិទ្យាជាអ្វី ?

ដើម្បីអោយងាយយល់ គេអាចសន្និដ្ឋានតាមពាក្យថា គណិតវិទ្យាមានគោលគំនិតដំបូង(notions fondamentales) បីយ៉ាងគឺ :

១. ទំហំ (grandeur)

LIBRARY
BUDDHIST INSTITUTE

២- បរិមាណ (quantité)

៣- លំដាប់ (l'ordre)

117 - ដូច្នេះតើវិជ្ជាការនៃសញ្ញាណកើតមកពីអ្វី ?

គេពិចារណាវិជ្ជាការនៃសញ្ញាណកើតមកពីទ្រឹស្ដីពីរគឺ :

១- ទ្រឹស្ដីពិសោធនិយម (thèse empiriste)

២- ទ្រឹស្ដីវិចារណញាណនិយម (thèse rationaliste)

118 - តើនរណាបានបញ្ជាក់ថាគតិវិជ្ជា នៃសញ្ញាណមកពី ទ្រឹស្ដីពិសោធនិយម ?

លោកចាន់ស្ទួតមីល (John - stuart - Mill) បានចែង ថាគតិវិជ្ជាការនៃសញ្ញាណកើតមកពីពិសោធន៍ត្រឹម ។

119 - ដើម្បីការពារទ្រឹស្ដីរបស់ខ្លួន តើលោកចាន់ស្ទួត មីល បានលើកយកអំណះអំណាង (Argument) អ្វីខ្លះមក អធិប្បាយ ?

ដើម្បីការពារទ្រឹស្ដីរបស់ខ្លួន លោកចាន់ស្ទួតមីល បានលើកយកអំណះអំណាងបីមកបញ្ជាក់គឺ :

ទី១ - បញ្ជាក់ពីការសង្កេតទូទៅ ពីសោធពិសេសញ្ញាណកើតវិញ្ញា ។

ទី២ - កើតមកពីសេចក្ដីបញ្ជាក់របស់ពិត ប្រាំរបស់យើងបញ្ជាក់ពីសម្ភារៈរបស់ខ្លួន ។

ទី៣ - ចង្អុលបង្ហាញពីប្រវត្តិគតិវិជ្ជាដែលថាគតិវិជ្ជាប្រែប្រួល តាមការប្រែប្រួលនៃមនុស្ស ។

120 - ចុះចំណែកលោកប្លាតុង (Platon) ដែលជាអ្នកទស្សនវិជ្ជាយ៉ាងធំម្នាក់ដែរ, ហើយដែលធ្លាប់ពិចារណារកហេតុនិងផលលើបញ្ហា ទាំងអស់នៅក្នុងធម្មជាតិ តើលោក បានឲ្យយោបល់យ៉ាងដូចម្តេចដែរទៅលើបញ្ហាសញ្ញាណគណិតវិទ្យា ?

លោកប្លាតុងបានពោលថា «សញ្ញាណគណិតវិទ្យា» បានផ្ដាច់ស្រឡះពី «ពិភពឥន្ទ្រិយ» (monde sensible) ហើយសញ្ញាណនោះឯងបានចាប់កំណើត នៅក្នុងពិភពមួយទៀតឈ្មោះហៅថា «ពិភពបញ្ញា» (monde intelligible) ។

121 - ចុះចំណែកលោកដេកាត (Descartes) វិញ តើយល់យ៉ាងដូចម្តេចដែរចំពោះបញ្ហាសញ្ញាណគណិតវិទ្យា ?

ក្រោយដែលបានពិសោធរកហេតុផលយ៉ាងល្អិតល្អន់ លោកដេកាតឲ្យយោបល់ចំពោះសញ្ញាណគណិតវិទ្យាថា: «ជាគំនិតសុទ្ធដែលមាននៅតាមធម្មជាតិ នៅក្នុងវិញ្ញាណក្ខន្ធ (Âme) ពោលគឺវត្ថុនេះកើតមាននៅក្នុងព្រលឹងមនុស្សតាំងពីកំណើតមក ។

122 - វិធីគណិតវិទ្យាមានគោលការណ៍ (Principes) របស់ខ្លួនប៉ុន្មាន ? គឺអ្វីខ្លះ ?

បើនិយាយតែគោលធំៗ គោលការណ៍គណិតវិទ្យាមានបីយ៉ាងគឺ :

១- អាក់ស្យូម (Axiome)

២- ប៉ូស្ទុយឡា (Postulat)

៣- និយមន័យ (définition)

123- អ្វីទៅហៅថា "អាកស្យូម" ?

អាកស្យូម គឺជាសំណើដែលមានលក្ខណៈច្បាស់លាស់ ដោយខ្លួនឯង ។

124- អ្វីទៅហៅថា "ប៉ូស្ទុយឡា" ?

ប៉ូស្ទុយឡា គឺជា "សំណើបុរេយាន" មានលក្ខណៈ ខុសគ្នាត្រង់ដែលគណិតវិទ្យា ទុកសំរាប់ស្រាយបញ្ជាក់ ។

125- អ្វីទៅហៅថា និយមន័យដែលជាគោលការណ៍នៃគណិតវិទ្យា ?

និយមន័យដែលជាគោលការណ៍គណិតវិទ្យា គឺជាការពិពណ៌នាពីលក្ខណៈ "វត្ថុគណិត" តាមវិធីសាស្ត្រខុសបញ្ញាណ រូបារម្មណ៍ ។

126- អ្វីទៅហៅថាវិចារគណិតវិទ្យា ?

(Qu' est-ce que le raisonnement mathématique?)

ដែលហៅថាវិចារគណិតវិទ្យា គឺ វិចារទាំងឡាយណា ដែលប្រើប្រាស់ចំបងគឺ

១- អនុមានញែកសង់ (D.duction constructive)

២- វិចារតាមកំណើន (Raisonnement par récurrence) ។

127- អ្វីទៅហៅថាវិចារអនុមានញែកសង់ ?

ដែលហៅថាវិចារអនុមានញែកសង់ គឺវិចារដែលពីតាក់តែងប្រព័ន្ធអាកស្យូម ប្រកបដោយលក្ខណៈ សម្មតិក (Hypothétique) ។

128- អ្វីទៅហៅថាវិចារតាមកំណើន ?

វិចារតាមកំណើន គឺជាវិធីរាវរកចម្លើយសំរាប់បញ្ហាពិសេសមួយ ។

129- តើគណិតវិទ្យា និង សាស្ត្រពិសោធន៍មានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេចខ្លះ? ព្រោះអ្វី?

គណិតវិទ្យាមានលក្ខណៈខុសស្រឡះពីសាស្ត្រពិសោធន៍ ត្រង់លក្ខណៈល្អិតល្អន់ពេញលេញ គឺ គណិតវិទ្យាពុំវិនិច្ឆ័យដោយលើការប្រហាក់ប្រហែលឡើយ ។ រីឯសាស្ត្រពិសោធន៍បានលក្ខណៈប្រហាក់ប្រហែលច្រើន ( Caractère approché ) ។

130- អ្វីទៅហៅថា "អាក់ស្យូម" ? ចូរអធិប្បាយបញ្ជាក់ពីមុខងារទាំងឡាយរបស់ "អាក់ស្យូម" នៅក្នុងសំណង់គណិតវិទ្យា ។

(វិញ្ញាសាក្រុងលីល ខែមិថុនា ១៩៥[illegible])

នៅក្នុងគណិតវិទ្យាគេបានអោយនិយមន័យថា "អាក់ស្យូម" គឺជាសំណើដែលមានលក្ខណៈជាក់ច្បាស់ដោយខ្លួនឯង ។

តើពុំត្រូវការសំរាយបញ្ជាក់អ្វីទៀតទេ គឺជាពាក្យរបស់គណិតវិទ្យានេះ ដែលគេបានប្រើជាមូលដ្ឋានក្នុងគណិតវិទ្យាបុរាណ ។

" អាក់ស្យូម " ជាពាក្យមកពីភាសាក្រិក ដែលអ្នកគណិតវិទ្យាបានយកមកប្រើ ។ អ្នកប្រាជ្ញគណិតវិទ្យាមុនគេគឺអឺគ្លីត ( Euclide ) ។ ...

ក្នុងការស្រាវជ្រាវស្ទង់គណិតវិទ្យា ការងារគឺត្រូវតែបានរក
ឃើញចំណេះខាងតរណីកាប្រមេះ ។ គេបានរកឃើញបាញ
គណិតវិទ្យាសារស្រឹង ដែលត្រូវនឹងត្រង់ខាងបុរេវិទ្យានេះបាន
យកធ្វើជាឧបករណ៍ សម្រាប់ធ្វើដំណោះស្រាយគណិតវិទ្យា
ដូចជានិយមន័យទាំងឡាយ ,,ប៉ូស្តុយឡា ,,អាក់ស្យូម និង
ទ្រឹស្តីបទជាដើម ។

យើងឃើញថា"និយមន័យ" ទាំងឡាយ សុទ្ធតែជាសំដៅ
បង្ហាញនូវលក្ខណៈសំខាន់ៗរបស់វត្ថុនានាដូចជា: ចំនុច ,
រេខា , ចំណុច , បន្ទាត់ , តិចតួ.. ។ ដូច្នេះឃើញថា
"និយមន័យ" ជាការចង្អុលនូវចំណុចគណិតវិទ្យារបស់ជា
រូបធាតុ (Matières) ទាំងឡាយរបស់ការស្រាវជ្រាវ
រកដំណោះស្រាយ ។ ចំណែក "អាក់ស្យូម" និង "ប៉ូស្តុយ
ឡា" វិញគឺជារូបការដែលសំរាយបញ្ជាក់ពុំបាន (Démon
stration) ។

យើងឃើញទៀតថា ប៉ូស្តុយឡា គឺជាសំណើដែលជាក់
លាក់ឥតគិតពុំអាចធ្វើសំរាយបញ្ជាក់បានឡើយ ។ ឧទាហរណ៍
ចំណុច (A) មួយនៅក្រៅបន្ទាត់ (D) គេអាចគូសបានបន្ទាត់
តែមួយស្របនឹង (D) ។

ចំណែក "អាក់ស្យូម" វិញអាចទាញនិយមន័យថា "ជា
សំណើប្រកបដោយការជាក់លាក់ផង និងពុំចាំបាច់ធ្វើសំរាយ
បញ្ជាក់ឡើយ" ដូចជាថា ÷ បរិមាណពីរដែលស្មើ
ដែលស្មើនឹងបរិមាណ ទី៣ ត្រូវបានដែលស្មើគ្នា ។ ឬគឺថា
ទាំងមូលធំជាងចំណែកមួយៗ ។ល។

ទោះបីយ៉ាងណាក៏ដោយ ក៏ «អាកស្យូម» ជាគន្លង ប្រទះនឹងការគិតគូរបស់ខ្លួនហ្មត់ ។ អ្នកគណិតវិទ្យាបានប្រើ «សំណើ» ថ្មីមួយថា «អាកស្យូម-ប៉ុស្ទុយឡា» គឺគេបានយក អាកស្យូមនិងប៉ុស្ទុយឡាមកប្រើជាមួយគ្នាតែម្តង ។ មូលហេតុ ដែលបណ្តាលអោយអ្នកប្រាជ្ញធរណីមាត្រ ប្រើសំណើថ្មីនេះ គឺគេចង់បង្កើតសំណោះស្រាយអោយប្រកបដោយ «ការជាក់-ណាក់ត្រឹមត្រូវ» តែទោះជាយ៉ាងណាក៏ដោយ ក៏គេឃើញថា សំរាយបញ្ជាក់របស់គេត្រូវពឹងផ្អែកទាំងស្រុងទៅលើរូបភាព ធរណីមាត្រ ។ ដូច្នេះគេត្រូវនិយាយតាមលោកដេកាត (Descart) ដើម្បីថាធរណីមាត្រគឺជាចិន្តាគតិ (Imagination) ។ ធរណីមាត្រដែលពុំប្រើទ្រឹស្តីលោកអឺគ្លីតបានបើកទំព័រយ៉ាងធំ បង្ហាញវិវត្តន៍នៃគណិតវិទ្យា ។

ឧទាហរណ៍ ៖ ដូចជាទ្រឹស្តីរបស់លោក ឡូបាតេវស្គី (LOBATSCHEWSKY) ដែលបង្ហាញថា ៖ ចំណុចក្រៅបន្ទាត់មួយ, គេអាចគូសបន្ទាត់ពីរស្របទៅនឹងបន្ទាត់នោះ ។ គេបានបង្ហាញនូវភាពពិតដោយផ្ទុយពីទ្រឹស្តីលោក «អឺគ្លីត» ។ នៅក្នុងឆ្នាំ ១៨៥១ លោករីម៉ាន់ (RIEMAN) បានបង្ហាញនូវទ្រឹស្តីខាងក្រោយនេះដែរ ។ លុះមកសម័យក្រោយមកទៀត អ្នកគណិតវិទ្យាទាំងអស់តែងសរសើរតាមគំនូសនៃលោកទាំងពីរនេះគ្រប់គ្នា ។

ចាំងពីពេលនោះមក ធរណីមាត្ររបស់លោកអឺគ្លីត ក៏ស្ថិតនៅលើតែកិច្ចការនៃការសិក្សាបឋម គឺថ្នាក់ទាបនៃការសិក្សាធរណីមាត្រប៉ុណ្ណោះ ។ ហើយអាកស្យូមក៏បានបាត់បង់

គុណលក្ខណៈសំខាន់របស់ខ្លួនដែរ  គឺអាក់ស្យូមបានរក្សានៅត្រឹមតែ "សំណើដើម" (proposition première) យើងឃើញថាអាក់ស្យូម  បានផ្លាស់ប្ដូរលក្ខណៈរបស់ខ្លួនទៅតាមកាលវេលានិងចំរើនរបស់អ្នកប្រាជ្ញ ។

តែអាក់ស្យូមមាននាទីរបស់ខ្លួនដដែលពោលគឺគេផ្លាស់ប្ដូរឡើយ ។ អាក់ស្យូមនៅតែជាគ្រឹះសំខាន់របស់គណិតវិទ្យារាប់ឲ្យកើតនិងលោកវេសភាគ :  ហើយកើតមានសញ្ញាណពិសោធមួយដែលយ៉ាងទ្រឹស្ដី របស់ពួកគេទាំងនោះគឺ : លក្ខណៈដាច់ណាត់ស្មើគ្នា ។ ឧទាហរណ៍ លោក ហ៊ីលប៊ែរ (Hilbert) បានប្រមូលអាក់ស្យូមទាំងអស់ ណាដែលសំខាន់ៗ បង្កបង្កើតគណិតវិទ្យាមួយ ។ អាក់ស្យូមទាំងនោះត្រូវបែកចែកជាប្រាំផ្នែក ហើយផ្នែកនីមួយៗសុទ្ធតែអាចជ្រើសរើសអាក់ស្យូមដើម្បីបង្កើតជាប្រព័ន្ធបាន ។

គេសម័យបច្ចុប្បន្ន ដែលគណិតវិទ្យាវិវត្តទៅមុខសាស់សាប់ គេឃើញអាក់ស្យូមបង្កើតជាប្រព័ន្ធ«អាក់ស្យូមប៉ាទិច(AXIOMATIQUE) ។ ហេតុដូច្នេះហើយបានជាគណិតវិទ្យាត្រូវប្រកបដោយសច្ចៈមិនផ្លាស់របស់ខ្លួន បានត្រូវគេហៅថា "សច្ចៈសំណុំ» (Vérités des ensembles) ។ ហើយសច្ចៈសំណុំនេះក៏ប្រកបដោយលោកិកណ៍យ៉ាងប្រសើរ ក្នុងការប្រើប្រាស់បន្ទាត់និងរង្វិលផ្ចិតដោយនៅជារូបភាពរបស់ខ្លួន ។ យើងបានសង្កេតឃើញថាប្រវត្តិអាក់ស្យូមនៅក្នុងគណិតវិទ្យាគឺមុខងាររបស់វា  មានសារៈសំខាន់ណាស់ចំពោះគណិតវិទ្យាទៅ ។ អាក់ស្យូមគឺជាសញ្ញាណដាច់ណាត់ដែលបាន

កំរិតការពិចារណាត្រូវលោកដេកាត ព្រមទាំងផ្តាច់អោយគេរោយ
ក្បួនគតិនៃការពិចារណាត្រូវទាំងអស់ ។
គួរលើកពិនិត្យ ទ្រឹស្តីរបស់អ្នកប្រាជ្ញសិក្សាពីអង់គ្លេសម្នាក់
ឈ្មោះរូសែល ( Russell ) ដែលពោលថា : «គណិតវិទ្យាគឺ
ជាសាស្ត្រដែលគេពុំដឹងថាគេនិយាយពីអ្វី , និងជាសាស្ត្រដែលគេពុំ
ដឹងថាតើគេនិយាយនោះត្រូវឬខុសផង » ។ ការចំរើនថ្មីនៃរូប
វិទ្យាចំពោះការស្រាយគណិតវិទ្យាត្រង់ទ្រឹស្តី លោកអ៉ីនស្តែន
ដែលបានពិពណ៌នាយ៉ាងច្បាស់ពីអាកាសមួយ បានសំរេចនូវ
គោលដៅប្រព័ន្ធយ៉ាងពេញចិត្តក្នុងការសិក្សាបញ្ជាក់ពីទ្រឹស្តី
គណិតវិទ្យា ។

* * *

# ៧- ស្ទង់រូបធាតុនិងវិធីពិសោធន៍

**131 - អ្វីទៅហៅថាស្ទង់រូបធាតុ ?**

ដែលហៅថាស្ទង់រូបធាតុ គឺស្ទង់ដែលសិក្សាពីរូបធាតុទាំងអស់ដោយពឹងផ្អែកទាំងស្រុងទៅលើពិសោធន៍ ។

**132 - តើគេត្រូវពិសោធស្ទង់រូបធាតុ ដោយប្រើវិធីយ៉ាងដូចម្តេចខ្លះ ?**

គេត្រូវពិសោធស្ទង់រូបធាតុ ដោយរៀបរៀងតាមបីយ៉ាង គឺ :

១- ធ្វើការសង្កេតពិនិត្យ (OBSERVATION)

២- ធ្វើសម្មតិកម្ម (HYPOTHESE)

៣- ធ្វើពិសោធន៍ (EXPERIMENTATION)

**133 - តើការសង្កេតពិនិត្យមានប៉ុន្មានបែប ?**

អ្នកស្ទង់និយម ឬអ្នកប្រាជ្ញខាង សំគាល់ឃើញថាការសង្កេតពិនិត្យមានពីរបែបគឺ :

១- ការសង្កេតពិនិត្យអកម្ម (observation passive)

២- ការសង្កេតពិនិត្យសកម្ម (observation active)

**134 - យ៉ាងដូចម្តេចទៅហៅថាការសង្កេតអកម្ម ?**

ការសង្កេតអកម្ម គឺការសង្កេតពិនិត្យ កត់ត្រាទុកភ្លាមៗនូវការទាំងឡាយដែលប៉ះពាល់ចំពោះត្រចៀកគ្មានការចំរើន ។

135- តើការសង្កេតពិនិត្យដោយ ឥន្ទ្រិយផ្ទាល់អាចផ្តល់នូវផលគាប់ប្រសើរសំរាប់ធ្វើសន្និដ្ឋាន ទៅលើស្យង់ពិសោធឬទេ ?

ឥន្ទ្រិយរបស់យើងពុំផ្តល់លទ្ធផលគាប់ប្រសើរសំរាប់ពិសោធស្យង់រូបធាតុអោយបានជាក់លាក់ឡើយ ។ ព្រោះថាឥន្ទ្រិយយើងមានសភាពពុំច្បាស់លាស់ ព្រមទាំងជាគ្រឿងបំភ័ន្តការពិតច្រើនណាស់ ។ ឧទាហរណ៍ៈ ចក្ខុយើងបានត្រូវខុសលក្ខណៈភ័ន្ត កាលណាយើងសង្កេតពិនិត្យវត្ថុទាំងឡាយ (Erreur de vision) ដែលមានភាពរហ័សរហួន ។

136- យ៉ាងដូចម្តេចទៅហៅថាការសង្កេតសកម្ម ?

ការសង្កេតពិនិត្យសកម្ម គឺការសង្កេតពិនិត្យទាំងឡាយណាដែលយកវិធីស្យង់មកប្រើ ។ ជាការសង្កេតពិនិត្យទៅលើការណ៍ផ្សេងៗដែលស្យង់តំរូវអោយធ្វើ ។

137- ដើម្បីសង្កេតពិនិត្យរូបធាតុទាំងឡាយតាមរបៀបសកម្ម តើស្យង់អោយសំគាល់ការណ៍ (faits) ប៉ុន្មានយ៉ាង ?

តាមរបៀបសកម្មស្យង់បានញ៉ាំងអោយប្រើការសំគាល់ទៅលើការណ៍ស្យង់ (faits scientifiques) ទាំងឡាយដូចតទៅៈ

១- ការណ៍ ជ្រើសរើស (fait choisi)

២- ការណ៍ សំគាល់ (fait remarqué)

៤- ការណ៍បកស្រាយ (fait interprèté)

៥- ការណ៍កែតំរូវ (fait r ct fié)

138- អ្វីទៅហៅថាការណ៍ជ្រើសរើស ?

ការណ៍ជ្រើសរើស គឺការណ៍សំខាន់ៗក្នុងរូបធាតុដែលបានគេរើសក្នុងកម្មវត្ថុនៃការសង្កេតរបស់ស្យង់ ។

139- យ៉ាងដូចម្ដេចទៅហៅថាការណ៍សំគាល់ ?

ការណ៍សំគាល់ គឺការណ៍ទាំងឡាយដែលបានប្រយោជន៍ដល់ការសង្កេតផ្ទាល់របស់អ្នកប្រាជ្ញ ។

140- អ្វីទៅហៅថាការណ៍វាស់ ?

ដែលហៅថា ការណ៍វាស់ គឺការណ៍របស់ស្យង់ដែលនិយាយពីបរិមាណយ៉ាងជាក់ច្បាស់បំផុត ។

141 អ្វីទៅហៅថាការណ៍បកស្រាយ ។

ការណ៍បកស្រាយ គឺ ការណ៍របស់ស្យង់ទាំងឡាយដែលពន្យល់ប្រាប់ហេតុពិតប្រាកដរបស់ពិសោធន៍ ។

142- ចុះចំណែកការណ៍កែតំរូវ , ជាការណ៍យ៉ាងដូចម្ដេចដែរ?

ការណ៍កែតំរូវ គឺការណ៍របស់ស្យង់ដែលបានសង្កេតពិនិត្យជាថ្មីបំផុតនូវលក្ខណៈទាំងឡាយ ហើយបានសន្និដ្ឋានជំរុះចោលសំណល់ដែលបណ្ដាលពីអត់ប្រយ័ត្ន ។

143- អ្វីទៅហៅថាសម្មតិកម្ម?

សម្មតិកម្ម គឺគំនិតដើមច្បាប់ដែលបំរុងបង្កើត, គឺជាការល្បងដោយគិតទៅលើការសង្កេតពិនិត្យដំបូង ។

144- តើគេអាចពោលថា សម្មតិកម្មខុសបានឬទេ ?

គេអាចពោលថាសម្មតិកម្មខុសបាន បើសិនជាសម្មតិកម្មនោះស្ថិតនៅជាគំនិតរកឃើញមុនពិសោធ (A priori) ។

145- ដូច្នេះតើសម្មតិកម្មមានប្រយោជន៍សំរាប់ស្ទង់ឬទេ ?

សម្មតិកម្មមានប្រយោជន៍សំរាប់ស្ទង់ណាស់ ព្រោះថាសម្មតិកម្មជាចំណុចតំបូងរបស់វិធានស្ទង់ពិតប្រាកដ បើសិនជាគ្មានសម្មតិកម្មទេ យកគំហើញច្បាស់ជាពុំអាចកើតបានឡើយ ។

146- អ្វីទៅហៅថាពិសោធន៍ ?

ពិសោធន៍គឺការយកសម្មតិកម្មទៅល្បងមើល,តើខុសឬត្រូវ ។

147- តើបាតុភូតណាខ្លះដែលអ្នកស្ទង់និយាយថាជាបានការ?

បាតុភូតដែលអ្នកស្ទង់និយាយថាជាបានការនោះក្រោយពិសោធន៍ គឺបាតុភូតដែលត្រូវទៅតាមធម្មជាតិ ។

148- គេបានពោលថាស្ទង់ មានច្បាប់របស់ខ្លួនត្រឹមត្រូវសំរាប់អនុវត្ត ។ តើស្ទង់នោះជាអ្វី ?

ច្បាប់ស្ទង់ គឺជាតំហើញជាក់លាក់របស់ស្ទង់ដែលបញ្ជាក់ពីទំនាក់ទំនងថេរគ្នារវាងបាតុភូតទាំងឡាយរបស់ធម្មជាតិ ។

49- តើច្បាប់ស្ទង់មានគុណសម្បត្តិយ៉ាងដូចម្តេចខ្លះ ?

ច្បាប់ស្ទង់ មានបំណងនឹងស្វែងរករបៀបខាងក្នុង នៅក្រោយការប្រែប្រួលទាំងប៉ុន្មាននៃការណ៍ ។ ច្បាប់នេះអាចបំណងនឹងពេញអ្វីដែលជាខ្លឹម (essence) ពេញពីអ្វីដែលគ្មាន គឺអ្វីដែលមិនទៅពីអ្វីដែលជាសំបូរ ។ ច្បាប់ស្ទង់មានបុនការត្រឹមតែការប្រកាសនូវតំណាក់និយម (déterminisme) ។

ច្បាប់ស្បត់មានប្រយោជន៍ជាចាំបាច់ណាស់សំរាប់គំនិត និង ជីវិតរាល់ថ្ងៃ ព្រោះច្បាប់នេះ អាចអោយយើងទាយទុកមុន បាននូវការណ៍ផ្សេងៗ។ តែទោះជាយ៉ាងណាក៏ដោយក៏យើង សង្កេតឃើញថា, ច្បាប់ស្បត់គ្មានសមត្ថភាពនឹងពន្យល់អ្វីៗ ទាំងអស់បានទេ ដោយហេតុថាច្បាប់នេះគ្រាន់តែបង្ហាញនូវ បំណង ដែលចងបាតុភូតទាំងឡាយ តែមិនអាចប្រាប់យើង អោយស្គាល់នូវអាថ៌កំបាំងនៃចំណងនេះបានទេ ។

**150- ដោយសារការជាក់លាក់របស់ស្បត់ តើអ្នកប្រាជ្ញបាន រកឃើញទ្រឹស្តីឈ្មោះអ្វី ?**

ដោយសារការជាក់លាក់របស់ស្បត់, អ្នកប្រាជ្ញបានរក ឃើញទ្រឹស្តីមួយថ្មីទៀតហៅថាទ្រឹស្តីកំណត់និយម (déterminisme) ។

**151 - តើទ្រឹស្តីកំណត់និយមសិក្សាពីអ្វី ?**

ទ្រឹស្តីកំណត់និយម សិក្សាពីការកំណត់យ៉ាងជាក់លាក់ ដែលមាននៅក្នុងការរស់និងក្នុងអត្ថធាតុទាំងឡាយ ដែល គ្មានឥន្ទ្រិយ ។

**152- តើបាតុភូតទាំងអស់នៅក្នុងធម្មជាតិ គេអាចសំគាល់ បានដោយសារអ្វី ?**

បាតុភូតទាំងអស់នៅក្នុងធម្មជាតិ, គេអាចសំគាល់បាន ដោយសារ ឥន្ទ្រិយរបស់យើងផ្ទាល់ខ្លួនផង ឬដោយសារ ឧបករណ៍ទាំងឡាយរបស់ស្បត់ផង ។

153- វិវត្តន៍របស់សម័យសព្វថ្ងៃ អាចអោយអ្នកប្រាជ្ញទាំងអស់ អស់ពីរឿងជឿលើវាសនាឬទេ ? ព្រោះអ្វី ?

វិវត្តន៍របស់សម័យបានធ្វើអោយពិភពលោកសម័យថ្មីរីកចំរើនគ្រប់វិស័យ, គឺសង្គមកិច្ច, សេដ្ឋកិច្ច និងវិទ្យាសាស្ត្រ ។ គេឃើញមនុស្សហោះហើរដូចបក្សី ដោយគ្រឿងដំណើរ បានទាន់ចិត្តតាមយន្តហោះប្រតិកម្មយ៉ាងចំលែកបំផុត ។ មនុស្សឈប់ប្រើខួរក្បាលដើម្បីគិតលេខដែលមានចំនួនច្រើនឥតគណនា ដោយប្រើម៉ាស៊ីនអេឡិចត្រូនិច ។ គេឃើញម៉ាស៊ីន អ័រឌីណាទ័រ (Ordinateur) បំរើមនុស្សបានយ៉ាងទាន់ចិត្ត ហើយមនុស្សបានទាញយកធម្មជាតិមកប្រើប្រាស់ បានស្ទើរតែគ្រប់វិស័យ ។ តែទោះជាយ៉ាងនេះក្តីក៏គេឃើញថា មានអ្នកប្រាជ្ញវិទ្យាសាស្ត្រភាគច្រើន, ក្រោយដែលខ្លួនអស់សមត្ថភាពក្នុងការគ្រប់គ្រងជីវិតមនុស្សអោយប្រសើរដោយអមតភាពបានក៏ . សម្រេចចិត្តតាមបានតែកាតព្វកិច្ចដែលមាននៅក្នុងធម្មជាតិ ហើយដែលគេសន្និដ្ឋានថាកំណត់និយម ។ ក្រោយមកពួកអ្នកប្រាជ្ញទាំងនោះវិលត្រឡប់មកជឿតាមព្រះសាសនា ដែលបាននិយាយពីការព្រាងប្រឌិតនៃជីវិតសត្វលោក ។ ហើយគេក៏បានហៅទ្រឹស្តីនេះថាជាទ្រឹស្តីវាសនានិយម (Fatalisme) ។

154- ហេតុអ្វី បានជាអ្នកប្រាជ្ញនៅតែជឿលើវាសនារបស់មនុស្ស ?

អ្នកប្រាជ្ញនៅតែជឿលើវាសនារបស់មនុស្សព្រោះអ្នកប្រាជ្ញ

ពុំទាន់កោយឃើញនូវហេតុនិងផល ដែលធ្លាក់ទៅលើមនុស្ស ម្នាក់ៗដោយវិធីសាស្ត្រស្មុស្បង់ ។ មានសភាពអាថ៌កំបាំងដែល ហួសវិស័យនិងពិចារណាបាន ទើបពួកអ្នកប្រាជ្ញខាងនោះវិល ត្រឡប់ទៅជឿតំនិតសាសនា ដែលបានកើតមានមកជាច្រើន សតវត្សមុនកំណើតរបស់ស្បង់ ។

155- អ្វីទៅហៅថាចៃដន្យ (Le hasard.)?

ចៃដន្យ គឺ អ្វីដែលគ្មានទិសៅ, គ្មានដើមហេតុ ។

អ្នកប្រាជ្ញឈ្មោះកួរណូ (Cournot) ពោលថា :-

« ចៃដន្យ គឺ ការជួបគ្នានៃបាតុភូតទាំងឡាយដែលបិតនៅក្នុង ពំពួកពីរខុសដាច់ឡែកពីគ្នា ក្នុងដំណើរហេតុផល »

156- ចូរអធិប្បាយវែកញែក តាមបែបទស្សនវិជ្ជានូវសំដី របស់អ្នកប្រាជ្ញឈ្មោះស្ពីណូសា (Spinoza) ដែល បានពោលថា : "ការអោយឈ្មោះហេតុមួយថាជាចៃដន្យ, គឺជាការទទួលស្គាល់នូវកង្វះនៃពុទ្ធិមនុស្ស"?

ដើម្បីវែកញែកទ្រឹស្តីរបស់លោក ស្ពីណូសា, គប្បីពោល បង្ហាញនូវនិយមន័យរបស់ពាក្យថា « ចៃដន្យ » ជាមុនសិន ។ ពាក្យចៃដន្យ, បើតាមនិយមន័យនូវខាងពោលថា :- « អ្វី ដែលគ្មានទិសៅ » ឬ អ្វីដែលគ្មានដើមហេតុ ។ ដូច្នេះចៃដន្យ គ្មានវត្តមានត្រឹមត្រូវឡើយ ។ ហេតុការណ៍ទាំងឡាយ ដែលកើតឡើងដោយចៃដន្យ គឺជាហេតុការណ៍ដែលពុំ អាចស្មានត្រូវ ។ ប្រភពនៃហេតុការណ៍កើតពីចៃដន្យគ្មាន

អ្នកប្រាជ្ញណាម្នាក់អាចលើកយកអតិប្បាយ ឬ ភស្តុតាង បែបរូបីក្នុងសង្គមជាតិឡើយ ។ រីឯអ្នកទស្សនវិជ្ជាសាតទៀត ក៏គ្មានសមត្ថភាពនឹងប្រើនូវសញ្ចេតនារបស់ខ្លួន ឬ ក៏ប្រើវិចារណញ្ញាណរបស់ខ្លួន ដើម្បីតាមដានរកមើលកំណើតនៃចៃដន្យ ដោយឃើញហេតុផលជាក់លាក់ដែរ ។ ពួកគេទាំងឡាយដែលសុទ្ធសឹងតែជាអ្នកប្រាជ្ញសង្គម ឬ ខាងមនោគតិនិយមជាន ចុះចាញ់បញ្ហានៃចៃដន្យគ្រប់គ្នា ។ ទោះយ៉ាងនេះក្តីឃើញនៅ ឃើញអ្នកប្រាជ្ញខ្លះ ទំបញ្ចេញគំនិតរបស់ខ្លួនដើម្បីល្បងលាង ការពិលប្រែក ។ ឧទាហរណ៍អ្នកប្រាជ្ញឈ្មោះកួណូ (Cournot) ដែលហ៊ានអោយនិយមន័យពីចៃដន្យថា:– ចៃដន្យ គឺជា « ការជួបគ្នានៃហេតុភូតទាំងឡាយដែលមិន នៅក្នុងជំពូកពីរខុស ដាច់ឡែកពីគ្នាក្នុងដំណើរហេតុផល (Causalité) ។ លោកកួណូបានបញ្ជាក់ថែមទៀតថា ចៃដន្យ « គឺអ្វីដែលគេមិនអាចកំណត់បាន , គឺការជួបគ្នារវាងសេរីលក្ខណ៍ទីមួយ ទៅប៉ះទង្គិចជាមួយនឹងសេរី (Série) លក្ខណ៍ទីពីរ, ហើយសេរីលក្ខណ៍ទីមួយនោះគោរពទៅតាមច្បាប់កំណត់និយមធាតុអាកាស ។ ចំណែកឯសេរីលក្ខណ៍ទីពីរគោរពទៅតាមច្បាប់កំណត់និយមចិត្តវិទ្យា ។

យើងយល់ឃើញថានិយមន័យ នឹងការវែកញែកដែលលោកកួណូបញ្ចេញឲ្យយល់មកនេះ គ្រាន់តែជាការយកអរូបីទៅដោះស្រាយអរូបីប៉ុណ្ណោះ ។ ឯចំណែកការពិតប្រាកដរបស់វត្ថុដែលយើងហៅថា ចៃដន្យនោះ ស្ថិតនៅក្នុងអាថ៌កំបាំង

ឥវ៉ែត ។ យើងធ្លាប់ឃើញអ្នកប្រាជ្ញពាក្យបរិយាយប្រកាន់យក គំនិតស្មុំទាំងអស់, ហើយគាត់ត្រូវទៅលើត្រីស្ដីនិងក្បួន ធ្វាតរបស់ «មហាភារត» ខ្លះនោះ ការដោះស្រាយ បញ្ហាផ្សេង ប្រហែលជាអាចពុំចាប់ខ្លួនក្នុងការស្រាវ ស្រាវតាមប្រសើរសមគួរបំណងរបស់ខ្លួនបាន ។ ព្រោះថា ឧទាហរណ៍ : គម្ពីរស្រុកចិនមួយសរសេរថា : កាលណោះ ស្ដេចគួសក្ដិគាត នាស្រុកនឹងបានរាបស់ខ្លួន, ក៏គាំណាងកាយុថា មានពាក្យមួយទៀតពាក់ពោលបោកមនុស្សលោក ។ មកដល់យាត់ សមុទ្រពីរួបនឹងអ្នកនេសាទកំពិលម្នាក់កំពុង នេកលើជុំចម្ងាយ រង់ចាំស្ទូចត្រីរង់ចាំស្ទូចទៅសមុទ្រ ។ ពេលនោះ ស្ដេច គួសក្ដិគាតបានសួរចាត់មនុស្សម្នាក់ពោលទៅកាន់អ្នកនេសាទ កំពិលនោះថា :

- «អូ ផលកំពិល បើកងតិត់តែពីរផក, តើស្ទូចកំណាត់ត្រី ទៅស្ទូរស៊ី?»

- ស្ដេចគួសក្ដិគាតបានអ្នកនេសាទចូលនោះឆ្លើយទៅវិញថា :

- «អញចាំទៅអនេះអោយមាត់ឥតប្រយោជន៍ធ្វើអ្វី? បើហោរា ទាយអោយអញរួចហើយ , ថា : ថ្ងៃត្រង់ទើបអញនឹងត្រី បាន រង់ចាំបើលចុះរឿងនេះពិតឬពុំពិត? » ។

កាលណោះស្ដេចគួសក្ដិគាត លបចាំមើលរហូតដល់ថ្ងៃត្រង់ តើអ្នកនេសាទត្រីបានតាមហោរាទាយឬទេ ?

លុះដល់ថ្ងៃត្រង់មែន , ការនេសាទក៏ញញួរញ័រស្ទូចទៅសម្ត្រី មែនៗ តាំងពីសងកែមួយពើកស្នាប់តែការត្រីពេញធ្នក ។ ស្ដេច ធ្វើសក្ដិគាតគួរលំនឹងហោរាទាយអស្ចារ្យ គោរពគាត់ពេក ។ ...

និងចំណាប់នេះ ស្តេចគាត់ក៏ខឹងនឹងអ្នកនេសាទដែលបាន ចាប់កូន
ចៅរបស់ខ្លួន, ក៏បញ្ជាឲ្យហ៊ុំព័ទ្ធចាប់ចាក់ផ្លុង អ្នកនេសាទនោះ
ចំណាក់ទៅក្នុងទឹកអស់វិញ ។ ពេលនោះ អ្នកនេសាទស្រាប់
តែផ្ទុះសំណើចលាន់រំពងហើយនិយាយថា :
ឱ ស្តេចពាក្យរបស់លោកនៅឆ្ងាយម្ល៉េះ! ថា ៗ នៅពេល
ដែលត្រង់អញត្រូវតែត្រីបានមួយផ្លុង, ក៏មិនដែលនៅពេលអញចាក់ក្នុង
លើត្រីនោះ, ផ្លុងអញត្រូវបាក់ ហើយខ្លួនត្រីទៅក្នុងទឹកវិញ
អស់, មូលហេតុនេះ យាតបុរសម្នាក់ចេញឲ្យមុខរបស់វា
ខ ហេតុការណ៍នេះមានឡើងឃើញប្រកពកំណើតថែមទៀតទេ
ទេ! ២ ។

រឿងក្នុងគម្ពីរចិនបានបំផុសគំនិតឡើងមួយ ដែលធ្វើឲ្យគំនិតទៅ
លើការទស្សន៍ទាយថ្នាំនៅប្រាសាទ ។ បើតាមទស្សនៈ
វិជ្ជា រឿងទាំងនេះជាថែមទៀតប៉ុណ្ណោះ ; គឺថាថែមទៀតបាន
បណ្តាលឲ្យបានអ្នកនេសាទគំនិត ជ្រើសរើសពេលដែល
ត្រង់ដែលហ្វូងត្រីសម្រេចមួយហ្វូង បាននាំគ្នាមកហែលលើផ្ទៃ
ទឹកក្បែរចាត់ប្រទេសហើយស្តេចកុជក្កនាគ , មិនដឹងមកពីរឿងអ្វី
ក៏ស្រាប់តែថែមទៀត បណ្តាលឲ្យកើតការអស្ចារ្យ ចង់មកលើ
ក៏សាគ្គះនាថានបគុស្សលោក ។ ទីបំផុតថែមទៀតនេះនាំស្តេច
កុជក្កនាគឲ្យផ្តួលនឹងការនេសាទគំនិតនោះ ហេតុនេះតែ
បំផ្លាញផ្លូវរបស់គាត់ បណ្តាលឲ្យត្រីដែលផងបាននៅឆ្ងាយ
ថែមទៀតទៅវិញដោយថែមទៀតអសគ្នានសំណុំ ។
ហេតុអ្វីក៏យើងហៅនរពាលថារឿងនេះជារឿងថែមទៀត ? ។
យើងហៅនពេលនេះ ព្រោះយើងឃើញថាស្តេចកុជក្កនាគ

កើតមនុស្សដោយចៃដន្យ ។ បន្ទាប់មកស្ដេចនាគក៏បានជួប និងអ្នកនេសាទដោយចៃដន្យ ហេតុទាល់តែចំណាញថ្នងរបស់ គាត់ចោលថែមទៀតផង ។ យើងឃើញថារឿងនេះកើតឡើង ដោយចៃដន្យទាំងអស់ , ព្រោះថារឿងដែលកើតឡើងដោយ គ្មានទីដៅនិងគ្មានដើមហេតុ ហៅតែជារឿងដែលគេ ស្មានមិនត្រូវផង ។ ឧទាហរណ៍នៃគម្ពីរមិននិយាយពីហោរា ចរិយ្ហុតនេះ , បានបង្ហាញអោយយើងឃើញក្បួនទាយដែលអាច ទីងពីដើមកំណើតនៃព្រឹត្តការណ៍ ដែលគេទាត់ថាចៃដន្យនោះ រហូតដល់ចំបញ្ចប់ឥតសល់ចន្លោះបន្តិចឡើយ ។ ដូច្នេះចៃដន្យ ពុំមែនជារឿងចម្លែកឡើយ ។ តែវាជារឿងទាំងឡាយដែល កើតចំពោះឡើងនូវព្រឹត្តការណ៍ផ្សេងទៀតផង , តែមនុស្សគ្រាន់ ថាព្រឹត្តការណ៍នេះទៀតកើតឡើងដោយចៃដន្យ ដូចតែតចៃ ដន្យជារឿងដែលកើតឡើងដោយអចេតនា , ព្រោះអ្នកប្រព្រឹត្ត ធ្វើពុំបានគិតទុកជាមុននោះ ។ តែរឿងរបស់ចៃដន្យខាងក ណើតជាក់លាក់ ដែលវិចារណញ្ញាណរបស់មនុស្សពុំអាចរ ចេញ « ពុទ្ធិសង្ខ » នេះបានឡើយ ។ មានតែព្រះពុទ្ធតែ មួយគត់ ដែលអាចមើលឃើញចន្លោះដែលពួកអ្នកជាប់ហើយ អន្ធពាលតាមប្រាណរបស់អ្នកដែលប្រព្រឹត្តធ្វើ ៖

ដោយមនុស្សពុំមែនមាន « ពុទ្ធិ » ប្រកបដោយការត្រាស់ ដឹងគតសល់ធូររៀបរាប់ទាំងឡាយក្នុងលោកនិង ព្រោះលោក ដូចព្រះពុទ្ធ , បានជាលោកសម្ដែងសារពាលថា ៖

« ការអោយឈ្មោះហេតុមួយថាចៃដន្យ , គឺការបន្ទូល ស្ដាប់ធ្ងន់ធ្ងរនៃពុទ្ធិមនុស្ស ។



*

* *

# ៨-ជីវវិទ្យា

**157 -** អ្វីទៅហៅថាជីវវិទ្យា ?

ជីវវិទ្យាជាវិជ្ជាដែលសិក្សាពីជីវិតនៃមនុស្សសត្វតិរច្ឆាន -រុក្ខ ជាតិទាំងអស់នៅក្នុងលោក ។

**158-** ដូច្នេះគេអាចសន្និដ្ឋានថា ជីវវិទ្យាជាវិជ្ជាសម្រាប់តែការ ដែលសិក្សាពី « ជីវិត » បានឬទេ ? ហេតុអ្វី ?

គេអាចសន្និដ្ឋានថា ជីវវិទ្យាជាវិជ្ជាសម្រាប់ខាងការ សិក្សាពីជីវិតបាន ព្រោះថាក្រៅពីការសិក្សាលើរូបធាតុទាំង ឡាយដែលប្រកបដោយសរីរាង្គគិត ដែលជាទីតាំងនៃជីវិត នោះ ជីវវិទ្យាបាននាំអោយសិក្សា លើវត្ថុធាតុទាំងឡាយក្នុង ធម្មជាតិ ដែលប្រកបដោយសរីរាង្គតែពុំមានវិញ្ញាណ ឬជីវិត ថែមទៀតផង ។

**159-** តើគេអាចសំគាល់លើភាវៈរស់( être vivant ) ដោយលក្ខណៈណាខ្លះ ? អ្វីហៅថាភាវៈរស់ ?

ភាវៈរស់គឺអ្វីដែលមានជីវិត គឺពុំដែលធ្លាប់សិក្សាពីជីវិតនោះ បានច្បាស់លាស់ , អ្នកប្រាជ្ញខាងជីវវិទ្យាបានចាត់ពពួក សាកសពសេស. ទៅលើបញ្ហារបស់មនុស្សមុនអ្វីទាំងអស់ ។ មនុស្សជាសត្វ ដែលមានគ្រឿងវិញ្ញាណខ្ពស់ជាងគេនិងមនោ សញ្ចេតនា ។ ដូច្នេះសិក្សាពីជីវិតមនុស្សងាយស្រួលជាងគេ បំផុតសម្រាប់ការសំគាល់ , ពិសោធន៍, និងវិភាគ ។ គេបាន ចាត់ទុកមនុស្សជាជា «ភាវៈរស់» (être vivant) ដែល

ប្រកបដោយលក្ខណៈពិសេសពោលគឺ «លក្ខណៈបុគ្គល» (Caractère individuel) ខុសនិងសត្វប្រភេទដទៃទាំងឡាយ ។

160- តើពិសោធន៍ ដែលអ្នកប្រាជ្ញជីវវិទ្យាចាប់យកមកធ្វើជាកម្មវត្ថុរបស់ខ្លួនមុនគេគឺអ្វី ? ហេតុអ្វី ?

អ្នកប្រាជ្ញជីវវិទ្យា បានលើកយកបញ្ហាសរីរាង្គរបស់ការរស់មកធ្វើជាកម្មវត្ថុរបស់ខ្លួនមុនគេ ។ ហើយមូលហេតុដែលបណ្ដាលឲ្យអ្នកប្រាជ្ញទាំងនោះលើកបញ្ហាសរីរាង្គមកធ្វើជាកម្មវត្ថុរបស់ខ្លួននោះគឺសរីរាង្គជាពិសោធន៍រូបដែលផ្ដល់ឲ្យគេនូវការសង្កេតពិនិត្យតាមបែបប្រត្យក្សនិយមយ៉ាងច្បាស់

161- ទស្សនៈដែលលើកយកការពិចារណារកហេតុពិតរបស់ជីវិតដោយធ្វើការសង្កេតពិនិត្យទៅលើសរីរាង្គទាំងឡាយរបស់ការរស់ តើអាចផ្ដល់ផលប្រយោជន៍អ្វីខ្លះក្នុងការសិក្សាពីជីវិត ?

ការស្រាវជ្រាវសិក្សាពីជីវិត ដោយផ្អែកទៅលើការពិនិត្យសង្កេតដែលធ្វើឡើងលើសរីរាង្គការរស់នៃការរស់, មិនគ្រាន់តែផ្ដល់នូវសេចក្ដីចំរើន ដោយបានប្រត្យក្សនិយមចំពោះ ទៅតែបានជំរុញអ្នកប្រាជ្ញជីវវិទ្យាខ្លះ ឲ្យហ៊ានធ្វើ វិភាគ ដោយប្រើការវះកាត់ទៅលើសរីរាង្គ ដើម្បីពិនិត្យមើលភាពខាងក្នុងនៃការរស់នោះថែមទៀតផង ។ ការហ៊ានពុះសរីរាង្គការរស់ដើម្បីពិនិត្យឲ្យប្រត្យក្ស, បានបង្កើតបញ្ហាមួយថ្មីទៀតដល់អ្នកស្រាវជ្រាវ, គឺបញ្ហាស្មុគស្មាញចាក់ស្រេះនៃសរី

រាងរបស់ភាវៈរស់ទៅតាមប្រភេទនីមួយៗរបស់វា ។ ទីបំផុត, ក្រោយដែលបានគេឃើញនូវភាពចម្លែកគ្នានៃភាវៈរស់ក្នុងក្រុមនីមួយៗ រួចហើយ, អ្នកប្រាជ្ញក៏អនុវត្តន៍កំរិតការស្រាវជ្រាវរបស់ខ្លួនអោយទៅត្រឹមពាក់កណ្ដាល, ពោលគឺគេបានប្រមូលការសិក្សាទាក់ទងសរីរាង្គរបស់ភាវៈរស់ទាំងអស់ ដោយប្រគល់កម្មវត្ថុទាំងនុ៎ះទៅវិទ្យាថ្មីមួយទៀតដែលមានឈ្មោះថា: «សរីរវិទ្យា» (physiologie) ដែលទាក់ទងនឹងសិក្សាអំពីមុខងារនៃរាងកាយនៃជីវិត ។

162 - តើសរីរវិទ្យាក្ដី ជីវវិទ្យាក្ដី មានតំរូវការលើគណិតវិទ្យាឬ គីមី-រូបវិទ្យាឬទេ ?

ដោយសរីរវិទ្យាក្ដី, ជីវវិទ្យាក្ដី ត្រូវការចាំបាច់នូវភាពប្រាកដនិយមនិងការស្ទង់មាត្រដែលទាក់ទងនឹងសីតុណ្ហភាព ទើបវិទ្យាទាំងពីរនេះត្រូវការជាចាំបាច់នូវគណិតវិទ្យានិងគីមី-រូបវិទ្យា ។

163- ចំពោះជីវវិទ្យាដែលមានលក្ខណៈជាសាស្ត្រពិសោធពិតៗនោះ តើបានឆ្លងកាត់វិវត្តន៍អ្វីខ្លះ ?

មុននឹងបានក្លាយខ្លួនជាសាស្ត្រពិសោធពិតៗ, ជីវវិទ្យាបានឆ្លងកាត់តំណាក់ការណ៍នៃការសិក្សាជាច្រើនប្រភេទគួរកត់សំគាល់ដូចតទៅនេះ :

ដំបូងការប្រមូលផ្ដុំនូវគន្លឹះក្នុងជាតិជាតូចជាក្រុមនាញរឹតការសិក្សារអោយក្លាយទៅជាវិទ្យាយ៉ាង ដែលសិក្សាកំសន្ទានទៅលើរបស់ភាវៈរស់តាមពួក ។ ហើយការប្រមូលផ្ដុំនិងចំណាត់ថ្នាក់ (classification) របស់ភាវៈរស់...

ក្លាយទៅជាក្បួនចាត់ក្រុមពីរឿងរបស់ធម្មជាតិ ដែលគេហៅថា «ប្រវត្តិធម្មជាតិ» (histoire naturelle) ។ ក្បួនសិក្សាអំ ចំណែកផ្ទាត់របស់ធម្មជាតិ មិនត្រូវតែបង្ហាញនូវភាពផល ការណលក្ខណៈជាប្រព័ន្ធ (systèmes) ប៉ុណ្ណោះទេ, តែត្រូវ បង្កើតកំណត់ច្បាប់ផលិតបកាយបែបសង្កត់ពិសោធន៍ ក្នុងរូបវិទ្យា (physique) ផងដែរទៀត ដែលការពិសោធន៍ស្ថិតនៅក្នុងកំ រិតតាមវិជ្ជមានៈក្រៅសង្កត់រូបវិទ្យា (បរមត្ថវិជ្ជា : métaphysique) នោះឡើយ ។

យើងបានឃើញថា,. ការស្រាវជ្រាវរូបធាតុរបស់ភាវៈរស់ ផ្តល់នូវចំណោះពិសោធន៍ផ្សេងទៀត ពីការមើលឃើញដើម កំណើតនៃភាវៈរស់ដែលបានផ្លាស់ប្តូរភេទពីសរីរាង្គរបស់ ខ្លួនពីកំណើតពិតមកជាសរីរាង្គថ្មី ដែលគេពុំអាចមើលស្គាល់ បាន ។ ឧទាហរណ៍ៈ សត្វស្លាបទឹកបានក្លាយទៅជាម្ជូស ។ សត្វផ្សេងទៀតបានក្លាយទៅជាអំពៅ ។ មនុស្សកាលពី សម័យបុរេប្រវត្តិមានរូបរាងជាស្វា ។ល។

ការផ្លាស់ប្តូរភេទរបស់ភាវៈរស់ បានត្រូវអ្នកប្រាជ្ញទាំងឡាយ ហៅឈ្មោះថា (បំលែងនិយម). (Le transformisme)

164- ក្រោយ ដែលបានបន្តការស្រាវជ្រាវទៅតាមជីវវិទ្យា តើអ្នកប្រាជ្ញ បានកត់សំគាល់សរីរាង្គកាយរបស់ មនុស្សថាយ៉ាងដូចម្តេចខ្លះ ?

បញ្ហា ដែលត្រូវលាបយកភាវៈរស់ទាំងអស់មកស្រាវជ្រាវ រកមើល គឺ ធ្វើចំណែកផ្ទាត់ទៅតាមប្រភេទពិតក្លាក, បន្ទាប់មកគឺ

ឃើញលក្ខណៈពិតក្នុងធម្មជាតិ ។ បានជាអ្នកប្រាជ្ញអោយ បញ្ជាក់ថា៖

« សរីរាង្គទាំងឡាយរបស់មនុស្សនិងសត្វ , សុទ្ធតែទទួល ដោយស្រោប ដែលចែកសត្វនិងមនុស្សជាប្រាំដែលត្រូវដាច់ពីគ្នា ។ ទី១គឺមជ្ឈដ្ឋានក្រៅ (Milieu extérieur) ចំណែក ទី២ គឺមជ្ឈដ្ឋានក្នុង (Milieu intérieur) ។ អ្នកប្រាជ្ញបារាំងពោលថា៖ « ក្រៅដែនក្រៅរបស់សារពាង្គកាយ គឺស្បែក ឬស្រោប ។ មជ្ឈដ្ឋានក្រៅមិនសូវមានឥទ្ធិពលលើសារពាង្គកាយទេ ។ រីឯមជ្ឈដ្ឋានក្នុងមានឥទ្ធិពលខ្លាំងណាស់ទៅលើសារពាង្គកាយ ព្រោះនៅក្រៅដែនខាងក្នុងមានសុទ្ធតែធាតុផ្សំ (Composant) របស់ការរស់ , ហើយសុទ្ធតែនៅត្រូវក្នុងឈាមនិងទឹករងៃ ។

165- តើសរីរវិទ្យាដែលទំបត្តការស្រាវជ្រាវរបស់ខ្លួន , ព្រមទាំងបានលទ្ធផលគាប់ប្រសើរយ៉ាងនេះ អាចឆ្លើយនឹងសំណួររបស់ « បរមត្ថវិជ្ជា » ពីបញ្ហា « ជីវិត » បាន ឬទេ ?

ថ្វីបើការស្រាវជ្រាវផ្នែកសរីរវិទ្យា ប្រកបដោយលទ្ធផលគាប់ប្រសើរក្នុងធម្មជាតិយ៉ាងនេះក្តី , ក៏ឃើញហើយថា « សរីរវិទ្យា » ពុំអាចឆ្លើយនឹងសំណួររបស់ « បរមត្ថវិជ្ជា » ពីបញ្ហាជីវិតបានឡើយ ។

166- តើ « បរមត្ថវិជ្ជា » សួរ « សរីរវិទ្យា » ដោយសំណួរ យ៉ាងដូចម្តេច ?

«ចាបភ្លៀង» ជាភូមិ «និរាស្សា» ថា ៖

«តើអ្នកណាបង្កើតភ្នែកសំរាប់មើល? បង្កើតត្រចៀកសំរាប់ស្ដាប់ ឲ្យមនុស្សចេះយំ-សើច-សប្បាយរីករាយ និងខឹង?»

167 - តើអ្នកប្រាជ្ញឈ្មោះអ្វី ដែលបានរកឃើញរូបមនុស្សដំបូងមុនគេក្នុងការស្រាវជ្រាវសរីរវិទ្យា ?

អ្នកប្រាជ្ញឈ្មោះក្លូតប៊ែណា (Claudes Bernard) បានរកឃើញរូបមនុស្សដំបូងមុនគេក្នុងការស្រាវជ្រាវពិសោធន៍វិទ្យា ។

168 - តើអ្នកប្រាជ្ញឈ្មោះអ្វីដែលជឿថា «សរីរាង្គកាយរបស់មនុស្សនិងសត្វ» មានលក្ខណៈដូចម៉ាស៊ីន ?

រ៉េណេដេកាត (Descartes) ។

169 - តើនរណាដែលបានរកឃើញកិច្ចការងាររបស់សរីរាង្គកាយរបស់មនុស្សនិងសត្វមុនគេ ?

ព្រះពុទ្ធសម្មាសម្ពុទ្ធបានរកឃើញរូបធម៌ និងការកកើតរាងកាយមនុស្សនិងសត្វទាំងអស់ជាយូរណាស់មកហើយ ។ ឧទាហរណ៍ដូចជាព្រះអង្គទ្រង់បានត្រាស់ ក្នុងព្រះគម្ពីរអភិធម្មថា៖ រូបកើតឡើងពីសភាវៈទាំងឡាយ ៤ គឺកម្ម ១-ចិត្ត ១-ឧតុ ១ និងអាហារ ១- ។ តើសំណួរថា តើក្នុងរូបនោះមានធាតុអ្វីខ្លះ? ព្រះពុទ្ធទ្រង់មានពុទ្ធដីកាប្រាប់រួចហើយដែរ គឺ ទ្រង់បានត្រាស់ឈ្មោះមួយផ្សេងទៀតថា «មហាភូត» ដែលមានកំណើតពីធាតុ ៤ គឺ៖

១ - បឋវីធាតុ ( ធាតុដី )
២ - អាបោធាតុ ( ធាតុទឹក )
៣ - តេជោធាតុ ( ធាតុភ្លើង )
៤ - វាយោធាតុ ( ធាតុខ្យល់ ) ។

* * *

# ៩ - មនុស្សវិទ្យា

(Sciences humaines)

170 - អ្វីទៅហៅថាមនុស្សវិទ្យា ?

វិជ្ជាដែលហៅថាមនុស្សវិទ្យា គឺវិជ្ជាទាំងឡាយដែលសិក្សាអំពីឥរិយាបថនិងអាកប្បកិរិយា (Comportement) មនុស្ស ។

171 - ដើម្បីកុំអោយច្រលំនៅពេលសិក្សា, តើគេអាចចែកមនុស្សវិទ្យាជាប៉ុន្មានផ្នែក ? តើអ្វីខ្លះ ?

ដើម្បីកុំអោយច្រលំក្នុងការសិក្សាពីមនុស្សវិទ្យា, អ្នកប្រាជ្ញសម័យថ្មីបានចែកការសិក្សាមនុស្សវិទ្យាជា៣ភាគធំៗទៅគឺ

១ - ប្រវត្តិវិទ្យា (Histoire)

២ - សង្គមវិទ្យា (Sociologie)

៣ - ចិត្តវិទ្យា (Psychologie)

172 - អ្វីទៅដែលហៅថាប្រវត្តិវិទ្យា ?

ប្រវត្តិវិទ្យា គឺការសិក្សាពីរឿងរ៉ាវរបស់មនុស្សដែលរស់នៅក្នុងសង្គមតាំងពីអតីតកាល ។ ជារឿងរ៉ាវដែលទាក់ទងនឹងព្រឹត្តិការណ៍ពិតៗនៃជនជាតិណាមួយ ប្រកបដោយទីកន្លែងនិងការកំណត់ជាក់លាក់ ។

173 - លក្ខណៈសំខាន់ដែលធ្វើអោយគេចាប់អារម្មណ៍យ៉ាងខ្លាំងថាប្រវត្តិវិទ្យាជាសម្បត្តិដែលពាក់ព័ន្ធដល់ទៅគឺអ្វី ?

នៃវត្ថុក្នុងប្រវត្តិវិទ្យា លក្ខណៈសំខាន់ដែលត្រូវមានជាបឋមគឺ
ហេតុការណ៍ជាក់ស្តែង « ការណ៍ប្រវត្តិវិទ្យា » ( Fait historique)

**174- អ្វីទៅហៅថា « ការណ៍ប្រវត្តិវិទ្យា » ?**

ដែលហៅថា « ការណ៍ប្រវត្តិវិទ្យា » គឺព្រឹត្តការណ៍ទាំងឡាយណាដែលមានលក្ខណៈជារូបី , បានប្រព្រឹត្តក្នុងអតីតកាលកន្លងទៅហើយពិតៗ , ប្រកបដោយការពិតប្រាកដយ៉ាងជាក់លាក់ , ហើយជាពិសេសជាការណ៍ទាក់ទងនឹងសង្គមមនុស្សនោះផង ។

ឧទាហរណ៍ : រូបសំណាកមើលឡើងដោយចំនួនដងគេ ។
វន្តះបាត្រូវទទួលយកទៅវត្តក្បាលដោយព្រះជាតិ ។ ចិនកន្លងមកពីហូកុង ដើរស្រាវជ្រាវបរិវេណភ្នំគិរីហើយ រកឃើញស្រាវជ្រាវប្រាប់ទៅក្រុមទាំងខ្លួនមុន ។
ព្រឹត្តការណ៍ទាំងនេះ គេអាចបានកត់ទុកក្នុងប្រវត្តិពង្សាវតាររបស់ខ្មែររួចហើយ ។ គឺជាព្រឹត្តិការណ៍ដែលមានកត់ត្រាក្នុងប្រវត្តិសាស្ត្រប្រកបដោយការពិតទីកន្លែងជាក់លាក់ ។

**175- តើការលថា « ប្រវត្តិវិទ្យា » ជាសម្បត្តិរបស់មនុស្ស តើគេអាចធ្វើពិសោធន៍ទៅលើសម្បត្តិនោះបានឬទេ?**

គេពុំអាចធ្វើពិសោធន៍លើសម្បត្តិប្រវត្តិវិទ្យាបានទេ ។ តែគេអាចវិនិច្ឆ័យរកការពិតរបស់សម្បត្តិនោះបានដោយវិធីម្យ៉ាងដែលគេហៅឈ្មោះថា « វិធីប្រវត្តិវិទ្យា » ។

**176- ក្នុងការវិនិច្ឆ័យរកការពិតនៃប្រវត្តិវិទ្យា តើគេអាចប្រើវិធីប៉ុន្មានយ៉ាង ? គឺវិធីអ្វីខ្លះ ?**

គេអាចវិនិច្ឆ័យប្រវត្តិវិទ្យាដោយប្រើវិធីពីរយ៉ាងគឺ :

១ - វិធីញែកការណ៍ក្នុងប្រវត្តិវិទ្យា ដែលគេហៅថា «វិភាគប្រវត្តិវិទ្យា» (analyse historique) ។

២ - វិធីប្រមូលផ្ដុំការណ៍ទាំងឡាយរបស់ប្រវត្តិវិទ្យាមកធ្វើសំយោគ ដែលគេហៅថា «សំយោគប្រវត្តិវិទ្យា» (Synthèse historique) ។

177 - ហេតុអ្វីបានជាគេដឹងការណ៍របស់ប្រវត្តិវិទ្យា ?

គេដឹងការណ៍របស់ប្រវត្តិវិទ្យា ព្រោះគេបានឃើញឯកសារជាច្រើនដែលគេបានរកឃើញ នៅសេសសល់ពីសម័យអតីតកាលរហូតមកដល់បច្ចុប្បន្នកាលនេះ ។

178 - តើឯកសារទាំងនោះមានរូបរាងជាអ្វីខ្លះ ?

ឯកសារទាំងនោះមានរូបរាងបែបផែនខុសប្លែកៗ ពិត្មាដូចជា: ឯកសារសរសេរមានក្រាំង-សាស្ត្រា-សិលាចារឹក។ល។ គ្រឿងប្រើប្រាស់គ្រប់យ៉ាងមានអាវុធយុទ្ធភណ្ឌ - ឧបភោគភ័ណ្ឌ ព្រមទាំងគ្រឿងសំណង់មានផ្ទះសំបែង, ប្រាសាទបុរាណក ទីឋានប្រវត្តិសាស្ត្រ ។ល។

ឯកសារផ្ទាល់មាត់សូរសំឡេងសម្រាប់ភាសាវិទ្យា ។ល។

179 - បើប្រវត្តិវិទ្យា ពឹងផ្អែកទាំងស្រុងទៅលើឯកសារផ្សេងៗ ព្រមទាំងភស្តុតាងជាសារពើភណ្ឌសេសសល់របស់មនុស្សសម័យដែលកន្លងផុតមកហើយ តើគេអាចទុកចិត្តលើប្រវត្តិវិទ្យាបានឬទេ ?

គេមិនអាចទុកចិត្តលើប្រវត្តិវិទ្យាទាំងស្រុងទេ តែគេអាចទុកចិត្ត

លើការស្រាវជ្រាវរបស់អ្នកប្រវត្តិវិទ្យាបានពោលគឺ គេមិនជៀស ទៅរកការគិតច្រលំនិងការខ្វះខាតឯកសារ ក្នុងការសរសេរ ប្រវត្តិសាស្ត្របាន ។

180- គេតែងពោលថា ប្រវត្តិវិទ្យាមានការណ៍ប្រកបដោយ វត្ថុវិស័យភាពរបស់ខ្លួន ។ ហើយគេតែងនិយមពោល ថែមទៀតថា «វត្ថុវិស័យភាព» នោះបានញុំាងអ្នក ស្រាវជ្រាវមុខវិជ្ជានេះ អោយស្ថិតនៅក្រោមការទំ- នៀនគ្រប់យ៉ាងបាន ។ តើអ្នកយល់យ៉ាងដូចម្តេច ?

វត្ថុវិស័យភាពក្នុងប្រវត្តិវិទ្យាសាកល្បតាមរូបី ដែលប្រកប ដោយភាពជាក់លាក់ និងគុណភាពញុំាងអោយគេជឿបាន ដោយពុំមានការសង្ស័យទៅលើភាពប្រាកដនិយម ដែលអ្នក ស្រាវជ្រាវប្រវត្តិវិទ្យាចំបង្ហាញក្នុងសមត្ថកម្មរបស់ខ្លួន ។ គឺជា កត្តាប្រាកដនិយម ដែលមានលក្ខណៈជាសកលភាព (Universalité) គ្រប់កាលវេលា ។

ឧទាហរណ៍ៈ ដោយវត្ថុវិស័យភាពក្នុងប្រវត្តិវិទ្យារួមការមួយនិង អក្សរចារិកក្រមខាំងប្រមត្ត នៃក្បាច់ចម្លាក់លើប្រាសាទនានា ដែលគេបានប្រមូលបានកើតនាំសំខាន់ប្រវត្តិវិទ្យា , អ្នកប្រាជ្ញ ឈ្មោះ សឺដេស (Cœdès) បានអោយយើងជឿបានថា «ប្រាសាទអង្គរវត្ត ជាស្នាដៃបុព្វបុរសខ្មែរ គឺព្រះមហាក្សត្រ មួយអង្គព្រះនាម «សុរិយាវរ្ម័នទី ២» សាងនៅពេលសតវត្ស ទី ១២ , សម្រាប់ដំកល់អដ្ឋិរបស់ព្រះអង្គ» ។

សេចក្តីបញ្ជាក់ថាប្រវត្តិសាស្ត្រនេះ បានកើតហេតុនេះទៀតថា

លើការស្រាវជ្រាវរបស់អ្នកប្រវត្តិវិទ្យាបានពោលគឺ គេទិតៀន ទោះបីការភ័ន្តច្រឡំនិងការខ្វះខាតឯកសារ ក្នុងការសរសេរ ប្រវត្តិសាស្ត្របាន ។

180- គេតែងពោលថា ប្រវត្តិវិទ្យាមានការណ៍ប្រកបដោយ វត្ថុវិស័យភាពរបស់ខ្លួន ។ ហើយគេតែងនិយមពោល ថែមទៀតថា «វត្ថុវិស័យភាព» នោះបានញ៉ាំងអ្នក ស្រាវជ្រាវមុខវិជ្ជានេះ អោយស្ថិតនៅក្រោមការទិ- តៀនគ្រប់យ៉ាងបាន ។ តើអ្នកយល់យ៉ាងដូចម្ដេច ?

វត្ថុវិស័យភាពក្នុងប្រវត្តិវិទ្យាសាកល្បងប៊ី ដែលប្រកប ដោយភាពជាក់លាក់ និងតត្តភាពញ៉ាំងអោយគេជៀសបាក ដោយពុំមានការលំអៀងទៅលើភាពបក្សនិយម ដែលអ្នក ស្រាវជ្រាវប្រវត្តិវិទ្យាចំបង្ហាញក្នុងសម្ដីគម្ពីររបស់ខ្លួន ។ គឺជា កត្តាបក្សនិយម ដែលមានលក្ខណៈជាសកលភាព (Universalité) គ្រប់កាលវេលា ។

ឧទាហរណ៍ៈ ដោយវត្ថុវិស័យភាពក្នុងប្រវត្តិវិទ្យារួតជាមួយនឹង អក្សរចារិកប្រមទំហំបមត្ថ នៃអក្សរចំណាស់លើប្រាសាទនានា ដែលគេបានប្រមូលយកធ្វើជាសំភារៈប្រវត្តិវិទ្យា , អ្នកប្រាជ្ញ ឈ្មោះ សឺដេស (Cœdès) បានបកប្រែអោយយើងដឹងថា «ព្រះការុណ្យវត្ត ជាស្ថាបនាបុព្វបុរសខ្មែរ គឺព្រះមហាក្សត្រ មួយអង្គព្រះនាម «សូរ្យវរ្ម័នទី ២» សាងនៅសតវត្ស ទី ១២ , សម្រាប់ដាក់អដ្ឋិរបស់ព្រះអង្គ» ។

សេចក្ដីបញ្ជាក់ជាប្រវត្តិសាស្ត្រនេះ បានធ្វើអោយគេដឹងថា 83

ឬការបូសនិយដ្ឋាននេះ ; សាលារៀនយើងមានមនុស្សពិតៗដែលអាចនឹងពន្យល់សាលារៀនហើយ ។ អាស្រ័យលើគុណវិស័យភាពប្រវត្តិ-វិទ្យាដែលមានរូបមន្តគ្រប់គ្រាន់ , អ្នកស្រាវជ្រាវប្រវត្តិវិទ្យារួចនេះបានចាកផុតពីការជំនឿគ្រប់យ៉ាង របស់មតិមហាជនក្នុងលោក ។ មិនតែប៉ុណ្ណោះសោតគំនិតដែលប្រកបដោយភាគលក្ខណៈរបស់ប្រវត្តិវិទ្យា បានធ្វើអោយសម្បត្តិក្នុងលោកសីលធម៌ ស្ថិតនៅក្រោមការជំនឿគ្រប់កាលទាំងពួងផង ។

181 - អ្វីហៅថាហេតុផលភាពនៃប្រវត្តិវិទ្យា ? ចូរលើកឧទា-ហរណ៍រូបី ?

ហេតុផលភាពនៃប្រវត្តិវិទ្យា គឺជាទំនាក់ទំនងនៃហេតុផលជាចាំបាច់ទាំងឡាយ ដែលបានចង្អុលពីមូលហេតុបង្កើតអោយមានការណ៍ប្រវត្តិវិទ្យា ។

ឧទាហរណ៍ : តើលោកវេជ្ជបណ្ឌិត វែរ - សង់ទីម - និងលោកសាស្ត្រាចារ្យ ថាច់ - ផា ស្លាប់ដោយសារអ្វី ? តើហេតុផលភាពនៅត្រង់ណា ? ។

បើយើងចង់បង្ហាញព្រឹត្តការណ៍ ជាក់លាក់ស្ដីពីមរណភាពរបស់លោកទាំងពីរនេះ , យើងទៀសពុំរួច នឹងហាមបង្ហាញនូវហេតុផលភាពនៃប្រវត្តិវិទ្យាឡើយ ។ ព្រោះរឿងមរណភាពលោកទាំងពីរ បានត្រូវគេបញ្ចូលទៅក្នុងប្រវត្តិសាស្ត្រខ្មែររួចហើយ ។ តើហេតុផលភាពនៅត្រង់ណា ?

បើចង់បង្ហាញនូវហេតុផលភាពនៃមរណភាពលោកទាំងពីរ គេត្រូវឆ្លើយអោយរួចនូវចំលើយដូចតទៅនេះ :

ទី១ - ហេតុអ្វីក៏លោកវែរសង់ទីម និងលោកថាច់ ផាស្លាប់ ?

ទី២ - ហេតុអ្វីក៏មានព្រឹត្តិការណ៍នៅវិទ្យាល័យ ១៩ មីនា?

ទី៣ - ហេតុអ្វីក៏មានការប៉ះទង្គិចគ្នា រវាងសិស្ស, បុគ្គលិក សិក្សាជាមួយនឹងរដ្ឋាភិបាល ?

ទី៤ - ហេតុអ្វីក៏បៀវត្សរ៍ចាយពុំគ្រាន់? និងហេតុអ្វីបានជា ទំនិញសព្វសារពើឡើងថ្លៃ?

ទី៥ - ហេតុអ្វីក៏ប្រទេសខ្មែរមានសង្គ្រាម? និងហេតុអ្វីក៏ខ្មែរ ត្រូវផ្លាស់នយោបាយ?

បើយើង ឆ្លើយនូវសំណួរទាំងប្រាំ ខាងនេះពុំរួចទេ, ច្បាស់ជា យើងរកការណ៍ប្រវត្តិស្តីពីអតីតៈកាល លោកទាំងពីរនេះពុំ ឃើញឡើយ ។ បើយើងរកពុំឃើញហេតុជាក់លាក់នៃការណ៍ប្រ- វត្តិពុំឃើញ, តើយើងអាចរកហេតុផលភាពនៃប្រវត្តិឃើញ ឬទេ? ទោះបីគេជឿថាប្រវត្តិវិទ្យាជាស្ពង់សម្រាប់សិក្សា ពីរឿងរ៉ាវទាំងឡាយរបស់មនុស្ស ឬ និងជាតិណាមួយក៏ ដោយ, ក៏គេពុំអាចធ្វើពិសោធន៍ដូចស្ពង់ផ្សេងទៀត ដើម្បីរក ហេតុផលភាពរបស់វាអោយឃើញបានឡើយ ។ ព្រោះថា គេរកចំណាក់ចំណងនៃការណ៍ប្រវត្តិជាក់លាក់ពុំឃើញ ពោលគឺ ចំណាក់ចំណងពីឃាតករទៅអ្នកបញ្ជាឃាតករ, ពីអ្នកបញ្ជា ឃាតករទៅអ្នកសម្រេចគំនិត ។ល។ និង ។ល។

## 182 - អ្វីទៅហៅថាទស្សនវិជ្ជានៃប្រវត្តិវិទ្យា?

(la philosophie de l' histoire)

ដែលហៅថាទស្សនវិជ្ជានៃប្រវត្តិវិទ្យា គឺការពិចារណាទៅលើ

ច្បាយដែលជារូបមន្ត សំរាប់រិះរកច្បាប់ទាំងរបស់ នៃវិវត្តន៍របស់មនុស្ស (évolution humaine) ។

183 - អ្វីទៅហៅថាវិវត្តន៍នៃប្រវត្តិវិទ្យា ?

(le devenir historique)

ដែលហៅថាវិវត្តន៍ប្រវត្តិវិទ្យា គឺការណ៍ប្រវត្តិវិទ្យា ដែលបណ្តាលមកពីចំនួនច្រើនផង និងលំដាប់ច្បាប់ដែលជាបុព្វហេតុនៃការណ៍នោះផង ។

184- គេបានពោលថា វិវត្តន៍ប្រវត្តិវិទ្យាមានលក្ខណៈជាកំណត់និយម (déterminisme) ផង, និងជាវាសនានិយម (fatalisme) ផង ។ តើអ្នកយល់យ៉ាងដូចម្តេចចំពោះបញ្ហាខាងលើនេះ ?

ចូរលើកឧទាហរណ៍មកពន្យល់ ?

គេបានពោលថា វិវត្តន៍ប្រវត្តិវិទ្យាមានលក្ខណៈជាកំណត់និយម :

តើវិវត្តន៍ប្រវត្តិវិទ្យាមានលក្ខណៈ ជាកំណត់និយមមែនឬទេ? ដើម្បីដោះស្រាយគំនិតខាងលើនេះ, គាប្បីយើងយល់ន័យនៃពាក្យវិវត្តន៍នៃប្រវត្តិវិទ្យាជាមុនសិន ។

វិវត្តន៍នៃប្រវត្តិវិទ្យាជាការណ៍ប្រវត្តិវិទ្យា ដែលបណ្តាលមកពីចំនួនច្រើន និងលំដាប់ច្បាប់ដែលជាបុព្វហេតុនៃការណ៍នោះផង ។ តើនៅក្នុងការណ៍ប្រវត្តិវិទ្យាមាននិយាយពីកំណត់

និយមឬទេ ? បើបាន តើកំណត់និយមនោះកើតមកពីចៃដន្យ ឬមួយកើតមកពីលំដាប់ល្បាប់ ? ឬមួយក៏ផ្ទុយគ្នាទៅវិញ ?

រឿងរ៉ាវទាំងឡាយដែលជាការណ៍ប្រវត្តិវិទ្យា ទោះបីកើតមកអំពីចៃដន្យក្តី, ឬកើតមកអំពីលំដាប់ល្បាប់ក្តី, ហេតុនៃការណ៍ទាំងនោះ ច្រើនតែមានលក្ខណៈជាកំណត់និយម ( déterminisme) ។

យើងសាកល្បងពិចារណារឿងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់ជាតិខ្មែរយើង ៖

មុនពេលរាជានិយមបានបាត់បង់ពីប្រទេសខ្មែរទៅ យើងបានសង្កេតឃើញព្រឹត្តិការណ៍ទាំងឡាយ ដែលបង្ហាញអោយយើងឃើញថា មានហេតុផលភាគច្រើនជាកត្តាប្រកាសវិវត្តន៍ពីរាជានិយមមកជាសាធារណរដ្ឋ ។ ឧទាហរណ៍ រូបីមួយគួរយើងលើកយកមកបង្ហាញក្នុងពេលនេះបាន ៖ ខ. បញ្ហារៀងគួស ។ គេបានដឹងថាមុនព្រឹត្តិការណ៍ ១៨ មីនា ១៩៧០, នៅឯកាសបុណ្យជាតិលើកចុងក្រោយបង្អស់មួយ, ពេលអតីតប្រមុខរដ្ឋ ដែលកំពុងតែដើរត្រួតពល ស្រាប់តែគួសបាក់ជាពីរកំណាត់ត្រឹមស្មើដូចគេយកកាំបិតមកកាត់ ។ អព្ភូតហេតុនេះគាប្បីល្មមគួរអោយពិចារណាដូចតទៅនេះ ៖

ទី១ - បើថាការបាក់គួស អតីតប្រមុខរដ្ឋក្នុងពេលពិធីជាតិនេះកើតឡើងដោយចៃដន្យក៏ជាបញ្ហាមួយដែរ ។ គឺថាពេលនោះមានខ្យល់បក់បោកយ៉ាងខ្លាំងពីទិសខាងជើង, វាយបំបាក់គួសនោះ ។ ដូច្នេះ យើងអាចពោលថាព្រឹត្តិការណ៍នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកើតឡើងដោយចៃដន្យ ។

ទី២- បើថាការចាត់ផ្លូវនោះ បណ្តាលមកពីមានលំដាប់ច្បាប់ ដែលជាបុព្វហេតុនៃការណ៍ គឺយើងសំដៅទៅលើន័យថា ៖ ផ្លូវចាត់ដោយការធ្វេសប្រហែសរបស់កម្រិត ដែលពុំទាន់ពិនិត្យអោយហ្មត់ចត់មុននឹងជ្រើសរើសផ្លូវយកមកតាំង ។ ប្រហែសដោយពុំបានប្រុងប្រយ័ត្នមើលផ្លូវឲ្យល់ ដែលកំពុងពោកបត់មកល្អិតផ្លូវ ឬទម្រាំនោះជាមនុស្សដែលពុំប្រសប់ឬខ្វះការប្រសប់ក្នុងមុខការរបស់ខ្លួន ។ ម្យ៉ាងទៀតយើងអាចពោលថា ជាគ្មានទេពកោសល្យ ក្នុងការធ្វើផ្លូវអោយបានដាច់ល្អ ។ នេះជាលំដាប់ច្បាប់ក្នុងប្រវត្តិវិទ្យាដែលជាហេតុផលនៃវិវត្តន៍ ។

បើយើងពិចារណាទៅលើកំណត់និយមវិញ, យើងឃើញថាព្រឹត្តិការណ៍នេះកើតឡើងដោយគេកំណត់ ទុកមកជាស្រេច, ព្រោះព្រឹត្តិការណ៍នេះគេបង្ហាញហេតុផលនៃវិវត្តន៍ប្រទេសដោយប្រផ្នូលមួយ ។ ព្រោះថាផ្លូវពុំសមអាចចាត់ចែងឡើយព្រោះផលនោះធ្វើអំពីខ្លាំងយ៉ាងដាច់ ។ មុននឹងយកមកតាំងកម្រិតបានជ្រើសរើសផ្លូវ យ៉ាងដាច់ក្នុងចំណោមផ្លូវ ប្រចាំថ្ងៃដែលមានចំនួនជាងអស់ ។ រីឯម្នាក់តាំងផ្លូវទៀតសោតក៏ជាមនុស្សដែលប្រកបពិភាក្សា នៃផ្លូវផ្គួរគិតរវាងបានសំរាំងរើសយ៉ាងហ្មត់ចត់ជាទីបំផុត ។ ដូច្នេះយើងឃើញថាកំណត់និយមពិតជាមានស្ថិតនៅក្នុងវិវត្តន៍ ប្រវត្តិវិទ្យាមែន ។

ត្រង់ចំណុចនេះគេបានហៅឈ្មោះថាវាសនានិយម (fatalisme) ក៏មាននៅក្នុងវិវត្តន៍ប្រវត្តិវិទ្យាដែរ តែយោបល់នេះពិតមែនឬ

បើយើងយក ឧទាហរណ៍ ពីរឿងគ្រួសារដែលយកពិចារណា ក៏យើងអាចឃើញបានដែរថា នោះបីមានប្រផ្នូលក្ដី, គ្មានប្រផ្នូលក្ដី, មានថៃស្បក្ដី, គ្មានថៃស្បក្ដី ក៏វិវត្តន៍ប្រទេសខ្មែរត្រូវតែដើរមកដល់ដំណាក់កាលនេះ ដោយខានពុំបាន ។ វាសនាប្រទេសហាក់ដូចជា ចៀសពុំរួចពីរឿងរ៉ាវទាំងឡាយដែលយើងជាខ្មែរទាំងអស់គ្នាធ្លាប់បានទទួលមកហើយឬ នឹងទទួលទៅពេលខាងមុខទៀតដោយខានពុំបានឡើយ ។

ឧទាហរណ៍ជាក់លាក់បញ្ជាក់ថា វិវត្តន៍ប្រវត្តិប្រទេសខ្មែរមានលក្ខណៈវាសនានិយម គឺបង្ហាញដោយយើងឃើញជាក់ច្បាស់នៅត្រង់ «ក្បួនពុទ្ធទំនាយ-ក្រុងទំនាយ» ដែលបានទាយទុកមកក៏គ្មានខុសបន្តិចសោះ ។

សេចក្ដីដូចបានអធិប្បាយមកហើយនេះ បានបញ្ជាក់ថាត្រឹស្ដីដែលពោលថា វិវត្តន៍ប្រវត្តិវិទ្យា មានលក្ខណៈដាក់ណត់និយមផង និងវាសនានិយមផងនេះសមហេតុសមផល, ព្រោះទាំងប្រកបដោយសច្ចៈភាពពិតកាស់ ។

## 185- អ្វីទៅហៅថាគោលដៅភាពនៃវិវត្តន៍ ?

(Qu'est ce que la finalité du devenir?)

គឺជាលទ្ធផលចុងក្រោយបង្អស់នៃវិវត្តន៍ប្រវត្តិវិទ្យា និងជាលទ្ធផលកំណត់ដោយហេតុប្រកបដោយកុសលផង អកុសលផង ។

## 186- គោលដៅភាពនៃវិវត្តន៍ប្រវត្តិវិទ្យា បានត្រូវអ្នកសាសនានិយមណាយកចិត្តទុកដាក់ជាងគេ? ហេតុអ្វី?

ព្រះសង្ឃកាតូលិកឈ្មោះ អូគុយស្ទាំង (St-Augustin) បានយកចិត្តទុកដាក់ផងដែរ ។ ព្រោះលោកបានបញ្ជាក់ថា "ព្រះអាទិទេពជាអ្នកញ៉ាំងអោយ វិវត្តន៍ទាំងអស់កាន់សម្រេច អោយដាច់ណាត់, ហើយប្រកបអោយគោលដៅជាក់លាក់, ទោះបីវិវត្តន៍នោះ មានលក្ខណៈជាប្រវត្តិសាស្ត្រ, ឬក្នុងធម្មជាតិនៃជីវិតមនុស្សសត្វក្តី"។ លោកអូគុយស្ទាំងបានពោលថា៖ "វិវត្តន៍ទាំងអស់បានផល់គោលដៅរបស់ខ្លួនមកស្រេចព្រះជាម្ចាស់ ។ ព្រះអង្គជាអ្នកសាងនូវវិវត្តន៍ទាំងអស់ក្នុងបុរីរបស់ព្រះអង្គ (Cité de Dieu) » ។

187 - អ្នកប្រាជ្ញខ្លះបានពោលថា ៖ "វិវត្តន៍កើតមកពីវឌ្ឍនភាពនៃបញ្ញារបស់មនុស្ស, តើអ្នកយល់ឃើញដូចម្តេចចំពោះមតិខាងលើនេះ ?

វិវត្តន៍នៅក្នុងប្រវត្តិវិទ្យា ខុសគ្នា នឹងវិវត្តន៍នៅក្នុងធម្មជាតិ ។ ប្រវត្តិវិទ្យាបានបង្ហាញវិវត្តន៍របស់ខ្លួន ដោយការណ៍ប្រវត្តិផ្សេងៗ ឬព្រឹត្តការណ៍បញ្ជាក់នូវគោលដៅភាពនៃឆ្ងាយ ។ ចំណែកវិវត្តន៍នៅក្នុងធម្មជាតិជាវិវត្តន៍ប្រកបដោយប្រព័ន្ធគំនិត (Systeme d'idées) ដើម្បីពន្យល់អំពីការរស់ទាំងឡាយ ដែលគេប្រទះឃើញនៅក្នុងការសិក្សាបរមត្ថវិជ្ជា (métaphysique) របស់លោកអូគុស្តកុង (Auguste Comte) ។ យើងឃើញថាទ្រឹស្តីដែល បង្ហាញពីយល់ឃើញខាងលើ, ជាគំនិតផ្ទុយស្រឡះពីទ្រឹស្តីលោក (Auguste Comte) ដែល

ការពោលថា ៖ “ វិវត្តន៍កើតមកពីឫទ្ធិអាទិទេព ” ពោលគឺ លោកម៉ុងតេស្គ្យ បានយល់ថា វិវត្តន៍សុទ្ធតែមានគោលដៅជាក់លាក់, ហើយម្យ៉ាងទៀតវិវត្តន៍នេះសុទ្ធតែកំណត់ដោយហេតុ, ជាវិវត្តន៍ច្រកចេញទៅរកវឌ្ឍនភាពក៏ប៉ុន្តែពុំមែនជាវឌ្ឍនភាព នៃបញ្ញាមនុស្សឡើយ ។

ប៉ុន្តែទ្រឹស្តីដែលពោល បញ្ជាក់ថាវិវត្តន៍ កើតមកពីវឌ្ឍនភាពនៃបញ្ញាមនុស្សបាន ស្របទៅនឹងគំនិតអ្នកប្រាជ្ញធំៗដូចជា លោកកង់ (Kant) និងលោកកុងដរសេ (Condorcet) ជាដើម។ លោកទាំងពីរយល់ថាវិវត្តន៍នេះកើតមកពីវឌ្ឍនភាព ដែលជាគុណធម៌មនុស្ស ។ មិនតែប៉ុណ្ណោះ លោកអ្នកប្រាជ្ញទាំងពីរនេះបានបញ្ជាក់ថែមទៀតថា : “ គឺជាវឌ្ឍនភាព នៃបញ្ញាមនុស្ស ” ។

បើយើងពិចារណាទៅលើគំនិតនេះ យើងឃើញថាគំនិត លោកកង់ (Kant) ក្តី, លោកកុងដរសេ (Condorcet)ក្តី, សុទ្ធតែផ្តួចផ្តើមស្របទៅលើការពិចារណា ដែលមកពីរូបគូ វិទ្យាសាស្ត្រ, មានរូបវិទ្យាជាដើមមកធ្វើជាមូលដ្ឋាន ។ គំនិត លោកទាំងពីរនេះគាំទ្រយ៉ាងពិសេស, ជំនឿលើផ្លូវត្រង់ពីកោតនៃ ដែលការប្រាស់សច្ចៈតែពីក្នុងចិត្តរបស់ស្ប៉ុ ។ ជាគំនិត ដែលឈរលើតែពីគុណភាពក្នុងរូបវិទ្យាប៉ុណ្ណោះៗពចំណែក ទ្រឹស្តីរបស់លោកម៉ុងតេស្គ្យ ដែលយល់ថា “ វិវត្តន៍ទាំងអស់ សុទ្ធតែមានគោលដៅជាក់លាក់ដោយហេតុ , ហើយលេចឮពី ឥទ្ធិពលនៃប្រភពពិសោធន៍គឺបរមត្ថវិជ្ជានោះ យល់ថាមនុស្ស

ទាំងអស់ កំលាំងទេពស្ថិតនៅផងអមតៈហើយជាប្រធាននៃ
កម្មនិងផលទាំងអស់របស់ពពួកជាតិទាំងការកើតរោយរីកចំរើន ឬ
បំផ្លាញទោលម្ភៃទាំងអស់នៅក្នុងលោកនិងក្រៅលោក. ដើម្បី
-បង្កើតសារសាស្ត្រឡើងវិញ ។

យើងយល់ថា , មតិដែលមានលក្ខណៈបដិបក្ខនឹងគ្នារវាង
អ្នកប្រាជ្ញទាំងពីរនេះ, បញ្ជាក់ពីការខ្វះសមត្ថភាពនៃបញ្ញា
មនុស្សក្នុងការស្រាវជ្រាវរក "ពុទ្ធិសច្ចៈ" ស្ដីពីវិវត្តន៍នេះឯង ។
ផ្ទុយទៅវិញយើងឃើញថាមានតែទ្រឹស្ដីនៃព្រះសមណគោតមប៉ុណ្ណោះ
ទេដែលអាចវិនិច្ឆ័យនៅឲ្យត្រឹមត្រូវបាន គឺថា "វិវត្តន៍នៃអ្វី
ទាំងអស់ដែលកើតតែកើតឡើងពីបច្ច័យទាំងឡាយ ដែលជា
គ្រឿងទាក់ទងគ្នាតាមលាដ់រវាងធាតុនិងសំណើនេះយ៉ាង ។ ម៉្យាង
ទៀតជាបច្ច័យដែលទាក់ទងរវាងផលនិងកម្មនេះ ។ បើជា
បច្ច័យកើតពីធាតុនិងសំណើវាជារបស់អនត្ត ពោលគឺ មិនទៀង
ព្រោះវានឹងនាំទៅរកការវិនាសវិញ ។ ហើយកំណត់និយម
ស្ថិតនៅត្រង់វិលទៅរកការលាយសូន្យនេះឯង ។ តែបើ
ជាបច្ច័យកើតពីកម្មនិងសំណើវិញ, គេឃើញថាកម្មវិធទាំងឡាយ
នោះអន្លោលតាមគ្នាចុះឡើងគតជាថ់ , តែការកំណត់និយម
វាគឺ ស្ថិតនៅត្រង់ការលាយបង្គួរផលនិងកម្មស្មើគ្នា ។ រួច
សេចក្ដីយកយើងយល់ថា នោះរឺវិវត្តន៍នេះ កើតមកពីអាទិទេព
កំណត់ក្ដី, ឬ កើតមកពីកំលាំងបញ្ញាមនុស្សក្ដី ក៏សុទ្ធតែមាន
បច្ច័យទាក់ទងរវាងគ្នាទាំងអស់, ទើបសំរេចជារូបរាងបាន ។
ផ្ទុយទៅព្រះពុទ្ធទ្រង់បានបញ្ជាក់ន័យរបស់ទ្រឹស្ដីនេះ បានជាក់
លាក់ពិតប្រាកដណាស់ ។

**188-** ដើម្បីត្រួតពិនិត្យលើវិវត្តន៍នៃប្រវត្តិវិទ្យា តើអ្នកប្រាជ្ញឈ្មោះអ្វី បានចង្អុលការសិក្សាប្រវត្តិវិទ្យាតាមបែបវិភាគ ?

ដើម្បីត្រួតពិនិត្យលើវិវត្តន៍នៃប្រវត្តិវិទ្យាអោយច្បាស់លាស់ លោកហេគែល (Hegel) ត្រូវការការសិក្សាប្រវត្តិវិទ្យាជាបីយ៉ាងគឺ :

១ - ត្រូវសិក្សាប្រវត្តិវិទ្យាតាមច្បាប់ដើម, ដែលជាប្រវត្តិវិទ្យានៃសាក្សីផ្ទាល់ ។

២ - ត្រូវសិក្សាប្រវត្តិវិទ្យាតាមបែបពិចារណា, ដែលទាក់ទង ធ្វើអោយអតីតកាលបិតនៅក្នុងបច្ចុប្បន្នជានិច្ច ។

៣ - ត្រូវសិក្សាប្រវត្តិវិទ្យាតាមបែបទស្សនវិជ្ជា ដែលបិតនៅក្នុងអតីតកាលនិងក្នុងសកល; ព្រោះថាប្រវត្តិវិទ្យាជាវិវត្តន៍មនុស្ស ដែលលោកហេគែល ចាត់ទុកថាជាសំណុំនៃបាតុភូត, នៃការរីកចំរើននៃគំនិតដែលបិតនៅបច្ចុប្បន្នកាលមួយគ្មានទីបញ្ចប់ ។

**189-** តាមពិតវិវត្តន៍នៃប្រវត្តិវិទ្យា ដែលបានដល់គោលដៅកំពូលរបស់ខ្លួនហើយអាចវិលមករកភាពដើមវិញទេ ?

ប្រវត្តិវិទ្យាក្រោយដែលវិវត្តន៍ទៅបានរាប់ពាន់ឆ្នាំ ក៏វិលត្រឡប់មកសូន្យដើមវិញ ។ ឧទាហរណ៍ខ្មែរសម័យអង្គរបានវិវត្តន៍ទៅដល់កំពូលនៃការរៀនសូត្រនិងរីកចំរើនគ្រប់វិស័យមានអរិយធម៌រុងរឿង ។ មកដល់សម័យបាក់បែកលង្វែក និងសម័យបច្ចុប្បន្នខ្មែរក៏វិលត្រឡប់មករកភាពសូន្យដើមវិញ គឺការធ្លាក់ចុះដុនដាបស្ទើរតែគ្រប់វិស័យ ដោយឥទ្ធិពល នៃសង្គ្រាម ។

១៩០- តើអ្នកប្រាជ្ញឈ្មោះអ្វី ? មានសញ្ជាតិជាអ្វី? ដែលបានសង្កេតឃើញថាអរិយធម៌ជាច្រើនដែលបានកើតមានជីវិតនៅលើពិភពលោកយើងនេះមក បានត្រូវរលាយរលត់ទៅវិញស្ទើរតែទាំងអស់ ?

អ្នកប្រាជ្ញឈ្មោះ តូនប៊ី (Toynbec) មានសញ្ជាតិជាអង់គ្លេស បានសង្កេតឃើញហើយ ដូចនេះក្រោយទាំងតាមបញ្ជាក់ថែមទៀតថា :

«នៅក្នុងសំណុំនៃវិវត្តន៍ប្រវត្តិសង្គមបុរាណ ២៨០ គេឃើញនៅសល់សង្គមអរិយធម៌តែ ២១ប៉ុណ្ណោះ។ ហើយអរិយធម៌ទាំង ២១ ដែលនៅសល់នោះ, ក្នុងរយៈកាល ៦០០០ ឆ្នាំក៏ពន្យល់ទុកតែអរិយធម៌ ៦ ដែលមានជីវិតរស់រហូតមកដល់បច្ចុប្បន្នកាលនេះ ។

១៩១ - តើយើងយល់ថាអរិយធម៌ក្នុងលោកទាំងមូល សុទ្ធតែបង្ហាញខ្សែនភាព ឬវិវត្តន៍វិលចុះវិលឡើងទាំងអស់ដូចគ្នាឬយ៉ាងដូចម្តេច ? ចូរពន្យល់ ។

តាំងប្រវត្តិសាស្ត្របានបង្ហាញភាពអាប់អោន និងរុងរឿងរបស់ខ្លួនតាមរយៈស្ថាប័នសង្គមសេដ្ឋកិច្ចសិល្បៈ - ទស្សនវិជ្ជាសីលធម៌ - ច្បាប់បដិវត្តន៍ ។ល។ ដែលគេយកមកធ្វើជាភស្តុតាងនៃអរិយធម៌ ។ ពន្លឺនេះពេលខ្លះក៏ភ្លឺហើយរលត់ទៅវិញក៏មាន ឬ ក៏ភ្លឺហើយភ្លឺទៀតក៏មានខ្លះ ឬ ម្រាកទៀតរលត់ហើយរលត់ទៀត ក៏មានដែរ ។

ឧទាហរណ៍ៈ ប្រទេសបារាំងសម័យអធិរាជណាប៉ូឡេអុង-បូណាប៉ាត (NAPOEEON - BONAPATE) ពន្លឺអរិយធម៌បានបញ្ចេញរស្មីត្រចះត្រចង់ ។ លុះដល់អ្នកសម័យស្ដ្រាតឡោកលីកទី ២ ពន្លឺនោះក៏រលត់រស្មីទៅវិញ ដោយសារញុីបង់ចូលកាន់កាប់ក្រុងប៉ារីសទាំងមូល ។ មកដល់សម័យបច្ចុប្បន្នបារាំង ហើយមុខរបរពីភាពអាប់អោន, រហូតបានឈ្មោះជាប្រទេសមហាអំណាចមួយក្នុងលោក ។ បានសេចក្ដីថា ពន្លឺអរិយធម៌ ក្រោយពីរលត់ហើយក៏ភ្លឺ, ក្រោយពីភ្លឺបកក៏រលត់វិញ ។

ចុះបើយើងក្រឡេកមើលប្រទេសចាមវិញ, ក្រោយពីបានពន្លឺត្រចះត្រចង់នៅសតវត្សទី ១៣ រហូតបានចូលកាន់កាប់ក្រុង «អង្គរ» របស់ខ្មែរអស់មួយរយៈកាលនោះ, ឥឡូវនេះចាមបានបាត់រស្មីរហូត ពេលគឺចាមបានរលត់ទៅបាតិ ដោយគ្មានថ្ងៃ និង បញ្ចេញពន្លឺឡើងវិញបានឡើយ ព្រោះថា «ចាម» បានបាត់បង់ប្រទេសរបស់ខ្លួនទាំងមូលពីផែនដី ពិភពលោកទៅហើយ ។

ដូច្នេះ ទ្រឹស្ដីដែលពោលថាវិវត្តន៍ប្រវត្តិវិទ្យាបានវិលចុះឡើងគ្មានឈប់នោះ (les théories cycliques du devenir historique) ពុំសូវត្រូវទាំងអស់ទេ ។

ឧទាហរណ៍ : ទ្រឹស្ដីរបស់លោកសូរ៉ូគីន (la théorie des fluctuations selon Sorokin) ដែលបានពោលថា៖ «សារាចារណាអរិយធម៌របស់មនុស្សជាតិនៅលើលោកនេះ, សាបរលាប និងនាន បំលាស់ប្ដូរកើតកក់ដែលវិលវល់ ផ្ទុយគ្នារវាងសម្ពួរនិងប្រព័ន្ធវប្បធម៌បីយ៉ាងគឺ :

១-គំរូគំនិតគតិបញ្ញាញ (tybe idéationnel) ដែលត្រូវសង្កត់ទៅលើកុសល (Bien) ខ្ពស់ខ្ពស់ផុតពីផ្ទើ និងវិចារណញ្ញាណ, ហើយដែលមានចិត្តនឹងនំទៀងទាត់ ។

២-គំរូឥន្ទ្រិយារម្មណ៍និយម (type sensua'iste) ដែលសំអាងទៅលើគំនិតថា, គប្បីភាពពិតប្រាកដក្នុងឥន្ទ្រិយារម្មណ៍ ប្រកបដោយគំនិតពិសោធនិយមត្រេកត្រអាលនិយម (esprit empirempiristeste et hedonistique)

៣-គំរូកណ្ដាល គឺគំរូគំនិតនិយម (type idéaliste) ដែលឋិតនៅកណ្ដាលគំរូពីរខាងលើនេះ ។

* * *

# សង្គមវិទ្យា

(la sociologie)

**192-** នរណាបង្កើតសង្គមវិទ្យាមុនគេ?

លោកអូគុស្តកុង (Auguste Comte) ពាក់កណ្តាលសតវត្សទី១៩ បានបង្កើតសង្គមវិទ្យាមុនគេ ។

**193-** ដូច្នេះលោកអូគុស្តកុង តើ ឲ្យនិយមន័យទៅលើពាក្យសង្គមវិទ្យាថាយ៉ាងដូចម្តេច?

លោកអូគុស្តកុង បានអោយនិយមន័យទៅលើសង្គមវិទ្យាថា: "សាស្ត្រវិជ្ជមាននៃបាតុភូតសង្គម" (science positive des phénomènes Sociaux) ។

**194-** តាមពិតសង្គមវិទ្យាគឺអ្វី?

តាមពិតសង្គមវិទ្យា គឺ ការសិក្សាទូទៅពីសង្គមមនុស្ស ។

**195-** ដើម្បីសិក្សាសង្គមវិទ្យាអោយបានច្បាស់លាស់ តើមានវិជ្ជាអ្វីខ្លះ ដែលអ្នកប្រាជ្ញសម័យថ្មីកំពុងតែនាំគ្នាសិក្សាពីសង្គមមនុស្ស?

អ្នកប្រាជ្ញសម័យថ្មីបានសិក្សាសង្គមមនុស្សទាំងមូល តាមវិធីសាស្ត្រផ្សេងៗគ្នា ។ បច្ចុប្បន្ននេះ ជាមួយនឹងការសិក្សាពីមនុស្សវិទ្យា, គេបានរកឃើញវិជ្ជាពីរទៀត ដែលអ្នកប្រាជ្ញសម័យថ្មីកំពុងយកចិត្តទុកដាក់ជាងគេ គឺ អេត្នូវិទ្យា (ethnologie) និងអេត្នូសាស្ត្រ (ethnographie) ។

196- អ្វីទៅហៅថា "ការណ៍សង្គម" (fait social) ?

ការណ៍សង្គម គឺ ជាលទ្ធផលនៃការរួមរស់ជាក្រុមរបស់មនុស្ស ឧទាហរណ៍ស្ថាប័ននានា (institution) ទំនៀម (mœurs) និងជំនឿរួម (croyances collectives)

197- អ្នកសង្គមវិទ្យាឈ្មោះ សឺត ដាវី (Georges-Davy) បានពោលថា "មនុស្សគឺជាសត្វដែលចេះរស់នៅក្នុងសង្គមផង និងជាសត្វដែលប្រកបដោយសភាវគតិនិយាមផង" ។ ចូរវែកញែកគំនិតរបស់អ្នកប្រាជ្ញខាងលើនេះតាមបែបសង្គមវិទ្យា?

ដើម្បីវែកញែកមតិរបស់លោកសឺត-ដាវី, គប្បីយើងយល់ន័យរបស់ពាក្យថា "សភាវៈនិយាម" សិន ។ សភាវនិយាម (Instinct de la règle) គឺ សភាវដែលមនុស្សគ្រប់រូបបានទទួលមកពី សង្គមដែលខ្លួនរស់នៅ ។ សភាវនោះបានបង្គាប់បញ្ជាមនុស្សឲ្យប្រតិបត្តិតាមស្ថាប័ន, ប្រពៃណី, ទំនៀមទំលាប់របស់សង្គមនោះ ។ មនុស្សដែលបានទទួលឥទ្ធិពលសង្គម ហើយតែងមានជាប់និងសភាវគតិកំណើត (instinct natif) របស់ខ្លួនទូរសភាវយ៉ាងដែលគេហៅថា "សភាវគតិនិយាម" នេះឯងជាចាំបាច់ ។

អ្នកសង្គមវិទ្យាជាច្រើនបាននាំគ្នាពិគ្រោះព្រមទាំងបញ្ចេញយោបល់គ្នាថា, ជីវិតនៅក្នុងបានកើតឡើងពីសភាវគតិដែលគេ

ហៅថា "សភាវគតិសង្គម" (instinct social) ពិតមែន ឬទេ?

តែចំណោទដូចខាងលើ ពុំស្គាល់នូវដំណោះស្រាយជាទីផ្ទ-ទាំងអស់គេទាំងឡាយនោះ ។ គេបានសង្កេតឃើញថាដំបូងមនុស្សទាំងឡាយតែងរស់នៅដាច់ឡែកតែឯង ឬក៏រស់នៅជាក្រុមពុំសូវមានវិន័យតាមទីកន្លែងនីមួយៗក្នុងពិភពលោក (les hommes vivent à l'état de hordes) ។ មនុស្សទាំងនោះពុំមានការអប់រំតាមបែបសង្គមកិច្ចដែលប្រកបដោយរចនាសម្ពន្ធត្រឹមត្រូវឡើយ ។ លោក "លេវីស្ត្រុះ" (Lévi Strauss) ពោលថា: "មនុស្សលោកមានលក្ខណៈមួយបែបដែលការណ៍សង្គមផ្តល់អោយ , គឺសិទ្ធិលេបខ្បួនមិនដែលប្រែប្រួលដោយពិធីយាមត្រឹមត្រូវ, ជាទំនៀម ឬ បែបបទដែលជាគ្រឿងបន្ថែមលើលក្ខណពីកំណើតរបស់ខ្លួន ។

គំនិតរបស់លោកឡេវីស្ត្រុះ បានឆ្លើយស្របនឹងមតិលោកសិកសាវិគ្រង់វគ្គទី២ ។ ចំណែកលោកប៊ែរសុន (Bergson) បានពោលថា "មនុស្សពុំមែនដូចជាសត្វដែលមានសភាវគតិសម្រាប់តែគ្រាប់តាមគេនោះឡើយ ។ តែមនុស្សជាសត្វដែលមានបញ្ញា ។ ហើយនៅពេលដែលយើងសង្គ្រប់បញ្ហាយ៉ាងច្បាស់របស់គេនិងពិចារណាពីកំណើតនោះ គឺ ជាច្បាប់ទំលាប់ ឬការណ៍នៃសង្គមទាំងឡាយដែលគេហៅថា "ភារកិច្ច" (obligation) ដែលបង្ខិតបង្ខំគេអោយអនុវត្តតាមយ៉ាងដាច់

ណាក់ ។ ដូច្នេះមនុស្សក្នុងក្រុមនីមួយៗមានសការគតិសង្គម ដោយឡែកពីគ្នា ខុសនឹងសត្វដែលមានអាកប្បកិរិយាតែមួយ ដដែលដូចគ្នាទាំងអស់ ។ ឧទាហរណ៍ : សត្វឃ្មុំគ្រប់សំបុកសុទ្ធតែមានអាកប្បកិរិយាដូចគ្នាទាំងអស់ រីឯមនុស្ស នៅក្នុងសង្គមផ្សេងគ្នាមានអាកប្បកិរិយាក៏ផ្សេងគ្នាដែរ ។

និក្ខេបបទពេលនេះ បានអោយលោកប៊ែរសុនសន្និដ្ឋានថា : ដោយសារតែទទួលឥទ្ធិពលមួយពីសង្គមរបស់ខ្លួននេះហើយ បានជាមនុស្សខុសនឹងសត្វ ។ ហើយវត្ថុដែលធ្វើមនុស្សអោយខុសនឹងសត្វនោះគឺ "កាតព្វកិច្ច" (obligation) នៃសង្គមនោះឯង ។

ដូច្នេះយើងឃើញថា សង្គមមានឥទ្ធិពលទៅលើមនុស្សយ៉ាងខ្លាំង ។ សង្គមកែច្នៃបញ្ញានៃសការគតិកំណើតរបស់មនុស្ស ហើយមានច្បាប់សំរាប់បង្ខិតបង្ខំមនុស្សអោយគោរពតាមបទបញ្ជារបស់ខ្លួនពុំអាចប្រកែកបាន ។ ដោយសង្គមមានឥទ្ធិពលយ៉ាងខ្លាំងទៅលើមនុស្ស ដូច្នេះហើយបានជាលោករូសូ (J.J.Rousseau) ពោលថា : "មនុស្សកើតមកសុទ្ធតែល្អទាំងអស់ ប៉ុន្តែសង្គមទៅវិញទេ ដែលធ្វើអោយមនុស្សខូចឈ្លើយ" ។

198- អ្វីទៅហៅថាសង្គមចិត្តវិទ្យា ?

សង្គមចិត្តវិទ្យា គឺការសិក្សាស្រាវជ្រាវពីអាកប្បកិរិយារបស់បុគ្គលម្នាក់ដែលរស់នៅក្នុងសង្គម ( Etu e du comportement de l' ndisi u vivent ans une société) ។

100

គឺជាការស្វែងរកសកម្មភាពនិងទង្វើ របស់បុគ្គលក្រោយដែលបានទទួលឥទ្ធិពលពីការណ៍សង្គម (fait social) រួចហើយ ។

199- អ្វីទៅហៅថាសង្គមវិទ្យាវត្ថុវិស័យ ?

(Qu'est ce que la Sociologie objective ?)

ដែលហៅថាសង្គមវិទ្យាវត្ថុវិស័យ , គឺសង្គមវិទ្យាដែលចាត់ការណ៍សង្គមជាមានលក្ខណៈដូចជាការណ៍ធម្មជាតិដែរ ។ ឧទាហរណ៍ៈ អ្នកសង្គមវិទ្យាម្នាក់បានស្រាវជ្រាវការណ៍សង្គមនៅលើកោះមួយដាច់ស្រយាលដើម្បីធ្វើ (these) របស់ខ្លួន ។ អ្នកសង្គមវិទ្យានោះបានសិក្សាការណ៍សង្គម នៃប្រជាជននៅលើកោះនោះដោយគ្មានស្វែងរកឫសគល់ ដោយគុះធ្លាយ ឬក៏ធ្វើវិភាគផ្សេងៗ ពីការណ៍និមួយៗរបស់សង្គមនោះឡើយ ។ អ្នកសង្គមវិទ្យានោះគ្រាន់តែកត់ត្រាពីព្រឹត្តការណ៍ ដែលធ្លាប់ឃើញកើតឡើងៗ ដូចជា (សិក្សាពីរបៀបសម្ពន្ធក្នុងសង្គម, របៀបរស់នៅរបស់ប្រជាជននោះ, ការបរិភោគ, ការចិញ្ចឹមសត្វ, អាពាហ៍ពិពាហ៍, មរណៈភាព ។ល។)

200- អ្វីទៅហៅថាសង្គមវិទ្យាពន្យល់ ?

(Qu'est ce que la sociologie explicative?)

សង្គមវិទ្យាពន្យល់ គឺសង្គមវិទ្យាណាដែលពន្យល់វែកញែក, ធ្វើវិភាគការណ៍ក្នុងសង្គមនិមួយៗ ដោយប្រៀបធៀបការណ៍សង្គមមួយទៅនឹងការណ៍សង្គមមួយទៀត ។ ចំពោះអោយកើតសិក្សាអត្ថសាស្ត្រ (Ethnographie) និងអត្ថវិទ្យា (Ethnologie) ។

**201-** តើអ្វីទៅហៅថាអេត្នូវិទ្យា ?

Qu'est-ce que l'Ethnologie ?

គឺការសិក្សាពីព្រឹត្តការណ៍ របស់សង្គមមនុស្សដោយធ្វើសំយោគទៅលើលក្ខណៈផ្សេងៗ នៃការណ៍សង្គមនោះមកពិចារណាពិនិត្យបញ្ជាក់ក្នុងគោលបំណង រិះរកវិវឌ្ឍន៍របស់សង្គមមនុស្សនោះ ។

**202-** តើអ្វីទៅហៅថាអេត្នូសាស្ត្រ ?

Qu'est-ce que l'Ethnographie ?

គឺការសិក្សាពីព្រឹត្តការណ៍របស់សង្គម មនុស្សដោយធ្វើវិភាគការណ៍របស់សង្គមនោះ ក្នុងគោលបំណងរិះរកវិវឌ្ឍន៍របស់មនុស្សនោះ ។

**203-** តើបើអេត្នូវិទ្យា និង អេត្នូសាស្ត្រ បានសិក្សាពីព្រឹត្តការណ៍របស់មនុស្សក្នុងសង្គមដូចគ្នា តើវិជ្ជាទាំងពីរនេះមានលក្ខណៈខុសគ្នាយ៉ាងដូចម្ដេចខ្លះ ?

អេត្នូសាស្ត្រនិងអេត្នូវិទ្យា ជាវិជ្ជាដែលសិក្សាពីព្រឹត្តការណ៍របស់មនុស្សក្នុងសង្គមនីមួយៗ ប្រកបដោយលក្ខណៈស្រដៀងគ្នាក៏ពិតមែនហើយ, តែគួរយើង បញ្ជាក់ថាវិជ្ជាទាំងពីរនេះមានលក្ខណៈពីរខុសគ្នាគឺ :

១- អេត្នូវិទ្យាជាសាស្ត្រសំយោគ ចំណែកឯ

២- អេត្នូសាស្ត្រជាសាស្ត្រវិភាគ ។

(L'Ethoologie est essentiellement une science

de synthèse et l'Ethnographie une science d'analyse)

204- តើការណ៍សង្គមមានលក្ខណៈសំខាន់អ្វីខ្លះ ដែលគួរកត់សំគាល់ ?

ការណ៍សង្គមមានលក្ខណៈសំខាន់ពីរ ដែលគួរកត់សំគាល់គឺ:

១- លក្ខណៈរួម (fait collectif)

២- លក្ខណៈបង្ខាប់បង្ខំ (fait coercitif)

205- តើការណ៍សង្គមណាខ្លះដែលមានលក្ខណៈរួម ? ចូរលើកឧទាហរណ៍មកបង្ហាញ ?

ការណ៍សង្គមដែលមានលក្ខណៈរួមគឺ ការណ៍ផ្សេងៗរបស់សង្គម, ដែលមនុស្សតាមរូបរួមគ្នាអនុវត្ត ដោយឥតខ្វល់ការបង្ខិតបង្ខំពីច្បាប់ទំលាប់អ្វីមួយឡើយ ។ ឧទាហរណ៍ : មាតាហ៍ពិតាហ៍ - ភាសា - ទំនៀមទំលាប់ ។ល។

206- តើការណ៍សង្គមណាខ្លះ ដែលមានលក្ខណៈបង្ខាប់បង្ខំ ?

ការណ៍សង្គមដែលមានលក្ខណៈបង្ខាប់បង្ខំ គឺការណ៍ប្រកបដោយរបៀប និងច្បាប់របស់សង្គមនោះហើយ ការណ៍សង្គមនេះតែងមានសភាពជាវិធានការវិនិច្ឆ័យផង (Sanction) ។ ឧទាហរណ៍ : វិន័យ និងច្បាប់របស់សង្គមនីមួយៗ ជាការបង្ខិតបង្ខំរបស់សង្គម ។

207- អ្វីទៅហៅថាសង្គមវិទ្យាប្រធានវិស័យ ?

(Qu' est-ce que la sociologie subjective ?)

ដែលហៅថាសង្គមវិទ្យាប្រធានវិស័យ គឺសង្គមវិទ្យាដែលគេបានស្រង់រូបមន្តរបស់វាពីប្រធានទាំងឡាយ ពោលគឺបុគ្គលដែលធ្លាប់បានស្គាល់ និង ធ្លាប់បានរស់នៅក្នុងសង្គមនោះ

208- អ្វីទៅហៅថាសង្គមវិទ្យាយល់ ?

(qu' est-ce que la sociologie compréhensive?)

ដែលហៅថាសង្គមវិទ្យាយល់ គឺសង្គមវិទ្យា ដែលប្រកបដោយការណ៍របស់ខ្លួនមានលក្ខណៈរូបី ។ ម្យ៉ាងទៀតក្រឹត្យការណ៍ទាំងអស់នៃសង្គមវិទ្យាយល់ ពុំបានទំនាស់ការណ៍របស់ខ្លួនទេ, តែញុំងអោយគេយល់ការណ៍របស់ខ្លួនទៅវិញ ។ ឧទាហរណ៍ ៖ គ្រួសារដែលរស់នៅលើកោះមួយនៅនូវែល-គីណេ (Nouvelle-Guinee) សុទ្ធតែយកបងប្អូនជនជាប្ដីប្រពន្ធទាំងអស់ ។ ហេតុអ្វី? គេអាចយល់បានដោយពុំបាច់ពន្យល់ថា កុលសម្ព័ន្ធតូចនេះ គ្មានឥទ្ធិពលអ្វីចំណុចមួយធំទៅតស៊ូសង្គមរបស់គេឡើយ ។ ពួកគេរស់នៅតាមបែបមនុស្សបុរេប្រវត្តិ ។

កាលណាគេធ្វើតារាងពង្សាវលី (généalogie) គឺដោយតម្រៀបតាមត្រកូលទាំងនោះ, គេគិតបានឃើញច្បាស់ដោយពុំមានពន្យល់ឡើយ ។

209- ហេតុអ្វីបានជាគេពោលថា សង្គមវិទ្យានិងប្រវត្តិ-
វិទ្យាមានកម្មវត្ថុខុសគ្នា ?

តាមតានេះគេឃើញថា សង្គមវិទ្យានិងប្រវត្តិវិទ្យាមានកម្មវត្ថុខុស
គ្នា ព្រោះប្រវត្តិវិទ្យាសិក្សាពីអ្វីដែលមានលក្ខណៈជាបុគ្គល
ពីព្រឹត្តិការណ៍ពិសេសមួយ ។ ចំណែកសង្គមវិទ្យាវិញ ពីអ្វី
ដែលមានលក្ខណៈទូទៅ ពីច្បាប់សកល ។

210 តើសង្គមវិទ្យាមានមុខងារអ្វីខ្លះ ?

មុខងាររបស់សង្គមវិទ្យាមានច្រើនណាស់ ព្រោះជាវិទ្យា
ដែលសិក្សាពីសង្គមមនុស្ស ។ ដូច្នេះព្រឹត្តិការណ៍ទាំងឡាយ
របស់មនុស្ស ដែលប្រកបដោយការណ៍ពិសេស ត្រូវតែជា
កម្មវត្ថុនៃការសិក្សានៃសង្គមវិទ្យាទាំងអស់ ។ ក្រៅពីនេះ គេ
មានការណ៍ផ្សេងៗដែលជាភារៈរបស់សង្គមវិទ្យាដែរ គឺការ
ចំណុចប្រាប់ពីកំណើតនិងវិវត្តន៍នៃសង្គមមនុស្ស ។ រួចមកនៃ
សង្គមប្រៀបធៀបបានត្រូវអ្នកជាតិទេសខាងពន្ធុវិទ្យា និង
ពន្ធុសាស្ត្រ (Ethnologie et Ethnographie) ក៏រក
អរិយធម៌ ឬក៏ហិនវាយនិងស្ថានត្រូវផល់សង្គមមនុស្ស ពី
អតីតកាលរហូតដល់បច្ចុប្បន្នកាល ។
ឧទាហរណ៍ : សង្គមវិទ្យាបានប្រាប់យើងអោយមើលឃើញ
បញ្ហា ឬ បញ្ហាមនុស្ស ពីសម័យបុរេប្រវត្តិ អាស្រ័យការសិក្សា
សង្គមវិទ្យានៅលើកោះមួយនៃប្រទេសនូវែលហ្គីណេ
(Nouvelle Guinée) ។

211 អ្វីទៅហៅថា ចិត្តវិទ្យា ?

ចិត្តវិទ្យាគឺ « សាស្ត្រនៃចិត្ត » ពោល គឺវិទ្យាដែលសិក្សាពីចិត្ត ។

212- តើការសិក្សាពីចិត្តវិទ្យា ត្រូវពឹងផ្អែកទៅលើវិជ្ជាណាខ្លះ ដើម្បីឲ្យការសិក្សានោះបានប្រាកដនិយម ហេតុអ្វី ?

គេត្រូវពឹងផ្អែកទៅលើបរមត្ថវិជ្ជា ( Métaphysique ) ជាចាំបាច់ ដើម្បីគេប្រាកដនិយមក្នុងចិត្តវិទ្យា ។ ព្រោះថា, បរមត្ថវិជ្ជាមានភារៈពន្យល់សញ្ញាណចិត្ត និង សញ្ញាណវិញ្ញាណក្ខន្ធ ដើម្បីតាមរកប្រភពកំណើតនិងវាសនានៃចិត្ត ។

213- អ្នកប្រាជ្ញឈ្មោះអ្វីបានចែកចិត្តវិទ្យាជាពីរបែប? តើអ្វីខ្លះ?

អ្នកប្រាជ្ញឈ្មោះវ៉ុល (Wolf) នៅសតវត្សទី១៨ បានចែកចិត្តវិទ្យាជាពីរបែបគឺ ៖

១ - ចិត្តវិទ្យាវិចារណញ្ញាណ (Psychologie rationnelle)

២ - ចិត្តវិទ្យាពិសោធ (Psychologie. empirique)

214- អ្វីទៅហៅថាចិត្តវិទ្យាវិចារណញ្ញាណ ?

ដែលហៅថាចិត្តវិទ្យាវិចារណញ្ញាណ គឺចិត្តវិទ្យាដែលផ្តល់រូបមន្តរបស់ខ្លួនពីការវិនិច្ឆ័យនៃវិចារណញ្ញាណ ( jugement de la raison ) ជាចិត្តវិទ្យាដែលបដិសេធគំហើញដែលបានមកពីប្រភពផ្សេងៗដូចជាផ្តល់ដោយពិសោធន៍, ឬផ្តល់ដោយសតិចលនាចិត្តឬប្រភពផ្សេងៗ ។ល។

215 អ្វីទៅហៅថាចិត្តវិទ្យាពិសោធ ?

ដែលហៅថាចិត្តវិទ្យាពិសោធគឺចិត្តវិទ្យាដែលយក «ការណ៍របស់ចិត្ត» មកធ្វើការតាមក្បួនវិធីពិនិត្យហេតុផលរបស់ចិត្ត ។

216- តើអ្នកប្រាជ្ញណាខ្លះ ដែលមានគំនិតយកចិត្តមកធ្វើវិភាគ ?

អ្នកប្រាជ្ញដែលយល់ថាវិទ្យាសាស្ត្រនៃចិត្ត ត្រូវតែយកចិត្តគេនោះ មកធ្វើវិភាគតាមបញ្ញាញាណរបស់ខ្លួនទៀត នោះគឺលោកម៉ែនដឺប៊ីរ៉ង់ (Maine de Biran) លោកប៊ែកសុន (Bergson) លោកជេម (James) លោកក្លូដ-លេវីស្ត្រូស (Claude Levi Strauss) ។ល។

217- ការសិក្សាពីចិត្ត ដោយប្រើវិធីពិនិត្យលើអាកប្បកិរិយា (comportement) របស់មនុស្សឬសត្វគេអោយឈ្មោះជាចិត្តវិទ្យាអ្វី ? ហើយវិធីពិនិត្យនោះមានចំនួនប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ការសិក្សាពីចិត្តដោយគ្រាន់តែពិនិត្យទៅលើអាកប្បកិរិយារបស់មនុស្សឬសត្វ, គេហៅថា « ចិត្តវិទ្យាអាកប្បកិរិយា » (Psychologie du comportement) ។ វិធីពិនិត្យនោះមានពីរយ៉ាងគឺ :

១- ពិនិត្យទៅលើប្រធានរបស់ការណ៍ចិត្តដែលគេហៅថាវិធី «ប្រធានវិស័យ» (méthode Subjective) ។

២- ពិនិត្យទៅលើវត្ថុរបស់ការណ៍ចិត្ត ដែលគេហៅថា វិធី «វត្ថុវិស័យ» (méthode objective)

218- អ្វីទៅហៅថាការណ៍ចិត្ត ? ( fait psychique )

ការណ៍ចិត្ត គឺអ្វីដែលធ្វើអោយយើងដឹង សភាពខាងក្នុងនៃចិត្តដូចជាសវេទនា( sentiment ), ការរំភើប( émotion

ចំណង់ (passion) ។ល។ ដែលគេហៅថា "ញាណរបស់ចិត្ត" ។ គេអាចហៅថា "ការណ៍នៃអាកប្បកិរិយា" ក៏បាន ព្រោះវាបង្ហាញអាកប្បកិរិយាទេ គេឃើញការណ៍ចិត្តទាំងពេញលេញ ។ ខ្លួនការណ៍នេះមានន័យអត្ថន័យ "ការណ៍ចិត្ត" ថា: - ជាសំណុំប្រតិកម្មភាវៈរស់ (être vivant)"

219- តើការបំបែកការណ៍របស់ចិត្ត មកពិនិត្យគឺជាមុខវិជ្ជាមួយ, តើវិជ្ជានោះឈ្មោះអ្វី ?

ការបំបែកការណ៍របស់ចិត្តមកពិនិត្យ និងពិចារណាការហេតុនិងផល គេហៅថា "ចិត្តវិភាគវិទ្យា" (Psychanalyse) ។

220- ហេតុអ្វី គឺមនុស្សអាចយកការណ៍របស់ចិត្តមកធ្វើវិភាគរកហេតុផលឃើញ ?

បានជាមនុស្សអាចយកការណ៍របស់ចិត្តមកធ្វើវិភាគបាន ព្រោះមនុស្សមានសតិស្មារតី និងវិចារណញ្ញាណ ។

221- តើវិធីពិនិត្យនិងពិសោធចិត្តវិទ្យាមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

វិធីពិនិត្យ និងពិសោធចិត្តវិទ្យាមានបីយ៉ាងគឺ :

១ - វិធីប្រធានវិស័យ ឬ ចិត្តវិទ្យា "ឧត្តមបុរិសៈ"
(la méthode subjective ou la psychologie en «1ère personne»)

២- វិធីវត្ថុវិស័យ ឬចិត្តវិទ្យា "បឋមបុរិសៈ"
(la méthode objective ou la psychologie en «3ème personne»)

108 ៣ - វិធីអន្តរប្រធានវិស័យ ឬចិត្តវិទ្យា "មជ្ឈិមបុរិសៈ"

(la méthode inter-subjective ou pychologie en «2e personne»)

**222-** អ្វីហៅថា "វិធីប្រធានវិស័យ" ក្នុងចិត្តវិទ្យា ?

ដែលហៅថាវិធីប្រធានវិស័យក្នុងចិត្តវិទ្យា គឺការស្វែងរកហេតុផលរបស់ចិត្តដោយយកចិត្តរបស់ខ្លួនឯងមកធ្វើជាប្រធានក្នុងការពិចារណា ។

**223-** អ្វីទៅហៅថា "វិធីវត្ថុវិស័យឬចិត្តវិទ្យាបឋមបុរិស:"?

ដែលហៅថា "វិធីវត្ថុវិស័យ ឬចិត្តវិទ្យា បឋមបុរិស:" គឺការពិចារណា[illegible]ហេតុផលនៃចិត្តដោយយក "វត្ថុផ្សេងៗ" ជាគ្រឿងពិចារណា ។ វត្ថុជាគ្រឿងពិចារណានោះគឺ : ឧទាហរណ៍ : ឯកសារ អក្សរសិល្ប៍, ការដោះស្រាយរបស់ជីវិតដែលមានលក្ខណៈជាសំដីឬអក្សររបស់អ្នកប្រាជ្ញ[illegible] ចិត្តខ្លួនជាចំលើយចំពោះសំណួរផ្សេងៗ ដែលជាវត្ថុ[illegible] គឺការណ៍របស់ចិត្ត ។

**224-** អ្វីទៅហៅថា "អន្តរប្រធានវិស័យឬចិត្តវិទ្យា ទុតិយបុរិស:" ?

ដែលហៅថា "អន្តរប្រធានវិស័យ, ឬចិត្តវិទ្យាទុតិយបុរិស:" គឺការពិចារណារកហេតុផលនៃចិត្តអ្នកដទៃ ដោយពិនិត្យ[illegible] ជាមួយអ្នកដទៃដូចជា ស្នេហា, មិត្តភាព, សមានចិត្ត ។ល។ ហើយនៅពេលនោះគេត្រូវសកយកការណ៍ នៃចិត្ត[illegible] នោះមកពិចារណាតែម្តង ។

* *

# ១០- ទំនោរនៃធម្មជាតិមនុស្ស

(tendance de la nature humaine)

**225**- អ្វីទៅហៅថាទំនោរ ?

ទំនោរ គឺការទោរទន់ទៅរកវត្ថុពិតណាមួយប្រកបដោយ បំណងនិងទិសត្រឹមត្រូវ ។ ឧទាហរណ៍ ការចាប់អារម្មណ៍ របស់បុគ្គលម្នាក់ចំពោះ សក្ការៈ, ការតណ្ហា, វិភាគបញ្ញា ដ៏ណាមួយ សឹងជាពិធីគួរបែងចំណូលចិត្ត, ចំណង់អារម្មណ៍ ។ វេលាណាអារម្មណ៍នោះឯងវាជាប់ទាក់ទងនឹងវត្ថុ: កើតកើត មានរូបភាពនៃគំនិតច្បាស់លាស់ ដែលបញ្ជាក់ថានេះហើយ “ជាទំនោរ” ។ ទំនោរនេះបញ្ចេញរូបច្បាស់ការណ៍ណាមានច្បាស់ កិរិយាទាំងក្រៅឆ្ពោះចេញមកដោយខ្ជាប់ខ្ជួន ។

**226**- តាមពិតទំនោរនៃមនុស្សចែកជាប៉ុន្មានគន្លងធំៗ គឺអ្វីខ្លះ?

តាមពិតទំនោរនៃមនុស្សចែកចេញជាធំៗគឺ :

១- ទំនោរ សរីរាង្គ (tendance organique)

២- ទំនោរអន្តរបុគ្គល (tendance inter-individuelle)

៣- ទំនោរសង្គម (tendance sociale)

៤- ទំនោរឧត្តមគតិ (tendance idéale)

៥- ទំនោរ ផ្ទាល់ខ្លួន (tendance personnelle)

**227**- អ្វីទៅហៅថា ទំនោរសរីរាង្គ ?

ដែលហៅថាទំនោរសរីរាង្គ គឺ ទំនោរទាំងឡាយ ដែល កើតឡើងពីសរីរាង្គរបស់មនុស្សផ្ទាល់ ។

**228** - តើទំនោរសរីរាង្គរបស់មនុស្ស ខុសនិងទំនោរសរីរាង្គរបស់សត្វដូចម្ដេចខ្លះ ?

ទំនោរសរីរាង្គរបស់សត្វ និងមនុស្ស ខុសគ្នាត្រង់សរីរាង្គមនុស្សខុសនិងសរីរាង្គសត្វ, ហើយម្យ៉ាងទៀតទំនោររបស់មនុស្សមានលាយឥទ្ធិពលរបស់សង្គម ។

**229** - តើការស្រេកឃ្លានអាហារ សំរាប់គាំពារជីវិតអាចផ្ដល់នូវទំនោរដាក់លាក់សំរាប់មនុស្សនិងសត្វឬទេ ? ចូរពន្យល់ ។

ការស្រេកឃ្លានរបស់មនុស្ស ឬ សត្វទៅលើអាហារ ជាទំនោរដាក់លាក់ ប៉ុន្តែមានលក្ខណៈខុសគ្នា ។ ទំនោរមនុស្សទទួលឥទ្ធិពលសង្គម ដែលគេជឿថាមានលក្ខណៈសំខាន់បីគឺ ៖

១ - លក្ខណៈសង្គមកម្ម (socialisation)

២ - លក្ខណៈស្មុគស្មាញ (complication)

៣ - លក្ខណៈចិត្តកម្ម (spiritualisation)

ដល់ទំនោរសត្វគឺ តម្រិះយារម្មណ៍ឃ្លាន និងចំណាប់សុទ្ធសាធ ។

អ្វីទៅហៅថាទំនោរ អន្តរបុគ្គល ?

(tendance inter- individuelle)

ដែលហៅថាទំនោរអន្តរបុគ្គល គឺទំនោរដែលកើតឡើងពីទំនាក់ទំនងរវាងញាណរបស់បុគ្គលផ្សេងៗ ទៅនឹងញាណរបស់ជនដទៃ ។

231 - ហេតុអ្វីក៏មនុស្សមានទំនោរដែលគេហៅថា «អត្តបុគ្គល» នេះ?

មនុស្សមានទំនោរអត្តបុគ្គល ព្រោះមនុស្សមានទំនោរដែលមានលក្ខណៈផ្សេងៗគ្នានៅក្នុងសរីរាង្គរបស់ខ្លួន ។

232 - តើទំនោរមានលក្ខណៈប្លែកៗ ដែលនាំឲ្យមនុស្សមានទំនោរហៅថា «អត្តបុគ្គល» នោះគឺអ្វីខ្លះ?

ទំនោរផ្សេងៗ ខាងក្រោម ដែលនាំឲ្យមនុស្សមានទំនោរអត្តបុគ្គលគឺ :

១ - សភាវគតិហ្វូងនិងសហានុចិត្តឆ្លង ។
(instinct grégaire et sympathic -contagion).

២ - សភាវគតិដែលកើត ដែលមនុស្សតាមទទួលពីម្ដាយរបស់ខ្លួន ។ (instinct maternel)

៣ - សហានុចិត្តរួមគ្នារបស់មនុស្ស ។ (sympathie communion)

៤ - ទំនោរបរត្ថភាព (tendance altruiste)

៥ - ទំនោរអត្តទត្ថភាព (tendance égoïste)

233 - អ្វីទៅហៅថាទំនោរសង្គម ?

(Tendance sociale)

ដែលហៅថាទំនោរសង្គម គឺទំនោរដែលកើតចេញពីកំណើតនៃមនុស្សជាតិរបស់មនុស្ស គឺកើតមានដែលកើតមានឡើងក្រោយពេលដែលមនុស្សនោះ បានរួមរស់ជាមួយគ្រួសារ និងមាតុប្រទេសរបស់ខ្លួន រស់ពេលក្មេង ។

**234-** អ្វីទៅហៅថាទំនោរឧត្តមគតិ ?

(Tendance idéale)

ដែលហៅថាទំនោរឧត្តមគតិ គឺទំនោរដែលកើតឡើងពីកំលាំងចិត្តរបស់មនុស្ស ក្រោយពីបានផ្ចង់ទៅលើគំនិតផ្សេងៗរបស់អ្នកដទៃ ។

**235-** តើកំលាំងអ្វីខ្លះ ដែលញុំាងមនុស្សអោយមានទំនោរឧត្តមគតិ ?

កំលាំងដែលញុំាងមនុស្សអោយមានទំនោរឧត្តមគតិ គឺ :

១- កំលាំងសំវេទនាក្នុងសាសនា ។
(sentiment religieux)

២- កំលាំងសីលសំវេទនា ។
(sentiment moral)

៣- កំលាំងសំវេទនាសិល្បៈ ។
(sentiment esthétique)

៤- កំលាំងសំវេទនាបញ្ញា ។
(sentiment intellectuel)

**236-** អ្វីទៅហៅថាទំនោរផ្ទាល់ខ្លួន ?

(Tendance personnelle)

ដែលហៅថាទំនោរផ្ទាល់ខ្លួន គឺទំនោរដែលមានលក្ខណៈឯកត្តនិយម (individualisme) ឬអត្តទត្ថបុគ្គលនិយម ។

**237-** តើកំលាំងអ្វីខ្លះ ដែលញុំាងមនុស្សអោយមានទំនោរផ្ទាល់ខ្លួន ?

គំនិតដែលញុំាងមនុស្សអោយមានចរិតផ្ទាល់ខ្លួនពិសេស៤យ៉ាង

១- គំនិតដែលកើតពីសេចក្តីគោរពលើសេចក្តីថ្លៃថ្នូររបស់ខ្លួន

(dignité personnelle)

២- គំនិតដែលកើតពីតម្រូវការឯករាជ្យ ។

(besoin de l'indépendance)

៣- គំនិតដែលកើតពីអំណាចគ្រប់គ្រងត្រួតត្រា ។

(besoin de domination)

៤- គំនិតដែលកើតពីអស្មិមានះ ។

(Amour propre)

**238-** តើចំណេះសង្គមមានប្រយោជន៍យ៉ាងណាខ្លះ ចំពោះសង្គមជាតិ ?

ចំពោះសង្គមជាតិចំណេះសង្គមផ្តល់ប្រយោជន៍ដូចតទៅនេះ ៖

១- ជំរុញពលរដ្ឋអោយស្រលាញ់ស្រុកកំណើតរបស់ខ្លួន ។

២- បង្កើតគំនិតស្រលាញ់ប្រពៃណី, សីលជាតិរបស់ខ្លួន ។

៣- ជំរុញអ្នកស្នេហាមាតុប្រទេស អោយបង្កើតពលិកម្មយ៉ាងធំ ដើម្បីចំរើនការពារមាតុប្រទេស ។

៤- ចំណេះសង្គមអប់រំពលរដ្ឋ អោយមានទស្សនគតិជាតិច្បាស់លាស់ ។

៥- បង្កើតមនោគមវិជ្ជាជាតិ ដែលជាកត្តាបញ្ចូលគ្នាប្រមូលផ្តុំ

សរុបសេចក្តីចំណេះសង្គមអប់រំអោយស្គាល់ រូបជាតិ ។

*

* *

## ១១- ឆន្ទៈ

(La volonté)

**239**- អ្វីទៅហៅថាឆន្ទៈ ?

( Qu'est-ce que la volonté ?)

ឆន្ទៈគឺកំលាំងចិត្តដែលជំរុញអោយមនុស្សយើង ធ្វើសកម្មភាពផ្សេងៗ ប្រកបដោយការត្រិះរិះពិចារណា ។

**240**- អ្វីទៅហៅថា "អំពើរបស់ឆន្ទៈ ?"

ដែលហៅថាអំពើរបស់ឆន្ទៈគឺ "ចេតនារម្មណ៍" ដែលកើតឡើងពីការណ៍របស់ចិត្ត ។

**241**- តើគេអាចយកឆន្ទៈមកធ្វើវិភាគបានឬទេ ?

បើគេអាចទាញចិត្តមកធ្វើវិភាគបាន, គេក៏អាចទាញយកឆន្ទៈមកធ្វើវិភាគបានដែរ ។ ព្រោះថា "ឆន្ទៈ" ជាកំលាំងនៃ "ចិត្ត" ។

**242**- បើឲ្យធ្វើវិភាគទៅលើឆន្ទៈ តើគេត្រូវប្រើមធ្យោបាយអ្វីខ្លះ ?

បើឲ្យធ្វើវិភាគទៅលើឆន្ទៈ គេត្រូវប្រើមធ្យោបាយផ្សេងៗដូចតទៅនេះ :

១- ត្រូវពិនិត្យអោយបានហ្មត់ចត់ នូវអំពើដែលគេត្រូវធ្វើ ។ ហើយនៅពេលនោះ គេត្រូវការសាបរំពាច់នូវមុខការត្រៀមត្រូវរបស់ចក្ខុត្រៀម ។

២- ត្រូវប្រមូលយកហេតុការណ៍ផ្សេងៗ ឬមូលហេតុទាំងឡាយមកថ្លឹងប្រៀបធៀបមើល, តើបានផលល្អឬអាក្រក់ ?

៣- ត្រូវហ៊ានសំរេចកិច្ចការទាំងឡាយដោយកុំញញើតញញើរ ។

៤- ទីបំផុតត្រូវហ៊ានប្រតិបត្តិ (exécution) សេចក្ដីសំរេចនោះ ។

## 243- អ្វីទៅហៅថា "ធម្មជាតិ" នៃឆន្ទៈ ?

(Qu'est-ce qué la nature de la volonté?).

តាមទ្រឹស្ដីបញ្ញានិយម (théorie intellectualiste) "ឆន្ទៈជាបញ្ញា" ។ ឧទាហរណ៍ : គំនិតរបស់លោក ស្ពីណូសា (spinoza) ។

បើតាមទ្រឹស្ដីពិសោធនិយម (théorie empiriste) ឆន្ទៈជាចំណង់ ។ ឧទាហរណ៍: គំនិតរបស់លោក កុងឌីយ៉ាក់ (conillac) ។

បើតាមទ្រឹស្ដីបរមត្ថវិជ្ជា (théor e métaphysique) ឆន្ទៈជាសេរីភាពជា (libre arbitre) សំដៅយក "សំណោចនៃចិត្តដែលបានសំរេចរួចហើយ" ។

## 244- តើគេបានរកឃើញប្រភពរបស់ឆន្ទៈថាកើតមកពីអ្វី ?

ឆន្ទៈត្រូវអ្នកប្រាជ្ញពិចារណាផ្សេងៗ ជាច្រើនគំនិតលោកនី ម្នាក់អោយយោបល់ខុសគ្នាទាំងអស់ ។ លោកអ្នកប្រាជ្ញខ្លះ ពោលថា : "ឆន្ទៈ"កើតពី"សេរីភាព" ព្រោះថា"ឆន្ទៈ"មាន សេរីភាពអាចប្រព្រឹត្តទៅដោយគ្មានអ្វីបង្ខិតបង្ខំ រារាំងឬប្រៀត ប្រែកឡើយ ។ ចំណែកលោកអ្នកប្រាជ្ញដែលជឿទៅលើ "កំណត់និយម" (déterminisme) បានពោលថា ឆន្ទៈ

កើតពីកត្តាសរីរាង្គ ចំណេះវិជ្ជា ការអប់រំ ឬពេលវេលាឲ្យឃើញថា កើតពី «កត្តាសរីរៈបញ្ញា - ចិត្តនិងសង្គម» ។ តែបើតាមទ្រឹស្ដីវាសនានិយមគេយល់ថា : «ឆន្ទៈកើតមកពីវាសនាដែលជាម្ចាស់នៃអំពើរបស់មនុស្ស» ។

245- បើឆន្ទៈឋិតនៅក្នុងចិត្តរបស់មនុស្ស តើគេអាចបណ្ដុះឆន្ទៈបានឬទេ ? ដោយវិធីណាខ្លះ ?

ដោយឆន្ទៈឋិតនៅក្នុងចិត្តរបស់មនុស្ស បានជាគេយល់ថា «បើគេបណ្ដុះ ឬ កាច់ចិត្តបាន, គេក៏អាចបណ្ដុះ ឬ កាច់ឆន្ទៈបានដែរ» ។ ក៏ប៉ុន្តែដើម្បីពង្រឹងឆន្ទៈ, គេត្រូវពឹងផ្អែកទៅលើកត្តាផ្សេងៗដូចជា :

១- កត្តាសរីរាង្គ (facteur organique) ដែលគេតែងនិយាយថា «បើកាយមានសុខភាពល្អ បណ្ដាលមកពីផ្ទះសម្បែងនិងមានអាហារបរិបូរណ៍, មានសំលៀកគ្រប់គ្រាន់, នោះខួរក្បាលដែលជាគ្រឿងទ្រទ្រង់នៃឆន្ទៈ ក៏អាចមានលំនឹងហើយស្អាតល្អ» ។

២- កត្តាបញ្ញា (facteur intellectuel)

ដើម្បីឲ្យមានឆន្ទៈល្អ, យើងត្រូវចេះបណ្ដុះបញ្ញា ។ ការបណ្ដុះបញ្ញាអាស្រ័យសុខភាពនិងការអប់រំ ដូច្នេះបញ្ញាជាម នៃអ្នកដឹកនាំជាកត្តាសំខាន់របស់បញ្ញា សំរាប់បណ្ដុះឆន្ទៈ ។ ឧទាហរណ៍ : ការអានសៀវភៅបណ្ដាលឲ្យរីកបញ្ញា ។ ហើយការរីកបញ្ញាបណ្ដាលឲ្យកើតឆន្ទៈព្រោះសម្បូរណ៍ឧត្តមគតិ ។

៣- កត្តាសវេទនា (facteur du sentiment)

សេចក្តីការជាកំលាំងខ្លាំងបំផុត សំរាប់បង្កើតឆន្ទៈ ។ ការរក្សាសេចក្តីនោះអោយរឹងប៉ឹងព្រមទាំងប្រកបដោយគុណសម្បត្តិ ជាលំហាត់ម៉្យាងទៀតខាងរបស់មនុស្ស ។ ហើយការបន្សាត់បង់នូវគុណវិបត្តិទាំងឡាយរបស់ចិត្តជាការត្រៀមត្រង់ឆន្ទៈអោយមានលំនឹង ។

៤- កត្តាឧត្តមគតិសង្គម (facteur de l'idéal social)

ដោយយើងបានឃើញថា : «មនុស្សជាសត្វដែលរស់នៅក្នុងសង្គម» ទើបយើងដែលងចូលពីឥទ្ធិពលសង្គមដែលតែងសង្កត់មកលើមនុស្ស ។ ដូច្នេះសៀបង្កើតឆន្ទៈជាកុសលបានអាស្រ័យយើងទះពត់ឆន្ទៈ អោយបានចំពោះសង្គមនោះផងដែរ ។ បើពុំដូច្នោះយើងនឹងត្រូវសង្គមរារាំងមិនអោយឆន្ទៈនោះ ប្រព្រឹត្តទៅបានឡើយ ។

ឧទាហរណ៍ : លោក រូសូ (J.-J. Rousseau) បានបញ្ជាក់ឆន្ទៈផ្ទុយពីឧត្តមគតិសង្គម ។ ឆន្ទៈលោករូសូកើតមានខែតកំប៉ុន្តែប្រើបានតែចំពោះលើរូបរូសូម្នាក់ឯងប៉ុណ្ណោះ ។ ពោលគឺលោករូសូ បង្កើតឆន្ទៈអោយដើរខុសការនិយមនៃសង្គមដែលគាត់រស់ ។ ចំរៀតគេយល់ថា «ឆន្ទៈលោករូសូត្រូវនឹងឧត្តមគតិសង្គមបារាំងវិញ, ពីងលោករូសូដែលកប់លើកោះដើមស្រល (îles des peupliers) ចង់ល្វយទៅជាមួយរស់ ។ នេះហើយ ឆន្ទៈដែលពុំស្របទៅនឹងឧត្តមគតិសង្គម។

*

*  *

# ១២- តំលៃ-ករណីយកិច្ចនិងកុសល

(Valeur, Devoir et Bien)

246- អ្វីទៅហៅថាតំលៃ ?

(Qu'est-ce que la valeur ?)

តំលៃគឺអ្វីដែលគេនិយមចង់បានគ្រប់គ្នា ។

**តើសំរាប់មនុស្ស តំលៃស្ថិតនៅលើអ្វី ? ហើយមាន ប៉ុន្មានយ៉ាង?**

សំរាប់មនុស្ស តំលៃស្ថិតនៅលើរូបនិងជីវិត ពោលគឺបើមាន រូបឥតជីវិតក៏ឥតតំលៃ, បើមានជីវិតឥតរូប ក៏ឥតតំលៃ ។ តែ ជួនកាលគេយល់ថា: តំលៃរបស់មនុស្សស្ថិតនៅលើកាយនិង ចិត្តទៅវិញ ។ អាស្រ័យហេតុនេះហើយទើបយើងឃើញកើត ការតំលៃពីរយ៉ាងផ្សេងគ្នាគឺ :

១- តំលៃសម្ភារៈ ឬតំលៃសេដ្ឋកិច្ច

(Valeur matérielle ou économique)

២- តំលៃគំនិត ឬសីលតំលៃ ។

(Valeur spirituelle ou morale)

248- អ្វីទៅហៅថាតំលៃសម្ភារៈ ឬតំលៃសេដ្ឋកិច្ច ?

ដែលហៅថាតំលៃសម្ភារៈ ឬតំលៃសេដ្ឋកិច្ច គឺតំលៃដែល មនុស្សសំគាល់ទៅលើគ្រឿងប្រដាប់ប្រើប្រាស់ ដែលមាន លក្ខណៈជាសម្ភារៈ ឧទាហរណ៍ផ្ទះ ដែយន្ត វិទ្យុ ប្រាក់ ។ល។ ហើយសម្ភារៈទាំងនេះមានតំលៃជាគោលគ្រឿង ជាសម្បត្តិ របស់សង្គមមនុស្សដែលហៅថាសេដ្ឋកិច្ច ។

## 249- អ្វីទៅហៅថាតំលៃគំនិត ?

ដែលហៅថាតំលៃគំនិតគឺតំលៃនៃគំនិតរបស់មនុស្សសំរាប់ញុំាងអោយកើតសេចក្ដីសុខ សន្តិភាព វឌ្ឍនភាពនិងសុខមាលភាពដល់សង្គមមនុស្ស ។ ឧទាហរណ៍ : ស្នាដៃរបស់លោកអាល់ប៊ែរកាមុស (Albert CAMUS) មានតំលៃខាងផ្នែកគំនិតក្នុងការត្រួសត្រាយរកសន្តិភាព ដែលមានទៅក្នុងគុណសម្បត្តិមនុស្សជាតិ ។ ដូច្នេះស្នាដៃនេះត្រូវគេបានទទួលរង្វាន់ណូបែល (Prix NOBEL) ។

## 250- អ្វីទៅហៅថាសីលតំលៃ ?

ដែលហៅថាសីលតំលៃ គឺតំលៃដែលកើតមកពីអំពើល្អរបស់មនុស្សក្នុងការគិតនិងអនុវត្តន៍ ។ តែសីលតំលៃត្រូវមានលក្ខណៈសំខាន់ត្រឹមត្រូវខ្លះផងដែរ ដូចជា :

១- តំលៃដែលចេញពីចំណង់នៃបុគ្គលម្នាក់ៗ ។

ឧទាហរណ៍ : យើងចង់បានសន្តិភាពសេរីភាពនិងសុភមង្គល ហើយអ្នកដទៃក៏ចង់បានវត្ថុទាំងបីយ៉ាងនេះដែរ ទើបយើងសន្និដ្ឋានថា វត្ថុនោះមានតំលៃសីលវិជ្ជា បើយើងចង់បានវត្ថុទាំងបី ហើយអ្នកដទៃត្រឡប់ជាពុំចង់បាន យើងពុំអាចសន្និដ្ឋានបានទេថា «ជាសីលតំលៃបានឡើយ» ។

២- តំលៃដែលមានកំណើតពីធម្មជាតិ ដោយមនុស្សពុំអាចជៀសវាងនិងបំពេញបាន ។

ឧទាហរណ៍ : មាតាបិតាមានបុត្រនិងចិញ្ចឹមបីបាច់កូន កូនត្រូវតបគុណនិងចិញ្ចឹមលោកវិញ ។ នេះជាតំលៃទី២ ដែលមានលក្ខណៈជាសីលតំលៃ ។

៣ - តំលៃខាងច្បាប់ណាដែលមានគុណបំផុត ។

ឧទាហរណ៍ ៖ អ្នកដំណើរដើរទៅប្រទះខ្លាចាក់ជើងកណ្ដាលព្រៃ, ក៏មានចិត្តចង់ជួយសង្គ្រោះរកថ្នាំបិតជើងនិងជួយព្យាបាលរបួសជាពសះស្បើយ ។ ដល់ខ្លាជាជើង ខ្លាស៊ីគោនិងកូនប្រពន្ធអ្នកដំណើរនោះ ។ ការពិចារណារបស់អ្នកដំណើរត្រូវមានគិរ (គឺត្រូវជួយឬសំលាប់ខ្លា?) ។ ព្រោះថា «ជួយគឺជាតំលៃ», «សំលាប់គឺជាតំលៃ» ។ ហើយតំលៃដែលមានគុណបំផុតនេះហើយជា «លក្ខណៈទី៣របស់សីលតំលៃ» ។

៤ - ជាតំលៃដែលមានលក្ខណៈត្រឹមត្រូវចំពោះខ្លួនឯងផង ចំពោះផងដែរ និង សង្គមលោកទាំងមូលផង ។

ឧទាហរណ៍ ៖ គ្រាប់បែកបរមាណូ មានតំលៃសំរាប់បញ្ចប់សង្គ្រាមលោកលើកទីពីរ តែគ្មានតំលៃសំរាប់អ្នករងគ្រោះគឺជនជាតិជប៉ុន ។ តែការរកឃើញរូបមន្តនៃគ្រាប់បែកនេះគួរប្រទះសំគាល់ បញ្ឈប់សំគុះប្រើប្រាស់គ្រាប់បែកនេះនៅពេលគ្រោះថ្នាក់ ។ ព្រោះតំលៃរបស់វានៅត្រង់មនុស្សខ្លាចពុំហ៊ានយកមកប្រើប្រាស់សំរាប់ការធ្វើសង្គ្រាម ។ សីលតំលៃនេះប្រកបដោយកុសលផលអកុសលផង, តែមានលក្ខណៈពោតតម្លៃសំរាប់បញ្ជាក់នូវលក្ខណៈទី៤ គឺ «សីលតំលៃ» ។

## 251 - អ្វីទៅហៅថាករណីយកិច្ច ?

ករណីយកិច្ច គឺ «លក្ខណៈនៃអ្វីដែលត្រូវធ្វើកំណត់ចិត្តដោយសេរីរបស់មនុស្ស» ឬជាភាពចាំបាច់នៃការធ្វើដោយសេរី

គេឲ្យឈ្មោះបញ្ញាដាច់អហំការរបស់វិចារណញ្ញាណ, «កង់» (KANT) ។ ឬប្រើពាក្យដោយខ្លី លោកកំណត់បញ្ញត្តិថា «ករណីយកិច្ចជាបញ្ញាដាច់អហំការមួយ» ។
(un impératif catégorique)

252- ករណីយកិច្ចមានលក្ខណៈសំខាន់ៗអ្វីខ្លះ ?

ករណីយកិច្ចមានលក្ខណៈសំខាន់ៗដូចតទៅ :

១- ជាបញ្ញាឬសេចក្ដីបង្គាប់មួយ ។

២- ជាអតិរេកភាពនៃតំលៃ (transcendance de valeur)

៣: ជាសាកលកិច្ច ដែលបើកសេរីភាពអោយអ្នកប្រព្រឹត្ត គោរពឬពុំគោរពតាម ។

៤- ជាបញ្ញាដែលមានពិសោធន៍ក្នុងជីវិត ។

៥- ជាគំនិតសកល ។

៦- ជាគំនិតដែលគួរអោយធ្វើតាមបាន ។

253- ហេតុអ្វីគេហៅថាករណីយកិច្ចមានលក្ខណៈជាបញ្ញាដាច់អហំការ. តើការបង្ហាញនូវលក្ខណៈទាំងនេះនាំញុំាងយើងអោយពិចារណាទៅលើមុខវិជ្ជាប៉ុន្មានយ៉ាង ?

«ករណីយកិច្ចមានលក្ខណៈជាបញ្ញាដាច់អហំការ» នេះជាការយល់ឃើញរបស់លោកកង់ (KANT) ។ ដើម្បីស្វែងយល់បញ្ហានេះអោយច្បាស់ យើងត្រូវធ្វើការពិចារណាទៅលើមុខវិជ្ជាផ្សេងៗនៃការសិក្សាគឺ :

១. ទេវវិជ្ជា (théologie)

២. សង្គមវិទ្យា (sociologie)

៣. ទ្រឹស្តីវិចារណញាណនិយម (Rationalisme) ។ល។

254- តាមទេវនិយម តើគេយល់ឃើញថាករណីយកិច្ចជាបញ្ញា មានប្រភពផ្សេងយ៉ាងដូចម្តេចខ្លះ ? ចូរលើកឧទាហរណ៍មកពន្យល់ ។

អ្នកទេវនិយមតាំងពីបុរាណថា ករណីយកិច្ចជាបញ្ញារបស់ព្រះអាទិទេព ។ ពោលគឺគេយល់ថាមានទេពជាអ្នកបង្គាប់បញ្ជា, ជាអ្នកសាងព្រហ្មលិខិត និងវាសនាមនុស្ស ។ អំណាចទាំងឡាយដែលញុំងអោយយើងធ្វើតាមសំដីលោកនោះ, ឬក៏ដល់តំណាលនោះ អាស្រ័យតែលើទេពនោះឯង ។ ហេតុដូច្នេះហើយបានជាករណីយកិច្ច ដែលបានកើតចេញមកពីព្រះអាទិទេព ត្រូវតែមានប្រភពជាធាតុពិតវិញ ។ លក្ខណៈករណីយកិច្ច ទោះបីត្រូវបែងចែកជា កុសលក្តី អកុសល ក្តី ក៏សុទ្ធតែបានមកពីព្រះ ។ ឧទាហរណ៍ : អាទិទេពបានបង្កើត ម៉ូស៊េ (Moïse) មក ដើម្បីនាំយកដឹកនាំជនជាតិហេប្រឺ (Hébreux) ពីទាសភាព (esclavage) ពោលគឺទ្រង់ដឹកនាំជាតិហេប្រឺ (ជ្វីហ្វ) ពីអាណាខេត្តអេស៊ីប (អាហ្វ្រិក) ផង និងដើម្បីនាំជនជាតិដែលជាទាសករនោះ អោយបាន រស់នៅប្រកបដោយសុខដុម (ពីព្រះបញ្ញត្តិទាំងដប់) ។

យើងបានឃើញថា ករណីយកិច្ចរបស់ ម៉ូស៊ីស (Moïse) មានពីរយ៉ាងគឺ :

១-រំដោះជនជាតិហេប្រឺពីអេស៊ីប (អារ៉ាប)

២- នាំជនជាតិហេប្រឺអោយទទួលព្រះបន្ទូលទាំងដប់នៅភ្នំស៊ីណាអ៊ី (Si Naï)

ដូច្នេះម៉ូអ៊ីស មានករណីកិច្ចត្រូវបំពេញបញ្ហាទាក់ទងនឹង ដោយខានពុំបាន, ហើយបញ្ហា ឬករណីយកិច្ចរបស់ម៉ូអ៊ីស ខាងបញ្ហាផ្ទាល់អហំការ, ព្រោះថាលោកម៉ូអ៊ីសបានត្រូវព្រហ្មលិខិតអោយទៅបានជាកូនចិញ្ចឹមរបស់បុត្រស្រីស្ដេច ផ្ការ៉ាអុង (PHARAON) គ្គី, នោះម៉ូអ៊ីសបានធ្វើជាវិស្វករប្រកបដោយអំណាចដ៏លើសលប់ក្ដី ក៏ម៉ូអ៊ីសពុំបានបំភ្លេចឬចៀសរួចពីករណីយកិច្ចជា បញ្ហាផ្ទាល់អហំការនេះឡើយ ។

យើងឃើញថា ករណីកិច្ចបានម៉ូអ៊ីសអោយទៅរបស់ទៅល តំណាងហេតុផ្លាក់ខ្លួនថា អ្នកទោសជាប់ច្រវាក់ត្រូវអោយមាស្នេ ។ តើម៉ូអ៊ីសគេចៀសវាងបានឬទេ ? យើងឃើញថាលោកម៉ូអ៊ីសពុំចៀសវាងតែប្រះយ៉ាងណាក៏ដោយ ក៏ចៀសពុំរួចពីករណីយកិច្ច ដែលមានលក្ខណៈខាងបញ្ហាផ្ទាល់អហំការរបស់ព្រះអាទិទេពបានឡើយ ។ ទីបំផុតយើងឃើញថា ម៉ូអ៊ីសរួចបានដឹកនាំទាសទាំងអស់ហូតបានទៅដល់ទេសក៏ ដ៏ផ្ដើមក្នុងការនាំជនជាតិហេប្រឺ គឺទទួលនូវព្រះបន្ទូលទាំងដប់របស់ព្រះអាទិទេព ។ នេះហើយជាករណីយកិច្ចដែលមានលក្ខណៈខាងបញ្ហាផ្ទាល់អហំការ របស់ព្រះអាទិទេព ។

255 - ការបែបសម្ភាសនិយម, តើករណីយកិច្ចខាងបញ្ហានោះមានលក្ខណៈយ៉ាងដូចម្ដេច ? ចូរលើកឧទាហរណ៍មកបញ្ជាក់

តាមតែបសង្គមនិយម ករណីយកិច្ចគឺមានតែបទបញ្ញាតែរ ។ក
បទបញ្ញារបស់សង្គម ។ អ្នកប្រាជ្ញឈ្មោះ ឌួខែម (Durkheim)
យល់ថា :

«សីលញាណរបស់មនុស្សមានឥទ្ធិពលសង្គម , ហើយសីលញាណនេះជាផ្សែបញ្ញានៅក្នុងខ្លួនយើង»

តាមគំនិតខាងលើនេះ , យើងឃើញថា ឥទ្ធិពលសង្គមប្រាប់សីលញាណមនុស្សអោយគោរពនិងធ្វើតាមឧត្តមគតិមួយ គឺ «ឧត្តមគតិសង្គម» ។ ឧទាហរណ៍ : ដើម្បីអោយបានទៅជាចៅក្រមមួយរូបពេញលក្ខណៈច្បាប់ , ជនទាំងឡាយត្រូវតែតាមបញ្ញា ដែលមានលក្ខណៈជាច្បាប់របស់សង្គមខ្លួនពេញ គឺៈ ដូចជានៅប្រទេសខ្មែរគេត្រូវមានលក្ខណៈដូចតទៅនេះ :

១- ត្រូវជននោះមានសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទី ២។
២- ត្រូវសិក្សានៅមហាវិទ្យាល័យច្បាប់ចំនួនបួនឆ្នាំ ។
៣- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ។
៤- ត្រូវបានជ្រើសរើសអោយធ្វើជា «ស្នូមាត្យា» ហើយបំរើការក្នុងសាលាកាត់ក្តីជាច្រើនឆ្នាំ ឬយ៉ាងហោចណាស់ត្រូវបានសញ្ញាប័ត្រជាន់ខ្ពស់ខាងវេត្តាល ។
៥- ត្រូវបានសេចក្តីយល់ព្រមបញ្ជាក់ដោយក្រិត្យក្រមតុលាការ : រដ្ឋមន្ត្រី ។

ដូច្នេះមនុស្សទាំងឡាយ ទោះបីខ្លួនចេះប្រសព្វប្រសើរយ៉ាងណាក្តី បើពុំបានបំពេញល័ក្ខខ័ណ្ឌដូចខាងលើនេះទេ , ពុំអាចនៅជាចៅក្រមពេញលក្ខណៈច្បាប់បានឡើយ ។ ឃើញថាសង្គមបានគុណតែលប់ធ្វើជាចៅក្រម អោយបំពេញករណីយកិច្ច

ខាងបញ្ញាខាងមនោការរបស់សត្វលោកលើបុគ្គល ។

256- សំនួរដែលថា: ករណីយកិច្ច ដែលខាងបញ្ញាខាងមនោការអាចប្រកបមកពីវិចារណញ្ញាណផងដែរតើអ្នកយល់យ៉ាងដូចម្តេច សូមលើកឧទាហរណ៍មកពន្យល់?

នោះបុគ្គលករណីយកិច្ចដែលមានលក្ខណៈខាងបញ្ញា កើតចេញមកពីប្រភពផ្សេងៗ តាមការយល់ឃើញរបស់អ្នកប្រាជ្ញខ្លះក៏ដោយ ក៏នៅមានអ្នកប្រាជ្ញខ្លះយល់ថា "បើករណីយកិច្ច ជាអំពើដែលបានមនុស្សជាអ្នកប្រព្រឹត្តទៅ ករណីយកិច្ចនោះឯងនោះមានប្រភពមកពីណាក៏ដោយក៏ទៀងនៅចិត្តរបស់មនុស្ស" ដូចដែរ ។ អ្នកប្រាជ្ញឈ្មោះ កង់ (Kant) ក៏នៅតែនិយាយថា "ថ្វីបើករណីយកិច្ចខាងបញ្ញាកើតមកពីមាគ៌ាទេព ឬឥទ្ធិពលសង្គមក្តី ក៏ករណីយកិច្ចនេះកើតចេញពីចិត្តរបស់មនុស្ស គឺ "វិចារណញ្ញាណ" នេះឯង ។ លោកអ្នកប្រាជ្ញនេះ យល់ថា "សីលវិជ្ជា" ជាផ្លូវមួយដ៏សំខាន់ ចំពោះមនុស្ស ។ លោកពុំព្រមទទួលស្គាល់ទេថា "សីលវិជ្ជាត្រូវតែកើតមកពីខាងក្រៅ គឺច្បាប់បង្គាប់គោលការណ៍មួយ ក្រៅពីមនុស្សខ្លួនឯងឡើយ" នោះជាគោលការណ៍នោះជាព្រះអាទិទេពអតិសេដ្ឋ (Dieu-transcendant) ឬជាអ្វីមួយដែលមានអំណាចក៏ដោយ ។ លោកកង់ (Kant) បន្ថែមទៀតថា:

"វិចារណញ្ញាណ ជាច្បាប់របស់ខ្លួនច្បាស់លាស់ណាស់ ដើម្បីបង្គាប់បញ្ជាខ្លួនមនុស្ស" ។ ដូច្នេះយើងឃើញថា

ទោះបីយ៉ាងណាក៏ដោយ ក៏អ្វីៗដែលកើតពីមនុស្សសុទ្ធតែត្រូវមានហេតុផលជាដរាប នៅក្នុងមនុស្សពុំអាចជៀសវាងបានឡើយ ។ ឧទាហរណ៍ :

ករណីអាក្រក់ ជាធាតុកិច្ចដាក់ទោសមនុស្ស ដោយអនុវត្តច្បាប់របស់សង្គម ។ បើយករណីអាក្រក់នេះដូចសុទ្ធតែបញ្ហាដាច់អហំការដោយមានច្បាប់និងគោលការណ៍ត្រឹមត្រូវ គឺមនុស្សទាំងអស់បានគោរពតាមច្បាប់ ដែលសង្គមមនុស្សដាក់ដោយអនុវត្តឬទេ ? ។ ការពុករលួយក្នុងសង្គមកើតមកពីអ្វី ?

យើងឃើញករណីយកិច្ចកើតមកពី "ចិត្ត" មនុស្ស គោលគឺវិចារណញ្ញាណរបស់មនុស្សដោយឥតប្រែកកបានឡើយ ។ ឧទាហរណ៍ : យើងពុំដែលឃើញព្រះអាទិទេពឬច្បាប់ណាបង្គាប់ឲ្យមនុស្សស៊ីសំណូកទេ ។ ដូច្នេះករណីយកិច្ចនេះកើតមកពីវិចារណញ្ញាណពិត ព្រោះ "មនុស្សជាសត្វដែលបរិភោគមនោសញ្ចេតនាហារ" ។

## 257- អ្វីទៅហៅថា សីលកុសល ?

(Qu'est-ce que le bien moral ?)

លោក ប្លាតុង ( Platon ) ពោលថា :

"កុសល ជាព្រះអាទិទេពរបស់គំនិត" ដូច្នេះយើងឃើញថាលោកប្លាតុង ទទួលស្គាល់ "ខ្លួនគំនិត" ជាជា "កុសល"។ ចំណែកអ្នកសាសនានិយម វិញថា "កុសលគឺ "បរមករុណា ឬ និព្វាន" ឬ "សុគតិភព" ព្រះពុទ្ធអង្គយល់ថា "កុសល" កើតមកពីធានអនុវត្តធម៌ប្រាំបីយ៉ាងគឺ :

១- សម្មាទិដ្ឋិ (ការយល់ឃើញត្រូវ)

២- សម្មាសង្កប្បៈ (ការត្រិះរិះត្រូវ)

៣- សម្មាវាចា (ពាក្យសំដីត្រូវ)

៤- សម្មាកម្មន្តៈ (ការងារត្រូវ)

៥- សម្មាជីវៈ (ការចិញ្ចឹមជីវិតត្រូវ)

៦- សម្មាវាយាមៈ (ការព្យាយាមត្រូវ)

៧- សម្មាសតិ (ការភ្ញាក់រលឹកនឹកឃើញត្រូវ)

៨- សម្មាសមាធិ (ការតាំងចិត្តត្រូវ)

រីឯគ្រិស្តសាសនិក ពុំយល់ថា កុសលកើតមកពីអំពើរបស់ខ្លួនឯងទេ តែគេយល់ថា : "ព្រះអាទិទេពជាកុសល" ព្រោះព្រះអង្គជាអ្នកតែងច្បាប់គំនិតនិងវិចារណញ្ញាណមនុស្ស" ។ ដូច្នេះ "កុសលគឺ បរមសុខ ដែលកើតពីអំពើត្រូវរបស់មនុស្ស និងព្រះអាទិទេព" ។

*

* *

# ១៣. សីលញ្ញាណ

(La conscience morale)

258- អ្វីទៅហៅថាសីលញ្ញាណ ?

ដើម្បីអោយនិយាយន័យរបស់ពាក្យ "សីលញ្ញាណ" បាន, ជាដំបូងយើងត្រូវស្គាល់ន័យនៃពាក្យ "សីល" និង "ញាណ" ជាមុនសិន ។

អ្វីទៅហៅថា "សីល" (morale)? ( តាមបែបទស្សនវិជ្ជា "សីល" គឺ សាស្ត្រដែលសិក្សាអំពីនិយាមទាំងឡាយ សំរាប់ដឹកនាំមនុស្សអោយធ្វើ "កុសល" ហើយនិងជៀសវាង "អកុសល" ).

(Science qui traite des règles à suivre pour faire le bien, éviter le mal.).

ចុះអ្វីទៅហៅថា "ញាណ" (conscience)? (តាមបែបទស្សនវិជ្ជា "ញាណ" គឺជាសភាវគតិ ដែលកប់នៅក្នុងចិត្តរបស់មនុស្សហើយដែលញុំាងមនុស្សអោយធ្វើវិនិច្ឆ័យអ្វីជា "កុសល" ឬ "អកុសល" ) ។

(Sentiment intérieur qui nous fait juger ce qui est bien et ce qui est mal.)

សរុបៈ "សីលញ្ញាណ" គឺ "សភាវគតិនៃចិត្ត ដែលប្រកបដោយនិយាម (règles) ញុំាងមនុស្សអោយដោះស្រាយបញ្ហា "កុសល" និង "អកុសល" ។

259- អ្វីទៅហៅថា "ចិត្តញ្ញាណ" ?

(Qu' est-ce que la conscience psycho...

លោកអ្នកប្រាជ្ញ ឈ្មោះ ឡាឡង់ (La Lande) អោយនិយមន័យថា: ជា « អន្តរញ្ញាណ ( ntuition) ដែលនាំចិត្តអោយដឹងភាពនិងអំពើរបស់ខ្លួន ផ្ទៃ:ចិត្តញាណ មិនគឺអ្វីក្រៅពីអ្វីដែលនាំអោយចិត្តស្គាល់សច្ចៈភាពពិតប្រាកដ នៃសកម្មភាពរបស់មនុស្ស » ។

260- តើ«សីលញ្ញាណ» និង«ចិត្តញាណ» ខុសគ្នាយ៉ាងដូចម្តេចខ្លះ? ចូរពន្យល់ ។

«សីលញ្ញាណ» និង «ចិត្តញាណ» វត្ថុទាំងពីរនេះ ជាសញ្ញាណនៃចិត្តដែលនាំអោយដឹងដូចគ្នា, គឺជាអំណោយដែលមានគុណសម្បត្តិទាមប្រាប់«សច្ចៈភាព»ដូចគ្នា ។ ក៏ប៉ុន្តែវត្ថុទាំងពីរមានលក្ខណៈខុសគ្នាត្រង់សកម្មភាពរបស់ខ្លួនពោលគឺ :

«សីលញ្ញាណ» ដឹងហើយប្រាប់មនុស្សអោយធ្វើករណីយកិច្ចទាំងឡាយ ។ ជាសម្លេងនៃចិត្ត ។

ចំណែក «ចិត្តញាណ» វិញ គ្រាន់តែជាពន្លឺនៃការដឹងប៉ុណ្ណោះ, ហើយក៏ប្រាប់មនុស្សអោយដឹងតែម្យ៉ាង ។ ហេតុដូច្នេះហើយបានជាអ្នកនិពន្ធម្នាក់ពោលថា :
«បើ«ចិត្តញាណ»ជាអ្នកទស្សនា “សីលញ្ញាណ” ជាអ្នកវិនិច្ឆ័យ» ។

**(si la conscience psychologique est spectateur ; la conscience morale est juge)**

261- គេពោលថា «ការត្រិះរិះទៅលើសីលញ្ញាណ»

បានបង្ហាញអោយឃើញនូវ «គំនិតទស្សនវិជ្ជាថ្មីៗ ដែលជាសកម្មភាពរបស់ចិត្ត» ។ តើគំនិតទស្សនវិជ្ជានោះជាអ្វីខ្លះ ? តើគេអាចចាប់យកមកពិចារណាពីហេតុផលនិងអំពើរបស់វាបានឬទេ ?

ការធ្វើវិភាគទៅលើ «សីលញាណ» បានអោយគេឃើញនូវគំនិតទស្សនវិជ្ជាពីរគឺ :

១- សីលវិនិច្ឆ័យ (Jugements moraux)

២- សីលសញ្ចេតនា (sentiments moraux)

ក្រោយដែលគេបានរកឃើញនូវគំនិតទាំងពីរនេះហើយគេក៏ចាប់ពិនិត្យ និងពិចារណាលើធាតុពិត និងលើអំពើរបស់វាទៀត ។ គេបានដឹងថា «សីលវិនិច្ឆ័យ» (jugements moraux) ជាធាតុបញ្ញាញាណ (éléments intellectuels) ដែលស្ថិតនៅក្នុងចិត្តរបស់មនុស្ស ។ គឺជានិយមញាណផ្តល់អោយពិចារណា ហើយអោយគំនិតទៅលើសកម្មភាពទាំងឡាយណាដែលប្រកបដោយកុសលឬអកុសល ។ ការពិចារណាការខុសត្រូវអាស្រ័យ ស្មើ ទៅលើប្រធានផ្សេងៗដូចជាការវិនិច្ឆ័យលើគេណាក៏ដោយ លើសិទ្ធិមនុស្ស លើយុត្តិធម៌និងសន្តិសុខលើច្បាប់ ។ ខណៈពេលសីលវិនិច្ឆ័យត្រូវពិចារណាលើការណ៍ចិត្តផ្សេងៗដែលទៀតផងដូចជា «ទំនួលខុសត្រូវ» (Responsabilité) ជាដើម ។ល។

ចំពោះ «សីលសញ្ចេតនា» វិញគេច្រើនហៅថាជា «ធាតុវេទនា» (éléments affectifs) ដែលនៅផ្សារភ្ជាប់

ការវិនិច្ឆ័យគឺការគោរពអំពើជាកុសល ហើយស្អប់ខ្ពើមអំពើ
«អកុសល» ។ល។

262- ដោយសីលញ្ញាណ ញុំាងចិត្តអោយធ្វើការពិចារណា និងអោយតំលៃទៅលើប្រធានផ្សេងៗរបស់មនុស្ស ជាតថាអ្នកប្រាជ្ញទស្សនវិជ្ជាភាគច្រើនចូលចិត្តចង់ដឹង, ចង់ស្គាល់, ព្រមទាំងចង់ឃើញ ដើមកំណើតនៃសីលញ្ញាណនេះ ។ តើសីលញ្ញាណកើតមកពីណាចូរពន្យល់ ។

ដើម្បីពិចារណាការកសីលញ្ញាណ អ្នកប្រាជ្ញជាច្រើនបានអោយគំនិត ឬ ទស្សនៈផ្សេងៗពីគ្នា :

១- លោក រូសូ ថា «សីលញ្ញាណ ជា «សំលេងអមតៈនៃព្រះអាទិទេព» ។ មិនតែប៉ុណ្ណោះ លោកបានបញ្ជាក់ថែមទៀតថា «សីលញ្ញាណជាចៅក្រមទិព្វដែលឋិតនៅក្នុងចិត្តរបស់មនុស្ស, ហើយចៅក្រមនោះសោតពុំមានការភ័ន្តច្រលំនៅក្នុងការពិចារណា ឬវិនិច្ឆ័យទាំងឡាយឡើយ ។

២- អ្នកប្រាជ្ញឈ្មោះរេត (Red) បានយល់ថា : «សីលញ្ញាណ ជាសេចក្តីភ្លាមៗ (sentiment immédiat) ដែលស្ថិតនៅក្នុងខ្លួននៃមនុស្សភាគតិច» ។

៣- ចំពោះពួក រ៉ូម៉ង់ទិក ពោលថា : «សីលញ្ញាណ ជាសក្តិមួយពិសេស (faculté spéciale) ដែលមានលក្ខណៈខុសពីវិចារណញ្ញាណ» ។

263- តើគំនិតនៃអ្នកប្រាជ្ញទាំងបីមើលឃើញ "សីលញ្ញាណ" ថាមានប្រភពមកពីណា, ហើយកើតពីអ្វី ?

ដោយពោលទៅតាមគំនិតរបស់អ្នកប្រាជ្ញខ្លះ យើងពោលថា «សីលញ្ញាណ» ដំបូងកើតមកពី «ចិត្ត» ពុំមែនកើតមកពីសរីរាង្គនៅខាងក្រៅពីចិត្តឡើយ ។ បន្ទាប់មកនៅក្នុងចិត្តចំនួន ១២១ របស់មនុស្ស, សីលញ្ញាណកើតមកពីស្តេចចិត្តក្នុងចំណោម «សោភណចិត្ត» ចំនួន ៥៩ ។ ជាស្តេចចិត្តដែលប្រកបដោយពន្លឺរស្មីដ៏រុងរឿង រហូតទាល់តែលោក «រូស្សូ» យល់ថាជា «សភាវគតិទិព្វ» ដែលបិតនៅក្នុងចិត្តរបស់មនុស្ស (១) ។

264- តើទ្រឹស្តីទស្សនវិជ្ជាណាខ្លះ ដែលសាកល្បងយក "សីលញ្ញាណ" មកពិចារណា? តើទ្រឹស្តីនីមួយៗយល់ថា "សីលញ្ញាណមានលក្ខណៈយ៉ាងដូចម្តេចខ្លះ ?

ទ្រឹស្តីដែលយក សីលញ្ញាណ មកពិចារណាគឺ :

១-ទ្រឹស្តី សីលធម៌ ឬមតិ មានពីកំណើត ។
(theorie de sens moral ou thèse inneist )

២-ទ្រឹស្តី ពិសោធនិយម ។
(theorie empiriste)

---

(១) : ចិត្តរបស់មនុស្សយើងមានចំនួន ១២១ គឺ : អសោភណចិត្ត៣០ និងសោភណចិត្ត៩១ ។ ចំណែក «សីលញ្ញាណ» កើតនៅក្នុងសោភណចិត្ត ៩១ នេះឯង, ហើយ «សីលញ្ញាណ» ជាស្តេចនៃសោភណចិត្ត ។

៣ - ទ្រឹស្ដីវិចារណញាណនិយម ។

(théorie rationaliste)

ទ្រឹស្ដីទី ១ យល់ថា «សីលញាណ» បានពីកំណើតមនុស្ស មក ។

ឧទាហរណ៍ : មនុស្សកើតមកមានខួរក្បាល, ដូច្នេះមនុស្ស កើតមកត្រូវយក «សីលញាណ» មកផង ។

ទ្រឹស្ដីទី ២ យល់ថា «សីលញាណ» កើតមកពី «ពិសោធន៍» របស់មនុស្ស ក្រោយដែលខ្លួនបានហាត់រៀនរៀនក្នុងជីវិត មកអស់កាលដ៏យូរ - ពោលគឺគេយល់ថា «សីលញាណ» កើតមកពី «វិវឌ្ឍន៍នៃពូជជាតិមនុស្ស» (លោកស្ប៉ិនស៊ែ) (Spencer) , ក្រោយមកទៀតគេជឿថាកើតមកពីការអប់រំនៃសង្គមមនុស្ស (លោកឌួខិម) ។

ទ្រឹស្ដីទី៣ យល់ថា «សីលញាណ» កើតមកពី «ខួរក្បាលមនុស្សដែលមានវិចារណញាណ» ដែលគេចាត់ទុកថាជាបុព្វសិទ្ធិពីកំណើតនៃមនុស្ស (une prérogative congénitale de l' homme) ។

ហេតុដូច្នេះហើយបានជាអ្នកនិយមលើទ្រឹស្ដីទី៣នេះ ហៅឈ្មោះ «សីលញាណ» ថា : ជា «វិចារណញាណអនុវត្ត» (Raison pratique) ។

# ១៤.ទំនួលខុសត្រូវនិងវិបាកវិនិច្ឆ័យ

(La Responsabilité et la sanction)

**265**- អ្វីទៅហៅថា ទំនួលខុសត្រូវ ?

( Qu'est.ce que la Responsabilité?)

ដែលហៅថាទំនួលខុសត្រូវគឺ ការធានារ៉ាប់រងលើអំពើទាំងឡាយដែលខ្លួនបានប្រព្រឹត្ត មានការទទួលសារភាព - ហ៊ានទទួលវិបាកវិនិច្ឆ័យផងដែរ ។

**266**- អ្វីទៅហៅថា ទំនួលខុសត្រូវខាងផ្នែកសង្គម ?

(Qu'est-ce que la Responsabilité sociale?)

ដែលហៅថាទំនួលខុសត្រូវផ្នែកសង្គម គឺទំនួលខុសត្រូវឬសារភាពចំពោះមុខច្បាប់នៃសង្គមនោះ ។

ឧទាហរណ៍ : ជនទាំងឡាយដែលប្រព្រឹត្តល្មើសនិងច្បាប់សង្គម ត្រូវតុលាការកោះហៅទៅកាត់ទោស ។ តែខុសនិងស្ថានទោស ឬ កាត់ទោសជននោះ ច្បាប់ត្រូវការជាចាំបាច់នូវទំនួលខុសត្រូវ គឺការឆ្លើយសារភាពផងដែរ ។ ដោយច្បាប់ត្រូវការ ទំនួលខុសត្រូវនៃជនជាប់ចោទសំរាប់ធ្វើជាតំណាងរបស់ខ្លួនដើម្បីគេឃើញមានការ ធ្វើទារុណកម្មដើម្បីបង្ខំជនដែលល្មើស ឬ ជនជាប់ចោទអោយសារភាពជាមុនសិន ។

**267**- អ្វីទៅហៅថាទំនួលខុសត្រូវខាងផ្នែកសីលវិជ្ជា ?

ទំនួលខុសត្រូវខាងផ្នែកសីលវិជ្ជា គឺការទទួលសារភាពទាំងឡាយ ដែលកុំបង្ខិតបង្ខំ ក្រោយទាំងជាសារភាពឬទំនួលខុសត្រូវ ដែលសាមីជនមានញាណគ្រប់គ្រាន់ផង ។ ឧទាហរណ៍ ៖

មនុស្សឆ្កួតគ្មានទំនួលខុសត្រូវខាងផ្លូវសង្គម និង សីលវិជ្ជា ឡើយ ។ ដូច្នេះ មនុស្សឆ្កួតគ្មានកំហុសចំពោះមុខតុលាការ ទៀត ។

268- តើទំនួលខុសត្រូវផ្នែកសង្គម បានត្រូវច្បាប់ចែកជាប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

ទំនួលខុសត្រូវផ្នែកសង្គម ត្រូវច្បាប់ចែកជាពីរផ្នែកទៀត គឺ ៖

១- ផ្នែកព្រហ្មទណ្ឌ (responsabilité penale)

២- ផ្នែករដ្ឋប្បវេណី (responsabilite civile) ។

ឧទាហរណ៍ : ចោរសំលាប់គេត្រូវទទួលទោសឧក្រិដ្ឋ ព្រោះ ជាទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។

ឧទាហរណ៍ ៖ ផ្ទះរលំគេ ម្ចាស់ផ្ទះត្រូវទទួលទោសផ្នែករដ្ឋប្បវេណី គឺទោសស្រាល ។ តុលាការបង្គាប់អោយម្ចាស់ផ្ទះ សងជំងឺចិត្តអ្នករងគ្រោះដោយបង់ជាប្រាក់ ។

269- តើទំនួលខុសត្រូវផ្នែកសង្គម និង ផ្នែកសីលវិជ្ជាមាន ទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ ចូរលើកឧទាហរណ៍ និងពន្យល់ ?

មនុស្សជាសត្វដែលអាចរស់នៅក្នុងសង្គមបាន, ដូច្នេះឥទ្ធិពលរបស់សង្គមតែងធ្វើអោយមនុស្សអោយ ប្រព្រឹត្តធ្វើតាមបញ្ជា វិធានអំណាចរបស់ខ្លួន ។ កាលណាមនុស្សទាំងឡាយណា ដែលតាមសុខចិត្តរស់នៅក្រោមអំណាច នៃសង្គមណាមួយ ហើយ, មនុស្សទាំងឡាយនោះត្រូវច្បាប់សង្គមបញ្ជា អោយ

អាចទំនួលខុសត្រូវក្នុងក្របខ័ណ្ឌច្បាប់និងអំណាចរបស់ខ្លួន ។ ទំនួលខុសត្រូវនេះបានត្រូវសង្គមចែកដាច់ពីគ្នាជាពីរពួកគឺ :

១- ផ្នែកព្រហ្មទណ្ឌ និង
២- ផ្នែករដ្ឋប្បវេណី ។

ក៏ប៉ុន្តែ ដោយទំនួលខុសត្រូវរបស់សង្គមត្រូវមានមនុស្សជាប្រធានក្នុងអនុវត្តន៍របស់ខ្លួន , ហើយមនុស្សនេះជាសត្វដែលបរិភោគ "មនោសញ្ចេតនាមាន" ទើបគេឃើញថាដើម្បីអោយមានយុត្តិធម៌ក្នុងការវិនិច្ឆ័យ, ចៅក្រមមិនត្រូវគិតតែពីបញ្ហាសង្គមទេ, តែត្រូវគិតលើបញ្ហាសីលធម៌ផងដែរ ។ តើទំនាក់ទំនងទាំងពីរនេះមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? ឧទាហរណ៍ : សង្គមកាត់ទោសមនុស្សម្នាក់អោយជាប់គុកប្លែងឆ្នាំព្រមទាំងបង្គំអោយធ្វើការងារធ្ងន់ ។ បុគ្គលគត ពុំមនុស្សនោះបានសំលាប់ប្រពន្ធរបស់ខ្លួន ។ ចៅក្រមកាត់ទោស, ចៅក្រមតាមគន្លងតែពីរក្នុងការកាត់ក្តីនេះ ព្រោះចៅក្រមខ្លួនឯងក៏ជាមនុស្ស, ចំណែកអ្នកមានទោសក៏ជាមនុស្ស ។ ចៅក្រមក៏មានប្រពន្ធ, អ្នកទោសក៏មានប្រពន្ធ។ បើជននោះត្រូវជាប់គុកប្លែងឆ្នាំ ហើយបង្គំអោយធ្វើការធ្ងន់ធ្ងន់ អោយទោសសំលាប់ប្រពន្ធដែលមានសហាយ ។ ក្នុងមួយពេលប្រពន្ធចៅក្រមមានសហាយវិញ, ហើយចៅក្រមសំលាប់គេ ចៅក្រមខ្លួនឯង ក៏ត្រូវគេយកមកកាត់ទោសដូចគ្នានឹងក្នុងករណីទោសមនុស្សនោះដែរ ។ ចៅក្រមតែងមានបញ្ហាសីលធម៌, គេក្នុងមារយាទរបស់ខ្លួនជានិច្ច ដោយពិចារណាលើកុសលនិងអកុសល ។ ម្យ៉ាងទៀតចៅក្រមអាចយកទំនួលខុសត្រូវ

វត្ថុកសីលវិជ្ជា ដាក់ផ្តួលក្រុមប្រឹក្សាតុលាការពិចារណា ដើម្បីជួយសំរាលទោសអ្នកជាប់ចោទ, ដូចពាក្យ «មេត្តា» និង «អនុគ្រោះ» ។ល។ តែក្រុមជាតប្រើច្បាប់ទំនួលខុសត្រូវសង្គមមកដាក់ទំនួលខុសត្រូវសីលវិជ្ជា ដើម្បីដាក់ទុកសំរេចទោស ជាទោសកម្មហ្មត់ចត់ហើយ តែបើអ្នកមានកំហុសត្រូវទទួលទោស តែត្រឹមចំពោះខ្លួនប៉ុណ្ណោះ ។ ចំណែកពលរដ្ឋមានជួយអ្នកទោស អោយបានរួចខ្លួនផង ក៏មានទោសជាសមគំនិតដែរ «បក្ខពួក» គឺនៅតែចាប់អ្នកជាប់ពិរុទ្ធ អោយទទួលទោសនិង តេឡើងតណៈចរិត ព្រោះច្បាប់បានទទួលស្គាល់ថា មនុស្សម្នាក់ មានមនុស្សជាតិញាណ, ជាផលគ្មានទំនួលខុសត្រូវខាងសីលវិជ្ជា, ហើយនិងមានមនុស្សធម៌ខាងទោស ។ ចូរយើងពិនិត្យមើលថា ទំនួលខុសត្រូវខាងផ្លូវសង្គម មានទំនាក់ទំនងយ៉ាងជិតស្និទ្ធណាស់ណា ជាមួយនឹងទំនួលខុសត្រូវខាងសីលវិជ្ជា ពុំអាចកាត់ផ្តាច់ពីគ្នាបានឡើយ ។

- អ្វីទៅហៅថា, ទំនួលខុសត្រូវក្នុងទ្រឹស្តីវិចារណញាណនិយម ?

ដែលហៅថា, ទំនួលខុសត្រូវក្នុងទ្រឹស្តីវិចារណញាណនិយមគឺទំនួលខុសត្រូវដែលចេញមកពីការពិចារណាដែលសាមីខ្លួនធ្វើ ។ គេគឺត្រូវបានទំនួលខុសត្រូវតាមការស្រម៉ៃ មានញាណត្រឹមត្រូវ, ពុំមែនជាមនុស្សល្ងង់សតិ, ឬមនុស្សឆ្កួត ។ គេជាមនុស្សមានសេរីភាព គឺពុំមែនបង្ខិតបង្ខំដោយអ្នកដទៃណាមួយនាក់ឬព្យាយាមការជួយ ។ ភក្ខះរបស់គេជាគន្លងដែល

ប្រកបដោយកុសលចិត្ត ៖ ហើយពុំមាននរណាម្នាក់មករារាំង ផលសំរេចនៃចិត្តរបស់គេបានឡើយ ។

ឧទាហរណ៍ ៖ លោករូស្សូបានរត់ភៀសខ្លួនទៅប្រទេសស្វីស ក្រោយដែលបានសរសេររិះគន់ប្រទេស និងសង្គមរបស់បារាំងនៅក្នុង "សៀវភៅ" របស់លោកមួយឈ្មោះ "អេមីល" (Emile) ។ ហេតុអ្វីក៏លោករូស្សូរត់ ? លោករូស្សូរត់ព្រោះគេបានតាមចាប់ខ្លួនគាត់ពីបទសរសេរ ដោយខុសរបៀបរៀបរយសង្គមរបស់គេ ។

លោករូស្សូរត់ព្រោះខ្លាចមានទំនួលខុសត្រូវខាងផ្នែកសង្គម។ ប្រាំឆ្នាំក្រោយមក រូស្សូក៏ត្រឡប់មកប្រទេសបារាំងវិញ ។ ហេតុអ្វីក៏រូស្សូត្រឡប់មកប្រទេសបារាំងវិញ ? គាត់ត្រឡប់មកប្រទេសបារាំងវិញ ព្រោះគេលែងតាមចាប់ខ្លួនគាត់, គេបានទុកជាមោឃៈ នូវដីកាចាប់ខ្លួនគាត់, ម្យ៉ាងទៀតគាត់ត្រូវត្រឡប់ចូលមកប្រទេសបារាំងវិញ ព្រោះគាត់មានទំនួលខុសត្រូវខាងវិចារណញ្ញាណ ។ ព្រោះរូស្សូមានវិប្បដិសារី រូស្សូដើរចោលកូនប្រពន្ធទុកអោយរដ្ឋចិញ្ចឹម, ហេតុដូច្នេះហើយ បានជាគាត់សរសេរវចនានុក្រមតន្ត្រី (Dictionnaire de musique) មួយចងដៃអោយរដ្ឋនោះវិញ ។ យើងឃើញថា រូស្សូមានទំនួលខុសត្រូវផ្នែកវិចារណញ្ញាណ ព្រោះគាត់មានសេរីភាព, គាត់រួចចាកពីលំដាប់ទំនៀមសង្គមហើយត្រឡប់ជាមានភក្តីភាពសង្គមវិញ ។

271 តើទំនួលខុសត្រូវ ផ្នែកប្រពៃណីនិយមមានលក្ខណៈ យ៉ាងដូចម្តេច ? ចូរពន្យល់ ។ 139

តាមប្រៃតណ៍និយម ផលណាក៏ដោយដែលបានប្រព្រឹត្តនូវអំពើអ្វីមួយ សុទ្ធតែត្រូវមានចង្វាប់ពីចិត្តរបស់ខ្លួនដែលបានពិចារណារួចហើយ ។ អ្នកប្រាជ្ញប្រៃតណ៍និយមជឿថាបើគ្មានសេចក្ដីសំរេចចិត្តទេ បុគ្គលពុំអាចអនុវត្តនូវអំពើអ្វីមួយបានឡើយ ទោះមានការបង្ខិតបង្ខំក្ដី ឃ្នាំងក្ដី, ពួកអ្នកប្រាជ្ញទាំងនោះយល់ថា "ចិត្ត" ជាកត្តាចំបងសំរាប់ការអនុវត្តអំពើទាំងឡាយនៃមនុស្ស ។

គេជឿថា "មនុស្សមានគួនចិត្តមួយ" ដែលអ្នកប្រៃតណ៍និយមគេហៅថា "សេរីអាត្មា" (libre arbitre) ធ្វើអោយគេសំរេចចិត្តការទាំងពួង ។ ម្យ៉ាងទៀតទំនួលខុសត្រូវដែលអ្នកប្រៃតណ៍និយមបានរកឃើញនោះ គឺទំនួលខុសត្រូវបណ្ដាលមកពីចិត្តចេតនារបស់មនុស្សដែលប្រកបដោយ "មូលហេតុ" នេះឯង ។

## 272- អ្វីទៅហៅថា "វិបាកវិនិច្ឆ័យ" ?

**Qu'est-ce qu'une sanction?**

វិបាកវិនិច្ឆ័យគឺជាវិបាក ដែលកើតឡើងពីការប្រព្រឹត្ត ការមិនប្រព្រឹត្តនូវអំពើ និងសំដែលមាននិយាមថា គំណាត់ ។ តាមរបបសីលវិជ្ជា វិបាកវិនិច្ឆ័យជារង្វាន់ឬទណ្ឌកម្មសំរាប់ផលទាំងឡាយដែលធ្វើអំពើ ។

## 273 - តើវិបាកវិនិច្ឆ័យរបស់មនុស្ស ត្រូវតែចែកជាប៉ុន្មានផ្នែក, គឺអ្វីខ្លះ ?

វិបាកវិនិច្ឆ័យរបស់មនុស្ស តាមអ្នកសង្គមវិទ្យា
(Sociologue) ចាត់ចែកជាពីរផ្នែក :

១- ផ្នែកសីលវិជ្ជាដែលគេហៅថា «វិបាកវិនិច្ឆ័យសីលវិជ្ជា»
(la sanction morale)

២- ផ្នែកសង្គមដែលគេហៅថា «វិបាកវិនិច្ឆ័យសង្គម»
(la sanction sociale)

**274 - អ្វីទៅហៅថាវិបាកវិនិច្ឆ័យសីលវិជ្ជា ?**

ដែលហៅថាវិបាកវិនិច្ឆ័យសីលវិជ្ជា គឺវិបាកវិនិច្ឆ័យដែលមានលក្ខណៈជាទំនួលខុសត្រូវនៃបុគ្គលម្នាក់ៗ ។ ជាសតិរកសប្បាយចិត្ត របស់បុគ្គលម្នាក់ដែលបានធ្វើល្អទៅលើគុណសម្បត្តិនៃកុសល ។ គេមានវិបាកវិនិច្ឆ័យខាងសីលវិជ្ជាកាលណាគេសប្បាយរីករាយ ក្រោយដែលបានធ្វើពលិកម្មអ្វីមួយ កាន់លទ្ធិប្រសើរលើសតាមចំណេះ ឬគេបានវិប្បដិសារីកាលណាគេបានធ្វើខុស កំហុសអ្វីមួយក្រោសតាមអំពើអកុសល ។

**275 - អ្វីទៅហៅថាវិបាកវិនិច្ឆ័យសង្គម ?**

ដែលហៅថាវិបាកវិនិច្ឆ័យសង្គម គឺវិបាកវិនិច្ឆ័យដែលមានលក្ខណៈជា «ទំនួលខុសត្រូវវត្ថុវិស័យ» (la responsabilité objective) ។ ក្នុងន័យនេះវិបាកវិនិច្ឆ័យមានសភាពជាការណ៍យកចិត្ត ឬជាការតបតស្នងរបស់បុគ្គលនីមួយៗ ចំពោះទំនួលខុសត្រូវសង្គមៗ លទ្ធផលនៃវិបាកវិនិច្ឆ័យសង្គមគឺ

ផ្ដល់ជាវង្វាន់ ឬធ្វើទោសបុគ្គលនិមួយៗ ដែលបានគុណូបការទៅ នៅក្រោមការត្រួតត្រានៃក្បាច់សង្គម ។

ជាមហាជនដែលបានធ្វើទោសបរភូមិ ត្រូវទទួលវិបាកវិនិច្ឆ័យ សម្រួមតួនាទី :

១- គុណូបការដាវគ្រឿងឥស្សរិយយស ( Médaille ) ចំពោះមហាជនណាដែលបានធ្វើឧត្ដមភ័យចំពោះគុណសង្គ្រោះ ។

២- ត្រូវជាប់គុក ឬត្រូវគេសម្រេចទោសជីវិតចំពោះមហាជនណា ដែលរត់ចោលជាតិ ។ល។

276- តើវិបាកវិនិច្ឆ័យ ត្រូវអ្នកប្រាជ្ញទាំងឡាយ សំគាល់ឃើញថាមានទ្រឹស្ដីប៉ុន្មានបែប ? តើទ្រឹស្ដីនោះបានលក្ខណៈយ៉ាងដូចម្ដេចខ្លះ ?

តាមការពិនិត្យរបស់អ្នកប្រាជ្ញសង្គមវិទ្យាវិបាកវិនិច្ឆ័យចេញមកពីសង្គមមនុស្សច្រើនជាងអ្វីទាំងអស់ ។ គេបានពិនិត្យឃើញថា មានទ្រឹស្ដីវិបាកវិនិច្ឆ័យ ពីរបែបរបស់សង្គមមនុស្ស :

១- សង្គមប្រពៃណីនិយម

២- សង្គមវិវត្តន៍ពិពិធសាស្ត្រ ។

១- នៅក្នុងសង្គមប្រពៃណីនិយម គេច្រើនតែនិយាយថា “វិបាកវិនិច្ឆ័យ” ត្រូវតែគោរពស្របតាមសាសនា “សេរីភាព” ពីទេពតាមបុណ្យនៃអ្នកធ្វើកំពើ ។ តែការវិនិច្ឆ័យតាមបែបសង្គមប្រពៃណីភាគច្រើនតែងកើតចេញពីជំនឿនៃសង្គម “ដែលឋិតក្រោមទ្រឹស្ដី” របស់ខ្លួនពីព្រោះ “បរមត្ថវិជ្ជា” ។

142 ឧទាហរណ៍ : សង្គមអង់គ្លេសពីអតីតកាលបានផ្ដន្ទាទោសអ្នកទៅ

ឈើ "ស្រីចូប់" ដោយចាប់យកទៅចងភ្ជាប់នឹងទាំងរស់ ។ ពុទ្ធហេតុ "ដោយគេមានជំនឿថា" ដើម្បីបញ្ឈប់អំពើកុសលរបស់ស្រីចូប់នេះ , គេត្រូវតែដុតទាំងរស់ - ។ បន្ទាប់មកគេត្រូវយកឈើម៉ាងស្រួចទៅដោត ចំកណ្តាលដើមទ្រូងសាកសពនោះទៀត ។

ការដាក់ទោសដែលមានលក្ខណៈប្រតិកម្មនិយមនេះ ជាមធ្យោបាយយ៉ាងសក្តិសិទ្ធិសំរាប់សង្គមអង់គ្លេស នាសម័យនោះ អ្នកសង្គមវិទ្យាយល់ថាជាគ្រឿងសំខាន់មួយ ដែលសំរាប់បំភ័យពួកម៉ាយ គ្រូបៀតវេទមន្តអាក្រក់ ( Magie noire) ដែលធ្វើអំពើ ( le maléfice ) ដើម្បីសងតាមបញ្ជារបស់ខ្លួនទៅលើអ្នកដទៃ- ទៀត ។ ម្យ៉ាងទៀត វិធានការវិនិច្ឆ័យនេះ បង្អាក់ឲ្យអ្នកចង់សាងទុក្ខអ្នកដទៃ ដោយវាចា ឬ បណ្តាសា ឲ្យរៀសរលាក់ខ្លួនទាំងនោះដោយអំពើចំណែកនេះ ។ ជាការឆ្លុះបញ្ចាំងនៃប្រតិកម្មនិយម ដែលគេនិយាយថា " ត្រូវតែធ្វើអាក្រក់ចំពោះមនុស្សអាក្រក់ " ( Re dre le mal pour le mal ) ។

៣- តាមបែបសង្គមវិវត្តន៍នីតិសាស្ត្រ វិធានការវិនិច្ឆ័យបុរាណទៅតាមវិវត្តន៍នីតិសាស្ត្រ គឺការវិវត្តន៍របស់ច្បាប់សង្គម ។ គេតាំងយកមនុស្សទៅកាត់ក ( ឧទាហរណ៍ៈ ស្តេចបារាំងឈ្មោះ ល្វីទី ១៦ ត្រូវរាស្ត្រកាត់ក្បាលកម្ម ដោយកាត់កនឹងម៉ាស៊ីន (Guillotine) ។ ប្រទេសអង់គ្លេសសម័យកណ្តាលគេសំឡាប់មនុស្ស ដោយចងព្យួរកខ្ពស់ក្រឡឹកដល់រាប់ម៉ឺននាក់ ។ ប្រទេសស្វ៊ីសសម័យបច្ចុប្បន្ន វិធានការវិនិច្ឆ័យបានត្រូវធ្វើឡើង...

ដោយចំពោះមុខសាច់ញាតិ " វាលកាលក្រោល " ដាក់ឃ្នាង
ស្រែកអោយប្រជានុរាស្ត្រគេទាំងអស់គ្នា ។ ក្នុងរាជ្យ
ព្រះបាទរាមាធិបតី ពួកកម្ពុជាត្រូវគេបង្ខំចោលស្រុក
ដែលមានខ្សែស្រឡាយ ទាំងអស់គ្នា : ( ឧទាហរណ៍ :
ឧកញ៉ាមន្ត្រី បានក្បត់ពិពរាជសារព្រះបាទរាមាធិបតី
ដោយរំពេចសារពើរចនា ហើយបន្ទាប់មកគេយក
ទៅសំលាប់ ។ ប៉ុន្តែពួកខ្មែរស្មោះត្រង់ដោយជាប់
គ្រួសារមួយតែទៅសំលាប់ចោលក្នុងព្រៃ ហើយ
កាត់ចិញ្ចាស់ ។ ហេតុនេះហើយបានជាពាក្យនេះ ផ្ទុក
ខ្មែរស្រុកទៅលើគ្រប់ស្ដុកស្ដម្ភ ។ ដែលរំពឹងទៅមុខ
ទៀត ។ ទោះបីជាយ៉ាងណា គេដាក់ពួកកម្ពុជាស្រុក
ដែលសាច់ញាតិដោយបន្ទាប់ទៅពីកងទ័ពសៀម ។ ការ
ធ្វើពួកកម្ពុជាឲ្យទៅលើគុក ដែលគ្មានប្រាប់សព្វគ្រប់ឲ្យរូបនោះ
ត្រូវគេហៅប្រជារាស្ត្រទាំងឡាយ ដែលរស់នៅ " មនុស្សមិន
សមនឹងព្រះរាជាទៅទៀតពីការទ្រុឌទ្រោម » ក្នុង
ការតស៊ូមនុស្សដោយសារគុណតំណៀលជនក្រីក្រ ។

*

* *

# ១៥. ជីវិតផ្ទាល់ខ្លួន : គុណធម៌

(Vie personnelle : vertu)

**277-អ្វីទៅហៅថា «ជីវិតផ្ទាល់ខ្លួន» ?**

ដែលហៅថា «ជីវិតផ្ទាល់ខ្លួន» គឺគុណធម៌របស់បុគ្គលម្នាក់ៗចំពោះសង្គមដែលខ្លួនរស់នៅ ។ គុណធម៌នេះបានគាំពារសំរាប់តែមនុស្សទាំងឡាយណា ដែលបានប្រព្រឹត្តនាប្រកបដោយកុសល ។

**278-តើសង្គមមនុស្ស បានទទួលស្គាល់គុណធម៌ដែលជាអំពើរបស់មនុស្សដែរឬទេ ? ឬក៏សង្គមមនុស្សបាននៅឆ្ងាយពីគុណធម៌ ប្រៀបដូចជាការរីកចំរើននៃសរីរាង្គរបស់មនុស្ស?**

សង្គមមនុស្សបានជួយអោយគាំពារទៅមនុស្ស, ព្រមទាំងជួយធ្វើអោយបានសំរេចនូវ «ឧត្តមគតិ» ខ្លះរបស់មនុស្ស ។ សីលវិជ្ជាដែលយើងសង្កេតឃើញ ជាផ្នែកមួយនៃគុណធម៌របស់មនុស្សនោះ, បានញ៉ាំងមនុស្សអោយទទួលស្គាល់កុសលដោយភាគច្រើន ។ មិនតែប៉ុណ្ណោះសោតសីលវិជ្ជាធ្វើមនុស្សក្នុងសង្គមអោយបានលក្ខណៈជាមនុស្សពេញខ្លួន ។ គឺចំនួនមនុស្សត្រូវដែលសីលវិជ្ជានិងឧត្តមគតិបានទំពួកសង្ខំទុកអោយមនុស្សសំរេចបំណងផ្ទាល់របស់ខ្លួន នៅក្នុងសង្គមនេះហើយ, បានជាមនុស្សស្គាល់គំរៃពិតរបស់ខ្លួន ព្រមទាំងហ៊ានតស៊ូ ការតចំពោះបញ្ហាផ្សេងៗ ។ ឧទាហរណ៍ៈ

១- មនុស្សសម័យបច្ចុប្បន្នបានសំរេចរើសគូស្រករ ដោយខ្លួនឯង ។

៣- មនុស្សអាចរើសមុខរបររបស់ខ្លួន ក្នុងសង្គម - ដោយពុំគោរពទំនៀមទំលាប់និងប្រពៃណីខ្លះ ដែលតំរូវអោយមនុស្សទទួលអនុវត្តទាំងទើសទាល់ ។

ឧទាហរណ៍ ៖ ពួកជាតិគឺព្រាហ្មណ៍ដែលមាននាទីស្វាធ្យាយព្រះធម៌រាជ្យស្ងួន, ទទួលភារៈព្រះរាជពិធីផ្សេងៗក្នុងការផ្សាយព្រហ្មញ្ញសាសនា, ត្រូវយកកូនមួយឬពីរប្រុសឬអូនប្រុសរបស់ខ្លួនដើម្បីបន្តតំណែងតទៅទៀត ។ តែគេឃើញថាឥឡូវការត្រៀបត់ហើយនៅប្រទេសខ្មែរ កូនប្រុសបានជ្រើសរើសការងារដោយខ្លួនឯង, ហើយលះបង់ប្រពៃណីរបស់ខ្លួនដោយដាច់ស្រឡះពីគ្នាទាំងស្រុង ។ កូនចៅបានតាមរៀនសូត្រការណ៍ពិត ពីប្រពៃណីរបស់ខ្លួនដោយឥតញញើតញញើប ។ នេះជាភស្តុតាងបញ្ជាក់អោយយើងឃើញថា, មនុស្សបានបង្កើតបុគ្គលិកលក្ខណៈរបស់ខ្លួន ពីវត្តមានដែល

មនុស្សមានពាក្យ បុគ្គលិកលក្ខណៈរបស់ខ្លួន ពីវត្ត ទៅជា ដែល នៃទូតកម្មពិត មនុស្សបច្ចុប្បន្ន កាន់តែទំនើប ដែលគុណធម្មជាតិ ដើមមកពីលក្ខណៈសគល ដូចជាបានទទួល នូវត្រូវលើការរើសតំណាង របស់ខ្លួន នៅក្នុងសង្គម ដើម្បីត្រួតត្រា ។

## 279-អ្វីទៅហៅថាគុណធម៌ពិត ?

គុណធម៌ពិត គឺសីលធម៌របស់បុគ្គលដែលបានបរិ-សុទ្ធពេញលេញ ។

**280-** អ្វីទៅហៅថាសញ្ញាណនៃគុណធម៌ ?

(Qu'est-ce qu'une notion de la vertu?)

ដែលហៅថា "សញ្ញាណនៃគុណធម៌" គឺការប្រាថ្នាគោលគំនិតនៃគុណធម៌ , គឺការយល់ច្បាស់ពីលក្ខណៈពិតនៃគុណធម៌ ឬក៏សារៈលក្ខណៈសត្វៈរបស់គុណធម៌"ក៏បាន ។

**281** អ្វីទៅហៅថាកំលាំងគុណធម៌ ?

ដែលហៅថា "កំលាំងគុណធម៌" គឺកំលាំងនៃចិត្តមនុស្សដែលញុំាងឲ្យមានភាពកុសល ។

លោកឡឺសែន (Le Se ne) យល់ថា "គុណធម៌" គឺសេចក្ដីក្លាហានក្នុងការស្វែងរកកុសល" ។

ចំណែកលោករ៉ឺនូវៀ (Rénouvier) យល់ថា "គុណធម៌ "គឺជាកំលាំងដែលមាន ការពិចារណា, ការជជែកផ្ទួន សេរីភាព ភាពជាម្ចាស់នៃខ្លួនឯង", សំណឹកនាំ ឬចំណាត់ចែងការដឹកនាំខ្លួនឯង" (direction de soi)។ លោកដេការត (Descartes) យល់ថាគុណធម៌ គឺ "ចិត្តបុណ្យ" (générosité) ។

ផ្សេងពីនេះ"គុណធម៌" គឺ "សេចក្ដីខ្ជាប់ខ្ជួន" (constance) "សេចក្ដីព្យាយាម" (persévérance) ឬជា "ទំលាប់នៃកុសល" ។ ខ្លះទៀតបានអោយនិយមន័យថា : "គុណធម៌គឺជានិស្ស័យច្បាស់លាស់ទៅក្នុងសីលចរិយា , ជាលំនឹងចិត្តស្រួលដែលកើតមកពីការប្រឹងប្រែង ។

**282-** តើគុណធម៌មានលក្ខណៈដូចម្ដេចខ្លះ ? ហើយចែកចេញជាប៉ុន្មានបែប ?

គុណធម៌របស់មនុស្សមានច្រើនបែប - ច្រើនយ៉ាងណាស់ ហើយមានលក្ខណៈពុំដូចគ្នាទាំងអស់ទេ ។ ហេតុដូច្នេះហើយ បានជាគេអាចចែក "គុណធម៌" ជាពីរពួកផ្សេងគ្នាគឺ :

១ - គុណធម៌សាមញ្ញ
២ - គុណធម៌កំណើត

## 283- អ្វីទៅហៅថា "គុណធម៌" សាមញ្ញ ?

ដែលហៅថា "គុណធម៌សាមញ្ញ" គឺគុណធម៌ដែលបានមកពីការហ្វឹកហ្វឺន - និងការអប់រំ ។

ឧទាហរណ៍ :— ការទៀងពេល (ponctualité)
— ការចេះប្រមាណមិនលោភហួស (sobriété)
— ភក្ដីភាព (loyauté)
— ភាពខ្ជាប់ខ្ជួន (constance)
— ការគួរសម (politesse) ។

## 284- អ្វីទៅហៅថា "គុណធម៌" កំណើត ?

ដែលហៅថា "គុណធម៌កំណើត" គឺ "គុណធម៌" ដែលមនុស្សបានទទួលបេតកពីដូនតារបស់ខ្លួនមក ។

ឧទាហរណ៍ : — ចិត្តល្អ (la bonté)
— ភាពបង្គាប់ស្រួល (docilité)
— ចិត្តសន្ដោស - មេត្តា - ។ ល ។

## 285- ចុះចំពោះលោក "អារីស្តូត" (Aristote(1)) បានយល់ថាគួរចែក "គុណធម៌" ជាប៉ុន្មានក្រុម ?

148 លោកអារីស្តូត បានចែក "គុណធម៌" ជាពីរក្រុមគឺ :

១ - គុណធម៌បញ្ញា (vertu intellectuelle) ។

២ - សីលគុណធម៌ (vertu morale) ។

**286-** ដូច្នេះ តាមទស្សនលោក អារីស្តូត តើអ្វីទៅហៅថា គុណធម៌បញ្ញា ?

លោកអារីស្តូត, បានអោយនិយមន័យនៃពាក្យ "គុណធម៌បញ្ញា" ថា :

"ជាគុណធម៌ដែលធ្វើអោយបញ្ញាវិះគិត កាន់តែល្អឡើងតាមរៀង សាងវុឌ្ឍិខាងសត្ថ:"

ឧទាហរណ៍ ÷ — សិល្បៈ (Art)

— សាស្ត្រ (Science)

— ការប្រុងប្រយ័ត្ន (La prudence)

— គតិបណ្ឌិត (La Sagesse)

— បញ្ញា (L' intelligence)

— ។ល។

**287-** អ្វីទៅហៅថា "សីលគុណធម៌" ?

លោក អារីស្តូតពោលថា :

"សីលគុណធម៌" គឺជាគុណធម៌ដែលមាននៅក្នុងចំណង់ ដែលចេះគ្រប់សង្កត់លើសំនុំវេទនារណា ញាណ និងក្នុង ចំណាប់ប្រព្រឹត្តអោយសមរម្យត្រឹមត្រូវ នោះជានៅក្នុងស្ថាន ការណ៍ណាក៏ដោយ ។

---

(១) អារីស្តូត (Aristote) ជាសាវ័ករបស់លោកប្លាតុង (Platon) ហើយប្លាតុងជា "សិស្សទោ" របស់ "សូក្រាត" (Socrate) ។/49

ឧទាហរណ៍ : — សេចក្ដីក្លាហាន (Le courage)
— ការចេះប្រមាណ (La tempérance)
— យុត្តិធម៌ (La justice)
— គតិបណ្ឌិត (La sagesse)
— ។ល។

288- តើក្នុងជំនឿសាសនា, គេអាចរកឃើញគុណធម៌អ្វីខ្លះទៀតក្រៅពីទស្សនៈលោក អារីស្តូត ?

នៅក្នុងជំនឿផ្នែកគ្រិស្តសាសនា ព្រះសង្ឃព្រះនាម សាំងតូម៉ា (Saint Thomas) ក្រៅអំពីការគាំទ្រទស្សនៈលោក អារីស្តូតយក, លោកបានបន្ថែមគុណធម៌ផ្សេងៗ ដូចតទៅនេះ:

១ - ជំនឿចំពោះព្រះគ្រិស្ត(La foi)
២ - ការសង្ឃឹម (L'espérance)
៣ - សប្បុរសធម៌ (La charité) ។

គុណធម៌ទាំងបីនេះ លោក «សាំងតូម៉ា» បានដាក់ឈ្មោះហៅថា «គុណធម៌ទេវកម្មវត្ថុ» ។

នៅក្នុងជំនឿផ្នែកសាសនាមហាម៉ាត់ គុណធម៌គឺការលះបង់ចិត្តក្នុងការធ្វើ «សត្វពលី» (Sacrifice) ពោលគឺការបូជាជីវិតខ្លួនថ្វាយព្រះអាឡាហ៍ ។

នៅក្នុងជំនឿផ្នែកព្រហ្មញ្ញសាសនា ក្រៅពីគុណធម៌សាមញ្ញធម្មតា គេបានសង្កេតឃើញការហាមធ្វើពិឃាត និងធ្វើអធម៌ ហើយការតំរង់ស្មារតីទៅលើការចិត្តអារម្មណ៍ណាមួយ ។ នៅក្នុងជំនឿផ្នែកព្រះពុទ្ធសាសនាគេបានឃើញ «គុណធម៌» ពោល បើទាំង ៣ ផែលព្រះអង្គបានទំនាស់គ្រប់ជាតិ ។

ឧទាហរណ៍ : ( ទានបារមី - ទានឧបបារមី - ទានបរមត្ថ-បារមី - សីលបារមី - សីលឧបបារមី - សីលបរមត្ថបារមី - ។ល។

289- ក្រៅពីទ្រឹស្ដីដែលហៅថា « គុណធម៌ » នេះ តើនៅមានគុណសម្បត្តិអ្វីទៀត ដែលអ្នកប្រាជ្ញបានអោយតំលៃប្រសើរជាង « គុណធម៌ »?

ក្រៅពីទ្រឹស្ដីហៅថា « គុណធម៌ » គេបានរកឃើញរបស់មនុស្សជាច្រើនទៀតដែលអ្នកប្រាជ្ញយល់ថាមានតំលៃជាងគុណធម៌គឺ : ឧទាហរណ៍ :

- សុក្រឹតភាព ( perfection ) ឬភាពល្អឥតខ្ចោះ ។
- គុណូបការ ( mérite ) ឬ « សីលធម៌ » ។ល។

290- អ្វីទៅហៅថាមនុស្សថ្លៃ? (Personnes de valeurs)

ដែលហៅថា « មនុស្សថ្លៃ » គឺមនុស្សទាំងឡាយណាដែលមានគុណធម៌ ឬគុណូបការៈសំខាន់ ឬខ្ពស់ជាងគេ ។ ឧទាហរណ៍ : រង្វាន់ណូបែលតែងតែផ្ដល់ទៅអោយតែ «មនុស្សថ្លៃ» ដូចជាលោក កាមុស, សាត្រ ហែរណាដវ៉ាត ពី សាំងតែព្រ ។ល។

តែចំពោះមនុស្សថ្លៃ គេបានចែកជាបីផ្នែកធំៗ ដើម្បីស្រួលចំណាំគឺ :

១ - បណ្ឌិត (le sage)
២ - វីរបុរស (le héros)
៣ - សន្តបុគ្គល (le saint)

291- អ្វីទៅហៅថា "បណ្ឌិត" ( le sage )

LIBRARY BUDDHIST INSTITUTE

បណ្ឌិតគឺ មនុស្សដែលមាន ចំណង់ទាញ (inspiration) ប្រកបដោយបញ្ញានិយម (intellectualisme) ។ មានរបៀបជីវិត (style de vie) ប្រកបដោយលំនឹង (équilibre) ។ មានឥរិយាបថធម្មជាតិ ស្របនឹងវិវត្តន៍ធម្មជាតិ ។ មានឥរិយាបថចំពោះត្រើយភាព (attitude envers la sensibilité) មិនរំភើបហួសហេតុ ។ មានឥរិយាបថចំពោះមនុស្សដទៃ ប្រកបដោយលក្ខណៈសាបុគ្គលនិយម (individualisme) ។ មិនគិតប្រយោជន៍ផ្ទាល់ខ្លួនហើយ ប្រកាន់ស្មើថា គុណតម្លៃការផ្ទាល់ផ្ទាល់ខ្លួនរបស់បណ្ឌិត ។

292 - អ្វីទៅហៅថា "វីរបុរស" ? (le héros)

វីរបុរស គឺមនុស្សដែលមានចំណង់ទាញប្រកបដោយសន្ទុះសភាវគតិ (élan instinctif) ។ មានរបៀបរស់នៅប្រកបដោយភាពក្លៀវក្លាហួសវិស័យ ។ មានឥរិយាបថចំពោះធម្មជាតិ ជាអ្នកឈ្នះលើធម្មជាតិ ។ មានឥរិយាបថចំពោះត្រើយភាពប្រកបដោយលង់លប់ (passion) មានឥរិយាបថចំពោះអ្នកដទៃជាបុគ្គលនិយមហួសហេតុ (ultra-individualisme) ហើយជាមនុស្សប្រកបដោយចិត្តធុរៈ (générosité) ។

293 - អ្វីទៅហៅថា "សន្តបុគ្គល" ?

សន្តបុគ្គលគឺមនុស្ស ដែលបានចំណង់ទាញប្រកបដោយជំនឿខាងសាសនា ។ មានរបៀបរស់នៅជាសាមញ្ញដែលស្វែងរកគតិបណ្ឌិតប្រកបភាព ។ មានឥរិយាបថធម្មជាតិខាងវិសេស (transcendance) ហើយយល់ថាគួរទាំងអស់ដែលនៅក្រៅធម្មជាតិ ។ មានឥរិយាបថចំពោះត្រើយភាពទុស

ង់គង់ទៃ តបសីវត្តិនិយម: (ascétisme) រកបរមសុខក្រៅលោក ។ ចំពោះអ្នកផងទៃ, គេជាមនុស្សប្រកបដោយគំនិតអត្យាស្រ័យនិងជាបុគ្គល ដែលមានចារមុទិតាចិត្តទៅលើសុគតិភព ។ សន្តបុគ្គលច្រើនជាមនុស្សស្អប់លោកិយ ធុញនឹងលោកិយហើយជឿថា មានតែបរលោកទេ ដែលមានយុត្តិធម៌ពិត និងមានសុភមង្គលពិត ។

*

* *

# ១៦. សិទ្ធិ និង ច្បាប់

294- អ្វីទៅហៅថា «ច្បាប់» ?

(Qu'est-ce que le droit ?)

អ្នកប្រាជ្ញល្បីឈ្មោះ លៃប៊ិនិច (Leibniz) ពោលថា៖ «ច្បាប់គឺជាសីលធម៌ណាមួយ» ។ តែចំពោះអ្នកប្រាជ្ញខ្លះទៀតថា៖ “ច្បាប់ជាកំលាំង” ឧទាហរណ៍ : “ព្រះអាទិទេពជាអ្នកបង្កើតលោក ព្រះអង្គជាអ្នកផ្ដល់នូវគុណធម៌និងអំណាចដែលជាកំលាំងចំពោះមនុស្សសត្វទាំងឡាយ, ព្រះអង្គទ្រង់មានអំណាចខ្ពង់ខ្ពស់, បុគ្គលត្រូវមានសិទ្ធិខ្ពង់ខ្ពស់ដែរ” ។ លោកហ្វ្រេដេរិចហេកែល ( Hegel ) ក៏បានសន្និដ្ឋានចំពោះនិយមន័យរបស់ “ច្បាប់” ថាជាកំលាំងដែរ ឧទាហរណ៍ : “ច្បាប់មិនប្រែប្រួលក្រៅពីការលោភលន់របស់ពួកឈ្មួញនៅក្នុងសង្គម ដែលមានច្បាប់ជាអ្នកបង្រៀនពួកគេ” ។ លោកសូក្រាតយល់ថា :

“ច្បាប់ គឺអ្វីដែលមនុស្សគិតថ្លឹងថ្លែងសមាធិទេពក្នុងការរកយុត្តិធម៌” តែចំពោះលោកសូក្រាត (Socrate) ច្បាប់របស់មនុស្សជាតិសេស “ច្បាប់វិជ្ជមាន” (lois positives) ដែលបង្កើតដោយមនុស្ស, សុទ្ធតែខ្វះគតិយុត្តិធម៌ទាំងអស់។ ចំពោះលោកសូក្រាត “ច្បាប់ដែលបង្កើតដោយសំដីទេវព្រហ្មជាកំលាំងដែលតែងតែទៅដោយយុត្តិធម៌ ហើយមានតែច្បាប់អាទិទេពមួយគត់ដែលយុត្តិធម៌” ។

ប៉ុន្តែអ្នកខ្លះទៀតបែរជាគេឲ្យនិយមន័យទៅលើ “ច្បាប់” ថា “និយាមជាការកត្តាកិច្ចទាំងអស់របស់មនុស្ស សំរាប់ការ

សិទ្ធិ និង សេរីភាព ដែលធម្មជាតិបានកំណត់សំរាប់
ដើម្បីជីវិតរស់នៅនៃសត្វលោកទូទៅ ។
អ្នកប្រាជ្ញខ្លះទៀតអោយនិយមន័យទៅលើ «ច្បាប់» ថា៖
«អ្វីដែលហាមនិងការពារមនុស្ស» ហេតុដូច្នេះហើយបាន
ជាគេឃើញមានពាក្យថា «រំលោភច្បាប់ត្រូវទោស, បើគោរព
ច្បាប់ត្រូវការពារ» (Violer la loi frappe, respecter
la loi protège) ។ នៅក្នុងន័យនេះ គេឃើញមានពាក្យថា:
«ច្បាប់មានចរិតលក្ខណៈអវិជ្ជមានផង និង វិជ្ជមានផង»
(Aspect négatif et positif du droit)

**295-អ្វីទៅហៅថា «ច្បាប់ធម្មជាតិ» ?**

ដែលហៅថាច្បាប់ធម្មជាតិ គឺច្បាប់ដែលកើតមកតំណាល
និងវិចារណញ្ញាណនៃមនុស្ស ។ គឺជាក្រុមគុណដែល
មនុស្សបានកាន់តាមជាតិសេសតីធម្មជាតិ ។ ចំពោះអ្នកប្រាជ្ញ
ឈ្មោះ ស៊ីសេរ៉ុង (Sicéron) យល់ថា : «ច្បាប់ធម្មជាតិជា
និការកត្តុបំផុត (Suprême) ដែលចារឹកនៅក្នុងធម្មជាតិ»
ចំណែកលោកគ្រូស៊ីយូស (Grotius) ពោលថា: «ច្បាប់ធម្ម
ជាតិជានិយាមមួយដែលបានកំណត់ដោយសតិវិចារណញ្ញាណ
ត្រឹមត្រូវ, ថាអំពើដែលមានសីលធម៌ ឬអយុត្តិធម៌ជាអំ
ពុះទៅតាមធម្មជាតិប្រកបដោយវិចារណញ្ញាណ» ។

**296-តើអ្នកប្រាជ្ញឈ្មោះអ្វីដែលបានពោលថា៖ «ច្បាប់ជា ផលនៃសង្គម» ? តាមបតិខាងលើនេះ តើច្បាប់មាន ទំនាក់ទំនងទៅនឹងសង្គមមនុស្សយ៉ាងដូចម្ដេចខ្លះ ?**

លោក ឌូកហ៊ីម (Durkheim) ជាអ្នកសង្គមវិទ្យាដែល
បានពោលថា «ច្បាប់ជាផលនៃសង្គម» ។ នៅក្នុងន័យនេះ,

លោក ឌួកហ៊ីម ពោលថា «ច្បាប់ដែលជានិយាមរបស់សង្គម ដូចជាគតិបណ្ឌិត - ទំនៀមទំលាប់ឬជាប្រពៃណីជាដើម សុទ្ធសឹងតែមានលក្ខណៈដូចច្បាប់ដែរ ។ ប៉ុន្តែ លោកឌួកហ៊ីម, ក៏បានថ្លែងបញ្ជាក់ទៀតថា «សង្គមពិតប្រាកដតែងតែពេញទៅដោយគុណវិបត្តិ និងអសុក្រឹតភាព» ។

ហេតុដូច្នេះហើយ បានជាយើងឃើញថា, ច្បាប់ដែលជានិយាមសង្គមឬជាផលនៃសង្គមនេះច្រើនតែពេញទៅដោយអយុត្តិធម៌ និង អសុក្រឹតភាព ។ ឧទាហរណ៍ : «សូក្រាតត្រូវបានគេយកច្បាប់អយុត្តិធម៌មកកាត់ទោស ក្រោយទើបបញ្ជាឲ្យសំលាប់ដោយទឹកថ្នាំពុលស៊ីក (cigue) ។ ដោយសារច្បាប់ ពិតជាផលរបស់សង្គមនេះហើយបានជាច្បាប់បានបាត់បង់នូវសីលធម៌នៃការរស់នៅខ្លួនឯងម្ដង ។ ហេតុក្លាយទៅជាឧបករណ៍សំរាប់ឈ្លានពានដល់ទ្រឹស្ដីទៅលើសិទ្ធិមនុស្ស ។ ឧទាហរណ៍ : សង្គមអាល្លឺម៉ង់សម័យសង្គ្រាមលោកលើកទីពីរ បានបង្កើតច្បាប់សម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វ (Juif) ។ ច្បាប់នេះជាផលរបស់សង្គមអាល្លឺម៉ង់សម័យនោះ បង្កើតដោយលោកហ៊ីត្លែរ (Hitler) ដើម្បីសងសឹកដល់ប្រជាជាតិអាល្លឺម៉ង់ដែលពួកជ្វីហ្វបានជញ្ជក់ឈាមជនជាតិនេះអស់កាលជាយូរណាស់មកហើយ ។

ច្បាប់របស់ហ៊ីត្លែរមានលក្ខណៈសង្គមសុទ្ធសាធ, ថ្វីបើថាច្បាប់នេះសីលធម៌, មនុស្សធម៌, ក៏ប៉ុន្តែឃើញថាច្បាប់នេះត្រូវពួកអាល្លឺម៉ង់សម័យនោះនាំគ្នាគោរពទាំងស្រុង ។ ដែលជាហេតុធ្វើឲ្យឃើញថា «ច្បាប់ជានិយាមរបស់សង្គម និងជាផលនៃសង្គមពិតមែន» ។ ដែលមានលក្ខណៈពោលទៅតាមវិវត្តន៍របស់សង្គមជាពិសេសគឺការលះបង់នៃសង្គមនោះផង ។

* *

# ១៧. គ្រួសារ

(La Famille)

**297-** អ្វីទៅហៅថា « គ្រួសារ » ?

គ្រួសារ គឺមនុស្សមួយក្រុម ដែលបានរួមរស់នៅក្រោមដំបូលផ្ទះជាមួយគ្នា ។ ឧទាហរណ៍ - ប្តី - ប្រពន្ធ - កូន ។ល។ ឬជាសមាជិកជាញាតិវង្ស ដែលមករួមរស់នៅក្នុងផ្ទះជាមួយគ្នា។ បើតាមអ្នកប្រាជ្ញផ្នែកសង្គមវិទ្យាពោលថា " គ្រួសារជាកោសិការស់ ( Cellule vivante ) នៃសង្គម ។

**298-** តើពីបុរាណកាល សម័យដែលមនុស្សមានពុទ្ធិ (La Connaissance) ពុំមានផ្ទះសាល, គេច្រើនសំគាល់អ្វីជាគ្រួសារ ?

ពីបុរាណកាល សម័យដែលមនុស្សមានពុទ្ធិពុំទាន់ផ្ទះសាល, គេច្រើនសំគាល់ថាជាគ្រួសារនូវ « បក្សសត្វនៃតូតិម » ( Clan totémique ) ពោលគឺមនុស្សមួយក្រុមដែលជឿថា គេទាំងឡាយមានដូនតាជាមួយគ្នា ។ គេបានសំរេចសាងរូបតំណាងដូនតានោះដើម្បីទុកគោរពបូជារួមគ្នា ។ ក៏ប៉ុន្តែគេបានសង្កេតឃើញថា តំណាងរបស់តូតិមនៅក្នុងគ្រួសារនៃកុលសម្ព័ន្ធសម័យបុរាណ ឬ គេរើសយកសាច់ស្រែពាលនៃពិភពលោកសម័យបច្ចុប្បន្ន មានគំនិតលន្ទង់ត្បាជាងតំណាងសាច់សារលោហិត ឬ តំណាងគ្រួសារស្វាយ ញោស់ ។ លោកហ្វ្រេស៊ើ ( Frazer ) បានបញ្ជាក់ក្នុងន័យនេះថា៖

« តំណាងដែលកើតឡើងដោយនិមិត្តរូបតូតិម ( Totem )

មានកំលាំងខ្លាំងជាងចំណងសាច់សារលោហិត និងចំណង គ្រួសារ" ។ (Le lien créé par le totem est plus fort que le lien de sang ou de famille)

**299- តើពាក្យថា "តូតឹម" (Totem) មានប្រភពពីណាមក?**

ពាក្យ "តូតឹម" ជាពាក្យរបស់ពួកក្នុងស្បែកក្រហមរស់នៅ ក្នុងទ្វីបអាមេរិកខាងជើង, សំរាប់សំគាល់រូបតំណាងរបស់ខ្លួន, ដែលសាងឡើងដោយឈើចម្លាក់លាបថ្នាំ មានសភាពជា បង្គោលសរសរ ហើយមានរូបផ្សេងៗ ។ ពាក្យ "តូតឹម" ត្រូវ អ្នកប្រាជ្ញខាងមនុស្សវិទ្យា (Ethonlogue) ជាតិអង់គ្លេស ឈ្មោះ ជ.ឡុង (J-Long) យកមកប្រើមុនគេក្នុងមនុស្សវិទ្យា នៅឆ្នាំ ១៧៩១ ។

**300- ក្នុងសម័យបច្ចុប្បន្ននេះ, តើកុលសម្ព័ន្ធណាដែលបាន រស់ក្នុងសភាព "តូតឹម" នៅឡើយ ?**

ក្នុងបច្ចុប្បន្នកាលនេះតូតឹមនៅមាននៅឡើយក្នុងពិភពលោក គឺកុលសម្ព័ន្ធនៅប្រទេសអូស្ត្រាលី, ពួកក្នុងស្បែកក្រហមនៅ ទ្វីបអាមេរិកខាងជើង, កោះនៅក្រោយទ្វីបអូស្យានី, នៅ ប្រទេសឥណ្ឌាបែកខាងកើត, នៅក្នុងទ្វីបអាហ្វ្រិក និងទ្វីប អាស៊ីសប្បុរសាវីយាន ។

**301- តើនៅក្នុងលោក រចនាសម្ព័ន្ធនៃគ្រួសារនិមួយៗដូច គ្នាឬទេ ?**

នៅក្នុងសកលលោក គ្រួសារនិមួយៗមានរចនាសម្ព័ន្ធមិន ដូចគ្នាទេ ។ គ្រួសារនិមួយៗមានផ្ទាល់តាមផ្នត់គំនិតរបស់ក្រុមគ្រួសារ ។

ម្តាយគេបានគោរពម្តាយ ដូចជាព្រះមាតាទេព្រោះទាំងបាន
ប្រគល់អំណាចគ្រប់គ្រងក្នុងគ្រួសារទៅឲ្យម្តាយគ្រប់គ្រង ។
បច្ចុប្បន្ន គេសង្កេតឃើញមានបណ្តាប្រទេសមានទឹកដីតូចៗ
ដែលគេហៅថា "ភូមិ" ។

គ្រួសារប្រភេទនេះ, គេហៅថាគ្រួសារមេបញ្ជា
(famille matriarcale) ។

គ្រួសារប្រភេទទី២ៈ ឪពុកជា ឪពុកបង្កើតកូនប្រុស ។
គេបានសារភាពថាឪពុកជាធំ, ព្រោះទាំងឪពុកជាអ្នកដឹកនាំ
ក្នុងគ្រួសារ ដែលតែងតែគេហៅថា ៖

"គ្រួសារបិតុភូត" (famille paternelle, នៅក្នុង
គ្រួសារដែលនិយមទុកឪពុកជាធំ, គេឃើញមានគ្រួសាររ៉ូម៉ាំង
(famille de type romain) គ្រួសារអាល្លឺម៉ង់ (famille
germanique) ។ល។

302- អ្វីទៅហៅថា "អាពាហ៍ពិពាហ៍" ?

ដែលហៅថា "អាពាហ៍ពិពាហ៍" គឺការផ្សំផ្គុំជាគូស្រករ,
ជាស្ថាប័នរវាងប្រុសម្នាក់និងស្រីម្នាក់ ដើម្បីបង្កើតគ្រួសារថ្មី
មួយទៀត ។ គឺជាពិធីមួយក្នុងចំណោមពិធីទាំងឡាយរបស់
ច្បាប់សង្គមមនុស្ស ដើម្បីភ្ជាប់ជាស្ថាប័នពីចំណងស្នេហា
រវាងប្រុសម្នាក់និងស្រីម្នាក់ ។

303- តើការប្រកាសជាផ្លូវការដោយពិធីមួយដើម្បីភ្ជាប់
ពីចំណងស្នេហារវាងស្រីម្នាក់ និង ប្រុសម្នាក់ នៅក្នុង
សង្គមមនុស្សត្រូវមានលក្ខខណ្ឌអ្វីខ្លះជាចាំបាច់ ?

ពិធីប្រកាសចំណងស្នេហា ផ្លូវការដែលយើងនិយមហៅថា "អាពាហ៍ពិពាហ៍" នោះ ត្រូវទទួលផលត្រឹមត្រូវតាមលក្ខណៈច្បាប់ការ, លុះត្រាតែសាមីខ្លួនប្រុសនិងស្រីមានបំពេញល័ក្ខខ័ណ្ឌខ្លះដូចតទៅនេះ ៖

១ - ល័ក្ខខ័ណ្ឌសម្ភារៈ (conditions matérielles)

២ - ល័ក្ខខ័ណ្ឌមេត្តា (conditions affectives)

៣ - ល័ក្ខខ័ណ្ឌសង្គម (conditions sociales)

៤ - ល័ក្ខខ័ណ្ឌសីលវិជ្ជា (conditions morales) ។

304 - អ្វីទៅហៅថា « ល័ក្ខខ័ណ្ឌសម្ភារៈ » នៅក្នុងអាពាហ៍ពិពាហ៍ ?

ដែលហៅថា "ល័ក្ខខ័ណ្ឌសម្ភារៈ នៅក្នុងអាពាហ៍ពិពាហ៍គឺ.

១ - សាមីខ្លួនទាំងប្រុសស្រី ត្រូវមានសុខភាពគ្រប់គ្រាន់ ។

២ - ត្រូវមានរបរចិញ្ចឹមជីវិតដើម្បីសាងគ្រួសារដោយខ្លួនឯង ។

៣ - ត្រូវមានគេហដ្ឋាន ឬ ប្រាក់កាសគ្រប់គ្រាន់ដើម្បី ធ្វើជាផ្ទះដែលមានលក្ខណៈជាគុណធម៌ សម្ភារៈសំរាប់ផ្ទះ ទាំងក្រៅ ( ចំណងដៃ , បណ្ណាការ និង គ្រឿងឧបភោគ ) ។

៤ - សម្ភារៈគ្រាប់ទិសនោះ ។ នៅសង្គមបច្ចុប្បន្នគេតែងត្រៀមដាក់ពិធីនោយកូនប្រុសទៅរកបង់ទ្រព្យតំលៃ ដើម្បីជាថ្លៃដោះស្រូវមាតាបិតាកូនស្រីដែលការគោរព ឬ ទ្រព្យគ្រឿងលម្អខ្លះទៀត

អោយធ្វើ ។ ដូចជាត្រូវជួយគ្នាវែស្រ ឧត្តកគ្នក អោយបាន ទាន់ពេលវេលា ។ ល ។

៥-ផ្លូវការ សម្ភារៈអាចក្លាយទៅជាសមត្ថភាពផ្ទាល់របស់ សាមីខ្លួនប្រុស ឬស្រីថែមទៀតផង ។

ឧទាហរណ៍ ៖ ព្រះរាមត្រូវលើកធ្នូសរបស់ ព្រះបាទជនករាជ ទើបបាននាងសីតាជាមហេសី ។

នាងកែវណារ៉ាត្រូវរកទឹកដោះខ្លាកូនលំបូងបាន ទើបអាច អភិសេកជាមួយនឹងព្រះរាជបុត្រស្ដេចបាន ។

សង្គមសម័យបច្ចុប្បន្ន , កូនប្រុសត្រូវមានសញ្ញាប័ត្រខ្ពង់ខ្ពស់ , ទ្រព្យសម្បត្តិ ឬ គុណសម្បត្តិណាមួយដែលមានតំលៃជាសម្ភារៈ ទើបអាចរៀបអាពាហ៍ពិពាហ៍និងកូនស្រីរបស់ អភិជនណាម្នាក់បាន ។

## 305-អ្វីទៅហៅថាសក្ដិអំណារវេទនា ?

ដែលហៅថា «សក្ដិអំណារវេទនា» គឺសក្ដិអំណាមួយដែល សង្គមតំរូវអោយ សាមីខ្លួនប្រុស និង ស្រីមានសេចក្ដីស្នេហា រាប់អានគ្នាទៅវិញទៅមកផង ។ គូស្វាមីភរិយាពុំត្រូវទទួលការ តំរូវតែលក្ខខណ្ឌណាក់មាតាបិតារបស់ខ្លួនឡើយ ។ ហេតុ ដូច្នេះហើយបានជាក្នុងពិធីអាពាហ៍ពិពាហ៍ «មេឃុំ» ត្រូវសួរ ជាផ្លូវការចំពោះមុខ គឺជនទាំងពីររបស់គូស្វាមីភរិយាទាំងពីរជា មុនសិន ដើម្បីបញ្ជាក់ពីវេទនា ( affectivité ) ក្នុងសេចក្ដី ស្នេហារបស់អ្នកទាំងពីរនេះ ។

ឧទាហរណ៍ ៖ មេឃុំត្រូវសួរថា ៖

« លោកស្រី - តើលោកព្រមទទួលការ « ទីកា » ជាភរិយាឬទេ ? » .

បាទ ! - (ពេលនោះគេឃុំត្រូវសួរទៅនាងស្រីវិញថា : « នាង « ទីកា » តើនាងសុខចិត្តទទួលលោកសុខជាស្វាមីឬទេ?)

• បាទ ! - ។ លុះអ្នកទាំងពីរនាក់ឆ្លើយដូច្នេះហើយ មេឃុំ, ប្រកាសជាឱឡារិកថា :

« នៅក្នុងនាមនៃច្បាប់, ពីថ្ងៃនេះទៅអ្នកទាំងពីរត្រូវមានសិទ្ធិនៅរួមរស់ជាមួយគ្នា, ព្រោះពិធីពេលរៀបការហើយផ្លូវការរួចហើយ ! » ។

នេះហើយជាលក្ខខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ ។

## 306- អ្វីទៅហៅថា « លក្ខខ័ណ្ឌ » សង្គម ?

ដែលហៅថា « លក្ខខ័ណ្ឌសង្គម » គឺលក្ខខ័ណ្ឌដែលស្ត្រី ស្វាមីភរិយាត្រូវបំពេញចំពោះសង្គមដែលខ្លួនរស់នៅ ។

គឺជាលក្ខខ័ណ្ឌស្របទៅនឹងច្បាប់របស់សង្គម ។ ម្យ៉ាងថា សង្គមតម្រូវអ្នកទាំងពីរអោយបំពេញលក្ខខ័ណ្ឌ ដែលមានលក្ខណៈជាការគួរពិត ។ សង្គមមានចំណូលចិត្តត្រូវចំពោះគូវិវាហ៍ទាំងឡាយនៃសមាជិករបស់ខ្លួន នៅក្នុងការពង្រីកគ្រួសារ ។ ហេតុដូច្នេះហើយបានជាគេឃើញលោកមេឃុំឬចៅសង្កាត់ បញ្ជាអោយមាតាបិតា ឬអ្នកមានអាណាព្យាបាល .នៃសាមី អាពាហ៍ពិពាហ៍ប្រកាសការត្រៀមបម្រុងសិន ដូចជាអត្តសញ្ញាណអោយគេដឹងពីអាពាហ៍ពិពាហ៍នោះ ។ គឺជាកិច្ចសន្យាជាសាធារណៈ គិតជាផ្លូវការនៃអ្នកទាំងពីរទៅចុងទៅ

ក្រុម ដោយមានសាក្សី និងត្រូវសារទៀតកំរើអវិញមិនចូលស្គាល់ ផង ។ គេហៅលក្ខណៈច្បាប់សង្គម ដែលត្រូវបញ្ជាក់ឡើង ដោយសំបុត្រ អាពាហ៍ពិពាហ៍ ។ ផ្ទុយការពិតបានបន្ថែមពិធី ក្នុងផ្លូវសាសនា ដោយសូមអោយព្រះធម៌ថ្វាយៈបុគ្គល ឬ វត្ថុ សក្ដិសិទ្ធិជួយតែងតាំងចំពោះក្រុមគ្រួសារថ្មីនេះផងដែរ ។

307- អ្វីទៅហៅថាលក្ខខណ្ឌខាងផ្លូវសីលវិជ្ជា ?

ដែលហៅថា «លក្ខខណ្ឌខាងផ្លូវសីលវិជ្ជា» គឺលក្ខខណ្ឌ ដែលគ្រួសារទាំងសង្កាត់តាមបន្ទំសាមីភរិយាត្រូវពិតាហ៍អោយ សញ្ញាចំពោះខ្លួនដោយលាយលក្ខណ៍អក្សរ ខានចុះហត្ថលេ- ខាត្រឹមត្រូវចំពោះមុខសាក្សី ដើម្បីជាភស្តុតាងការពារសេចក្ដី សុខទាំងសងខាង ។

ឧទាហរណ៍ : ប្ដីត្រូវមានលក្ខណៈខាងផ្លូវសីលគុណធម៌ (vertu morale) ជាមនុស្សពិតហើយមានសិទ្ធិ ( droit ) គ្រប់គ្រងភរិយាទៅតាមច្បាប់ មនុស្សពិតប្រាកដ ។ ហាម ផ្ដាច់ពុំអោយភរិយា ទៅធ្វើការបណ្ដើរប្រើប្រាស់ការ សំឡាញ់ការគុណ ។ ពេលតែបំរើអោយភរិយាដែលខ្លួនបាន រៀបការទៅអោយធ្វើជាស្រីផ្ដាសា ។ បង្ខំសេព សន្ធនៈពេលប្រពន្ធមានផ្ទៃ ឬ ក្នុងពេលឈឺ ( ការប្រព្រឹត្តបែប នេះសុទ្ធតែច្បាស់ជាពុំទាន់ហើយបញ្ហាល ដោយភរិយា ទទួលរំលោភ ត្រូវច្បាប់ផ្ដន្ទាទោសទៅតាម ផ្សេងៗតាមច្បាប់សង្គម ) ។

ខាងមាតាបិតាវិញ ទាល់តែច្បាប់អោយកូនប្រុសស្រីព្រម ព្រៀងគ្នាអាស្រ័យតាម ចំពោះមុខច្បាប់និងទៅក្រុម ,

ដោយជៀសវាងអំពើលោភលន់ការទទួលកំរៃបាត្តូនដោយ ផ្លូវកុសលកម៌ ។ ដើម្បីបំពេញ ចំពោះបញ្ញើស ជួន កាលត្រូវបញ្ហាជាទោសនិងជាចំនួនច្រើនកំនត់ទៅខ្លួនឯង ។

**308- អ្វីទៅហៅថា “ ជាតិប្រមាណ ” ? ( La Natalité )**

ដែលហៅថា “ជាតិប្រមាណ” គឺការត្រួតពិនិត្យនូវស្ថិតិនៃកំណើតរបស់មនុស្ស នៅក្នុងរដ្ឋ-ប្រទេសនីមួយៗ ។ ជាតិប្រមាណជាវិចារណការណ៍ របស់បញ្ហានយោបាយ និងសេដ្ឋកិច្ច ។ គេត្រូវការ ចង់ដឹងចំនួន មនុស្សកើត, មនុស្ស ដែលកំពុងរស់នៅរយៈពេលបញ្ហាក៏ត្រូវគេចែកមនុស្សទៅតាម លំដាប់អាយុខុសគ្នាត្រូវចែកជា : មនុស្សចាស់, មនុស្សពេញវ័យ, មនុស្សជំទង់, កូនក្មេង ។ ល ។

ការចំនួនមនុស្សស្លាប់ក៏ជាមុខងារនៃការស្រាវជ្រាវនៃ ជាតិប្រមាណដែរ ។ សព្វថ្ងៃមនុស្សត្រូវការ ចង់ដឹងចំនួនសមាជិក របស់ខ្លួនយ៉ាងត្រឹមត្រូវបំផុត ដើម្បីរៀបចំវេគាសម្ព័ន្ធសង្គម នយោបាយ - សេដ្ឋកិច្ច និងអប់រំអោយស្របទៅតាមកាល សម័យនិងកាលៈទេសៈនៃសតវត្ស ។

*
*   *

# ១៨. យុត្តិធម៌ និង ការគោរពបុគ្គល- សប្បុរសធម៌

(La Justice et le respect de la personne La charité)

309- អ្វីទៅហៅថា "យុត្តិធម៌" ?

យុត្តិធម៌គឺគុណធម៌ប្រកបដោយឧត្តមគតិសកល, ជាគំនិតល្អ ត្រឹមត្រូវតែមួយ ដែលហូរចេញមកពីចារណាការណ៍ មនុស្សជាតិ ។ ជួនកាល « យុត្តិធម៌ » មាននិយមន័យថា :

"ការគោរពយ៉ាងទៀងទាត់នូវសិទ្ធិរបស់ជនម្នាក់ៗ ពោល គឺការបើកអោយជនម្នាក់ៗ មានសិទ្ធិរបស់ខ្លួន" ។

310- តើយុត្តិធម៌អាចចែកជាប៉ុន្មានសណ្ឋាន ?

យុត្តិធម៌អាចចែកជាបីសណ្ឋានគឺ :

១- យុត្តិធម៌ក្នុងការប្តូរ

២- យុត្តិធម៌ក្នុងការចែក

៣- យុត្តិធម៌ក្នុងការបង្គាប់

311- អ្វីទៅហៅថា « យុត្តិធម៌ » ក្នុងការប្តូរ ?

ដែលហៅថា "យុត្តិធម៌ក្នុងការប្តូរ" គឺការត្រឹមត្រូវតែ ល្មមៀងក្នុងការប្តូរ ។ គេអាចពោលថាការប្តូរមានយុត្តិធម៌ កាលណាការប្តូរនោះ បង្ហាញរបស់ដែលបានដោយស្មើគ្នាមក ប្តូរ ។ គឺយុត្តិធម៌ស្ថិតនៅលើសមមូល ( équivalence ) នៃរបស់ក្នុងការប្តូរនោះឯង ។

12- អ្វីទៅហៅថា « យុត្តិធម៌ក្នុងការចែក » ?

ដែលហៅថា "យុត្តិធម៌ក្នុងការចែក" គឺយុត្តិធម៌ដែលមនុស្សទាំងឡាយទទួលស្គាល់ថា ត្រឹមត្រូវទៅតាមដែលខ្លួនបានទទួលរង្វាន់ជាថ្នូរនៃកំលាំង - ស្មារតី - និងតំរូវការរបស់ខ្លួន ។ គឺថាចំណែកដែលគេបានទទួលអំពីដៃនៃមនុស្សយុត្តិធម៌ម្នាក់ ឬពីច្បាប់នៃសង្គមរបស់ខ្លួន ។

313 - អ្វីទៅហៅថា "យុត្តិធម៌ក្នុងការបង្ក្រាប" ?

ដែលហៅថា "យុត្តិធម៌ក្នុងការបង្ក្រាប" គឺជាយុត្តិធម៌ដែលមានលក្ខណៈជាសមភាពសមាមាត្រ ។ ជាការបង្ក្រាបមួយបែបដែលចាប់អ្នកមានពិរុទ្ធ អោយទទួលកំហុស ឬ សងជម្ងឺចិត្តជនរងគ្រោះអោយស្មើនិងចំនួនតែកំហូចខាត ។ លោក តាល្យ៉ុង យល់ថា "បើជនណាធ្វើអោយខូចភ្នែកអ្នកដទៃត្រូវសងភ្នែករបស់ខ្លួនមកគេវិញ, ឬបើនរណាធ្វើអោយគេបាក់ធ្មេញត្រូវតែសងធ្មេញទៅគេវិញ" ហេតុដូចនេះហើយបានជាគេតែងនិយាយពោលពីយុត្តិធម៌បង្ក្រាបរបស់លោកតាល្យ៉ុងនេះដែលតែងនៅច្បាប់ថា : "យកភ្នែកទៅសងភ្នែក, យកធ្មេញទៅសងធ្មេញ" តែបច្ចុប្បន្នកាលនេះច្បាប់ពាក់ព័ន្ធអោយគេ បញ្ឈប់ចេញពីលោកតាល្យ៉ុង គឺសងតំលៃខូចខាតអោយ ការសងជាប្រាក់ដែលសមគួរនៃតំលៃណាមួយជាទីពេញចិត្ត នៃអ្នករងគ្រោះនោះ ។

314 - តើរហូតមកដល់សព្វថ្ងៃនេះ យុត្តិធម៌ពិតកើតមាននៅក្នុងសង្គមមនុស្សឬទេ?

សង្គមនេះយុត្តិធម៌ពិតពុំកើតបានទៅក្នុងលោកទេ ។ ព្រោះគេពុំឃើញមានសហប្រមូលតែកំលាំងអំណាច ដែលជារូបបគ្គនៃយុត្តិធម៌នេះសោះ ។

ឧទាហរណ៍: ទៅក្រៅពុំសួរយកច្បាប់យុត្តិធម៌ពិតប្រាកដមកកាត់ក្តីឡើយ ។ លោកសូក្រាត មហាទស្សនៈវិទូក្រិកស្លាប់ដោយពេរក្រម, ពុំមែនស្លាប់ដោយច្បាប់នៃប្រទេសក្រិកទេ ។ លោករូស្សូបានចុតស្នាដៃសរសេររបស់លោកស្តីពី «វិសមភាព» (l'inégalité) នៃសង្គមមនុស្សសម័យសតវត្ស ទី ១៨ ហើយដែលមានរូបលោកជា សមាជិកក្នុងសង្គមនោះផងដែរ ។ បណ្ឌិតយល់ឃើញថា, "មនុស្សមានវិសមភាពតាំង ពីកំណើតមកម្ល៉េះព្រោះមនុស្ស ជាសត្វលោកដែលរស់នៅក្នុងធម្មជាតិ, ហើយធម្មជាតិនេះឯងជាប្រភពនៃ «វិសមភាព» ដែលគេហៅថា "វិសមភាពធម្មជាតិ (inégalité naturelle) ។ ឧទាហរណ៍: វិសមភាពនៃកោសល្យគិត សម្បុរខ្មៅស សុខភាព, បញ្ញាគិត ចរិយារបស់មនុស្សដែលមានពីកំណើតមក ។ គឺប៉ុន្តែបណ្ឌិត ជាទយល់ច្រាស់ថាច្បាប់ទាំងអស់សុទ្ធតែយុត្តិធម៌, គឺអ្វីដែលទេ ពិច្បាប់សុទ្ធតែយុត្តិធម៌ទាំងអស់ ។ លោកប្លាតុង (Platon) សាវ័ក របស់សូក្រាតក៏ពោលមកថា, ប្រទេសច្បាប់របស់រាជ្យទេក្បួនណាមួយដែលមានយុត្តិធម៌ពិតប្រាកដ, ហើយ យុត្តិធម៌ដែលជា "ឧត្ដម:" នោះស្ថិតនៅតែក្នុង "បុរីអាទិទេព" ណាណាទេ ។

ទ្រឹស្តីតែអត្ថន័យទាំងឡាយក្នុងសង្គមលោក. ទំនួលគាសម្ពន្ធនៃការរស់នៅរបស់មនុស្សនោយមានយុត្តិធម៌ខ្លះ, ក៏

ប៉ុន្តែគេនៅតែសង្កេតឃើញថា «មនុស្សដែលជាអ្នកប្រព្រឹត្ត
ខូចអំពើទាំងឡាយ បានរំលោភលើគតិសន្យារបស់ខ្លួន ក្រោយ
ទាំងហ៊ានបំពានបំពានលើសេរីភាពនិងសិទ្ធិរបស់មនុស្សដែល
ច្បាប់បានតំរូវអោយគោរពដដែល ។ សរុបសេចក្តីមក,
«អយុត្តិធម៌ក្នុងសង្គមក្តី, ក្នុងពុទ្ធលក្តីសុទ្ធតែកើតមកពីមនុស្ស
ប្រព្រឹត្តខុសធម្មជាតិ , ព្រោះតែមនុស្សបរិភោគបរិនាសរព្ធគតា
ផង, បរិភោគមហិច្ឆតាផង ។

## 315 - អ្វីហៅថា «សប្បុរសធម៌» ?

ដែលហៅថាសប្បុរសធម៌ គឺគុណធម៌ពិសេសរបស់មនុស្ស
ទាំងឡាយណាដែលមានចិត្តល្អនិងមនុស្សធម៌ ។

ជនដែលមានចិត្តសប្បុរស, ជាជនដែលមានគុណៈប្រកប
ដោយឧត្តមគតិមនុស្សជាតិ, មានព្រហ្មវិហារនិងចិត្តប្រណី
បេត្តា ( persévérauce ) ។

## 316 - គេបានពោលថា «ការធ្វើទានជាអំពើប្រកបដោយ លក្ខណៈអយុត្តិធម៌ក្នុងសង្គម ។ តើអ្នកយល់យ៉ាងដូច ម្តេចចំពោះមតិនេះ ?

ច្បាប់សប្បុរសធម៌បានបញ្ជាប់នៅក្នុងសីលវិជ្ជាថា អោយជន
ទាំងឡាយធ្វើទាន ។ ទោះបីទានោះតិច ឬច្រើនក្តី, ល្អ ឬ
ពុំល្អដោយបាច់ប្រសើរក្តី ក៏គេនិយមអោយតំលៃទៅលើទឹក
ចិត្តសប្បុរសធម៌នេះណាស់ ។

ការធ្វើទានសព្រោះអ្នកក្រីក្រកំសត់ទុរគត ដោយផ្តល់អោយ
នូវគ្រឿងឧបភោគបរិភោគ, សំលៀកបំពាក់ ថ្នាំពេទ្យ និង

ជាសមាជិកក្នុងសង្គមរបស់ខ្លួន, ជាអំពើអយុត្តិធម៌ដែល "ច្បាប់ត្រូវ" របស់អាទិទេពផ្តន្ទាទោសអ្នកកាន់អំណាចនៃសង្គមនោះដោយពុំអាចប្រកែកបាន ។

ទស្សនៈដែលពោលខាងលើនេះ ជាច្បាប់របស់មនុស្សម្នាក់ៗ ដែលបានទទួលមរតកពីធម្មជាតិ នូវសិទ្ធិរបស់ខ្លួន, ហើយសិទ្ធិនេះត្រូវតែហ៊ានផ្តន្ទាច្បាប់សង្គមណា ដែលទទួលស្គាល់ថា "មនុស្សទាំងអស់គ្មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់" តែផ្ទុយទៅវិញ សង្គមនោះបានព្រងើយកន្តើយនឹងសមាជិករបស់ខ្លួនចំពោះសិទ្ធិរកស៊ីនិងការរស់នៅរបស់បុគ្គលទៅវិញ ។

*

* *

ទីលំនៅ ដើម្បីស្នាក់អាស្រ័យផាសុកភាពបញ្ជាក់អោយឃើញ នូវតំលៃនៃសប្បុរសធម៌, ព្រោះថាសីលវិជ្ជាក្តី, ច្បាប់សង្គមក្តី ពុំបានដាក់កំហុសទោសលើអំពើល្អ ដែលគេចាត់ទុកថា ជាឧត្តមគតិមនុស្សជាតិនេះសោះឡើយ ។

ក៏ប៉ុន្តែ, មានគំនិតមួយទៀត ដែលពោលអះអាងថា ស្គាល់តំលៃពិតរបស់មនុស្ស នោះមិនកៀនចំពោះសប្បុរសធម៌នេះទេវិញ ។ មតិនោះបានជឿថា, ការខ្វល់អោយស្នាក់អាស្រ័យក្តី, ការអត់អោនដោយមានសន្យាស្រ័យ, ការសង្គ្រោះ (assistance) ការប្រណីមេត្តាក្តី សុទ្ធតែជាសញ្ញានៃតំរូវការរបស់យុត្តិធម៌ ។ ពោលគឺពុំមែនជាយុត្តិធម៌របស់សង្គមលោកពិតប្រាកដទេ, តែជាគ្រឿងថ្នួងបន្ថំសំរាប់សាងការជិះជាន់គេទៅទៀត ។ គេបានសន្មតថា អ្វីដែលមិនយុត្តិធម៌ គឺអយុត្តិធម៌, បើអយុត្តិធម៌ហើយសុទ្ធតែខុសនឹងច្បាប់មនុស្សជាតិទាំងអស់ ។ គេជឿថា ការធ្វើទានដែលជនណាម្នាក់ ធ្វើទៅលើស្មូមយាចកមួយរូប, គឺជានាំអោយស្មូមយាចកនោះ មានការអាម៉ាស់មុខជាទីបំផុត, ហើយអ្នកធ្វើទាន ជាមនុស្សកំណាចទៅវិញ, ព្រោះបានធ្វើតែអោយអាម៉ាស់មុខចំពោះសង្គមមនុស្ស ។

មនុស្សនេះនោះបានបញ្ជាក់ថា ពួកអ្នកក្រីក្រជាបន្ទុករបស់សង្គម, ដូចនេះសង្គមត្រូវតែធ្វើច្បាប់សំរាប់ជួយពួកទាំងនោះអោយជិតដល់, ប្រៀបដូចមាតាដែលមានភារៈត្រូវតែចិញ្ចឹមកូនរបស់ខ្លួនយ៉ាងដូច្នេះដែរ ។ ការបណ្តោយអោយមនុស្សក្រតោកស៊ុំទាល, ការពុំគិតបញ្ហារបស់មនុស្សទាំងឡាយដែល

# ១៩ បញ្ហាសេដ្ឋកិច្ច

(Problème économique)

**317** - អ្វីទៅហៅថា «សេដ្ឋកិច្ច» ?

ដែលហៅថា «សេដ្ឋកិច្ច» គឺសិល្បៈដ៏ប្រសើរក្នុងការ ចាត់ចែងចំណូល និងចំណាយនៅក្នុងគ្រួសារ, ការចាយវាយនិងការចូលមកវិញយ៉ាងប្រសព្វនៃថវិកា. សម្បត្តិទ្រព្យ ឬផលិតកម្មរបស់បុគ្គលម្នាក់ ឬរដ្ឋប្រទេសណាមួយ ។

**318** - តើសញ្ញាណនៃ «សេដ្ឋកិច្ច» នៅបុរិមប្រទេស គេយល់ថាកើតមកពីអ្វី ?

សញ្ញាណនៃ សេដ្ឋកិច្ច នៅបុរិមប្រទេស, គេយល់ថា កើតមកពីគំនិតសាសនាគ្រិស្ត គឺគេបានឃើញថា គណៈសង្ឃនៃសាសនាគ្រិស្ត បានអោយគំនិតបង្កើតនូវទ្រឹស្តីពីរយ៉ាងគឺ : ទ្រឹស្តីតំលៃត្រឹមត្រូវ (théorie du juste prix) និង ទ្រឹស្តីការប្រាក់ត្រឹមត្រូវ (théorie du juste intérêt) ។

**319** - អ្វីទៅហៅថា «សេដ្ឋកិច្ចនយោបាយ» ?

ដែលហៅថា សេដ្ឋកិច្ចនយោបាយ គឺសុទ្ធតែភាពវិយោគ ពុទ្ធិនៃធាតុភូត (connaissance des phénomènes) ការផលិតចាយ, បរិភោគនិងប្រើប្រាស់នូវភោគទ្រព្យធម្មជាតិ ឬ ពុទ្ធិនៃធាតុភូត ដែលសិក្សាពីកេតនភ័ណ្ឌ សម្ភារៈ នៅក្នុង សង្គមមនុស្ស ។

**320** - តើសេដ្ឋកិច្ចនយោបាយ មានកម្មវិធីសិក្សាយ៉ាងដូចម្តេចខ្លះ ?

សេដ្ឋកិច្ចនយោបាយមានកម្មវត្ថុសិក្សាដូចតទៅ ៖

១. តម្រូវការនិងកត្តាទាំងឡាយនៃផលិតកម្ម ។

២. ការរៀបចំនូវផលិតកម្មតាមបែបសកល ។

៣. ការផ្ញើជំនួញ ឬ ទិញដូរ ភោគផល ។

៤. តំលៃផ្សេងៗនៃផលិតកម្ម ។

៥. អំពីដើមទុន ។

៦. ប្រាក់សំរាប់ចាយ ឬ រូបិយវត្ថុ ។

៧. របៀបចែកចាយនូវផលិតផល ។

៨. ចំណាត់ការនៃរដ្ឋាភិបាលក្នុងការផលិត , ចែកចាយនិងប្រើប្រាស់គ្រឿងឧបភោគ បរិភោគ ឬ ភោគផលទាំងនោះ ។

**321**- តាមទស្សនៈអ្នកសេដ្ឋកិច្ចសេរីនិយម (économiste-libéraliste) អ្វីទៅហៅថា "សេដ្ឋកិច្ចនយោបាយ" ?

ពួកអ្នកសេដ្ឋកិច្ចសេរីនិយម បានអោយនិយមន័យ ទៅលើ "សេដ្ឋកិច្ចនយោបាយ" ថា :

"ការសិក្សាអំពីច្បាប់ទាក់ទងការបង្កើតផល , ចាយចែកនិងប្រើប្រាស់ ភោគទ្រព្យផ្សេងៗ" គឺជានិយមន័យរបស់លោក ហ្សង់-បាទីស-សេ (Jean-Baptiste Say) (១៧៦៧-១៨៣២) អ្នកសេដ្ឋកិច្ចជាតិបារាំងម្នាក់ ។

**322**- ចុះចំពោះពួកសេដ្ឋកិច្ចសង្គមនិយម (économiste socialiste) វិញ តើយល់យ៉ាងដូចម្ដេចដែរ , ចំពោះពាក្យថា "សេដ្ឋកិច្ចនយោបាយ" ?

ចំពោះពួកអ្នកសេដ្ឋកិច្ចសង្គមនិយមយល់ថា “សេដ្ឋកិច្ចនយោបាយ គឺការសិក្សាអំពីសកម្មភាពមនុស្សក្នុងការផលិតសកម្មភាពនេះ ទាក់ទងជាមួយនឹងកោតគ្រឿងផ្សេង” ។

305- អ្វីទៅហៅថា «សេដ្ឋកិច្ច» ?

ដែលហៅថា “សេដ្ឋកិច្ចមនុស្ស” គឺ “សេដ្ឋកិច្ចនយោបាយដែលសិក្សាតែក្នុងទ័ណ្ឌនៃតំលៃខាងឆ្ងាយរបស់មនុស្ស” ។
ឧទាហរណ៍ :

(ទីលំនៅ - កំរិតជីវភាពប្រជាជន - លក្ខខណ្ឌនៃការងារ សុខភិបាល ។ល។ )

304- អ្វីទៅហៅថា «សេដ្ឋកិច្ចសង្គម» ?

ដែលហៅថា “សេដ្ឋកិច្ចសង្គម” គឺ «សំណុំពុទ្ធិដែលទាក់ទងនិងជីវភាពរស់កម្មករ - កសិករ ជាមួយនឹងការលើកស្ទួយកំរិតជីវភាពនៃអ្នកទាំងអស់នេះ ។ នៅដើមសតវត្សទី២០ “សេដ្ឋកិច្ចសង្គម” មានលក្ខណៈថា “សកម្មភាពជីវសេដ្ឋកិច្ច, សំណុំទង្វើដែលទាក់ទងនឹងការបង្កើនផល ការចែកនិងការប្រើប្រាស់នៃភោគផលទាំងនោះ” ។

305- តើសេដ្ឋកិច្ចនយោបាយ មានទំនាក់ទំនងជាមួយនិងសីលវិជ្ជាឬទេ ? ហេតុអ្វី ?

សេដ្ឋកិច្ចនយោបាយ មានទំនាក់ទំនងជាមួយនិងសីលវិជ្ជា កាលណាសេដ្ឋកិច្ចនយោបាយនោះជាឧបករណ៍ សំរាប់ជំរើជ្រើសរើស ឬគោលបន្ទាត់នយោបាយនៃលទ្ធិណាមួយ ។ ពិតមែនហើយថា “សេដ្ឋកិច្ចនយោបាយគឺជាស្នូលដែលសិក្សាតែពុទ្ធិ

នៃបាតុភូតរបស់ផលិតកម្ម - ការចែកចាយអោយប្រើប្រាស ប្រែប្រួលទៅតាមពេលវេលា, ក៏ប៉ុន្តែស្ទើរនឹងមានបាតុភូតផលិតកម្មការចែកចាយផលិតផលទៅលើមនុស្ស នៅក្នុងសង្គមរបស់ខ្លួនដែលមានតែការតាំងនៅក្នុងសំណុំនោះដែរ ។

ដូចនេះហើយបានជា ពុំអាចនឹងគេចរួចពីការសង្កត់សង្កិននៃសេដ្ឋកិច្ចនយោបាយបានឡើយ, កាលណាសង្គមនេះជាចាប់ផ្តើម ប្រើប្រាស់នូវលទ្ធិណាមួយ មកស្រាយហេតុនេះហើយ បានជាគេបើកសេដ្ឋកិច្ចនយោបាយស្ថិតនៅក្រោមកម្លាំងរបស់ "នយោបាយសេដ្ឋកិច្ច" ហើយដែលជាប្រភពកើតមានឡើងនូវ ស្ទើរសេដ្ឋកិច្ចទាំងប្រភេទសំរាប់ដំណើរនយោបាយសេដ្ឋកិច្ចពីគឺ : សេដ្ឋកិច្ចសេរីនិយម (économie libéraliste) និងសេដ្ឋកិច្ចសង្គមនិយម (économie socialiste) នេះឯង ។

## 326- អ្វីទៅហៅថា " នយោបាយសេដ្ឋកិច្ច " ?

ដែលហៅថា "នយោបាយសេដ្ឋកិច្ច" (Politique économique) គឺនយោបាយដែលធ្វើឲ្យដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសក្នុងសង្គមណាមួយ ដោយយកផលិតកម្ម, ពាណិជ្ជកម្ម និងបច្ចេកទេសនៃសេដ្ឋកិច្ច មកកែលម្អ បានបញ្ចូលទៅក្នុង "សេដ្ឋកិច្ចនយោបាយ" ផងដែរ ដើម្បីកែច្នៃប្រព័ន្ធឡើងវិញ ដើម្បីលើកស្ទួយជីវភាពនៃប្រជាពលរដ្ឋ ។

## 327- អ្វីទៅហៅថា " សេរីនិយមសេដ្ឋកិច្ច " ?

ដែលហៅថា "សេរីនិយមសេដ្ឋកិច្ច" គឺសេដ្ឋកិច្ចដែលបើកសេរីភាពអោយឯកជនគ្រប់គ្រង និងលក់ដោយសេរី ខ្លួនឯងផល

ផ្សេងៗការបំពេញកិច្ច , គឺជាវត្ថុធានសំណាច ចូលទៅក្រៀក ក្រែកក្នុងការត្រួតពិនិត្យតំលៃទិញ - លក់របស់ឯកជនឡើយ ។ ជាក្រុមហ៊ុនដែលបង្កើតដោយពួកមូលធន ( Capitalistes ) ។

328- អ្វីទៅហៅថា " សង្គមនិយមសេដ្ឋកិច្ច " ?

ដែលហៅថា " សង្គមនិយមសេដ្ឋកិច្ច " គឺសេដ្ឋកិច្ចដែលកើតដោយលោក " ការលម៉ាក់ " ( KARL - MARX ) ជាតិអាល្លឺម៉ង់នៅដើមសតវត្សទី ១៩ ។ ជាសេដ្ឋកិច្ចដែលបង្គាប់ប្រយោជន៍ដល់សម្ពុហភាពផលប្រយោជន៍រួមទាំងអស់ ( Intérêt collectif ) ដោយប្រគល់អំណាចដោយរដ្ឋកាន់កាប់សេដ្ឋកិច្ចទូទៅជំនួសឯកជន - គេហៅ គឺរដ្ឋជានាយទុន ( Etat patron ) ។

329- តើទ្រឹស្តីសង្គមនិយមសំខាន់ៗ នៅក្នុងលោកមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ទ្រឹស្តីសង្គមនិយមសំខាន់ៗ នៅក្នុងលោកមានបីយ៉ាងគឺ :

១ - ទ្រឹស្តីសង្គមនិយមហួសវិស័យ ឬទ្រឹស្តីកុំមុយនីស :
(socialisme utopique ou communisme)

២ - ទ្រឹស្តីសង្គមនិយមក្លាស៊ិចទាំងមូល :
(socialisme classique intégral) និង

៣ - ទ្រឹស្តីសង្គមនិយមក្លាស៊ិចធូ
(socialisme classique mitigé) ។

330- អ្វីទៅហៅថា "សង្គមនិយមហួសវិស័យ ឬកុំមុយនីស" ?

ដែលហៅថា «សង្គមនិយមហួសវិស័យ ឬ កុម្មុយនីស» គឺ លទ្ធិ «ខ្លួនសំខាន់និយម» លទ្ធិដែលប្រគល់ការគាំពារគ្រប់បែបយ៉ាងទៅអោយរដ្ឋជាតំណាង ព្រមទាំងទទួលស្គាល់ថា កម្មសិទ្ធិទាំងអស់ជារបស់រដ្ឋ» ។

331 អ្វីទៅហៅថា «សង្គមនិយមក្លាស៊ិចទាំងមូល» ?

• ដែលហៅថា «សង្គមនិយមក្លាស៊ិចទាំងមូល» គឺជារបបមួយ ដែលទទួលអោយរដ្ឋជាភាគរស់នៅរបស់ប្រជាជនទាំងមូលតែស្នើអោយរដ្ឋប្រគល់កម្មសិទ្ធិខ្លះ មកប្រជាជនវិញ គឺដូចជាៈ ម្ហូបអាហារ - សំលៀកបំពាក់ ផ្ទះសំរាប់នៅ ។ល។

332 - អ្វីទៅហៅ «សង្គមនិយមក្លាស៊ិចថ្មី» ?

ដែលហៅថា «ទ្រឹស្តីសង្គមនិយមក្លាស៊ិចថ្មី» គឺ ទ្រឹស្តីដែលទទួលអោយរដ្ឋធ្វើជាម្ចាស់លើសហគ្រាសធំៗទាំងអស់, ហើយស្នើអោយរដ្ឋកិច្ចស្រុះអោយបានផលល្អលើគោលនៃកម្មករ-កសិករ និងសំរួលតំរូវការរស់នៅនៃផលទាំងអស់នោះផង ។

333 - គេបានដឹងថា «បញ្ហាសេដ្ឋកិច្ច» នៅក្នុងពិភពលោក បានចោទឡើងយ៉ាងខ្លាំងចំពោះប្រទេសទាំងអស់ ។ តើមូលហេតុនៃបញ្ហាសេដ្ឋកិច្ចនេះ កើតមកពីណា ? តើបញ្ហានេះអោយមានវិបាកអ្វីខ្លះ ?

បញ្ហាសេដ្ឋកិច្ចនៅក្នុងពិភពលោក, បានក្លាយទៅជាបញ្ហាដ៏សំខាន់បំផុត ដែលគេពុំអាចនឹងរកផ្លូវដោះស្រាយបានឡើយ ។ ឥឡូវនេះ, បានក្លាយទៅជាវិបត្តិសង្គមនៃប្រទេស

ពិព្ធយៗ. ហើយដែលគេអាចនឹងដោះស្រាយទៅបាន លុះត្រាតែគេរកឃើញដោះស្រាយទៅលើតាក់តិកតែម្ដង ។ មូលហេតុនៃវិបត្តិសេដ្ឋកិច្ចដំបូងបណ្ដាលមកពី «វឌ្ឍនភាពនៃតិចនិច, និងការប្រើម៉ាស៊ីន» (la mécanisation) ពោលគឺផលិតផលដែលបានមកពីការប្រើម៉ាស៊ីន បានឡើងកំរិតហួសពីសេចក្ដីត្រូវការនៃប្រជាជន, ហេតុបណ្ដាលឲ្យទៅជាសម្បូរពេកពាសពេញទាល (la surproduction) ហើយពេលនោះ បញ្ហាទីផ្សារសំរាប់លក់ចេញគោក, បរិភោគនិងគ្រឿងប្រើប្រាស់សព្វសារពើក៏បានកើតឡើង ។ ប្រទេសខ្លះដែលធ្លាប់តែជាអ្នកទិញ, ក៏ស្រាប់តែក្លាយទៅជាអ្នកលក់វិញ ។ បញ្ហាមួយទៀត គឺប្រទេសដែលធ្លាប់លក់ពុំព្រមសុខចិត្តចែកចំណេញផលប្រទេសដែលធ្លាប់ទិញ ដែលក្លាយទៅជាអ្នកលក់នោះនោះ, ព្រោះប្រទេសនិមួយៗត្រូវការរក្សាវិបុលភាព (prospérité) និងរក្សាតុល្យការពាណិជ្ជកម្ម (balance commerciale) ជាតិខ្លួន ។ ការតះតាការភោគផលពន្ធនាំយកប្រទេសខ្លះហាមគេនាំចូល លក់ផលិតផលបរទេសចូលក្នុងផ្សារវៃមួយ, ហើយពេលនោះជំលោះក៏កើតមានឡើងរវាងប្រទេសមហាអំណាចនានា ។ បញ្ហាសេដ្ឋកិច្ចនេះ ជាប្រភពនៃបញ្ហានយោបាយ, ព្រោះកាប្រទេសដែលមានសេដ្ឋកិច្ចខ្វះផ្លូវទៀតក្រៅសារគុណប្រយោជន៍ទាងផ្លូវសីលវិជ្ជា, ក្នុងពេលបំពានបញ្ហាពិភពលោក ... ជាតិខ្លួនទៅ ... [illegible]

[illegible]

— ក្នុងគណិតវិទ្យា គំរូការវត្តវិស័យភាពរបស់មនុស្សជាតិ នោះបង្ហាញសំរាប់មនុស្សនិមួយក្នុងការស្វែងរក ។ គំរោងនៃគត្តិ ភាពបូរាណ និង សញ្ញាណនៃសច្ចៈ ។

គ- គំហើញនៃគំរូការបញ្ញា

ត្រូវពោលថា :

— ចំពោះរង្វង់គំនិតមនុស្សគ្រោះខោវរកពិតពុម្ពរូប, ពុំសូវប្រកាន់ប្រជាសាងគំរូការពិសោធន៍ក្នុងសង្គមឡើយ ។

— សង្គមបានបញ្ចប់សន្តិស្ថានដោយសំយោគវិធីផាសិទ្ធ ។

— វត្តវិស័យភាព បានជួយញុំាំងបញ្ញាអោយសន្តិស្ថានបានរូបមន្តត្រឹមត្រូវ ។

— ទ្រឹស្តីស្រុលទូលាយនៃសង្គមទំនើប គឺជាផលិតកម្មនៃប្រព័ន្ធ ប្រកបដោយគុណលក្ខណៈរូបរួមគ្នារវាងបញ្ញានិងវត្ថុប្រែរូប

ឃ- គំហើញនៃគំរូការសំរេច

ត្រូវពោលអោយបានថា :

— អ្នកប្រាជ្ញពិតប្រាកដពុំបានសុខចិត្ត ទទួលស្គាល់ភាពស្រពិចស្រពិលក្នុងធម្មជាតិឡើយ ព្រោះវានាំអោយមានគ្រោះថ្នាក់ ។

— គំរូការធម្មជាតិ ត្រូវពិនិត្យអោយឃើញសច្ចៈច្បាស់លាស់សិនសិបវិនិច្ឆ័យ ឬ អនុវត្ត ។

— គំរូការសំរេចរបស់អ្នកប្រាជ្ញ ត្រូវរក្សាបត្តសច្ចៈអោយឃើញសេចក្តីទាំងមនុស្សអោយត្រួតត្រាលើកំលាំងទាំងពួង នៃ ធម្មជាតិ ។

— គោលគំនិតទាំងអស់ត្រូវតែផ្តល់លើចិត្តវិទ្យា នៃបញ្ញាទ្វិភាគ ។

## ២- ទស្សន៍ និង គណិតវិទ្យា

### ក- ការពិចារណាទៅលើប្រវត្តិវិទ្យា

ត្រូវរំលឹកថា :

— គណិតវិទ្យាបានញែកខ្លួនពីទស្សនៈពីតាគ័របន្តិចម្តងៗ ។

— អ្នកគណិតវិទ្យាក្រិច ពុំបានពិចារណាតែសត្វៈតាមវិធីទស្សនៈ តែបានពិចារណាទាំងវិធីបរមត្ថវិជ្ជា ។

— ត្រូវរំលឹកនូវឧទាហរណ៍ពីវិញ្ញាណរបស់លោក "ដេការ៍ត" ពុំមែនសាកលវិទ្យាល័យទេ តែបំពេះលោកនេះវិញ្ញាណជា "សត្វមួយ" ទៅវិញ ។

— អ្នកគិតវិទ្យាសម័យបច្ចុប្បន្ន បាននាំយកពីរសត្វៈនៃពិតពិត ក្នុងគេនៅសរសេរទស្សនបរមត្ថវិជ្ជាក្រិចបូរាណ ដែលនេះពិចារណាមិនបានចំណុះលើផែនដី ។

— ទស្សនវិទូ, ត្រូវតែស្គាល់បានចំណុះចំពោះតែលើរណារីយ ដែលខ្លួនរស់នៅពុំរណ្ដោះ, គឺពុំបានស្គាល់អោយហ្វេសពីក្រុមដែលនេះបានឡើយ ។

### ខ- ស្បង់ពុំមែនជាទស្សនវិជ្ជាទេ :

ត្រូវពោលថា :

— អ្នកប្រាជ្ញទាំងឡាយ នៅពេលត្រូវការគ្រប់គ្រងលើជាតុ ក្នុងវិស្វយ៉ាសុទ្ធតែបានគាំទ្រខ្លួនអោយទៅជា ទស្សនវិទូទាំងអស់សិន ។

— ស្បង់កន្សល់ការក្នុងអោយជាគុណ ឬអោយពេលាសត្វនៃគំនិត ដែលបានចំនាក់ចំនងទៅនឹងបាតុភូត ។

— ទស្សនលោក "កុងសេត" (GONSETH) ដែលនិយាយពី "រូបភាពនៃញាណក្នុងលេខយកពិចារណា ។

— ទស្សនវិជ្ជាពុំមែនជា « រូបមន្តនៃញាណ » ទាំងអស់ទេ, តែមានលក្ខណៈស្រដៀងគ្នា ។

— ព្រោះបញ្ហាជីវិតតែងត្រូវការនូវគំនិតខ្ពង់ខ្ពស់, ហើយមានគោលដៅចាប់យកសច្ចៈក្រៅពិសោធន៍ ( réalité non-empirique).

*គ- តំណែងទស្សនវិជ្ជានៃសាសនា*

— សាសនានិងលទ្ធផលសាសនាពុំមែនជាគំនិតទស្សនវិជ្ជាទេ ។

— សាសនានិងទស្សនវិជ្ជាជួយគ្នាទៅវិញទៅមក ។

— ទស្សនវិទូពិនិត្យរូបធាតុក្រៅនៃលោក - ហើយសាសនាផ្ដួចពិនិត្យភាពខាងក្នុងនៃលោក ។

— សេចក្ដីសន្និដ្ឋានរបស់ទស្សនវិទូតែម្យ៉ាង - ប្រើតែពុំស្រួលច្បាស់ តែអាចពិចារណាដែលពាក់ព័ន្ធនឹងសាសនាលុះត្រាតែត្រូវទស្សនវិជ្ជាដ៏ខ្ពង់ខ្ពស់ជាតិ ។

## ៣ សេចក្ដីបញ្ចប់

*ត្រូវសរុបសេចក្ដីថា*

— សាសនាសក្ដិសិទ្ធិគ្រប់គ្រងលើគំនិតមនុស្ស ។ ទស្សនវិទូត្រូវប្រើបញ្ញាដើម្បីស្រាវជ្រាវ, សាសនាត្រូវប្រើជំនឿរបស់ខ្លួនដើម្បីបញ្ជាក់សច្ចៈ ។ សាសនាជំរុញទស្សនវិជ្ជាអោយដល់គោលដៅដោយលាក់ហើយកុំអោយឈប់ពាក់កណ្ដាលផ្លូវ ។ តើតំរៀងទាំងពីរនេះអាចចោលនៃគ្នារៀងខ្លួនបានទេ? ទស្សនវិជ្ជាដែលខ្វះគំនិតពិសោធន៍ផ្ដល់លទ្ធផល គឺជាការអោយអន្តរាយដល់សន្តិភាពមនុស្សជាតិពុំខាន ។

**ប្រធានទី២:** — « គណិតវិទ្យា និង ពិសោធន៍ » តើវិជ្ជាទាំងពីរ នេះមានទំនាក់ទំនងរវាងគ្នាឬផ្ទាល់ដាច់ពីគ្នា បើមានដូច ម្តេចខ្លះ ? ចូរពន្យល់ ។

(ម៉ែត្រូប៉ូល - សម័យប្រលងខែមិថុនាឆ្នាំ ១៩៥៣ - សំរាប់ថ្នាក់គណិតវិទ្យា)

គំរោងអត្ថាធិប្បាយ

១ សេចក្តីផ្តើម .— គេច្រើនពោលថា គណិតវិទ្យាខុសគ្នា ស្រឡះពីសាស្ត្រពិសោធន៍ ។ គណិតវិទ្យារកសច្ចៈនៅក្នុងខ្លួនវា លើក្រដាស , លើក្តារខៀន , ពុំបាច់យកវត្ថុមកពិសោធន៍និង រង្វាស់ទេ, តែច្រើនយកនិមិត្តរូបផ្សេងៗ មកពិចារ ណាទៅវិញ ។ ចំណែកសាស្ត្រពិសោធន៍ ត្រូវរកសច្ចៈក្នុង មន្ទីរពិសោធន៍ដោយរើសយករូបវត្ថុ ដែលមានមកពិចារណា, តាមសន្និដ្ឋានយកសំរេចនៅក្នុងប្រដាប់ពិសោធន៍ផ្សេងៗ ។ តើពិសោធន៍ស្ទើរតែគ្មានដែលមានសារៈសំខាន់ សំរាប់ គណិតវិទ្យាឬទេ ?

២ តួសេចក្តី

១- តើមានពិសោធន៍ក្នុងវិជ្ជាទាំងពីរ

— មនុស្សដែលកើតមុនគ្រិស្ត [illegible] ព្រោះតែខ្លួនមានគុណប្រយោជន៍ មនុស្សព្រោះដោយគ្នានៅតាមលំដាប់ [illegible] បន្ទាប់មកក៏ [illegible] ផល់ល្អមាត្រក់ , [illegible] [illegible] ។

— ការប្រើថ្នាំគ្រាប់ និង ថ្នាំព្យាបាលរោគ តែងត្រូវធ្វើទៅតាំងពីសម័យបុរេប្រវត្តិ ។ លទ្ធផលគឺមនុស្សត្រូវស្លាប់ ឬបាត់សរសៀយពីផ្ទៃ ។

— រហូតមកដល់សំណាក់លោក «ក្លូតប៊ែរណា» (Claude-Bernard) ទើបគេបានធ្វើវិធីប្រើពិសោធន៍ត្រឹមត្រូវ ។ រីឯគណិតវិទ្យាក៏ដូចគ្នាដែរ, ត្រូវបានទទួលផលផ្លាស់ប្តូរ ត្រឹមត្រូវនៅសម័យលោក «ក្លូតប៊ែរណា» ។

ក- ពិសោធន៍គណិតវិទ្យា

— ពិសោធន៍នេះកើតឡើងតាំងពីបុរាណកាលពិតប្រាកដ - គឺគេចាប់ផ្ដើមដោយសារតម្រូវការនឹងផ្លូវការលើប្រទេស ។

— ធរណីមាត្រ ( géométrie ) កើតឡើងដោយតម្រូវការផ្នែកការវាស់ដីតាមប្រវែង និងទំហំ - ដូចជាគេបានវាស់ដីក្នុងនៅតាមមាត់ទន្លេ «នីល» ( le Nil ) - ចំណែកគណិតវិទ្យាកើតឡើងពីការរាប់វត្ថុ ។

( arithmétique ) កើតមកពីការរាប់គិតលេខ ។

— គណិតវិទ្យា កើតមកពីពិសោធន៍រូបធាតុក្នុងជីវភាពរបស់គេរាល់ថ្ងៃ ។

— គណិតវិទ្យាកើតមកពីការចិញ្ចឹមជីវិតទាក់ទងផ្សេងៗ ។

ខ- ដើមកំណើតនៃវិស័យគណិតវិទ្យា

— គណិតវិទ្យាកើតពីពួកក្រិច បុរាណដែលមានសម្បត្តិធំធេងខាងការប្រឌិតខ្លួនឯង ។ ដែលរស់នៅក្នុងលោក មានគតិស្ម័គ្រចិត្ត ។

— បន្ទាប់មកពិសោធន៍ក៏ចាប់បានផ្សាយភាពរៀង ។

— រូបរាងទាំងឡាយរបស់សញ្ញាណគណិតវិទ្យា សុទ្ធតែកើតមានពីតម្រូវការណ៍ ; ព្រោះយើងកើតចេញផ្សាយរូបរាងពីរវត្ថុពីសញ្ញាណមកផ្សាយភូតិកម្ម ។

— ដូច្នេះរូបរាងនៃគណិតវិទ្យាកើតពីសញ្ញាណទាំងឡាយដែលមូល បន្ទាប់មកក៏យករូបឡាស់លាស់ ព្រោះគេចង់ធ្វើអោយប្រសើរ ណាំ ។

## ២- ពិសិដ្ឋភាពវិចារណញាណក នៃ គណិតវិទ្យា និង ពិសោធន៍

— កំណើតគណិតវិទ្យា ក៏មានពិសោធន៍ចូលលាយឡំខ្លះដែរ ។

— ចំណាត់ថ្នាក់ នៃ ប្រភេទធម្មជាតិ ឬ គេទស្សន៍តែកើតមុនស្រង់ពិសោធន៍ទាំងអស់, ចំណែកឯច្បាប់ដែលកើតមកពីការស្រាវជ្រាវ, តែកើតពីមនុស្សបង្កើតប្រតិភាគតិ ជាវិធ្យប្រតិតរបស់មនុស្សប៉ុណ្ណោះ ។

### ក- គណិតវិទ្យាបង្កើតរូបិយកម្មនៃពិសោធន៍

— មួយគណិតវិទ្យាពុំមានបំពេញស្រួលៗទេ - តែចង់គេសំរេចគំនិតជៅពាក្យ "ភាពស្រួល" ឬ ព្យាក់ "សម្មតិកម្ម"

— គណិតវិទ្យាពុំត្រូវការចំណើយ "ពិតពេត្រូវ" ទេតែត្រូវការតែងភ្ជាប់ភាពសុខស្រួលរបស់ខ្លួន ឬ តក្កភាព នៃ មនុស្ស ប៉ុណ្ណោះ ។

— ចំណែកស្ម្បង់ពិសោធន៍ ទទួលយកសម្មតិកម្មណាដែលត្រូវគេបញ្ជាក់ពិសោធន៍ ។

ខ- គណិតវិទ្យាត្រូវការស្បង់

— ពិចនិច ជួយស្បង់នោះមាន ការស៊ើបស៊ៀនខាង ពិសោធន៍និងវិចារណញាណ ។

— គំហើញថ្មីៗ ដែលកើតពីគណិតវិទ្យាបានត្រូវយោងពីក្នុងស្បង់ ទាំងការពិត : សញ្ញាណថ្មីៗ ។

— បើតាមប្រធានវិស័យភាព, គណិតវិទ្យាគ្មានមធ្យោបាយ អ្វីនោះហួសពីសមត្ថភាពរបស់ខ្លួន ។

— បើតាមវត្ថុវិស័យភាព, ពិភពគណិតវិទ្យាជាពិភពព្រះគន់ និយមថ្មីបើតក្កវិទ្យានោះ មានលក្ខណៈផ្សេងពីវត្ថុធាតុជ្រើយពីនោះ ។

៣- អន្តរគមន៍របស់គណិតវិទ្យានិងស្បង់ ចំពោះរូបមន្តពិសោធន៍

ក- ការរីកគណិតវិទ្យា

— តាមពិចារណារបស់លោក «អូគុស្តកុង» ( Auguste-Comte ) គួរយកពិចារណានេះពេលនេះបាន ។ ព្រោះ អូគុស្តកុងបានពោលថា “ ស្បង់គណិតវិទ្យានេះបំរើប្រទេស ដោយពុទ្ធិសត្វៈបានដំណើរយ៉ាងណាក៏ដោយចាញ់ ឧបករណ៍ដែលគំនិតមនុស្សបង្កើតឡើង សំរាប់ពិសោធគណិតភូតពិតនៃធម្មជាតិ ” ។

— តែអ្នកប្រាជ្ញវិទ្យាសប្បាយចិត្តណាស់ ការណាគណិតវិទ្យាប្រាប់គាត់ត្រាតផលផលល្អៗសំរាប់ពិសោធន៍ ។

ព្រោះពិសោធន៍បច្ចុប្បន្នក៏ផ្តល់ពុទ្ធិក្នុងសត្វៈដែរ ព្រោះ គណិតវិទ្យា មានសញ្ញាណនៅក្នុងនោះ ។

## ៣ សេចក្ដីបញ្ចប់

ត្រូវគូសបញ្ជាក់ថា ៖

- ស្បត់ធម្មជាតិ ដែលវិវត្តទៅជាស្បត់គិតសាកលមនុស្សជាណរូប ។
- ស្បត់គណិតវិទ្យា ដែលក្លាយទៅជាគំនិតសាធារណវិចារណញ្ញាណពិតមនុស្សជាណទៀត ។
- ចំណេះពិតប្រាកដចុះស្ម័គ្រទៅលើគំនិតវិទ្យាសាស្ត្រ រកឃើញដោយវិទ្យាសាស្ត្រពិតទេ, តែវាស្ថិតនៅលើគំនិតសំខាន់ៗដែលជាម្ចាស់នៃគំនិតវិចារណញ្ញាណរបស់មនុស្ស ចំពោះចំណុចអំពីធម្មជាតិ វិទ្យាសាស្ត្រពិតនោះ ។

* * *

ប្រធានទី ១ – តើទស្សនវិជ្ជាមានគុណប្រយោជន៍ សំរាប់បង្ហាញការពិចារណានៅក្នុងស្យង់, និងបង្ហាញនូវវិធីទាំងឡាយរបស់ស្យង់, យ៉ាងដូចម្ដេចខ្លះ? ចូរពន្យល់ ។

(ក្រុងរ៉ែនស៊ីយប្រឡងខែមិថុនា១៩៥២)

**គំរោងអត្ថាធិប្បាយ**

**១ សេចក្ដីផ្ដើម** — ទស្សនវិជ្ជាខុសនិងស្យង់ត្រង់លក្ខណៈទូទៅរបស់វិជ្ជានេះព្រមទាំងសច្ចៈក្នុងវត្ថុ (réalité de la connaissance) ដ៏ទូលំទូលាយនិងផ្ដល់គំនិតជ្រៅជាន់ប្រមាណ ។ ចំណែកស្យង់វិញ, វិជ្ជានេះក៏បានផ្ដល់នូវគន្លឹះសំរាប់ត្រួសត្រាយសច្ចៈដល់ទស្សនវិទូមិនតិចដែរ ។ ដើម្បីបំពេញចំណង់របស់មនុស្សដែលចង់រកវត្ថុពិតនិងការពិតរបស់ពិភពនោះ, គេឃើញវិជ្ជាទាំងពីរនេះ បានចេញមុខមកបំពេញតួនាទីរបស់មនុស្សជាតិវិជ្ជានានា ។ ការពិតស្យង់និងទស្សនវិជ្ជាមានសម្ពន្ធដែលជាប់ទាក់ទងរបស់ខ្លួនជាមួយគ្នា ពោលគឺវិចារណញ្ញាណ (la raison) ។ ទស្សនវិទូទាំងឡាយដែលស្រឡាញ់សច្ចៈធម៌, បាននាំគ្នាជ្រើសរើសយកវិធីស្យង់ដើម្បីបញ្ជាក់ទ្រឹស្ដីរបស់ខ្លួន, ដែលជាហេតុបណ្ដាលអោយស្យង់ក្លាយទៅជាមាគ៌ាមួយ នាំអោយបានដល់នូវពុទ្ធិសច្ចៈសំរាប់ការប្រព្រឹត្តទៅជាធម្មតានៃវិចារណញ្ញាណមនុស្សជាតិ ។

**២ តួសេចក្ដី**

*ក- ស្យង់និងតក្កវិជ្ជា :*

*ក ស្យង់និងមុខងារទស្សនវិជ្ជានៃភាសា*

ត្រូវបញ្ជាក់ថា ទស្សនវិទូតែងត្រូវការភាសាសំរាប់ពិពណ៌នា ខាងលើអំពីទាំងអស់ ។

— ស្ទង់ផ្ទាភាសាសំរេច ។

— គណិតវិទ្យាបានយកពីរូបមន្តនៃភាសា ។

— ទស្សនវិទូ យករូបមន្តភាសា ដើម្បីពិចារណាទំនាក់ទំនង គុណធម្មជាតិ ។

— ស្ទង់តាមខាងនូវខាងទស្សនវិទូ ពីគំនៃនពិសោធន៍ របស់គំនិតក្រៅសត្វ: ។

## ខ- គំរូការនៃវត្ថុវិស័យភាពរបស់គំនិត

— ត្រូវបញ្ជាក់ថា :

— ស្ទង់ផាពុទ្ធិក្រៅគំនិតពីកំណើតរបស់មនុស្ស

— លោកម៉ារីស្តូតសារគរបស់ទស្សនវិទូបារាំង, ជឿថា គំនិតមនុស្សប្រកបដោយបញ្ញាស្អាប់ ប្រៀបដូចក្ដារទាល់ ល្អស ។

— គំនិតមនុស្សខ្វះពិសោធន៍ ដកពីនៃវត្ថុទាំងអស់ ។

— គំនិតបញ្ញាមនុស្សត្រូវការវត្ថុខាងក្រៅ ដើម្បីវិវត្តន៍នៃ សត្វ:

— ផ្ទុះវត្ថុវិស័យភាពជារូបមន្តសំខាន់បំផុត សំរាប់គំនិត មនុស្ស ។

— លោកហ្គុងសេត (M - GONSETH) ជឿថាទស្សន មនុស្សស្ថិតនៅចំកណ្ដាលបំណែរ ពីរនៅខាងខ្លួន "រូបមន្តខ្លួន ញាណ" (forme intuitive) និង "មនោវិចារណញ្ញាណ" (idéal rationnel) ។

(lutte des prestiges ou potlachs) ជាដើម ។ ការពិត
ពេលនោះមកហើយ ដែលគេឃើញកើតមានបក្សសម្ព័ន្ធនៃ
ប្រទេសទាំងឡាយក្នុងពិភពលោក ។

**334-តើការងារមានគុណសម្បត្តិអ្វីខ្លះ ? ចូរលើកយកទស្សនវិជ្ជារបស់អ្នកប្រាជ្ញមកពន្យល់ ។**

អ្នកប្រាជ្ញជាច្រើនបានអោយតំលៃទៅលើការងារ ។ អ្នកខ្លះបានពោលថា "ការងារជាប្រភពនៃសាមគ្គីភាព" (លោកឌួកខឹម) ។ ការងារជា«ចំណងសំរាប់ចងមនុស្សអោយរួមរស់ដោយសុខសាន្តជាមួយក្រុមគ្រួសារខ្លួន» ។ អ្នកខ្លះទៀតបានយល់ថា "ការងារផ្តល់នូវសេចក្តីសប្បាយត្រេកត្រអាលជាវត្ថុធាតុនៃសុភមង្គល ។ លោក «ស្ប៉ិនស៊េ» (Spencer) យល់ថា : «ការងារជាសកម្មភាពស័ក្តិសិទ្ធិតែងតែអោយនឹកឃើញនូវតំលៃផ្ទាល់ខ្លួន» ។ លោក "វ៉ិលសុន" ទៀតថា : "ការងារជាអំពើយ៉ាងប្រពៃរបស់មនុស្ស សំរាប់បញ្ជាក់ដោយលក្ខណៈប្រាជ្ញា និងសេរីភាពពេញ" ។

ចំណែកលោក «ដេការត» (Descartes) វិញ, «ការងារធ្វើអោយមនុស្សទៅជាម្ចាស់ និងជាម្ចាស់នៃធម្មជាតិ" ។ លោក "ប្រុគសុន" យល់ថា : «ការងារគឺជាការដែលមនុស្សបានធ្វើធម្មជាតិអោយទៅជាខ្លួនអោយមានប្រយោជន៍» ។ ចំណែកលោក "កាល់ម៉ាក់" ទៀតថា : "ការងារជាសារៈកម្មប្រកបដោយប្រាជ្ញាស្មារតីកំណត់និយមសម្ភារៈ" ។ សរុបសេចក្តីទៅ «ការងារជាអាតូពិតរបស់មនុស្សទាំងអស់គ្នា

ក្នុងលោក, ជាព្រលឹងដែលប្រកបដោយសកម្មភាពរស់រវើក របស់មនុស្ស, គឺជាច្បាប់ធម្មជាតិដែលញ៉ាំងមនុស្សអោយ បន្តការរស់នៅរបស់ខ្លួនបានក្នុងកិត្តិយស ។ គឺជាតំលៃ ពិសេស ដែលលើកមនុស្សអោយខ្ពស់ជាងសត្វទាំងពួង ព្រោះជាវឌ្ឍនភាពនិងសុភមង្គលកើតមកពីការងារ ។ គ្មាន ការងារសង្គមពិភពលោកនឹងរលត់សូន្យ ” ។

**335- អ្វីទៅហៅថា “ កម្មសិទ្ធិឯកជន ” ?**

ដែលហៅ “ កម្មសិទ្ធិឯកជន ” គឺកម្មសិទ្ធិដែលបុគ្គលម្នាក់ៗ មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់, ចាយវាយ, ឬទាញផល ប្រយោជន៍ផ្សេងៗពីវត្ថុទាំងឡាយណាដែលខ្លួនមាន ។

**336- តើកម្មសិទ្ធិដែលមាន លក្ខណៈជាមូលធន, បានមក ដោយវិធីណាខ្លះ ?**

កម្មសិទ្ធិមូលធន ច្រើនបានមកពីវិធីសំខាន់បីយ៉ាងគឺ :

១- ដោយសារការកាន់កាប់ ភោគទ្រព្យធម្មជាតិដែលរដ្ឋពុំ យកចិត្តទុកដាក់, ដូចជាកម្មសិទ្ធិ លើដីធ្លី ឬព្រៃ-ភ្នំបឹងទន្លេ ត្រីស្សារការណ៍ ។ល។

២- ដោយសារការងារនៃពួកមូលធនដែលមានលក្ខណៈជា ការកេងប្រវ័ញ្ចគេ ។ ឬចាប់យកដោយប្រយោលលើកំលាំង របស់វណ្ណៈអធន ។

៣- ដោយសារមរតក - ដែលម្ចាស់កម្មសិទ្ធិបានទទួលពីឪពុក ម្ដាយ ឬជីដូនជីតារបស់ខ្លួនមក ។

**337- អ្វីទៅហៅថា “ បញ្ញាសង្គមកិច្ច ” ?**

ដែលហៅថា " បញ្ហាសង្គមកិច្ច " គឺ បញ្ហាដែលទាក់ទងទៅ
នឹងជីវភាពរបស់មនុស្សទាំងឡាយដែលជាសមាជិកនៃសង្គម
នោះ ។ បញ្ហានេះមានវិជ្ជាការសំខាន់ពីរយ៉ាងនេះ :

- វិជ្ជាការសេដ្ឋកិច្ច, សំរាប់ដាក់វិន័យការចិញ្ចឹមជីវិតនៃសមា-
ជិកសង្គម ។

- វិជ្ជាការ សីលវិជ្ជា ; សំរាប់ការពារយុត្តិធម៌ និង សិទ្ធិនៃ
ខ្លួនរបស់សមាជិកសង្គម, ដែលត្រូវចាត់ចែងដោយអ្នកដឹក-
នាំសង្គមនោះផ្សះផ្សាសំរួលបញ្ហារស់នៅរបស់ខ្លួនផង ។

* * *

## ២០ - បញ្ហានយោបាយ : រដ្ឋ-ប្រជាជាតិ-មាតុប្រទេស

(Problème politique : l'Etat, la nation, la patrie)

**338-** អ្វីហៅថា “ រដ្ឋ ” ?

គេបានអោយនិយមន័យរដ្ឋទៅតាមទំនោរនៃទស្សនគតិដែលចង់បញ្ជាក់នូវអាណាចក្រ ដែលមានស្ថាប័ននិងសំភារៈយ៉ាងត្រឹមត្រូវ ។ ខ្លះថា “ រដ្ឋជាសង្គមសរុបទាំងមូល ” ខ្លះទៀតពោលថា “ រដ្ឋគឺអង្គការមួយ ដែលមានសមាសភាគដូចតទៅ :

• អង្គការលើ , អង្គការក្រោម និង បង្កាត់នយោបាយនៃអ្នកទាំងពីរក្រុមនោះ ។ ដើម្បីបញ្ជាក់ពីបន្សាសម្ពន្ធ ដែលមាននៅក្នុងសង្គមនៃអាណាចក្រនោះ ខ្លះបានអោយនិយមន័យថា “ រដ្ឋ គឺជាអង្គការប្រមូលផ្តុំនៃអង្គការបី អង្គការរដ្ឋបាល , អង្គការតុលាការ , និងអង្គការនយោបាយ ។ ខ្លះទៀតពោលប្រៀបធៀបរដ្ឋទៅនឹងសង្គម ដោយពោលថា “ រដ្ឋជាខួរក្បាលនៃសង្គម ” ។ តាមពិត រដ្ឋគឺ “ អាណាចក្រមួយដែលមានអ្នកដឹកនាំនិងពលរដ្ឋ , ប្រកបដោយអង្គការឯកតី : អង្គការនយោបាយ , អង្គការសេដ្ឋកិច្ច , អង្គការរដ្ឋបាលនិងអង្គការតុលាការ ” ។

**339-** តើរដ្ឋនិមួយៗមាន “ អនុគមន ” ជាចាំបាច់អ្វីខ្លះ ?

– រដ្ឋនិយមត្រូវមានអនុគមន៍ ៣ យ៉ាងគឺ:

- អនុគមន៍សាសនា (fonctions religieuses)
- បឋមអនុគមន៍ (fonction primaire)
- ទុតិយានុគមន៍ (fonction secondaire) ។

អនុគមន៍សាសនា មានភារៈរៀបចំពិធីបុណ្យ និងបង្ការសន្តិ ការសាសនាឱ្យស្របទៅតាមគតិការស្ម័គ្រចិត្ត ។

បឋមអនុគមន៍មានភារៈរៀបចំអំណាចបី ដើម្បីការគ្រប់គ្រងឱ្យប្រកបដោយយុត្តិធម៌ ដោយបំបែកដាច់ពីគ្នាការសំរាប់ បំពេញអំណាចនោះ ។ អំណាចទាំងបីនោះគឺ :

— អំណាចនីតិបញ្ញត្តិ (pouvoir législatif)
— អំណាចនីតិប្រតិបត្តិ (pouvoir exécutif)
— អំណាចតុលាការ (pouvoir judiciaire)

ទុតិយានុគមន៍ មានភារៈការពារ, ធ្វើឲ្យ ទទួលបន្ទុក មានអប់រំសាស្ត្រនិងសិល្បៈពីរប្បបប្រជាជាតិ និងសេដ្ឋកិច្ច សន្តិសុខ-សាធារណៈ ។ល។

340- អ្វីទៅហៅថា "សេរីភាព" ?

សេរីភាពគឺភាពដែលគេពុំមានអ្វីរារាំងដល់ធម្មជាតិ (ដោយការសំ របស់លោកគ្រូ) ។ លោកគ្រូសូពោលថា : "មនុស្សកើតមកមានសេរីភាពតែម្តង (l'homme est né libre" ។ ហើយ គូរូស ហើយតាមក្រោលោកគ្រូសូពោលថា : (សូមកុំឱ្យរំលោភ ការសំលាប់សេរីភាពធម្មជាតិរបស់មនុស្ស) ។

តែហេតុលោកម្ចាស់ទីនេះពោលថា "សេរីភាព គឺជាលទ្ធផល នៃការគិតយល់ឃើញ" តាមសេចក្តីថា "សិទ្ធិសេរីភាពសេរីភាព

ផលម្នាក់ៗ អោយតាមត្រឹមត្រូវ កុំអោយមនុស្សម្នាក់ ទៅជាន់លើសិទ្ធិមនុស្សម្នាក់ទៀតបាន មនុស្សទាំងអស់ត្រូវប្រគល់អំណាចទៅសង្គម ដើម្បីរៀបចំអោយតាមគោលច្បាប់ ហើយផែនការមានមនុស្សទាំងអស់នោះ ជាអ្នកទទួលបញ្ញាវិញ ។

**341 - អ្វីហៅថា "លទ្ធិប្រជាធិបតេយ្យ"**

(La Démocratie)

ដែលហៅថាលទ្ធិប្រជាធិបតេយ្យ គឺលទ្ធិដែលរាស្ត្រជាម្ចាស់នៃអំណាច ។ ក្នុងឋានៈជាម្ចាស់នៃអំណាច រាស្ត្រមានភារកិច្ចជ្រើសរើសអ្នកតំណាងរបស់ខ្លួន ដើម្បីបង្កើតច្បាប់អនុវត្ត ដែលធានានូវគតិទាំងបួនអោយ :

សមភាព, សេរីភាព, ភាតរភាព, [illegible] សុភមង្គល ។

**342 - អ្វីទៅហៅថា "លទ្ធិផ្តាច់ការ" ?**

(Absolutisme ou totalitarisme)

ដែលហៅថា «លទ្ធិផ្តាច់ការ» គឺលទ្ធិជារបបដែលរដ្ឋមានអំណាចផ្តាច់ការ ។ លទ្ធិផ្តាច់ការតម្រូវអោយរាស្ត្រគោរពអ្នកដឹកនាំម្នាក់ដែលមានអំណាចផ្តាច់មុខតែឯង, ជាទេវាធិបតេយ្យដែលអាចសម្រេចនិងធ្វើអ្វីតាមអំពើចិត្ត ។ ជាលទ្ធិដែលគ្មានសេរីភាព, សមភាពនិងភាតរភាព, ព្រោះអំណាចទៅមកតែក្នុងដៃបុគ្គលម្នាក់ ឬ មួយក្រុម ។

**343 អ្វីហៅថា "អនាធិបតេយ្យនិយម"**

(Anarchisme)

ដែលហៅថា «អនាធិបតេយ្យនិយម» គឺលទ្ធិមួយដែលទាមទារអោយមនុស្សទាំងអស់មានសេរីភាព រស់នៅតាមបំណង ឬ តាមសេចក្ដីប្រាថ្នារបស់ខ្លួន ។ តាមលទ្ធិដែលបើកអោយការស្រេចក្នុងសង្គមនិមួយៗ មានសិទ្ធិបះបោរប្រឆាំងនិងអាជ្ញាធររបស់រដ្ឋវិញបាន កាលណាអាជ្ញាធរនៃរដ្ឋនោះជាឧបករណ៍នៃលទ្ធិផ្ដាច់ការ ។ ពួកអនាធិបតេយ្យនិយម អោយតំលៃទៅលើធម្មជាតិ មនុស្សដែលគេជឿថាមានសការគតិខ្ពង់ខ្ពស់លើសលុបជាងអ្វីទាំងអស់ ។ ពួកអនាធិបតេយ្យនិយមប្រឆាំងជានិច្ចនិងទង្វើរបស់រដ្ឋ ដែលមានលក្ខណៈជាការធ្វើបង្ខំ ឬ វិធានការវិនិច្ឆ័យ ។

344 អ្វីហៅថា "ទ្រឹស្ដីទេវវិទ្យា" ?

(théorie théologique)

ដែលហៅថាទ្រឹស្ដីទេវវិទ្យា គឺទ្រឹស្ដីដែលបកស្រាយពីអំណាចទេពនៃព្រះជាម្ចាស់, ជាទស្សនៈដែលជឿថាអ្នកកាន់អំណាចរដ្ឋនិមួយៗ បានទទួលបញ្ជាពីព្រះអាទិទេពដើម្បីដឹកនាំមនុស្ស ។ ឧទាហរណ៍ — ពួកមហាម៉ែតគេជឿថា ពួកកាលីហ្វជាទូតនៃព្រះជាម្ចាស់ ។ ព្រះរដ្ឋពាក់បញ្ញារនាយកោកចុះពីឋានសួគ៌មកដើម្បីដឹកនាំមនុស្ស ។

ទ្រឹស្ដីដែលដឹកនាំដោយជំនឿនេះ តែងតែបង់ទូលទ្ធិប្រជាធិបតេយ្យ ហើយសម្រេចតាមលទ្ធិផ្ដាច់ការ ។

345 អ្វីទៅហៅថាគតិនិយមនៅក្នុងរដ្ឋ ?

(Réaliste dans l' Etat)

គតិនិយមក្នុងការជួ គឺភាពសំខាន់នៃសមាសភាពតែលក្ខណៈនេះ
ដែលប្រកបដោយគតិ: (le réel) ក្នុងការសិក្សា, ក្នុងគុ
ណធម៌រវាងអ្នកដឹកនាំនិងប្រជារាស្ត្រ ។ ជាប្រព័ន្ធដែលពិនិត្យ
គុណនិងទោស (វិភាគ) ក្នុងការប្រើអំណាច, សេរីភាព,
និងសិទ្ធិរបស់អ្នកដឹកនាំនិងប្រជាពលរដ្ឋ ។ ជាប្រព័ន្ធដែល
ជួយសំរួលការងារទាំងផ្នែកនយោបាយ, សេដ្ឋកិច្ចនិង
សីលធម៌រវាងរដ្ឋនិងប្រជារាស្ត្រ និងជាប្រព័ន្ធនៃកិច្ចព្រម
ព្រៀងគ្រប់យ៉ាងរវាងអ្នកទាំងពីរក្រុម ។

346 - អ្វីទៅហៅថា «មនសិការជាតិ» ?

(conscience nationale)

មនសិការជាតិ គឺអារម្មណ៍ ឬគំនិតការពារជាតិដែលបណ្ដាល
មកពីការចែករំលែកក្នុងការស្នេហាជាតិ ។ អារម្មណ៍នេះកើត
មកពីមនុស្សម្នាដែលផ្សាយតែងតែប្រកាន់តាំងពីអតីតកាល
មក, ជាការរួមសុខទុក្ខជាមួយគ្នាជានិច្ច ។ ម្យ៉ាងទៀត,
ព្រលឹងនៃជាតិនិមួយៗ គឺការប្រមូលផ្ដុំគ្នាក្នុងអតីតកាល,
បច្ចុប្បន្នកាលនិងអនាគតកាលដែលតែងតែភ្ជាប់ទំនាក់ទំនងជាមួយ គឺ
ស្រលាញ់ហើយគោរពក្រុមគ្រួសារ ដោយស្មោះត្រង់ទៅនឹងជា
តិ ។

347 - អ្វីទៅហៅថា «មាតុប្រទេស» ?

(La Patrie)

មាតុប្រទេស គឺជាភូមិកំណើតដែលមនុស្សទាំងឡាយធ្លាប់
រស់នៅជាមួយគ្រួសាររបស់ខ្លួន ។ ស្នេហាមាតុប្រទេសគឺ

ស្នេហាដី , ភ្នំ , ទន្លេ , ព្រៃព្រឹក្សាដែលខ្លួនធ្លាប់ស្គាល់ជាផា
របស់ជាតិខ្លួន ។ គឺជាសេចក្ដីទាក់ទងប្រកបដោយ
សភាវគតិ ; ជាសេចក្ដីសាមូហភាព (Sentiment de masse)
ដែលជាប់ជំពាក់នឹងស្រុកកំណើត , នឹងភាសា នឹងប្រពៃណី
នឹងបរិយាការណ៍ទូទៅ (ambiance générale) ។
ស្នេហាមាតុប្រទេស បណ្ដាលដោយគេភ្ជាប់ស្នេហ៍ដោយស្រើប
ឬដោយកំហឹង ហើយមូលជាជីវិតជាតិពិសេស ។

*

* *

# អត្ថាធិប្បាយ

— ក្នុងគណិតវិទ្យាគេពុំអាចនិយាយថាត្រូវឬខុសទេ, ទោះនៅក្នុងសម្ព័ន្ធវិទ្យាដែលគេចេញពីការពិសោធន៍ក៏ដោយ ក៏អាចគិតហាក់ដូចជាគេពុំចាំបាច់ស្រាវជ្រាវ ។

## ៣- សេចក្ដីបញ្ចប់ ៖

ត្រូវបញ្ចប់ក្នុងសេចក្ដីបញ្ចប់ថា ៖

— លោកអូស៊ែលក៏បានពិភាក្សាថា ពុំមែនប្រាកដនៅក្នុងគណិតវិទ្យាចំណុះរបស់វា ។ ការដែលស្វែងរកសច្ចៈក្នុងសម្ព័ន្ធផ្អែកលើពិសោធន៍មានសច្ចៈនៅត្រឹមពុំចាំបាច់ជៀសវាង ។ ឧទាហរណ៍ គណិតវិទ្យាបានរាប់ពីវិធីគណនាវិភាគពលឡូស់ក្នុងយានអាវុធយ៉ាងត្រឹមត្រូវ, ស្ទង់បានទេ ព្រោះពិសោធន៍ដោយបង្ហាញលទ្ធផលយ៉ាងជាក់ច្បាស់ណាស់ . តែចំណុចយានអាវុធនោះបើក បានបំផ្លាញផ្ទះសម្បែងជាតិវេទាលធូរអោយត្រូវ ។ តែទោះជាយ៉ាងណាក៏ដោយក៏យើងឃើញថា បតិលោកអូស៊ែលបានផ្ដល់អោយឃើញថាគិតថាគណិតវិទ្យាដែលកើតពីវិញ្ញាណគំនិតរបស់មនុស្ស ។

* * *

ប្រធានទី៤:— «ហេតុអ្វីបានជាក្នុងករណីខ្លះគេអាចពោលថា៖ គណិតវិទ្យាមានសារៈសំខាន់ហួសស្មើរតែជៀសវាងពុំបាន ?»

ចូរពន្យល់និងវែកញែកទស្សនខាងលើនេះ ។

(ក្រុងកង់ ខែតុលាឆ្នាំ ១៩៧១ – វិញ្ញាសាសំរាប់ថ្នាក់គណិតវិទ្យា)

**គំរោងសង្ខេបប្លង់**

**១ សេចក្ដីផ្ដើម —** *គំរូការរូបវិទ្យាច្រើនដូចនឹងគំរូការគណិតវិទ្យា ។ រូបវិទ្យាមានលក្ខណៈត្រឹមត្រូវ ៖ ឧទាហរណ៍ ដាក់សៀវភៅទំងន់ពីរលើបិតត្រូវបិតគំរងដុះ, ដូចនេះវិញបើគេពុំបិត គ្រប់ពិតនៃសៀវភៅត្រូវបើកត្រឡប់មកវិញ ។ ស្បែកបង្ហាញភាពពិតជារូប ។ រីឯគណិតវិទ្យាដូចនឹងរូបវិទ្យាត្រង់គណិតវិទ្យាបង្ហាញពុំបានច្បាស់លាស់សោះ ៖ ឧទាហរណ៍ មុំពីររបស់ត្រីកោណពុំអាចស្មើនឹងមុំកែងពីរបានទេ ។ តើលក្ខណៈត្រង់ណាដែលពោលថា គណិតវិទ្យាមានសារៈសំខាន់ហួសស្មើរជៀសវាងពុំបាន ?*

**២ តួសេចក្ដី**

*១- ប្រវត្តិនៃគណិតវិទ្យា*

*ក- គំរូការដាច់ខាត*

*— យើងអាចយកលោកអារីស្តូត ជាតំណាងនៃទស្សនគណិតវិទ្យា ។*

— គណិតវិទ្យា ដែលបង្រៀនមកហើយ សុទ្ធតែយកចិត្តទុកដាក់ពីក្រិត្យ លក្ខណៈពិតប្រាកដដដែល សំរាយបញ្ជាក់មានចរាចរទៅ លើការត្រឹមត្រូវ ។

## ១- សារធិបទនៃគណិតវិទ្យាក្នុងកាលសម័យ

— គេបានទិតៀនទ្រឹស្តី ដែលគណិតវិទ្យាបង្កើតឡើយបាន ប៉ុស្ទុយឡា (postulats) ។ ឧទាហរណ៍ : ប៉ុស្ទុយឡា អឺគ្លីត ។

មកដល់សតវត្សទី ១៩ ទើបមានអ្នកប្រាជ្ញផ្នែកគណិតវិទ្យា រុស្ស៊ីឈ្មោះឡូបាតឆេវស្គី (Lobatchevski) ; អ្នកប្រាជ្ញ អាល្លឺម៉ង់ឈ្មោះរីម៉ាន (Riemann) និងអ្នកប្រាជ្ញហុងគ្រី ឈ្មោះបុលយ៉ៃ (Bolyaï) គេឃើញរូបមន្តពិត ហើយបដិសេធ ប៉ុស្ទុយឡាអឺគ្លីតចោល ។

## ២- ចំណើយនៃគណិតវិទ្យា

### ក- គេអាចនិយាយពីតំរូវការនៃគណិតវិទ្យាបាន

— តំរូវការគណិតវិទ្យា បានត្រូវគេសំគាល់ឃើញថាស្រង់ រូបមន្តពីល្បង់ខ្លះដែរ ។ និយមន័យគណិតវិទ្យានិងនិយមន័យ រូបវិទ្យាសុទ្ធតែចេញមកពីពិសោធន៍បញ្ហាខាងរស់ ។ ការស្វែង យកចំណុចត្រង់នេះថា គណិតវិទ្យាមានសារៈសំខាន់ណាស់ ស្មើរទៀសវាងពុំបាន ព្រោះបានពិចារណាត្រឹមត្រូវ ។

— តែអ្នកប្រាជ្ញបច្ចុប្បន្នដូចជាលោក "ហ៊ីលប៊ែរ" (Hilbert) និងពួកអ្នកប្រាជ្ញសាលាវីយែន (Vienne) ពោលថា «គណិតវិទ្យា» ពុំសូវមានសារៈសំខាន់អ្វីឡើយ ។

ខ- គណិតវិទ្យាមានព្រំដែនត្រឹមត្រូវ

— គណិតវិទ្យា បានព្រំដែនរបស់ខ្លួនព្រមជាមួយដែលគេពោលថា : " សារៈសំខាន់របស់គណិតវិទ្យាបានក្លាយទៅជាសារៈសំខាន់នៃគោលការណ៍ ដែលគ្មានជំទាស់និងគោលការណ៍នៃអនុមានពាក្យ ២ ។

— សារៈសំខាន់ក្នុងរូបវិទ្យា មានរបៀបផ្សេងពីសារៈសំខាន់ក្នុងគណិតវិទ្យា ត្រង់តំលៃ និងលទ្ធផលដែលសំរេចចេញពីពិសោធន៍ ។

## ៣ សេចក្តីបញ្ចប់

— យើងឃើញថា មតិដែលពោលអះអាងមកនេះ ក៏បានយោបល់ត្រឹមត្រូវប្រកបដោយភាពសមរម្យណាស់ដែរ ។ ព្រោះថា គណិតវិទ្យាបានបង្ហាញគន្លងភាពជាក់លាក់ខ្ពស់ដោយចាប់អារម្មណ៍ ។ គណិតវិទ្យា បង្កើតរូបមន្តទាំងឡាយ ដែលជាគោលបំណងស្វែងរកភាពប្រាកដនិយម ។ តែលុះដល់សម័យវិវត្តដល់កំរិតទាំងនេះដែរ គណិតវិទ្យាក៏ស្ថិតនៅត្រឹមតែមានតំលៃសំរាប់តែក្នុងករណីពិសេស សម្ពុរណ្ណការ , ព្រោះថា ប្រការពីមធ្យោបាយពិតនៃគណិតវិទ្យាសុទ្ធ , តំលៃទាំងឡាយនៃគណិតវិទ្យាបានមកពីគំនិតបញ្ញានៃមនុស្សផងដែរ ។

*

*   *

ប្រធានទី៥ .. " ហេតុអ្វីក៏គណិតវិទ្យា ត្រូវគេនាំគ្នាចាត់ទុកថា ជាឧបករណ៍សំខាន់មួយ ក្នុងចំណោមស្បត់ទាំងឡាយ ? " ចូរលើកឧទាហរណ៍ និងវែកញែកតាមបែបទស្សនវិជ្ជា ។

(ក្រុងមេត្រូប៉ូលីតាំង-សម័យប្រលងខែឧសភាឆ្នាំ១៩៥៩
ថ្នាក់គណិតវិទ្យា)

**គំរោងអត្ថាធិប្បាយ**

**២ សេចក្តីផ្តើម .—** លោកកង់ (Kant) សរសេរថា " នៅក្នុងទ្រឹស្តីពិសេសនៃធម្មជាតិ , ពាក្យថាស្បត់ពិតប្រាកដពុំមាននៅឡើយ តែគេឃើញមានតែបរិមាណគណិតវិទ្យាប៉ុណ្ណោះ " ។ ៥០ ឆ្នាំក្រោយមក លោកគូតុស គុង បានសរសេរក្នុងសៀវភៅទស្សនវិជ្ជារបស់លោកថា " នៅសម័យបច្ចុប្បន្ននេះ , ស្បត់គណិតវិទ្យាពុំសូវមានប្រយោជន៍ ដោយសារពុទ្ធិសង្ខេះនិងគំនិតរបស់ខ្លួន ក្លាយទៅជាឧបករណ៍សំរាប់មនុស្សស្រាវជ្រាវរកច្បាប់នៃបាតុភូតធម្មជាតិ " ។

វិវត្តន៍នៃស្បត់នៅសម័យនៃលោកអ្នកប្រាជ្ញទាំងពីរ បានផ្តល់លទ្ធផលផល " គណិតវិទ្យា " តែម៉្យាងប៉ុណ្ណោះ ។ មកដល់សព្វថ្ងៃនេះ ទស្សនៈនេះបានត្រូវគេយកមកអនុវត្តក្នុងស្បត់មនុស្ស ស្បត់ធម្មជាតិ , ជាពិសេសក្នុងស្បត់ចិត្តវិទ្យា និងសេដ្ឋកិច្ចនយោបាយ ។

យើងបានឃើញថា គណិតវិទ្យាបានផ្តល់វិស័យទាំងឡាយ ស្ទើរតែគំនិតមនុស្សរកសន្និដ្ឋានពុំត្រូវ ។

## ៣ គូសេចក្តី

១. គណិតវិទ្យាជាឧបករណ៍សំខាន់ នៅគ្រប់វត្ថុជា ធម្មជាតិនៃស្បង់ ។

— ស្បង់បង្ហាញការពិត នៅគ្រប់ឧបករណ៍ គឺសោតន៍ក្នុង ធម្មជាតិរបស់ខ្លួនជាវត្ថុរូបី - ឧទាហរណ៍ : ហ្វូង តារាដែល ស្ថិតក្នុងលំហអាកាស , សីតាធាតុវត្ថុជាតិដែលចក្ខុឃើញបាន ឃើញ ។ សភាវគតនាដែលកន្ត្រាក់អារម្មណ៍ឲ្យយើងអាយនឹកក្នុង ផល់ - ព្រមទាំងសំណុំការណ៍ ដែលយើងពិនិត្យ ឃើញនិង ត្រាប់ស្គាល់ ។

— គណិតវិទ្យាមានរូបីកម្មខ្លះតែរូបីកម្មគេអាចធ្វើសំរាយ បញ្ជាក់បានងាយ ដែលមានសម្មតិកម្ម , អាក់ស្យូម , ទ្រឹស្តីស្វយ ច្បាប់ខ្លះទៀត ។

— តំរូវរបស់គណិតវិទ្យាក្នុងការស្វែងរករូបីទូទៅជាការបង្ហាញ និយមន័យជាដើម ។

២. គណិតវិទ្យាជាឧបករណ៍សំខាន់ នៅគ្រប់ធម្មជាតិ ពិតរបស់ខ្លួន ។

ក- ឧបករណ៍សំខាន់គ្រប់វត្ថុគណិតវិទ្យា :

— គណិតវិទ្យាមានវត្ថុធាតុរបស់ខ្លួនជាបរិមាណរូបី ។

— គណិតវិទ្យាមាន បរិមាណដែលគេយកទៅសិក្សា រាប់ពាន់ ផែរ ។ បរិមាណទាំងនេះជាកាសាររបស់ស្បង់គឺសោតន៍ ។

— ហេតុនេះហើយលោក " ក្លូដប៊ែរ៉ាត " ពោលថា :

«សូត្រជាការសារបស់បញ្ញា ជាពិសេសសូត្រជាយក្សោភាយ នៃគណិតវិទ្យា»

ខ- ឧបករណ៍សំខាន់នៅត្រង់វិធីជា «សម្មតិកម្មអនុមានវិញក» ៖

— លោក អាដាម៉ារ (HADAMARD) ពោលថា «គណិតវិទ្យា ជាសូត្រទូទៅលើធម្មជាតិ ដែលគេអាចពិចារណាឃើញពិត»

— លោក «ពួងកែរ៉េ» ពោលថា : «ដោយលក្ខណៈសម្មតិកម្មអនុមានវិញក មានក្នុងគណិតវិទ្យានេះហើយ ទើបគេអាចស្រាវស្រាវរកសច្ចៈឃើញពីធម្មជាតិទាំងអស់នៅលើលោកនិងក្រៅលោក» ។

— លោកអាញស្តែន (EINSTEIN) ពោលថា : «គណិតវិទ្យាជាស្ពានសំរាប់រូបវិទ្យា ក្នុងការរាវរកគោលការណ៍បង្កើតថ្មី» ។

## ៣ សេចក្ដីបញ្ចប់

លោក ឡេអុង - ប្រុនស្វិច (Léon Brunschvigg) ពោលថា :

«ចំណេះរបស់មនុស្សដែលជាវត្ថុតាមនៃពិសោធន៍ មានសច្ចៈ ក្នុងវិចារណញ្ញាណនិងវិស័យភាព» ។

គំនិតលោកអ្នកប្រាជ្ញនេះយល់ថា វត្ថុវិស័យភាពកើតពីការពិនិត្យ ។ ឯចំណែកវិចារណញ្ញាណកើតពីទ្រង់ទ្រាយនៃគណិតវិទ្យាដែលគេញែកទៅដោយពិសោធន៍ ។

— ពិសោធន៍ផ្តល់វត្ថុធាតុគ្រប់យ៉ាង ដល់គណិតវិទ្យា ឯចំណែកឯគណិតវិទ្យាជាទងស្ពានអោយការគំហើញក្នុងស្យង់ ។

— ឯគណិតវិទ្យាផ្តល់រូបមន្តគិតទៅស្យង់ ដើម្បីដោះស្រាយបញ្ហាអាថ៌កំបាំងក្នុងធម្មជាតិដែលមនុស្សពុំបានដឹង ។

* * *

ប្រធានទី៦.– "តើគេអាចសន្មតបានថា" ការណ៍ទាំងឡាយសុទ្ធតែត្រូវគេពិនិត្យឃើញតាមរយៈនៃកញ្ចក់ទ្រឹស្តីឬ? ចូរពន្យល់តាមបែបទស្សនវិជ្ជានូវមតិខាងលើនេះ

(ក្រុងម៉ុងត្រេប៉ូល - ខែឧសភា ឆ្នាំ ១៩៥៥
វិញ្ញាសាសំរាប់ថ្នាក់វិទ្យាសាស្ត្រពិសោធន៍)

**គំរោងគំនិត**

## ១ សេចក្ដីផ្ដើម — *ត្រូវបញ្ជាក់គំនិតដូចតទៅ ៖*

*— មនុស្សស្គាល់ធម្មជាតិ ដោយសារឥន្ទ្រិយទាំងឡាយរបស់ខ្លួន ។*

*— មនុស្សមានវិញ្ញាណសំរាប់ពិចារណា ខាងលើវត្ថុធាតុធម្មជាតិ ។* គុណសម្បត្តិថ្មី *តែម្យ៉ាងទៀតអាចយល់ឃើញការដឹងស្គាល់របស់មនុស្សអាចយល់ឃើញគំណត់របស់ខ្លួនទាំងអស់ទេ — ដូចជាគុណភាពសម្បត្តិបន្ទាប់បន្សំ* (qualité secondaires) *ទាំងឡាយដែលកើតឡើងនៃជាតិខ្លួន អាស្រ័យហេតុនេះហើយបានជាគ្មានគេអាចនិយាយថា "មនុស្សដឹងការណ៍ទាំងឡាយនៃធម្មជាតិដោយទ្រឹស្តី" ។*

## ២ សេចក្ដីអធិប្បាយ

*១- គេពុំអាចដឹងនិងស្គាល់ "ការណ៍សាស្ត្រ"* (fait scientifique) *ដោយកញ្ចក់ទ្រឹស្តីឡើយ ។*

— អ្នកពិសោធន៍ទាំងឡាយខ្លះដូចជាលោក «ម៉ាសង់ឌី» (MAGENDIE) ជាដើមបានអះអាងថាការពិសោធន៍ក្នុងការណ៍របស់ធម្មជាតិតែងប្រទះឃើញលទ្ធផលដែលស្មាន់នៅក្នុងនោះ ។

— ប៉ុន្តែស្មាន់ត្រូវបញ្ជាក់នូវការណ៍ដែលពិត គឺបានមកពីការពិពណ៌នានិងវិភាគដ៏ល្អិតល្អន់ផង ។

— ពាក្យថាទ្រឹស្ដីដំបូងបានមកពីសម្មតិកម្មធំៗ (grandes hypothèses) ប៉ុណ្ណោះ ។

— ស្ទុះដើម្បីស្វែងរកសច្ចៈ, ស្មាន់ពុំមានចំណងខាងទ្រឹស្ដីបានឡើយ ។

គឺប៉ុន្តែបើមានតែទ្រឹស្ដីគ្មានការពិចារណា, គឺរកសច្ចៈពុំឃើញដែរ ។ ព្រោះដូចជាលោកវីវែល «WHEWELL» ធ្លាប់ពោលមកហើយថា ៖ "ទ្រឹស្ដីគឺសំខាន់ណាស់ក្នុងការស្វែងរកសច្ចៈព្រមទាំងពិចារណា ទស្សនៈយ៉ាងល្អិតល្អន់"

— អ្នកប្រាជ្ញម្នាក់ពោលអះអាងថា «ខ្ញុំរកសច្ចៈឃើញដោយបំណេះដឹងរបស់ខ្ញុំពុំមែនដោយទ្រឹស្ដីទេ» (c'est à l'aide de mon savoir et non de théorie que j'ai découvert le vrai!)

២. ការណ៍កំណើតរបស់ធម្មជាតិ ដែលមនុស្សបានស្គាល់ក៏អាស្រ័យដោយទ្រឹស្ដី :

(Le fait brut lui-même est perçu quelque chose de théorique).

— អ្នកប្រាជ្ញអាចស្គាល់ដឹង និងរកឃើញវត្ថុបំណងរបស់ខ្លួន ក៏អាស្រ័យដោយទ្រឹស្តី ឬគោលការណ៍ដែលអ្នកប្រាជ្ញបុរាណបានត្រួសត្រាយខ្លះមកហើយ ។

— អ្នកប្រាជ្ញថ្មីរកការណ៍ពុំឃើញទេ, បើគ្មានអ្នកនាំគំនិតអោយរកវត្ថុបំណងនេះ ព្រោះថាវត្ថុវិស័យភាពនៃគតិថ្មីក៏កើតបានអាស្រ័យប្រធានវិស័យភាព ចេញមកបង្ហាញខ្លួនអោយគិត, អោយពិចារណា ។

— គេត្រូវការភាសាដើម្បីបញ្ជាក់គំនិតអ្វីមួយ ដែលជាសម្មតិកម្មពន្យល់ ។ ឧទាហរណ៍ៈ លោក«ប្តូឡេមេ» (Ptolémée) ពោលថា«ព្រះអាទិត្យរះហើយលិចទៅវិញនៅជើងមេឃ» នេះជាភាសាដែលបង្ហាញអោយមនុស្សដឹងថា «ព្រះអាទិត្យធ្វើអ្វីខ្លះ» ។ ដូច្នេះទ្រឹស្តីចេញជាភាសានូវករណីសំខាន់របស់គំហើញវៀងវា ក្រោយទាំងចំណេះចេះដឹងទាំងឡាយ ។

— ភាសាជាយន្តទេសក៏ ដ៏ជាលិខិតកម្មវិចារណញ្ញាណ ។

— ដោយទ្រឹស្តីលោកគ្រូគេឲ្យពុំអាចប្រែលំថា «ក្រុមផ្កាយសាយទៅជាក្រុមសត្វ» បានឡើយ ។

## ៣ សេចក្តីបញ្ចប់

ទ្រឹស្តីពិតមែនតែអរូបី ក៏ប៉ុន្តែគេអាចចាត់ទុកថា ជាកូនសោសំរាប់បង្ហាញការណ៍ទាំងឡាយបាន ។ សត្វៈទាំងឡាយដែលបានលំឱនឈាប់ប្រសើរ ក៏អាស្រ័យទ្រឹស្តីធ្លាប់គេឃើញហើយបញ្ជាក់ថា មានគត្តភាពឬភាពប្រាកដនិយមពីមុនមកផងដែរ ។ ដូច្នេះទ្រឹស្តីពុំត្រាន់តែជាការសន្មតអោយប្រើបានប៉ុណ្ណោះទេ, តែជាតំណែលសង្កត់ពីសោគល័ក្ខណ៍ចាប់យកមកធ្វើជារូបមន្តនៃការពិចារណា ។

*

* *

**ប្រធានទី៧ .— “តើស្ទង់ដែលសិក្សាពីសីលវិជ្ជាខុសពីស្ទង់ នៅក្នុងធម្មជាតិយ៉ាងដូចម្ដេចខ្លះ ? ” ចូរពន្យល់តាមបែបទស្សនវិជ្ជា ។**

( ក្រុងបែរណុសវែរ - ខែឧសភា ឆ្នាំ ១៩៥០
វិញ្ញាសាសំរាប់ថ្នាក់គណិតវិទ្យា )

**គំរោងអត្ថាធិប្បាយ**

**១ សេចក្ដីផ្ដើម.—** *ស្ទង់ដែលសិក្សាពីសីលវិជ្ជា បានពឹងផ្អែកការពិចារណានៃវិចារណញ្ញាណ មកធ្វើជាមូលដ្ឋានដើម្បីស្វែងរកសច្ចៈដូចជាចិត្តវិទ្យាជាស្ទង់នៃចិត្ត , ជាវិធីគំនិត, ដើម្បីបង្ហាញគត្តភាពនៃចិត្ត ។ ចំណែកឯស្ទង់ធម្មជាតិ , ជាកិរិយាធន៌ដែលប្រាប់គំហើញក្នុងធម្មជាតិ ។ ស្ទង់ទាំងពីរគង់ទាក់ទងជានិច្ចទៅនឹងវិចារណញ្ញាណរបស់មនុស្ស ។ តើត្រង់លក្ខណៈណាខ្លះដែលបង្ហាញថាស្ទង់ទាំងពីរនេះខុសគ្នា ?*

**២ តួសេចក្ដី**

***១ - ស្ទង់ធម្មជាតិនិងស្ទង់សីលវិជ្ជា :***

*ក - ស្ទង់ធម្មជាតិមាន កម្មវត្ថុរបស់ខ្លួន គឺធម្មជាតិដែលមានជីវិត , ជាឧបករណ៍នៃពិសោធន៍និងសកម្មភាពនៃធម្មជាតិ*

*—មនុស្សមិនគ្រាន់តែជាសត្វសម្ភារៈ ប្រកបដោយជីវិតប៉ុណ្ណោះទេ , តែជាគំនិតដែលប្រកបដោយវិចារណញ្ញាណ និងមនសិការសីលវិជ្ជា ហើយនៅក្នុងន័យនេះ ចិត្តវិទ្យាបានក្លាយទៅជាផ្នែកមួយនៃស្ទង់ធម្មជាតិ ។*

— រូបវិទ្យាស្ថិតនៅក្នុងចន្លោះនៃស្ទង់ធម្មជាតិ ។

— ស្ទង់ធម្មជាតិបានអោយវត្ថុធាតុដើមទៅមុខវិជ្ជាដូចតទៅៈ តារាវិទ្យា , សិលាវិទ្យា , រូបវិទ្យា , គីមី .

— ធាតុរស់នៃវិជ្ជាទាំងឡាយដែលគេប្រទះ ឃើញក្នុងស្ទង់ធម្មជាតិដែរគឺ : កាយវិទ្យា , ជីវវិទ្យា ។ល។

## ខ - សច្ចៈដែលបានមកពីស្ទង់ធម្មជាតិ បានប្រែភាពទៅជាស្ទង់សីលវិទ្យា :

— ប្រវត្តិសាស្ត្រសិក្សាពីមនុស្ស និង សង្គមរបស់មនុស្សតាំងពីសម័យបុរេប្រវត្តិ ។ កាលណាប្រវត្តិវិទ្យាក្លាយទៅជាសង្គមវិទ្យា ពេលនោះហើយដែលគេសង្កេតឃើញលក្ខណៈនៃស្ទង់សីលវិទ្យា ។

## ២. តើស្ទង់ទាំងពីរខុសគ្នាត្រង់លក្ខណៈណាខ្លះ ?

— ស្ទង់ទាំងពីរខុសគ្នាត្រង់លក្ខណៈខ្លះដូចជា ៖

— ស្ទង់ធម្មជាតិមាន កំណត់និយមកំណើតរបស់ខ្លួនជាឯកតាទោល ។

ឧទាហរណ៍ : សត្វដង្កូវបានក្លាយទៅជាមេអំបៅតែពុំមានអ្វីប្លែកនៅក្នុងសីលធម៌ឡើយ ។ ខុសគ្នានឹងមនុស្សដែលវិវត្តពីល្ងង់ទៅជាមានបញ្ញាដោយការសិក្សា, ការអប់រំ, ពោលគឺកំណត់និយមសម្ភារៈ (le déterminisne matérialiste )

— ស្ទង់សីលវិជ្ជាមានសីលធម៌ពិសេសរបស់ខ្លួនត្រង់វិវត្តន៍នៃវិចារណញ្ញាណនៃលទ្ធានុករណ៍នៃគន្លឹះ ។ មនុស្សខុសនឹងសត្វត្រង់វិវត្តន៍បញ្ញា ។

## ៣- សេចក្ដីបញ្ចប់

— ស្បង់ធម្មជាតិ ដែលខុសនិងស្បង់សិលវិទ្យាត្រង់លក្ខណៈ សិលតំណែលខ្លះ ដោយកំណត់និយមមានឯកតាខុសគ្នាពីធម្មជាតិ មកក្ដី ក៏គេសង្កេតឃើញថាមានលក្ខណៈស្របគ្នាដោយភាគច្រើនត្រង់លទ្ធផលទាំងឡាយ ដែលទាក់ទងនិងវិចារណញ្ញាណ ។ ព្រោះថាគំហើញទាំងឡាយ ដោយពិសោធន៍ក្នុងស្បង់ដែលប្រើសម្ភារៈ ខុសនិងគំហើញ ដែលចេញពីវិភាគវិចារណញ្ញាណសុទ្ធសាធ ។

* * *

ប្រធានទី ៨ .— “ តើគេអាចបញ្ចូលវិជ្ជាឯកទេសនៃវិទ្យាសាស្ត្រ ក្នុងវប្បធម៌ទូទៅ របស់មនុស្សបានឬទេ ? ហេតុអ្វី ? ចូរពន្យល់និងវែកញែក ។

( ក្រុងរ៉ែន - ខែឧសភា ឆ្នាំ ១៩៥០.
វិញ្ញាសាសំរាប់ថ្នាក់វិទ្យាសាស្ត្រពិសោធន៍ )

**តំរោងគ្រោងពិច្ឆាយ**

## ១- សេចក្តីផ្តើម

— *ពេលវេលាបាននាំមកអោយមនុស្សនូវចំណេះដែលមានសភាពផ្សេងៗគ្នា ។ ចំណេះទាំងអស់ បានវិវត្តទៅរកគោលដៅខុសៗគ្នា ដែលមនុស្សពុំអាចប្រសោបយកមកទុកជាវិជ្ជាសមោធាន សំរាប់ចំណេះផ្ទាល់របស់ខ្លួនម្នាក់ឯងបានឡើយ ។ គឺថាវិវត្តន៍វិទ្យាសាស្ត្រ បានជ្រើសរើសមុខងារឯកទេសរបស់ខ្លួន* (**Spécialisation de la science**) ។

*លោកអូគុស្តកុង* (A. Comte) *ពោលថា៖ “ គំហើញនៃទ្រឹស្តីវិជ្ជាប្រវែងលពិតពីរសតវត្សរ៍ក្រោយនេះ បាននាំមកនូវការចំរើនខាងការស្រាវជ្រាវក្នុងវិទ្យាសាស្ត្រ ព្រមទាំងបណ្តាលអោយមនុស្សលេចយ៉ាងតនូលក្នុងកិច្ចការប្រចាំថ្ងៃរបស់ខ្លួន ” ។ ឯកទេសក្នុងវិទ្យាសាស្ត្ររីកចំរើន រហូតទាល់តែ មតិខ្លះយល់ថា ជាចំណែកមួយនៃវប្បធម៌ទូទៅរបស់មនុស្ស ។ តើឯកទេសវិទ្យាសាស្ត្រនិងវប្បធម៌ទូទៅរបស់មនុស្សខុសគ្នាយ៉ាងដូចម្តេចខ្លះ ?*

## ២– តួសេចក្ដី

១ - ឯកទេសក្នុងស្ទង់ប្រឆាំងនឹងវប្បធម៌ទូទៅ :

ក - ការងារទាំងឡាយរបស់វិវត្តន៍នៃគំនិត សុទ្ធតែជាកត្តា បួយនៃវប្បធម៌ ។ ប៉ុន្តែវប្បធម៌ដែលបានបកពីគំហើញ ផ្នែកឯកទេសហួសហេតុ ផ្ដល់កាលត្រឡប់ទៅជាប្រឆាំងនឹងវប្បធម៌ពិតរបស់មនុស្សទៅវិញ ។

— វប្បធម៌កើតពីចំណេះមនុស្ស គឺការបណ្ដុះបណ្ដាលបញ្ញា។

— អ្នកប្រាជ្ញឯកទេស ដែលគិតតែពីមុខងារឯកទេសរបស់ខ្លួនពេកក៏ត្រឡប់ ទៅជាល្ងង់ខ្លៅទៅវិញ ។ ព្រោះខ្លួនពុំបានស្គាល់វិជ្ជាដទៃទៀត របស់អ្នកតាខ្លួនតិងចំណេះ ទាំងឡាយដទៃដែលកំពុងវិវត្តទៅគ្មានទីបញ្ចប់ ។

— គំនិតឯកទេសបានធ្វើអោយខ្វះសតិអ្នកសិក្សា , ព្រោះជាគំនិតឯកត្តាតែម្នាក់ឯង ។

ខ - ឯកទេសក្នុងស្ទង់ប្រឆាំងនឹងវប្បធម៌មនុស្សជាតិ :

— ដើម្បីអោយមានគំនិតមនុស្សជាតិ គេត្រូវសាងឬបង្កើតអ្វី ដែលមានប្រយោជន៍ចំពោះមនុស្សទូទៅ ។

— ឯកទេសស្ទង់បណ្ដុះគំនិតថ្មី ក៏ពិតមែនហើយតែ , វាបាន នាំចិត្តមនុស្សអោយយោរយៅ , ហើយក្រហើន កោងកាច , មានអំនួតប្រទេសប្រឆាំងម្នាក់ឯងក្នុងសង្គមមនុស្ស ដោយការឆ្ងើងឆ្ងៃ ។

(la spécialisation scientifique risque d'endurcir le coeur et de rendre impoli)

— ក្នុងវិស័យកសិកម្ម, ការរីកចំរើនខាងវិធីវិចារថ្មី បាននាំឲ្យមានការប្រែប្រួលក្នុងទស្សនៈ ដែលគេធ្លាប់គិតនឹងពិចារណារួចហើយ ។

— វិជ្ជាឯកទេសក្នុងសង្គម នាំឲ្យមនុស្សល្ងង់ខ្លៅទៅវិញ ព្រោះនាំមនុស្សឲ្យដើរតែក្នុងផ្លូវរបស់ខ្លួន ។

— អ្នកប្រាជ្ញផលិតគ្រឿងប្រហារខូចសីលធម៌និងមនុស្សធម៌ ។

— អ្នកប្រាជ្ញឯកទេសសង្គមក្នុងផ្លូវល្អ ជួយជីវិតមនុស្សក្នុងវិស័យវេជ្ជវិទ្យា និងផលិតកម្មមណ្ឌលដារបណ្ណីយដ្ឋាន ។

២ - មធ្យោបាយរួមនៃសង្គមឯកទេសខ្លះជាមួយវប្បធម៌មនុស្ស :

— ឯកទេសក្នុងសង្គម ជាជំនួយក្នុងវិស័យវប្បធម៌ ។

— គប្បីពិសិក្សាសម័យបច្ចុប្បន្នខ្លះថ្វីបើយល់ថា វិជ្ជាឯកទេសចង់ដើរផ្លូវផ្សេងតែម្នាក់ឯងក៏ដោយ, ក៏ហាក់ដូចជានៅឲ្យតំណែងនៅលើមុខវិជ្ជានេះ ។

និក្ខេបបទ (thèse) នៃនិស្សិតនៅពេលចេញពីមហាវិទ្យាល័យ មានលក្ខណៈឯកទេសទាំងស្រុង ។

—វិជ្ជាឯកទេសបង្កើតគំនិតថ្មី ចំពោះវិចារណញ្ញាណមនុស្ស ដូចជាសំដីរបស់អ្នកប្រាជ្ញម្នាក់ពោលថា :

«សុខចិត្តឲ្យវប្បធម៌ខ្វែងគ្នា, ប៉ុន្តែកុំឲ្យតែវិនាសដី.»
(Il faut croiser les cultures pour ne pas ruiner le sol)

— គំរូការក្នុងវិស័យឯកទេសខ្លះបានគឺ អ្នកប្រាជ្ញជាច្រើនខាងសង្គមដូចជាលោក «រ៉ូសេល» (Russel) លោក «វ៉ាយ

វ៉ៃហេត» (whitehead), លោក «ហ៊ុយស៊ែល» (Husserl) លោក «ពៀរ៍ស» (Peirce) ។ល។

អោយពិចារណាតាមបែបទស្សនវិជ្ជា ពោលគឺជាននវិជ្ជា សិក្សាពីទស្សនវិជ្ជាទៅវិញ ។

— អត្ថន័យមួយបានសំយោគគំនិតឯកទេសនៃស្បង់ ចំពោះទ្រឹស្តីមនុស្សថា : «គួរទុកអ្នកឯកទេសអោយបន្តការស្រាវជ្រាវរបស់ខ្លួនចុះ កុំអោយតែខូចការរីកចំរើននៃវប្បធម៌មនុស្ស» ។

(Le spécialiste peut avoir son violon d' Ingres)

— ស្ត្រីមានវិជ្ជាឯកទេស របស់ខ្លួនក្នុងការថែទាំផ្ទះសំបែងនិងគ្រួសារ ។ គ្រួសារនិងសិល្បៈនៃគ្រួសារក្នុងការស្វែងរកសុភមង្គលត្រូវស្ត្រីទាំងឡាយចាត់ទុកជាវិជ្ជា ឯកទេសរបស់ខ្លួន ។

## ៣- សេចក្តីបញ្ចប់

— គំហើញឯកទេសមានសារៈសំខាន់ កាលណាសិទ្ធិមនុស្សត្រូវគេរំលោភ ។ ស្បង់បរត្តិកគ្រាប់បែកអ៊ីដ្រូសែន (Bombe H) មានអំណាចបញ្ឈប់ការឈ្លានពានរបស់សត្រូវដែលឥតគោរពច្បាប់សកល ។

— គួររំលឹកសំដីលោក «ប៊ែរសុន» (Bergson) ដែលពោលថា “រូបកាយដែលចេះតែធាត់ធំទៅ តែងតែចាំនូវព្រលឹងពិសេសមួយ !» ពោលគឺមនុស្សត្រូវការអ្វីដែលពុំមែនជាខ្លួន ដើម្បីសង្គ្រោះ ។

— លោក «អាឡាំង» (Alain) ពោលថា «វប្បធម៌ត្រូវការសេចក្ដីសប្បាយ, តែសប្បាយនោះត្រូវមានវត្ថុជាកុសល» ។

— ដូច្នេះ វប្បធម៌តែងត្រូវការឆករខសក្ខុតស្យើជានិច្ចតែក្នុងលក្ខណៈជា «អត្តភាពពិសេស» (mystique du dépassement) ។

*

* *

ប្រធានទី៩.– "ចូរពិចារណាលើគំនិត របស់ទស្សនវិទូសម័យបច្ចុប្បន្នម្នាក់ដែលពោលថា: តក្កវិជ្ជា គឺជាសីលវិជ្ជានៃគំនិតដូចជាសីលវិជ្ជាជាតក្កវិជ្ជានៃអំពើ" ចូរវែកញែកតាមបែបទស្សនវិជ្ជានូវទស្សនខាងលើនេះ ។

(ក្រុងទូលូស - ខែឧសភា ឆ្នាំ ១៩៥០ - វិញ្ញាសា សំរាប់ថ្នាក់ទស្សនវិជ្ជា)

គំរោងអត្ថាធិប្បាយ

## ១– សេចក្ដីផ្ដើម

— សភាពការណ៍នៃមុខងាររបស់មនុស្ស ឬ ទង្វើមនុស្សប្រៀបធៀប [illegible] ។

— [illegible] ទស្សនវិទូ [illegible] ទស្សនៈទាំងពីរ [illegible] ។

— សេចក្ដី [illegible] លើគំនិតថា [illegible] សីលវិជ្ជា [illegible] តក្កភាព ។

— ផ្ទុយទៅវិញ តក្កភាពនិងវិចារណញ្ញាណត្រូវអ្នកសីលវិជ្ជាជ្រើសទុកជាឧបករណ៍ការពារការប្រព្រឹត្តដោយអំពើ ។

តើវិជ្ជាទាំងពីរនេះមានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្ដេចខ្លះ ?

## ២– តួសេចក្ដី

១- តក្កវិជ្ជានិងសីលវិជ្ជា ពុំអាចបែកចេញពីគ្នាបានឡើយ:

ក- [illegible] វិជ្ជាទាំងពីរនេះ [illegible] រួមតែមួយ [illegible]:

— មិនត្រូវការអ្វីដែលកំណត់រួចហើយ (déterminisme) តែត្រូវការអ្វីដែលពន្យល់យ៉ាងហ្មត់ចត់, និងត្រូវការអ្វីដែលបង្គាប់ដោយច្បាប់សកល ។

— សន្តាន ឬវង្សត្រកូលនៃវិជ្ជានេះ នៅក្នុងសំណុំជាមួយគ្នា : ឧទាហរណ៍ : តក្កភាព - សច្ចៈភាព - សីលវិជ្ជាកុសល, ករណីយកិច្ច ។ល។

— អ្នកប្រាជ្ញតក្កវិទ្យា ពុំហ៊ាននិយាយពីអរូបីនៃមនុស្សភាពរបស់ខ្លួនដែលប្រកបដោយ តក្កភាពផ្លូវឆ្ងាយ(ឧទាហរណ៍: រូបបានកើតមក, ផ្លាស់ប្តូរលក្ខណៈ, ហើយវិនាសទៅវិញ) ។

— តក្កវិជ្ជា ផ្អែកលើសញ្ញាណពិតប្រាកដដើម្បីបញ្ជាក់សច្ចៈ តើអាចជៀសវាង សីលវិជ្ជាបាន ឬទេ?

**ខ- ថ្វីបើមានសភាពស្របគ្នាក៏ដោយ ក៏យើងឃើញថា "តក្កវិជ្ជា ពុំមែនជា "សីលវិជ្ជានៃគំនិត" ហើយ "សីលវិជ្ជាពុំមែនជាតក្កវិជ្ជានៃអំពើ" ទេ ។**

— គំនិតតើជា ឧបករណ៍ដែលមានសារៈសំខាន់នៃសីលវិជ្ជា ព្រោះថា គំនិតដែលយើងគិតពិចារណារាល់ថ្ងៃបានបង្កើតនូវបរិយាកាសមួយព្រមទាំងបង្កើតនូវសំណេរ ទុកសំរាប់ដាស់សតិយើងអោយធ្វើអំពើអ្វីមួយ ។

— ដូចនេះសីលធម៌ពុំមែនកើតមកពីតក្កភាពទេ ។

— ហើយតក្កភាពក៏ពុំអាចបង្កើតអំពើបានដែរ ។

— ចិត្តបង្កើតអំពើ ព្រោះថាបើចិត្តពុំបង្កើតសកម្មភាពរបស់ខ្លួនទេ, គ្មានអ្វីធ្វើអំពើបានឡើយ ។

— ទង្វើគ្មានអភិរេសដ្ឋពុំបាននិវេទ ។

— សីលធម៌ ពុំអាចកើតបានឡើយបើខ្វះ «ចិត្តប្រយ័ត្ន» «ចិត្តជាកុសល» ។ ព្រោះថាខ្សែរដូចខាងចាប់ផ្ដុំនិងការពិតស្រឡះ ។

## ២- ក៏ប៉ុន្តែតិមួយបានអះអាងថា :

— តក្កភាពនិងសីលវិជ្ជាបានបកពី «វិនិច្ឆ័យនៃតំលៃ» ដែលចេញពី ពិសោធន៍ដូចគ្នា ។

— អ្នកតក្កវិជ្ជាបានពិនិត្យផ្គត់គំនិតរបស់មនុស្ស តាមវិធីដែលអ្នកសីលវិជ្ជាបានធ្លាប់សង្កេតពិចារណាមកហើយ ។ ដូច្នេះយើងឃើញថាវិធីនៃវិជ្ជាទាំងពីរនេះមានសភាពដូចគ្នា ។ អ្នកមួយគិតយ៉ាងល្អិតល្អន់ដោយប្រើវិចារណ៍ស្វែងរកសច្ចៈ ។ អ្នកមួយទៀតគោរព គោលការណ៍សីលវិជ្ជា ដែលគ្មានលាយឡំនិងអកុសលធម៌ ។

— ដូច្នេះឃើញថាវិជ្ជាទាំងពីរមានគោលដៅតែមួយ ។ គួរធ្វើសំយោគបទថា ÷

— គេពុំអាចគិតពិចារណាប្រកបដោយតក្កភាព ដោយខ្វះសីលសម្មាទិកម្មបានឡើយ ។

— ដើម្បីរកតក្កភាពក្នុងសច្ចៈគេត្រូវប្រើអារម្មណ៍ ដែលជាសីលចរិយា ។

— បញ្ញារបស់មនុស្សម្នាក់ៗ ពុំមែនបានមកដោយខ្វះធុនងារនៃចិត្ត ឬកំលាំងនៃវេទនាបានឡើយ (puissances affectives) ។

— ពស្សុនដែលបានចាំដោយសំដែងតក្កភាពពាក្យ អាស្រ័យ ពិចារណាដោយពិត្តភាព ។ ខ្ទះការពិចារណាដោយការពិចារណាធនមនិលៈធ្មា តក្កភាពពិតពុំកើតមានឡើយ ។

## ៣ – សេចក្តីបញ្ចប់

— គួរបញ្ជាក់មកថា ៖

— តក្កភាពនៃលោកប្រាឌីន (M- PRADINES) ពិតជាពុះ ការពិតរឿងការកុហកតំផិត, ឬប្រការសុខាខ្មីអិសត្វនំដេ៍ ។ ត្រង់ត្រូវដែល អ្នកប្រាជ្ញសីលវិទ្យាគេបញ្ជាក់ឡើង, ហេតុនេះត្រូវ សង្កេតឃើញសណ្ហាន់ថា ត្រឹមត្រូវត្រូវតែថា : គេអាចសង្កេត ឃើញក្នុងសីលវិទ្យានូវអំពើពាកុសលគ្រប់យ៉ាង ។

— សីលវិទ្យា និង តក្កវិទ្យា សុទ្ធតែបំរើគោលការណ៍សច្ចធម៌ ដូចគ្នាគឺ : តក្កភាពស្វែងរកសច្ចៈ, សីលវិទ្យាស្វែងរកកុសល ហើយគុណតម្លៃទាំងពីរក៏ពុំមែនខុសឆ្ងាយពីគ្នាឡើយ ។

*

* *

**ប្រធានទី១០**.—ទ្រឹស្តីទស្សនវិជ្ជាមួយបានសួរថា: " តើទីបញ្ចប់នៃជីវសីលវិជ្ជា (vie morale) គឺជាការស្រាវជ្រាវរកសុភមង្គលឬ ? "

ចូរពន្យល់និងវែកញែក ។

(ក្រុងវ៉ែន - ខែកញ្ញា ១៩៥០ - វិញ្ញាសាសំរាប់ថ្នាក់គណិតវិទ្យា .)

**តំរោងអត្ថាធិប្បាយ** .

**១- សេចក្តីផ្តើម** .— គួរបញ្ជាក់គំនិតខ្លះដូចតទៅ:

មនុស្សបានកើតមកនៅលើពិភពមួយ ដែលកាចសាហាវយង់ឃ្នង - បណ្តាលមកពីធម្មជាតិដែលមានកំណត់និយមរុំព័ទ្ធដោយអវិជ្ជា (Ignorance) ផងនិងតំរូវការសំផង ។

— ការជួយដោះទុក្ខមនុស្ស - សត្វតាមវិធីណាក៏ដោយក៏អាចចាត់ទុកថាជាអំពើប្រកបដោយកុសលបានដែរ ។

— មនុស្សបានស្វែងរក គោលដៅមួយ ដែលទ្រឹស្តីសីលវិជ្ជាមានភារៈស្រាវជ្រាវរកប្រគល់អោយពេញ ។

— សុភមង្គល ជាចំណីអាហាររបស់មនុស្សនិងសត្វដែលរស់ក្នុងលោកសន្និវាសនេះ ។

**២- តួសេចក្តី**

— ការស្វែងរក សច្ចៈក្នុងជីវិតរបស់មនុស្ស ជាមុខងាររបស់ទស្សនវិទូ - ។ អ្នកខ្លះពោលថា:

« ក្នុងលោកនេះ គ្មានសំណាវិជ្ជាពិតប្រាកដនិងគ្មានសច្ចៈពិតប្រាកដឡើយ »

— ពួកស្តូអ៊ីស៊ីយ៉ាង (stoïciens) មើលឃើញថា ជីវិតគឺទុក ត្រូវរាក់ហើយលោកិយនាំមកនូវតែទុក្ខ ។
— ត្រូវបណ្ដាច់ត្រូវរាក់រាល់វត្ថុសង្ខារ ដើម្បីរកសុខសន្តិភាព ហើយ ។ ម្យ៉ាងទៀតត្រូវហ៊ានទំលុះចោលនូវតណ្ហា ។
— តែគំនិតខាងលើបានត្រូវពួកអ្នកនិយមវឌ្ឍនភាពរិះគន់ថា ខ្វះការតស៊ូក្នុងជីវិត ។ ត្រូវរកមធ្យោបាយដើម្បីកំចាត់បរិស្ថា បំបាត់ទុក្ខព្រួយ, សាងសុភមង្គលអោយជីវិត ។
— លោក "អេពីគួរ" (Eqicure) ពោលថា :
«គេត្រូវតែចេះសប្បាយជាមួយនឹងអ្វីទាំងអស់ ដែលធម្មជាតិផ្ដល់អោយហើយ ដើម្បីបានក្រេបទឹកឃ្មុំនៃជីវិត»
— លោកប្លាតុង (Platon) បានបញ្ចេញ យោបល់ចំពោះជីវិតថា: "គេត្រូវតែចេះរស់នៅ តាមការពិនិត្យវត្ថុធាតុ ដែលនៅជុំវិញយើង" ។
— លោកអារីស្តូត (Aristote) បញ្ជាក់ថា :
"មនុស្សគ្រប់ ត្រូវចេះអោយតម្លៃទៅលើជីវិតអោយបាន ប្រសើរដោយប្រាកដនិយម"
— ទស្សនវិជ្ជាពុំបានបង្រៀនមនុស្ស អោយរស់សង្ឃឹមក្នុងជីវិតឡើយ, តែផ្ទុយទៅវិញ, បានធ្វើអោយមនុស្សរកមធ្យោបាយ ដោយបញ្ចេញទ្រឹស្តីដែលមានលក្ខណៈជាបង្គាប់បញ្ជា :
— "បើអ្នកចង់មានត្រូវតែសងបំណុល, បើចង់អោយមានកិត្តិយសត្រូវតែទៀងត្រង់ ។ល។"
— លោក"កង់"ចង់អោយមនុស្សគោរពច្បាប់មួយជាចាំបាច់ ក្នុងការស្រាវជ្រាវរកសុភមង្គល ។ លោកបានពោលថា

«អ្នកត្រូវធ្វើជានិច្ច របៀបតាមតែគោលគំនិតនៃឆន្ទៈរបស់អ្នកអាចតំណាងដូចជាគោលការណ៍ នៃនីតិសកល» (Agis toujours de telle sorte que la maxime de ta volonté puisse valoir en même temps comme principe d' une législation universelle)

**២-សេចក្ដីបញ្ចប់**— ត្រូវបញ្ជាក់សេចក្ដីខ្លះដើម្បីបញ្ចប់ដូចជា:

— ការរស់នៅរបស់មនុស្ស ត្រូវចេះសំរបខ្លួនទៅតាមសង្គមមនុស្ស ។ ត្រូវចេះសាងកុសលផង និងពិចារណាក្នុងអំពើនោះផង ។ បើពុំដូច្នោះទេ សុភមង្គលក្នុងលោកនិយមិនប្រាកដជាកើតឡើងទេ ។

— «យើងមិនអាចចូលប្រយុទ្ធក្នុងសមរភូមិ ដោយកាន់ផ្កាកុលាបមួយនៅដៃទេ» នេះជាសំដីលោកកក់ ។ (Nous ne voudrions pas traverser la bataille une rose à la main» ។

— ព្រះនិងផ្លូវផ្ទឹនណាដែលតាមផ្លូវខ្លួនឯង» ។

តម្កល់ទុកតាមច្បាប់លេខ ៩៦ ចុះថ្ងៃទី ២៤-២-៧៥
បោះពុម្ពលើកទី ១ ចំនួន ២.៥០០ ក្បាល

រោងពុម្ព **មហាលាភ** លេខ ២៨២
កាច់ជ្រុងមហាវិថីប្រជាធិបតេយ្យ - ឧកញ៉ាម៉ែន ភ្នំពេញ



ក្រុមការងារនិពន្ធ៖ រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្រសួងអប់រំ
យុវជននិងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម